# ហង្សយន្ត



មជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ

CEDORECK

93

# ហង្សយន្ត

## HANG—YON

*(l'Oie mécanique)*

7250/89

000041

# ហង្សយន្ត

# HANG—YON

*(l'Oie mécanique)*

*Publié avec le concours*
*de la Direction du Livre et de la Lecture du Ministère de la Culture*
*et du Fonds International pour la Promotion de la Culture de l'UNESCO*

**មជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ**
**CENTRE DE DOCUMENTATION ET DE RECHERCHE**
**SUR LA CIVILISATION KHMÈRE**
**CEDORECK**
**1986**

បោះពុម្ពជាថ្មីតាមការ ផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ទី ៥
ភ្នំពេញ ព.ស ២៥០៩ គ.ស ១៩៦៦

# វប្បធម៌ - អក្សរសាស្ត្រខ្មែរ

នាំដោយ

ឃីង ហុក ឌី

១៥

000041

**Collection Littérature Khmère**
*dirigée par Khing Hoc Dy*

**15**

# HANG YON (Hań-yont )
*(L'Oie mécanique)*

Illustration de la couverture : Chhéa Davy
Maquette, mise en page et fabrication : Mlle Lim Sovanna
Khim Ong

Réimpression de la 5e édition de l'Institut Bouddhique
Phnom-Pénh : 1966
© Cedoreck, Paris, 1986
ISBN 2-86731-022-9

# លំនាំដើម

## ក - ប្រភព និង រចនាបថរឿង

"រឿង ហង្សយន្ត នេះគ្មានក្នុងគម្ពីរបញ្ញាសជាតកបាលី ឬ គម្ពីរបាលីណាទេ"(១)។ តាមការពិនិត្យផ្ទៀងផ្ទាត់នឹងគម្ពីរបញ្ញាសជាតក(២) យើងឃើញមានរឿងទី ១៥ ដែលមានតួអង្គឯកឈ្មោះ "សុវណ្ណកុមារ"(៣) ដូចក្នុងរឿងហង្សយន្តហើយឈ្មោះនេះជាចំណងជើងរឿង តែផ្ទៃរឿងនិងអត្ថន័យខុសគ្នាស្រឡះ មានតែឈ្មោះតួអង្គពោធិសត្វ (៤) មួយប៉ុណ្ណោះដែលស្របគ្នា ។

កវីនិពន្ធបានប្រាប់ក្នុងលំនាំដើមរឿងថា រឿងហង្សយន្តនេះស្រង់ប្រែពីភាសាសៀមមកជាភាសាខ្មែរវិញ ដូចមានសេចក្តីដកស្រង់បញ្ជាក់ស្រាប់ ៖

" ទើបខ្ញុំនឹងស្រង់ស្រាយ ស្រាយអស់អាថ៌ប្រែពាក្យពី
សៀមបទប្រាកដថ្មី ជាពាក្យខ្មែរវិញទោងណា ។"

(ទំព័រ ៣)

ពិតមែនតែកវីនិពន្ធបានបញ្ជាក់ថា រឿងហង្សយន្តស្រង់បកពីភាសាសៀម ក៏យើងពុំទាន់រកឃើញរឿងសៀមណាដូចរឿងហង្សយន្តខ្មែរនៅឡើយក៏ទេដែរ (៥)។

រចនាបថរឿងហង្សយន្ត ជាអត្ថបទកំណាព្យបែបចាស់បុរាណគឺមានបទ កាកគតិ ព្រហ្មគីត ពំនោល ភុជង្គលីលា គឺជាអត្ថបទល្បែងសំរាប់អានកំសាន្តអារម្មណ៍លេងរបស់ជនានុជនខ្មែរយើងនៅសម័យកណ្តាល គឺជាអត្ថបទគ្មានឈ្មោះកវីនិពន្ធ គ្មានកាលបរិច្ឆេទ គឺគ្មានបានប្រាប់ថ្ងៃ ខែ ឆ្នាំ ដែលបានតាក់តែងរឿង តែតាមទម្រង់ភាសា និង ទម្រង់រចនាបថកំណាព្យកាព្យឃ្លោង រឿងហង្សយន្ត ច្បាប់ពុទ្ធសាសនបណ្ឌិតដែលមជ្ឈមណ្ឌលឯកសារស្រាវជ្រាវអរិយធម៌ខ្មែរយកមកបោះពុម្ពឡើងវិញនេះ និពន្ធឡើងប្រហែលនៅចន្លោះសតវត្ស ទី ១៧ - ទី ១៨ ។

តែតាមការស្រាវជ្រាវរបស់ព្រះមហា វស់ ឈុត និងអ្នកស្រី ឃុន ខុន (៦) លើកាលបរិច្ឆេទរឿងហង្សយន្តដោយប្រៀបធៀបលើសាស្ត្រាស្លឹករឹតនានា និង សៀវភៅបោះពុម្ពទាំងឡាយនៅស្រុកខ្មែរ បានបញ្ជាក់ឱ្យឃើញនាមអ្នកនិពន្ធ ពេលវេលាតែងរឿង ក្នុងរជ្ជកាលស្តេចគ្រងរាជ្យ ពោលគឺរឿងហង្សយន្ត និពន្ធឡើងដោយចៅឃមបុណ្យភក្តិ ឱក នៅក្នុងមហាសករាជ ១៥៩០ ដែលត្រូវនឹងឆ្នាំ មមែ នព្វស័ក គ.ស. ១៦៦៨ ក្នុងរាជ្យព្រះជ័យចេស្តារាមាឥសូរសុរិយោវង្ស ។ ដូចនេះរឿងហង្សយន្ត ជាផលិត

កម្មអក្សរសាស្ត្រ ក្នុងសតវត្សទី ១៧ ស្រករគ្នានឹងរឿង ខ្យងសង្ខ របស់ ឧកញ៉ាសុភាធិបតី " អ៊ុក " ដែរ ( ៧ ) ។ តែរឿងហង្សយន្ត នៃពុទ្ធសាសនបណ្ឌិតដែលមជ្ឈមណ្ឌលឯកសារស្រាវជ្រាវអរិយធម៌ខ្មែរយកមកបោះពុម្ពផ្សាយទៀតវិញនោះ បាត់សំនាំដើមអ្នកនិពន្ធបានជាគ្មានបញ្ជាក់ នាមកវី និង ពេលវេលាតែងរឿង ។

"តាមកាលបរិច្ឆេទដែលបានដោះស្រាយរួចមកហើយ រឿងហង្សយន្ត ជាការរៀបរៀងក្នុងជំនាន់ រឿងខ្យងសង្ខ របស់ ឧកញ៉ាសុភាធិបតី " អ៊ុក " តែហេតុអ្វីបានជាអ្នកនិពន្ធខំប្រែរឿងនេះក្នុងជំនាន់ហ្នឹងមក "ជាពាក្យខ្មែរវិញណា ------" មានន័យថា រឿងនេះមុនជារបស់ខ្មែរ រួចមានគេលួចប្រែទៅជាសៀម ដូចនេះ ហើយដើម្បីកុំឱ្យបាត់សម្បត្តិអក្សរសាស្ត្រខ្មែរ អ្នកនិពន្ធខ្មែរត្រូវបកប្រែមកជា " ពាក្យខ្មែរវិញ " ។(៨)

រឿងហង្សយន្ត មានទម្រង់រូបរាងបែបរឿង ជាតក (៩) ដែរ គឺ តួអង្គឯកជាពោធិសត្វ ចុះមកចាប់បដិសន្ធិនៅស្ថានមនុស្សលោកដូចឃើញក្នុងផ្ដើមសេចក្ដីរឿងស្រាប ៖

| | |
|---|---|
| " និទានកាលសម្ដេច | ព្រះសពេជ ( ១០ ) សម្ពុទ្ធា |
| ស្ដេចសាងបារមិតា | ពុំទាន់ត្រាស់ជាពង្សពុទ្ធ ។ |
| អន្ទោលទៅដោយខ្ចាត | ព្រះយកជាតិជាក់ប្រាកដ |
| ជាស្ដេចស្ដែងសន្ធត | នាមព្រះសុវណ្ណកុមារ ។ |
| ព្រះអង្គត្រាច់រង្គាត់ | នៅក្នុងវដ្ដសង្សារា |
| ស្ដេចសាងព្រះសម្ភារ | ពុំទាន់ទំព្រះបារមី |

( ទំព័រ

ឯតួអង្គឯកស្រី ជាកវីន្សារពេជ គឺ ជាអគ្គមហេសីព្រះបរ ធិសត្វ ហើយដល់ទីបញ្ចប់ គឺតួអង្គឯកប្រុស សជាតិជាពុទ្ធអង្គ តួអង្គស្រីជានា ពិម្ពា ។ ឯតួអង្គឯទៀត ក៏សជាតិជាលំដាប់តពុគ្នាទៅទៀតតាមកម្មផលរបស់ខ្លួនម្នាក់ៗ ។

## ២ - ចំណងជើងរឿង

បណ្ដារឿងល្បែងខ្មែរនានា កវីនិពន្ធតែងយកឈ្មោះតួអង្គឯកក្នុងរឿងមកដាក់ជាចំណងជើងរឿង ប្លែកតែរឿង ហង្សយន្ត កវីនិពន្ធឃើញព្រ

ឡប់ជាយកយានជំនិះគ្មានវិញ្ញាណដែលហោះហើរលើអាកាសបានដោយគ្រឿងយន្ត មកធ្វើជាចំណងជើងរឿងវិញ ។ តាមការសង្កេតឃើញថា តួអង្គក្នុងរឿង ល្បែងជាច្រើនតែងហោះហើរលើអាកាស អាស្រ័យលើមន្តអាគម សិល្បសាស្ត្រ ឬ ដំបងសិល្ប៍ ប្រតិសិល្ប៍ ឬ យក្ស សត្វឥន្ទ្រី សេះ ឬ ដំរីហោះ ។ល។(១១) ពោលគឺ ការហោះហើរលើអាកាសអាស្រ័យលើមន្តសិល្បសាស្ត្រ និង សត្វមានវិញ្ញាណដែលមានឥទ្ធិឫទ្ធិ ជាអច្ឆរិយៈហួសអ្វីដែលជាភាពមនុស្ស ផ្ទុយទៅនឹងរឿង ហង្សយន្ត សុវណ្ណកុមារហោះហើរលើអាកាសបានអាស្រ័យទៅលើយានជាគ្រឿងច្នៃប្រឌិតដោយសិប្បករជារូបហង្ស ដោយបន្ថែមគ្រឿងយន្តជាឧបករណ៍ហោះហើរបាន ដូចជាយន្តហោះសព្វថ្ងៃ ។ ធាតុទាំងនេះបង្ហាញថា កវីនិពន្ធខ្មែរយើងមានអារម្មណ៍ប្រឌិតអ្វីដែលច្នៃស្ថាបនាឡើងបានដោយប្រាជ្ញាចំណេះវិជ្ជានៃសិប្បករ ឬ វិស្វករ បែបអ្នកនិពន្ធបារាំង ស៊ុល វេន ដែរ ។

អ្វីទៅសត្វហង្ស ហើយអ្វីទៅដែលហៅថាយន្ត

" ហង្ស " ជាពាក្យបាលី ឯ " ហំសា " ជាពាក្យសំស្ក្រឹត គឺសំគាល់សត្វស្លាបមានសណ្ឋានបែបសត្វក្ងានដែរ គឺជាយានជំនិះព្រះព្រហ្ម ។ ពាក្យ " យន្ត " ជាពាក្យបាលី ឯ " យន្ត្រ "(១២) ជាពាក្យសំស្ក្រឹត សំគាល់អ្វីដែលជាគ្រឿងចក្រត្រូវនឹងពាក្យបារាំងថា " ម៉ាស៊ីន " ។

ក្នុងបណ្ដាអត្ថបទអក្សរសាស្ត្រនានា យើងប្រទះឃើញ ហង្សយន្ត មានក្នុងអត្ថបទល្បែងពីរ គឺ មួយក្នុងរឿង ព្រះជិនវង្ស និងមួយទៀតឃើញក្នុងរឿង ហង្សយន្តនេះឯង ។ តែហង្សយន្តក្នុងរឿងបន្ទាប់នេះ មានសារៈសំខាន់ក្នុងការស្ថាបនារឿង ដូចសេចក្ដីថាមានការប្រទាក់ក្រឡាជាទំនាក់ទំនងរឿងរចនាឡើងនៅលើជុំវិញយានជំនិះនេះឯង ពោលគឺតួអង្គឯក សុវណ្ណកុមារ ចេញទៅរៀនវិជ្ជាសិល្បសាស្ត្រនឹងគ្រូទិសាបាមោក្ខក៏ដោយសារហង្សយន្ត បានជួបស្នេហ៍ស្និទ្ធជាមួយនឹងនាង បទុមកេសរ ក៏ដោយសារហង្សយន្ត រួចខ្លួនពីស្លាប់ក៏ដោយសារហង្សយន្ត ព្រាត់ប្រាស់ប្រពន្ធក៏ដោយសារដោះខ្សែហង្សយន្ត ហើយទីបញ្ចប់ បានត្រឡប់ចូលទៅនគរវិញក៏ដោយសារហង្សយន្ត ។

ប្រសិនបើកវីនិពន្ធរឿងនេះមានគំនិតរក្សានិយមបែបកវីនិពន្ធនានានៅសម័យនោះ គួរតែដាក់ចំណងជើងថា " រឿងព្រះសុវណ្ណកុមារ " ដែលជាតួអង្គឯក ។ តែផ្ទុយទៅវិញកវីនិពន្ធមានគំនិតច្នៃប្រឌិតបានយកយានជំនិះជាគ្រឿងយន្តមកឲ្យចំណងជើងរឿងទៅវិញ ពោលគឺរឿង ហង្សយន្តនេះឯង (១៣) ។

## គ - ខ្លឹមរឿង

" នៅទេពបុរី ព្រះបាទអាទិត្យវង្សា និង នាងពិម្ពា បាន បង្កើតព្រះរាជបុត្រាមួយព្រះអង្គព្រះនាម សុវណ្ណកុមារ ។

ធំឡើងដោយទ្រង់ពុំសព្វព្រះទ័យនឹងរាជធីតា នៃនគរបំណុះទាំង ១០១ រាជកុមារក៏យាងតាមហង្សយន្តមួយ ដើម្បីស្វះស្វែងរើសរកមហេសី ។

ទ្រង់បានយាងទៅដល់បញ្ចបុរី បានទៅរៀនចប់ត្រៃវេទនឹង ព្រាហ្មណ៍បុរោហិតម្នាក់ហើយទៅលបលួចស្រលាញ់ព្រះនាង បទុមកេសរ ដែល ជាព្រះបុត្រីនៃនគរនោះ ។ ដោយដឹងថា បុត្រីមានគភ៌ ព្រះរាជាក៏ឲ្យ ពេជ្ឈឃាតតាមចាប់បុរសពានរាំងយកទៅសម្លាប់ ។

ដោយកលឧបាយផ្សេងៗ រាជកុមារក៏បានពង្រាត់ បទុមកេសរ តាមហង្សយន្តហោះឆ្ពោះមកកាន់មាតុភូមិវិញ ។

មកដល់ពាក់កណ្តាលផ្លូវ មហេសីក៏ប្រសូតបុត្រ ។ សុវណ្ណកុមារ ក៏ ដាក់មហេសីនៅក្រោមដើមក្រស្នា ហើយទើបឡើងហង្សយន្តទៅរកភ្លើងមកឲ្យមហេសី អាំង ។ ដោយទ្រង់បានទៅលួចឆក់យកភ្លើងពីសំពៅមួយយ៉ាងប្រញាប់ប្រញាល់ ពេក ភ្លើងនោះក៏ឆាបឆេះ បណ្តាលឲ្យហង្សយន្តធ្លាក់ទៅក្នុងសមុទ្រ ។ នាយ ភេត្រាម្នាក់បានស្រង់ព្រះកុមារឲ្យរួចពីក្តីស្លាប់ ។ បាត់ស្វាមីយូរពេក នាងបទុម កេសរ ក៏ដើរតាមរកដោយផ្ញើទារកទុកនឹងដើមក្រស្នា ។

ព្រះបាទព្រហ្មទត្តនៃនគរពារាណសី ដែលបានទៅក្រសាលព្រៃ បានទៅឃើញនេះហើយ ក៏រើសយកមកចិញ្ចឹមដាក់ឈ្មោះថា ចៅក្រឹស្នកុមារ ។ ដល់ត្រឡប់មកពីរកស្វាមីពុំឃើញ ហើយថែមទាំងបាត់ទារកទៀតនោះ បទុម កេសរ ក៏បានទៅជួបនឹងយាយ មាលា របស់ព្រះបាទព្រហ្មទត្ត ហើយក៏នៅសំ ណាក់នៅទីនោះទៅ ។

ដោយឃើញបុត្រចិញ្ចឹមពេញកំលោះហើយ ព្រះបាទព្រហ្ម ទត្តក៏ឲ្យអាមាត្យរើសរកមហេសីមកថ្វាយព្រះរាជបុត្រ ។ អាមាត្យក៏បាននាំ នាង បទុមកេសរ មកថ្វាយ ដែលជាហេតុនាំឲ្យម្តាយនិងកូនស្គាល់គ្នា ហើយខំជួយ រកព្រះ សុវណ្ណកុមារ ដែលនៅទីបំផុតក៏បានជួបជុំគ្នាដូចបំណង ។ ចៅក្រឹស្នកុមារ ក៏បាននាំបិតាទៅពិនិត្យហង្សយន្ត ដែលនាយសំពៅម្នាក់បានស្រង់យកមកថ្វាយព្រះបាទ ព្រហ្មទត្ត ។ សុវណ្ណកុមារ ក៏ខំជួសជុលហង្សយន្តដោយអាថ៌កំបាំងបំផុត រហូតដល់ប្រើ

ប្រាស់បាន ជួបកំបញ្ចិះមហេសី និង បុត្រាត្រឡប់មកកាន់ទេពបុរីវិញ ហើយបាន ជួបជុំព្រះញាតិវង្សយ៉ាងរីករាយ ។

ប៉ារីស៍ ថ្ងៃទី ១៦ ធ្នូ ១៩៨៥

ឃឹង ហុកឌី

1

## បញ្ជីឯកសារលើរឿងហង្សយន្ត

| | | | | |
|---|---|---|---|---|
| ១ - សាស្ត្រាស្លឹករឹតហង្សយន្ត | លេខបញ្ជីពុទ្ធសាសនបណ្ឌិត្យ | ៥៦៥ | - ៥ | ក៏១ភ |
| ២ - | - " - | - " - | ៥៦៦ - ១ | - |
| ៣ - | - " - | - " - | ៥៦៧ - ១ | - |
| ៤ - | - " - | - " - | ៥៦៨ - ១ | - |
| ៥ - | - " - | - " - | ៥៦៩ - ៣ | - |
| ៦ - | - " - | - " - | ៥៧០ - ៤ | - |
| ៧ - | - " - | - " - | ១៤៧២ - ១ | - |
| ៨ - សាស្ត្រាស្លឹករឹតហង្សយន្ត | លេខបញ្ជីសាលាចាំងចុងបូពាំប្រទេសបារាំង | ៤២ - ៤ | | - |
| ៩ - | - " - | - " - | ២៩០ - ២ | - |
| ១០ - សាស្ត្រាលើក្រដាសហង្ស | លេខបញ្ជីសាលាចុងបូព៌ាប្រទេស | ៧០ - ៣ | | - |
| ១១ - សៀវភៅរឿងហង្សយន្ត | ពុទ្ធសាសនបណ្ឌិត្យ | - ១៩៦១ | | |
| ១២ - | - " - | បណ្ណាគារគីម ឌី - ១៩៦៥ | | |
| ១៣ - | - " - | បណ្ណាគារសេរីរដ្ឋ - ១៩៥៩ | | |
| ១៤ - | - " - | បណ្ណាគារសេងងួនហួត - ១៩៦៦ | | |

១-សូមអានអារម្ភបទ " ហង្សយន្ត " ពុទ្ធសាសនបណ្ឌិត្យ ទំព័រ ង

២-គឺជាសមូហភាពនៃរឿងរ៉ាវទាំង ៥០ រឿង ដែលជាអតីតជាតិនៃព្រះពុទ្ធគោតមបរមគ្រូ ក្នុងកំឡុង ដែលព្រះអង្គបានអន្ទោលទៅចាប់កំណើតនៅភពផ្សេងៗ ។ បញ្ញាសជាតកគឺជាគម្ពីរដែលមាននៅប្រទេសខ្មែរ ថៃ លាវ និង ភូមា ។

៣-សូមអានសៀវភៅលោកគ្រូ ញ៉ុក ថែម - <u>បញ្ញាសជាតកសង្ខេប</u> ភ្នំពេញ មហាវិទ្យាល័យអក្សរសាស្ត្រ ឆ្នាំ ១៩៦៣ ទំព័រ ១១៩ - ១២៨ និងអត្ថបទលោក L. FINOT - " Recherches sur la littérature laotienne " <u>BEFEO</u> , 1917 , XVII , 5 , page 41 - 52

៤-ពាក្យសំស្ក្រឹត " ពោធិសត្វ " - បាលី "ពោធិសត្ត" សំគាល់ " បុគ្គលអ្នកមានចិត្តជាប់ក្នុងការត្រាស់ដឹង " ឬ " បុគ្គលអ្នកមានចិត្តជាប់ក្នុងប្រាជ្ញាជាគ្រឿងត្រាស់ដឹង " ។

៥- cf. Kingkeo ATTAGARA - <u>The Folk Religion of Ban Nai</u> , <u>A hamlet in Central Thailand</u> , Ph.D. , Indiana University , 1967 , 597 p. , G. KRULL - <u>Tales from Siam</u> , LONDON , 1966 W.A.M. URQUHART , <u>Tales from Old Siam</u> , Bangkok , S.D. , 155 p. , P.SCHWEISGUTH , <u>Etude sur la littérature siamoise</u>, Paris , Maison neuve , 1951 .

៦-ព្រះមហា រស់ ឃុត និងអ្នកស្រី ឃុន ខុន - " ចៅឃមភក្តី ឆក និងហង្សយន្ត " ក្នុង ឃួន សុខម្ម - ស្រាវជ្រាវរកអ្នកនិពន្ធខ្មែរ - ភ្នំពេញ មហាវិទ្យាល័យអក្សរសាស្ត្រ ឆ្នាំ ១៩៧១ ទំព័រ ២៣ - ២៩

៧-<u>ខ្យងសង្ខ</u> - ភ្នំពេញ - ពុទ្ធសាសនបណ្ឌិត្យ - ១៩៥៧ - ២៥៦ ទំព័រ

៨-ព្រះមហា រស់ ឃុត - " - ទំព័រ ២៩

៩-" ជាតក " ជាពាក្យ បាលី អានថា ជាតៈកៈ ហើយអានតាមសំនូរខ្មែរ ថា " ជាដក់ " គឺរឿងរ៉ាវពីក្នុងជាតិមុនៗនៃព្រះពុទ្ធអង្គ មានទាំងអស់ចំនួន ៥០០ រឿង ឧទាហរណ៍ : មហាវេស្សន្តរជាតក ជាដើម ។ រឿងនេះមជ្ឈមណ្ឌលឯកសារស្រាវជ្រាវអរិយធម៌ខ្មែរ និង ពុទ្ធិកសមាគមខ្មែរ បានបោះពុម្ពឡើងវិញនៅឆ្នាំ ១៩៨២ ។

១០-ព្រះសព្វជ្ញ ជាពាក្យសំស្ក្រឹតក្លាយមកពីសំស្ក្រឹត សវ៌ជ្ញ បាលីថា សព្វញ្ញូ គឺអ្នកត្រាស់ដឹងសព្វគ្រប់ទាំងអស់ពោលគឺ ព្រះពុទ្ធអង្គនោះឯង ។

១១_ខ្យងសង្ខ - ភ្នំពេញ - ពុទ្ធសាសនបណ្ឌិត្យ - ១៩៥៧ - ២៥៦ ទំព័រ
ជ័យសុរវង្ស - ភ្នំពេញ - គីម គី - ១៩៥២ - ២ ភាគ
ពុទ្ធិសែន - ភ្នំពេញ - ពុទ្ធសាសនបណ្ឌិត្យ - ៨១ ទំព័រ
ព្រះសុធន - ភ្នំពេញ - ១៩៥៣ - ១៤៤ ទំព័រ
១២_ពាក្យនេះមានន័យម្យ៉ាងទៀតគឺ សំគាល់អ្វីដែលទាក់ទងនឹងមន្តអាគមឥទ្ធិអាម
ដូចជា កន្ទែនរុងយន្ត - អាវយន្ត ។ល។ សំរាប់ការពារគ្រាប់មេរុវជាដើម
១៣_សូមអានសេចក្ដីសង្ខេបរឿង ហង្សយន្ត ទំព័រ ឆ - ឈ
cf. KHING Hok Dy , " Note sur le motif du cygne mécanique dans la littérature populaire khmère ", Mon-Khmer Studies VIII , The University Press of Hawaii , 1979 , p. 91-IOI

# សេចក្ដីបញ្ជាក់

តាមសេចក្ដីសម្រេច របស់កិច្ចប្រជុំការងារក្នុងក្រសួង លើកទី ៤ ពីថ្ងៃទី ៨ តុលា ១៩៦៤ ស្ដីអំពីរឿងបោះពុម្ពសៀវភៅនានា របស់រដ្ឋាស្ថានពុទ្ធសាសនបណ្ឌិត្យ ក្រុមជំនុំបានសម្រេចយោបល់ដូចតទៅ ៖

**ក) អំពីខ្នាតសៀវភៅ:** ខ្នាតសៀវភៅទាំងអស់ លើកលែងតែសៀវភៅព្រះត្រៃបិដក និងវចនានុក្រមខ្មែរចេញ តទៅថ្ងៃមុខ ត្រូវកំណត់ឲ្យមានខ្នាតតែ ៣ ដូចតទៅនេះ ៖

១– សៀវភៅរឿងរ៉ាវផ្សេងៗ មានរឿង ទុំទាវ ជាដើម ដែលមានបែបក្នុងកម្មវិធីសិក្សា ត្រូវយកទំហំប៉ុនសៀវភៅ សុបិនកុមារ គឺ ១៤×២០ ស.ម. ។

២– សៀវភៅច្បាប់ផ្សេងៗ ព្រមទាំងសៀវភៅធម៌សម្រាយពួកខ្នាតតូច ដូចជាកាមកេរ្តិ៍ មួយពាន់មួយយប់ សីមាវិនិច្ឆ័យ សប្បុរិសធម៌ ជាដើម ត្រូវយកទំហំប៉ុនសៀវភៅ គតិលោក ជាគំរូ គឺ ១២×១៦ ស.ម. ។

៣– សៀវភៅខ្នាតកណ្ដាលឯទៀតៗ ទាំងសម្រាយ ទាំងបាលី ដូចជាសៀវភៅ សាមណេរវិន័យ ធម្មបទ មង្គលត្ថទីបនី សៀវភៅ

ផ្នែកក្រមដំទុំទំនៀមទម្លាប់ ទាំងភាសាខ្មែរ និងបាលីជាដើម ត្រូវយកទំហំប៉ុនសៀវភៅ គិតហិបដិបត្តិ ជាគំរូ គឺ ១៦×២៤ ស.ម. ។

## ខ) ទម្រង់ខាងក្នុង :

១– ពិនិត្យឡើងវិញនូវឈ្មោះអ្នកនិពន្ធដើម បើមាន ត្រូវដាក់នៅដើមទំព័រ បើគ្មាន ត្រូវដាក់កំណើតសាស្ត្រា វត្តណា ឯកសារនៅទីណា ។ ឯឈ្មោះអ្នកចម្លង ឬអ្នកពិនិត្យ លែងឲ្យដាក់នៅទំព័រខាងមុខទៀតហើយ ត្រូវយកទៅដាក់នៅក្នុងអារម្ភកថាវិញ ។

២– បើមានកែប្រែពាក្យពេចន៍ថ្មី ឬឃ្លាជាប្រយោគថ្មី ត្រូវធ្វើលេខយោងបញ្ជាក់ ដាក់នៅខាងក្រោម ឬ ក្នុងអារម្ភកថា ។

៣– ត្រូវដាក់ប្រាប់ នូវលើកនៃការបោះពុម្ពផ្សាយ ពីមួយលើកទៅមួយលើក ឲ្យរៀងគ្នា ។

៤– ចំពោះសៀវភៅសិក្សា ពាក្យកាព្យ ត្រូវលៃលកដាក់លេខគាថា រៀង ៗ គ្នា នៅដើមឃ្លា ពីដើមដល់ចប់ ។

ចំពោះរឿងហង្សយន្តនេះ វិជ្ជាស្ថាន ដាក់លេខរៀងគាថា ម្តង ៥ ម្តង ៥ ពីដើមដល់ចប់ ដើម្បីតម្រូវឲ្យងាយដល់សាស្ត្រាចារ្យ ឬ សិស្ស យកទៅប្រើការ ។

មួយវិញទៀត, កាលបោះពុម្ពលើកទី ១ ដល់ទី ៤ មានពាក្យពេចន៍ខ្លះ បានភ្ញាំងភ្ញាត់ឃ្លៀងឃ្លាតចាកច្បាប់ដើម ។ ក្នុងលើកទី ៥ នេះ យើងបានកែតម្រូវឡើងវិញ ។

វិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ

# អារម្ភបទ

រឿងហង្សយន្តនេះ គ្មានក្នុងគម្ពីរបញ្ញាសជាតកបាលី ឬ គម្ពីរបាលីណាទេ ជារឿងដែលលោកអ្នកនិពន្ធក្នុងសម័យមុន បានតែងឡើង ដោយពុំបានប្រាប់នាមលោកអ្នកនិពន្ធ ឬ សករាជឡើយ ។

ដោយរឿងនេះ ជារឿងកំសត់ពីរោះពីសា ហើយជាវណ្ណគតិខាងអក្សរសាស្ត្រមួយដ៏ល្អប្រពៃ, ព្រះសង្ឃស្ទើរតែគ្រប់វត្តអារាម ក្នុងព្រះរាជអាណាចក្រកម្ពុជា បានចាប់ចម្លងត ៗ គ្នា ដាក់ស្លឹករឹត សម្រាប់ឲ្យកុមារសិស្សវត្តសិក្សាអក្សរសាស្ត្រជាតិ ជាយូរយារមកហើយ ។

វិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ បានចាត់ឲ្យចម្លងរឿងនេះ ចេញពីសាស្ត្រាស្លឹករឹត ដែលមានក្នុងបណ្ណាល័យនៃវិជ្ជាស្ថាននេះ យកមកពិនិត្យផ្ទៀងផ្ទាត់ ហើយចាត់ការបោះពុម្ពផ្សាយឡើង ដើម្បីរក្សាស្នាដៃកវីនិពន្ធខ្មែរសម័យបុរាណ ទុកជាកេរ្តិ៍តទៅ កុំឲ្យបាត់បង់ និងដើម្បីជាប្រយោជន៍ឲ្យអ្នកអាន ៖

ក) បានយល់ច្បាស់ថា ជាតិខ្មែរយើង មានកេរ្តិ៍មតិកអក្សរសាស្ត្រជាច្រើនបែប,

ខ) បានស្គាល់ព្រឹត្តិការណ៍អក្សរសាស្ត្រខ្មែរសម័យបុរាណ,

គ) បានចេះចាំរឿងនិទាន និងពាក្យពេចន៍បុរាណច្រើន បែកប្រាជ្ញា អាចធ្វើការរចនា និងការនិពន្ធរបស់ខ្លួនឲ្យមានសម្រស់,

ឃ) បានប្រៀបធៀបវោហារពាក្យពេចន៍សម័យចាស់ និងសម័យថ្មី ហើយបើត្រូវការនិពន្ធរឿងអ្វី អាចធ្វើសេចក្តីនិពន្ធរបស់ខ្លួនឲ្យមានលំអ ឲ្យត្រូវគ្រប់សម័យ ។

ការចម្លងនិងការពិនិត្យផ្ទៀងផ្ទាត់នេះ បានទុករឿង និងពាក្យពេចន៍ ក្នុងផ្នែករឿង ឲ្យនៅតាមច្បាប់ដើម ឥតកែប្រែ គ្រាន់តែសម្រួលពាក្យខ្លះ ដែលយល់ច្បាស់ថា តក់ដោយការចម្លងត ៗ គ្នាជាច្រើនតំណមកហើយ ឲ្យត្រូវតាមច្បាប់ដើមឡើងវិញ និងគ្រាន់តែប្រើអក្សរតាមវចនានុក្រមខ្មែរ សម័យបច្ចុប្បន្នប៉ុណ្ណោះ ។

វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ សង្ឃឹមថា សៀវភៅរឿងហង្សយន្ត នេះ និងបានជាកម្លាំងមួយ អាចជួយពង្រីកអក្សរសាស្ត្រជាតិឲ្យមាន វឌ្ឍនាការជាតិយោភាពតទៅ ។

ពុទ្ធសាសនបណ្ឌិត្យ

# សង្ខេបរឿង

ក្នុងកាលដ៏កន្លងទៅហើយ មានព្រះរាជាមួយព្រះអង្គ ព្រះនាមអាទិត្យវង្ស អគ្គមហេសីព្រះនាមពិម្ពា ជាស្ដេចបានអានុភាពជាងស្ដេចទាំង ១០១ មានព្រះស្នំ ៦ ពាន់ តែងគាល់បម្រើ សោយរាជ្យនៅក្រុងទេពបុរី ។ ព្រះស្នំទាំង ៦ ពាន់នោះ សឹងពុំមានបុត្រាមួយសោះ ។ ពួកសេវកាមាត្យ ខ្លាចសាបសូន្យព្រះនគរ ក៏ក្រាបទូលព្រះរាជាថា “បពិត្រព្រះសម្មតិទេព ព្រះនគរយើង បើឥតពីព្រះអង្គទៅ នឹងពុំមានក្សត្រណាមួយ សោយរាជ្យតទៅឡើយ” ។ ព្រះរាជា ទ្រង់ត្រាស់បង្គាប់ព្រះនាងពិម្ពាព្រះអគ្គមហេសី ឲ្យប្រដាប់ផ្កាភ្ញីបូជាពួកទេវតា, ឲ្យទាន, ចាំសីលអធិដ្ឋានសូមព្រះរាជបុត្រាមួយព្រះអង្គ ។ ព្រះនាង ក៏ទ្រង់ធ្វើតាមព្រះរាជបញ្ជា ។ ដោយអំណាចបុណ្យបារមីនៃព្រះនាង ក៏កក្រើកទៅដល់អាសនានៃសក្កទេវរាជ ។ ទ្រង់បើកទិព្វចក្ខុមើលហេតុសព្វគ្រប់ ទ្រង់អារាធនាព្រះបរមពោធិសត្វ ដែលជាទេវបុត្រមួយព្រះអង្គ ឲ្យចុះមកចាប់បដិសន្ធិក្នុងផ្ទៃនៃព្រះនាងពិម្ពា ។ លុះព្រះគភ៌គ្រប់ ១០ ខែហើយ ក៏ប្រសូត្រព្រះរាជបុត្រ ១ ព្រះអង្គ មានសម្បុរដូចមាស ។ ពួកព្រាហ្មណ៍ថ្វាយព្រះនាមថា « ព្រះសុវណ្ណកុមារ » ។ លុះមានព្រះជន្ម ១៦ វស្សា ព្រះវររាជបិតាទ្រង់ឲ្យនាំព្រះរាជធីតានៃស្ដេចទាំង ១០១ មកថ្វាយ តែព្រះ

រាជកុមារ ពុំសព្វព្រះរាជហឫទ័យសោះ ទ្រង់ទូលព្រះវររាជបិតាថា នឹងស្វែងរកព្រះអគ្គមហេសីផ្ទាល់ព្រះអង្គ ។

គ្រានោះ មានជាងពីរនាក់ ជាងម្នាក់ ចេះធ្វើប្រាសាទនិងក្បាច់របនាផ្សេងៗ ម្នាក់ទៀត ចេះធ្វើរូបសត្វ ដូចជារូបគ្រុឌ ក្ងោក ជាដើម មានខ្សែទាញ អាចជិះហោះឰដ៏អាកាសបាន ។ ព្រះរាជា ទ្រង់ព្រះរាជ-បញ្ជាឲ្យជាងពីរនាក់នេះ ធ្វើហង្សយន្តមួយ ជាព្រះទីនាំងសម្រាប់គង់ហោះទៅកាន់ទីផ្សេងៗ ។ លុះជាងទាំងពីរធ្វើរួចហើយ, ព្រះរាជាទ្រង់គង់លើហង្សយន្ត ទៅកាន់ទីនានា មានព្រៃហិមពាន្តជាដើម ។

ឯព្រះរាជកុមារ ទ្រង់មានព្រះបំណងចង់ចេញទៅរៀនសិល្បសាស្ត្រ ក៏ទ្រង់ចូលទៅទូលលាព្រះវររាជមាតាបិតា។ ទ្រង់អនុញ្ញាត ហើយប្រគល់ហង្សយន្តដល់ព្រះរាជកុមារ។ ទ្រង់គង់លើហង្សយន្តនោះ ហោះទតព្រៃព្រឹក្សាចំនួន ៣ សប្តាហ៍ ចូលដល់នគរបញ្ចាល ទ្រង់ទុកហង្សយន្តលើឈើធំ ១ ដើម ហើយយាងចូលទៅសំណាក់ផ្ទះចៅព្រាហ្មណ៍ហោរាម្នាក់ ដែលជាបុរោហិតព្រះចៅក្រុងបញ្ចាល សុំរៀនសិល្បសាស្ត្រ ។ មិនយូរប៉ុន្មាន ព្រះសុវណ្ណកុមារ រៀនចេះសិល្បសាស្ត្រ យ៉ាងស្ទាត់ជំនាញ ។ ព្រាហ្មណ៍ហោរា បានសុំព្រះអង្គធ្វើជាកូនធម៌ តែងនាំព្រះអង្គទៅគាល់

ព្រះចៅក្រុងបញ្ចាលរាល់ ១ ថ្ងៃ ។

ឯព្រះចៅក្រុងបញ្ចាល ព្រះអង្គមានព្រះរាជធីតាមួយព្រះអង្គ ព្រះនាមបទុមកេសរ មានព្រះជន្ម ១៦ វស្សា មានព្រះរូបល្អលើសស្ត្រីក្នុងព្រះនគរនោះ ។ ថ្ងៃមួយ ព្រះនាងទ្រង់ទតឃើញព្រះសុវណ្ណកុមារកំពុងយាងក្បែរប្រាសាទ មានព្រះទ័យចាប់ប្រតិព័ទ្ធចំពោះព្រះអង្គ អន្ទះអន្ទែងក្នុងព្រះទ័យផ្ទំពុំលក់ មានព្រះឆវីវណ្ណសៅហ្មងខុសធម្មតា ។ ស្រីបម្រើម្នាក់សួរព្រះនាង ៗ ប្រាប់ថា "ទ្រង់មានសេចក្ដីប្រតិព័ទ្ធចំពោះព្រះសុវណ្ណកុមារយ៉ាងខ្លាំង" រួចទ្រង់ប្រាប់ឧបាយឲ្យស្រីនេះ ទៅទូលព្រះសុវណ្ណកុមារ ។ ស្រីបម្រើ ក៏ទៅទូលព្រះសុវណ្ណកុមារ ៗ សន្យាថា នឹងមកកាន់ប្រាសាទព្រះនាងក្នុងពេលរាត្រី ។ លុះពេលរាត្រី ព្រះសុវណ្ណកុមារ គង់លើហង្សយន្ត ទៅកាន់ប្រាសាទព្រះនាងបទុមកេសរ ហើយយប់ក្រោយៗ តែងតែយាងមកយ៉ាងនេះ ដរាបព្រះនាងទ្រង់គភ៌ ។

ព្រះចៅក្រុងបញ្ចាលទ្រង់ជ្រាបថា ព្រះរាជធីតាមានគភ៌ ទ្រង់ធ្វើឧបាយឲ្យចាប់ព្រះសុវណ្ណកុមារបាន ឲ្យពេជ្ឈឃាតនាំទៅសម្លាប់ ។ ព្រះរាជកុមារបញ្ឆោតពួកពេជ្ឈឃាត ឲ្យនាំព្រះអង្គទៅក្បែរគល់ឈើដែលទុកហង្សយន្ត ព្រះអង្គឡើងគង់លើហង្សយន្តនោះ ហោះមកកាន់ប្រាសាទ

ព្រះនាងបទុមកេសរ ឲ្យព្រះនាងគង់លើហង្សយន្ត ហោះទៅត្រង់មុខប្រាសាទព្រះចៅក្រុងបញ្ចាល ស្រែកហៅពីលើអាកាស ហើយហោះទៅកាន់ក្រុងទេពបុរីវិញ ។

លុះយាងទៅបាន ១ សប្តាហ៍ ព្រះនាងបទុមកេសរទ្រង់ឈឺព្រះឧទរនឹងប្រសូតព្រះរាជបុត្រ ។ ព្រះរាជកុមារ ចុះហង្សយន្តឈប់ក្បែរឆ្នេរសមុទ្រ ។ ព្រះនាង, កាលបើប្រសូតរួចហើយ ទ្រង់រងាញាក់ព្រះអង្គស្ទើរសន្ទប់បាត់ស្មារតី ព្រះចក្រីទ្រង់ក្រឡេកទៅឃើញសំពៅ ១ បើកកណ្តាលសមុទ្រ ក៏គង់ហង្សយន្តទៅយកភ្លើង លុះត្រឡប់មកវិញ ភ្លើងក៏ឆេះខ្សែហង្សយន្ត ជាប់ធ្លាក់ព្រះអង្គ ក្នុងសមុទ្រនោះទៅ ។

រីព្រះនាងទេវី ចាំមើលព្រះស្វាមីពុំឃើញមក ទ្រង់បីព្រះរាជបុត្រទ្រង់ព្រះកន្សែងក្នុងព្រៃ លុះនឿយព្រះកាយពល យាងទៅទៀតពុំបានក៏ដោះចិញ្ចៀនព្រះទម្រង់ ចងភ្ជាប់នឹងព្រះហស្តព្រះរាជបុត្រ ហើយផ្តេកលើកម្រាលព្រះពស្ត្រ ក្រោមឈើក្រស្នាមួយដើម ហើយត្រាច់រកព្រះស្វាមីទៀត ។

ថ្លែងពីព្រះសុវណ្ណកុមារ ទ្រង់ហែលក្នុងមហាសមុទ្រ ត្រូវនាយសំពៅម្នាក់រើសបាន ។ ក្រោយមក មាននាយសំពៅម្នាក់ទៀត រើស

បានរូបហង្សយន្ត ។

ថ្ងៃមួយ មានក្សត្រមួយព្រះអង្គ ព្រះនាមព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិក្នុងក្រុងពារាណសី ទ្រង់យាងទៅក្រសាលព្រៃហិមពាន្ត លុះយាងទៅទៀបឈើក្រស្នា ទតឃើញព្រះរាជកុមារនោះ ក៏រើសយកមកចិញ្ចឹមសន្មតព្រះនាមថា " ចៅក្រឹស្នកុមារ " ។

ព្រះនាងទេវី កាលបើមិនជួបព្រះស្វាមី ក៏ត្រឡប់មកដើមក្រស្នាវិញ ពុំឃើញព្រះរាជបុត្រ ទ្រង់សោកសន្ធប់បាត់ស្មារតី លុះដឹងស្មារតីវិញ ទតមើលឆ្វេង-ស្តាំ ឃើញដីទក់ទី ដឹងថា មាននរណារើសព្រះរាជបុត្រ, ក៏យាងទៅតាមស្នាមទ័ពព្រះបាទពារាណសី ដរាបដល់ផ្ទះដូនចាស់តាចាស់នៅក្បែរព្រះនគរ ។ គាត់ជាអ្នកក្រងផ្កាថ្វាយព្រះរាជា ។ ព្រះនាង សុំដូនចាស់តាចាស់ធ្វើជាកូនធម៌ ហើយក្រងផ្កាថ្វាយព្រះរាជារាល់ថ្ងៃ ជំនួសដូនចាស់ ។

លុះចៅក្រឹស្នកុមារ បានព្រះជន្ម ១៦ វស្សា ព្រះបាទព្រហ្មទត្តទ្រង់ជ្រើសរើសព្រះធីតានៃក្សត្រនានា រហូតដល់កូនសេដ្ឋីគហបតី ឲ្យធ្វើជាអគ្គជាយា ។ តែព្រះរាជកុមារពុំសព្វព្រះរាជហឫទ័យសោះ ។ ស្រាប់តែអាមាត្យម្នាក់ ក្រាបទូលព្រះរាជា អំពីរូបសម្ប័ទរបស់ចៅយាយមាលា ។

ព្រះរាជាទ្រង់ឲ្យនាំព្រះនាងបទុមកេសរនោះមក ។ ព្រះរាជកុមារគ្រាន់តែឃើញព្រះនាងភ្លាម មានព្រះទ័យប្រតិព័ទ្ធយ៉ាងខ្លាំង ។ ព្រះអង្គអភិសេកព្រះរាជកុមារនិងព្រះនាងបទុមកេសរ តាមព្រះរាជប្រពៃណី ឲ្យគង់លើប្រាសាទមាសមួយដ៏ល្អឆើត ។

ក្នុងយាមទី ១ នៃរាត្រីនោះ ព្រះរាជកុមារ ទ្រង់ចូលក្នុងក្រឡាព្រះបន្ទំព្រះនាងបទុមកេសរ, ស្រាប់តែមានទេពតាមួយអង្គ មកបណ្ដាលឲ្យមេឆ្មាដើរទៅជិតកូនវា ។ កូនឆ្មានិយាយថា នរណាអេះ ហ៊ានដើរលើក្បាលអញ ? ។ មេវាឆ្លើយថា កូនកុំនិយាយដូច្នេះ យើងជាសត្វតិរច្ឆាន, ចំណង់បើមនុស្ស ម្ដេចគេហ៊ានយកម្ដាយឯងធ្វើភរិយា ។ ព្រះរាជកុមារទ្រង់ព្រះសណ្ដាប់ដូច្នោះ ក៏ត្រឡប់មកក្រឡាព្រះបន្ទំវិញ ។ យាមទី ២ ទ្រង់ចូលទៅទៀត, ស្រាប់តែមេនិងកូនពពែនិយាយពាក្យដូច្នោះទៀត, ព្រះអង្គក៏ត្រឡប់ទៅវិញ ។ យាមទី ៣ ទ្រង់ចូលទៅទៀត ទ្រង់ឮកូននិងមេសេះនិយាយគ្នានូវពាក្យដដែល ព្រះអង្គរំពឹងថា " ខ្លួនព្រះអង្គគឺព្រះបិតារើសមកពីព្រៃ " ក៏អធិដ្ឋានថា " បើស្ត្រីនេះ ជាមាតារបស់អញមែន សូមកុំឲ្យសត្វនេះចរចាគ្នាទៀត " រួចទ្រង់យាងចូលទៅ ។ រីសត្វទាំងនោះពុំនិយាយគ្នាឡើយ ។ លុះព្រះរាជកុមារយាងចូលទៅដល់

ព្រះនាងបទុមកេសរ ទ្រង់ជ្រាប់ហេតុសព្វគ្រប់ ក៏ទ្រង់ព្រះកន្សែងទាំងពីរ ព្រះអង្គ ។ តមក ព្រះនាងទ្រង់ឲ្យជាងសង់សាលាទាន ១ សម្រាប់ ដាក់ទានបាយចំណីដល់អាគន្តុកជន នៅក្បែរទ្វារព្រះនគរ ហើយឲ្យ ជាងគូរគំនូរ រៀបរាប់ពីប្រវត្តិរបស់ព្រះនាង និងព្រះសុវណ្ណកុមារ រួច ទ្រង់ផ្តាំបង្គាប់នូវហេតុសព្វគ្រប់ នឹងយាយមាលា ។

ថ្ងៃពីនាយសំពៅ ដែលរើសបានហង្សយន្ត ក៏នាំរូបហង្សយន្ត នេះមកថ្វាយព្រះបាទព្រហ្មទត្ត ។ ទ្រង់ប្រគល់ហង្សយន្តនេះ ដល់ទៅ ក្រឹស្នកុមារ ។ ព្រះនាងបទុមកេសរ ឃើញហង្សយន្តដូច្នោះ ទ្រង់ព្រះ កន្សែងជាខ្លាំង ។

ចំណែកឯនាយសំពៅ ដែលស្រង់ព្រះសុវណ្ណកុមារ បានបើក សំពៅទៅចតនៅនគរពារាណសីដែរ ។ ព្រះសុវណ្ណកុមារ ទ្រង់ចុះពី សំពៅយាងទៅក្បែរព្រះបរមរាជវាំង ទ្រង់ចូលទៅកាន់សាលានោះ លុះ សោយព្រះស្ងោយហើយ យាងទតរូបគំនូរ ទ្រង់យល់ថា «គំនូរនេះជា ប្រវត្តិរបស់ព្រះអង្គ» ទ្រង់ស្ទុតព្រះដង្ហា យាងទៅទៀតពុំបាន ទ្រង់ព្រះ កន្សែងនៅទីនោះ ។

ពួកឆ្មាំអ្នកចាំសាលាទាន ឃើញដូច្នោះ រត់ទៅជម្រាបយាយមាលាៗ

ទៅទូលព្រះនាង ។ ឲ្យគេនាំព្រះសុវណ្ណកុមារចូលទៅក្នុងប្រាសាទ ។ ព្រះនាង, លុះទតឃើញព្រះសុវណ្ណកុមារច្បាស់ហើយ ក៏ស្ទុះទៅឱបព្រះបាទា, ឯចៅក្រឹស្នកុមារក៏ជូប្នោះដៃ, តាំងពីព្រះអង្គទ្រង់សោកាសន្ទប់នៅទីនោះ ។ ព្រះរាជាព្រហ្មទត្ត ឲ្យអាមាត្យទៅទូលសួរអំពីរឿងសោកានៃក្សត្រតាំងពីព្រះអង្គ ។ ព្រះសុវណ្ណកុមារ ទ្រង់ត្រាស់ថា ត្បិតយើងជាបងព្រះនាងបទុមកេសរ ព្រាត់គ្នា ទើបតែនឹងបានជួបក្នុងគ្រានេះ ។

ក្សិណានោះ ចៅក្រឹស្នកុមារ យកហង្សយន្តមកថ្វាយព្រះសុវណ្ណ-កុមារជាព្រះបិតា ។ ព្រះអង្គទ្រង់រៀបចំហង្សយន្តបានល្អដូចដើម ហើយប្រទានរង្វាន់ជាច្រើនដល់នាយសំពៅទាំងពីរ ព្រមទាំងយាយមាលា ។ ក្នុងរាត្រីនោះ ចៅក្រឹស្នកុមារ ទ្រង់សរសេរព្រះរាជសារមួយច្បាប់ បិទនៅទ្វារប្រាសាទ ក្រាបថ្វាយបង្គំលាព្រះបាទព្រហ្មទត្ត ហើយព្រះសុវណ្ណកុមារ ព្រះនាងបទុមកេសរ និងចៅក្រឹស្នកុមារ ក៏ទ្រង់ឡើងគង់ហង្សយន្ត ហោះទៅកាន់ក្រុងទេពបុរី ជាជាតិភូមិរបស់ព្រះអង្គដោយសិរីសួស្ដី ។

* * *

# រឿងហង្សយន្ត

## បទកាកគតិ

១– អហំយើងខ្ញុំ   ក្រុញក្រាបប្រណម្យ   ព្រះអង្គឥតឆ្គង
កាលកបសទ្ទឹក   ពោធិព្រឹក្សទន្ទង   ព្រះអង្គជាប្បង់
ទូទាំងត្រៃភព ៗ

ស្ដេចផ្ដួចការកេ-   ត្រាត្រាប់ត្រៃជត   ត្រដឹងស្កល់ស្កប់
ផ្ញុកសត្វនិករ   អមរសាយសព្វ   នានាំគ្រាន់គ្រប់
ជាក់ជល់និព្វាន ៗ

បង្គំព្រះធម៌   ប្រសើរមានអាថ៌   ជាសំណាញ់ញាណ
សម្ដេចពុទ្ធវង្ស   ស្រោចស្រង់សត្វបាន   បរិបូណ៌បិតហាន
សុខសួគ៌ទៀងទាត់ ៗ

បង្គំសង្ឃសាង   សីលសុទ្ធលះលាង   បាបបោះបង់បាត់
ទុក្ខសោកប្រាយប្រាស   លាភលះស្នេហ៍ស្និទ្ធ   សេពសោយសម្បត្តិ
សួគ៌សួស្ដីសោដ្ឋា ៗ

៤– អញខ្ញុំត្រេកអរ   លុតលើកទសករ   ដោមដាក់សិរេ
ក្រុញក្រាបវន្ទា   ទេវតាណា   សាយសព្វសុសសោ-

ឡសទាំងចក្រវាឡ ។

បង្គំមហាក្សត្រ ថ្លៃមានបុណ្យក្តាត់ ឥសូរក្ខុបាល

គ្រងឥន្ទ្របត្ត កស្ត្រវង្គបរិពារ ក្រុមក្សាន្តបុណ្យបារ-

មីអម្ចាស់ថ្លៃ ។

ខ្ញុំបង្គំគុណ គ្រូប្រសើរលន់ ប្រដៅខ្ញុំនៃ

បានបរិបូណ៌ចប់ ក្បួនច្បាប់ប្រពៃ ជាពន្លឺក្រៃ

បទគុណគ្រូគាប់ ។

៨— គុណព្រះមាតា គុណព្រះបិតា នៃខ្ញុំគោរព

ទូលទុកនៅនា- សិរសាសោតសព្វ ថ្ងៃតែងគោរព

គុណគម្ពីរ ។

## បទព្រហ្មគីតិ

១— ព្រះគុណទាំងប្រាំពីរ ស្មើជីវិតថ្លៃថ្លា

ឧត្តុង្គឧត្តមា ខ្ពស់អនេកអនន្តក្រៃ ។

ធ្ងន់លើសលែងប្រឹថពី បវីទាំងផែនដី

ជ្រាលជ្រៅ ៗ ក្រាស់ក្រៃ លែងសាគរគម្ពីរ ។

តេជះខ្ញុំថ្វាត់ថ្វាយ បង្គំកាយវរវន្ទា

សូមសំរឹទ្ធិប្រា- កដកបកើតស្រីសួស្តី ។
ទើបខ្ញុំនឹងស្រង់ស្រាយ ស្រាយអស់អាថ៌ប្រែពាក្យពី-
សៀមបទប្រាកដទី ជាពាក្យខ្មែរវិញហោនណា ។

៦— និទានកាលសម្តេច ព្រះសពេជសម្ពុទ្ធ
ស្តេចសាងបារមីតា ពុំទាន់ត្រាស់ជាពន្សពុទ្ធ ។
អន្ទោលទៅដោយខ្នាត ព្រះយកជាតិជាក់ប្រាកដ
ជាស្តេចស្តែងសន្ទត នាមព្រះសុវណ្ណកុមារ ។

៧— ព្រះអង្គត្រាច់រង្គាត់ នៅក្នុងវដ្តសង្សារ
ស្តេចសាងព្រះសម្ភារ ពុំទាន់ទុំព្រះបារមី ។

## បទកាកគតិ

៨— ឯកោពជា មុនមានព្រះមហា- ក្សត្រមួយជាឥ-
ស្សរស័ក្តិច្បាស់ច្បង គ្រប់គ្រងធានី ក្រុងទេពបុរី
ជាចៅនគរ ។

ព្រះអង្គជាក្សត្រ ចមចៅចក្រវត្តិ សម្តេចភូធរ
ចម្រើនសួស្តី វុឌ្ឍីព្រះពរ ទ្រង់ព្រះនាមករ
អាទិត្យវង្សា ។

មានអគ្គមហេសី    វរវណ្ណក្សត្រី    នាមនាងពិម្ពា
ទេវីវរលក្ខណ៍    អង្គអគ្គជាយា    ទ្រង់ឆោមសោភា
សោភ័ណសល់ស្រី ។

នាងនាថឧត្តម    លើសលើព្រះស្នំ    ស្រឹង្គារនារី
ទាំងប្រាំមួយពាន់    ណាស់ណាន់ប្រក្រតី    សម្រាប់ភូមី
បមរៅចក្កវត្តិ ។

ស្តេចគង់ប្រាសាទ    ប្រសើរស្អាងស្អាត    ទីងព្រះបូររតន៍
ស្រីស្រស់ស្រឹង្គារ    បរិពារបរិសុទ្ធ    មន្ត្រីជុំជិត
គង់គាល់រាជា ។

ស្តេចមានអំណាច    ទាំងឯកសតរាជ(១)    បង្គំរាជា
កោតព្រះបារមី    រឹទ្ធិចេស្តា    ថ្វាយសួយសព្វគ្រា
ជាអចិន្ត្រៃយ៍ ។

១៤— ពីរពង្សបមក្សត្រ    ស្តេចសោយសម្បត្តិ    រម្យរាជ្យថ្កាថ្កៃ
គ្រប់គ្រងស្រឹង្គារ    ព្យាបាលសព្វថ្ងៃ    ប្រាំមួយពាន់នៃ
សឹងគ្មានបុត្រា ។

កាលនោះអាមាត្យ    ក្រាបទូលព្រះបាទ    សម្តេចចេស្តា

---
១ ស្តេចទាំង ១០១ អង្គ ។

បពិត្រអម្ចាស់ ថ្លៃណាស់ជាតិជា អស់យើងករុណា

ជាខ្ញុំសម្លាយ ។

សូមទានអម្ចាស់ មែនមានបុណ្យណាស់ លើសស្ដេចទាំងឡាយ

គឺមោះឥតបុត្រ បរិសុទ្ធតោមឆាយ ប្រាណប្រុសពណ្ណកាយ

ទឹងសោយរាជ្យស្នង ។

បំណោរទៅលង់ ឥតទឹងព្រះអង្គ អម្ចាស់ហើយហោង

ឥតអង្គក្សត្រា ឯណានៅស្នង សេពសោយរាជ្យគ្រង

ក្រុងទេពបុរី ។

ស្ដេចស្ដាប់អាមាត្យ ក្រាបទូលព្រះបាទ សព្វគ្រប់សេចក្ដី

ស្ដេចវឹងទៅឋាន បិតហាននារី ថ្លែងប្រាប់អស់ក្ដី

នៃនាងទាំងឡាយ ។

២០— អស់ស្រីស្រីង្គារ ស្ដាប់ព្រះឱង្ការ បន្ទូលប្រាប់ប្រាយ

ប្រជាប់កិច្ចា បូជាថ្វាត់ថ្វាយ ទេពតាទាំងឡាយ

សឹងសូមបុត្រា ។

ស្ដេចចូលបន្ទំ សុខសួស្ដិ៍ករម្យ នូវនាងពិម្ពា

អយិអគ្គមហេសី ក្សត្រីកញ្ញា សំណោះបរទា

បន្ទូលប្រាយប្រាប់ ។

ថាហៃប្អូនស្ងួន ព្រលឹងខ្ញុំម្ងួន ស្ងួនមាសនាងស្ដាប់
ពាក្យពីរៀមរ៉ែក បងអ្នកទឹងប្រាប់ ចូរប្អូនប្រដាប់
ដូចពាក្យបងថា ។

ពីថ្ងៃនេះទៅ ចូរនាងប្អូនពៅ ប្រដាប់ក្បីផ្កា
សំអាតសំអាង ហើយនាងបូជា អស់ទាំងទេវា
សព្វទិនរាត្រី ។

ហើយចាំសីលា សាងសូមបុត្រា ប្រាណប្រុសពិសី
ឲ្យសោយពង្សស្នង គ្រប់គ្រងបុរី តាងយើងជាផ-
សូរអស់ពស្ត្រផង ។

២៥— នាងស្ដាប់ព្រះប- ន្ទូលទើបស្រើតន់ ធ្វើដោយគន្ធង
យកព្រះរាជទ្រព្យ ប្រដាប់ឥតគ្គង់ ឲ្យជាទានហោង
សព្វទិនទិវា ។

ហើយនាងប្រដាប់ ផ្កាក្បីស្រេចស្រាប់ ទៀនធូបផ្កាលា
ថ្វាយសព្វទិសទស សោឡសសួគ៌ា ចាំសីលការនា
សាងសូមបុត្រថ្ងៃ ។

នាងថ្វាយភ្ញីផ្កា សព្វទិនទិវា ជាអចិន្ត្រៃយ៍
ទ្រង់ព្រះចិន្តា ប្រាថ្នាសព្វថ្ងៃ ស្មោះពីហឫទ័យ
នាងសូមបុត្រា ។

តេជះបារមី សម្តេចទេវី ចាំសីលភាវនា
កក្រើកទៅដល់ មណ្ឌលអាសនា ចមទៅទេវា
អង្គឥន្ទ្រកោសិយ ។

ស្តេចបើកទិព្វចក្សុ ទតមើលយល់ជាក់ ជ្រាបអស់សេចក្តី
សព្វប្រការស្រេច សម្តេចកោសិយ អ្នកហោះទៅនី-
មន្តទេវបុត្រថា ។

៣០— បពិត្រអ្នកមាន- បុណ្យអើយសូមទាន ព្រះអង្គលីលា
ច្យុតចុះចាក លះលោកសួគ៌ា ស្អាងបារមិតា
នៅមនុស្សលោកនាយ ។

ជាបុត្រក្សត្រា អាទិត្យវង្សា- ធិកដ៏ឆោមឆាយ
ទូវនាងពិម្ពា ជាយាពណ្ណរាយ បើអ្នកក្រងាយ
ខ្ញុំជួយអ្នកណា ។

កាលនោះទេវបុត្រ ស្តែងស្តេចច្យុត ចុះពីសួគ៌ា

ត្រាច់ត្រង់មកចាប់ បដិសន្ធិនា- ផ្ទៃនាងជាយា
ពិម្ពាទេវី ។
នាងនាថទ្រង់គភ៌ ចូលទៅទូលដល់ ព្រះបាទនរបតី
ទូលថាសូមទាន ខ្ញុំមានគភ៌ខ្ចី ធុតធាប់ដូចក្តី
ខ្ញុំសូមបុត្រា ។
ស្តេចស្តាប់នារី សម្តេចភូមិ ត្រេកអរសោមនស្សា
ស្តេចឲ្យស្រីឆ្មារ ជ្រោមជ្រែងរក្សា នៃនាងពិម្ពា
គភ៌ព្រះប្អូនស្រី ។

៣៩– លុះទសមាសា ប្រសូតបុត្រា ប្រាណប្រុសពិសី
ដូចមាសនព្វគុណ កែវគន់មណី ទ្រង់កល្យាណី
លើសលែងក្សត្រា ។
ស្តេចឲ្យមេទំ គីលៀងជិតជុំ ជិះក្រង់រក្សា
ព្រះរាជបុត្រក្សត្រ ពន្លកថ្លៃថ្លា សម្តេចរាជា
ថ្នាក់ថ្នមបេតី ។
លុះចម្រើនធំ បុត្រវង្សឧត្តម ទ្រង់ដោមពិសី
លើសក្សត្រដៀងជាក់ វង់ភក្ត្រប្រិមប្រិយ ដូចចន្ទបូណ៌មី

ភ្លឺផ្លេកចាំងវែង ។

ពុំនោះសោតណា ហាក់ដូចទេវតា ច្យុតពុំលែង
និម្មិតមកជា- បុត្រាស្តេចស្តែង ទ្រង់នាមលើសលែង
ក្សត្រផងនានា ។

សម្តេចជនទី ជនកនរបតី បន្ទូលត្រាស់ថា
ឲ្យក្សត្រព្រាហ្មណ៍ព្រឹទ្ធ បណ្ឌិតហោរា គួររកពេលា
ប្រសើរបុក្សពារ ។

៤០— ទើបព្រះភូធរ ចម្រើនព្រះពរ បុត្ររតន៍សង្ហារ
ទ្រង់ព្រះនាមហៅ ចៅសុវណ្ណកុមារ ត្រកូលត្រកាល
ពន្លកក្សត្រថ្លៃ ។

លុះព្រះជន្មវស្សា បុត្រស្ងួនពុំងា សោឡសឆ្នាំនៃ
ព្រះវរបិតា ករុណាពេកក្រៃ ទឹងឲ្យគេដំថ្កូ-
ក្រោមតាងកជា ។

កាលនោះព្រះបាទ ត្រាស់ប្រើអាមាត្យ ជាអ្នកភ្នាក់ងារ
នាំព្រះឧង្ការ រាជសារទៅថា ទឹងអស់ក្សត្រា
ទាំងរយឯកក្សត្រ ។

ត្បិតអញនឹងឲ្យ　កូនអញសេពសោយ　រាជរម្យសម្បត្តិ
ឲ្យអស់ក្សត្រា　នាំនារីរតន៍　បុត្រីមហាក្សត្រ
ចូលមកថ្វាត់ថ្វាយ ។

ព្រះសុវណ្ណកុមារ　ត្រកូលត្រកាល　ជាក្សត្រពណ្ណរាយ
ទតសព្វសពាង្គ　នៃនាងទាំងឡាយ　រើសឯងឯនាយ
តាមសព្វព្រះទ័យ ។

៤៩– ក្សិណនោះអាមាត្យ　ក្រាបទូលព្រះបាទ　ក្សត្រាដៀស្ឋ័យ
នាំព្រះឱង្ការ　រាជសារក្សត្រថ្ងៃ　ចេញទៅឆាប់ក្រៃ
ដល់អស់ក្សត្រា ។

ថ្វាយព្រះរាជសារ　ពីព្រះភូបាល　អាទិត្យវង្ស
ឲ្យនាំសារសព្វ　មកប្រាប់ក្សត្រា　ឲ្យនាំកញ្ញា
អស់បុត្រីក្សត្រ ។

បរចូលទៅថ្វាយ　ក្សត្រថ្ងៃពណ្ណរាយ　ចមទៅចក្រវត្តិ
ស្ដេចនឹងឲ្យជា-　ពនិតាបុត្ររតន៍　មហេសីមហាក្សត្រ
ព្រះសុវណ្ណកុមារ ។

ឯអស់ក្សត្រា　ឯកសតរាជា　ស្ដាប់ព្រះឱង្ការ

ស្រេចហើយប្រាមប្រាប់ បង្គាប់ភ្នាក់ងារ    រៀបបណ្ណាការ
ឆាប់ ៗ ពេកក្រៃ ។

៤៩– អាមាត្យវៃថ្កាន    ក្រាបទូលក្សត្រក្សាន្ត ព្រះចៅចមក្រៃ
អាទិត្យវង្សា    ពជាជៀស្លផ័យ    ស្តេចជោបព្រះទ័យ
សព្វប្រការផង ។

## បទព្រហ្មគីតិ

៨– ក្សិណនោះអស់ក្សត្រា    រៀបបណ្ណាការហើយហោង
សឹងប្រាប់បុត្រស្ងួនគ្រង    ឲ្យប្រដាប់ខ្លួនទៃ ។
ឯអស់ពជកញ្ញា    ឮបិតាប្រាប់ឈ្មោះនៃ
ត្រេកអរពន់ពេកក្រៃ    ចង់ជាអយិអគ្គមហេសី ។
នាងនាថប្រដាប់អង្គ    សោតសឹងទ្រង់ព្រះពស្ត្រថ្មី
អស់អង្គនាងនារី    សឹងតែងខ្លួនទៃណា ។
ព្រះពស្ត្រប្រពៃផ្លង់    ប្រដាប់អង្គដូចទេវតា
ទ្រង់គ្រឿងពារពស្ត្រា    ដូចស្រីសួគ៌និម្មិតមក ។
នាងខ្វះទ្រង់ព្រះពស្ត្រ    ទិព្វស្រេចស្រស់ហើយនាងយក
សុភ័គខៀវខឹមមក    ជណ្ដាប់ដើរលំអអង្គ ។

នាងខ្លះព្រះពស្ត្រព្រៃ  ស្បៃតាំងផៃល្អបញ្ចង់
ដណ្ដប់ដិតដល់អង្គ  ដូចស្រទាប់ស្រទំមេឃ ។
ព្រះភ័ក្ត្រផូរផង់ផាត់  នារីរេតន៍រូបល្អពេក
ស្អាងអង្គល្អអនេក  ប្រដាប់ដូចស្រីសួគ៌ា ។
១៩— នាងខ្លះរូបល្មមល្មៃ  ទ្រង់កោសេយ្យផុសផុលផ្កា
ជាក្នក់ក្នង់មាលា  កូតានជាសដកម៉ៃមាស ។
ទ្រង់ព្រះសុភ័គស  ចំដាយដរប៉ាក់ដេរដាស
ដណ្ដប់ដើរយានយាស  យល់ប្រដាប់ល្អសោភី ។
នាងខ្លះទ្រង់ព្រះពស្ត្រ  ប៉ាក់ស្រេចស្រស់ឆ្លាក់ជាភ្ញី
ស្បូត្រខ្សែសយរតន៍មណី  រន្ទាលខែងតាំងកក្រា ។
ទ្រង់ស្បៃកោសេយ្យឯក  ល្អិតល្អពេកពណ៌ផ្កាច្បារ
សិកសែមកែមកាល់ផ្កា  ខ្សែសយស្បូត្រលេចឈាយ ។
នាងនាថក្រមុំតូច  ប្រដាប់ដូចស្រីសួគ៌នាយ
អស់អង្គទ្រង់ឆោមឆាយ  ដូចស្រីសួគ៌និម្មិតមក ។
២០— ប្រុសណាយល់សំអាង  រូបរតន៍នាងនាថពន្លក
ភ្លេចចិត្តនឹងគិតរក  ស្រីឯទៀតពុំបានណា ។

នាងខ្វះព្រះពស្ត្រស ស្រេចស្រស់ល្អបរិបូណ៌ជា
សឹងប៉ាក់ជាភ្ញីផ្កា ដេរជាយជិតល្អប្រពៃ ។
ទ្រង់ព្រះសុក័គស្វាយ ខៀវប្រុះលាយរតន៍កោសេយ្យ
សូត្រខ្សែស្រយមាសម័យ កែមដោយផ្កាបុប្ផាផង ។
នាងខ្វះស្បៃកោសេយ្យា ប៉ាក់សឹងផ្កាភ្ញីតាំងទង
ព្រះពស្ត្រទ្រង់នោះផង ខ្សែស្រយសើមកាល់ជាយប៉ាក់ ។
ទ្រង់រូបឆោមសោភា ស្រីកញ្ញាសមវង់កក្រ្ត
សមទូវព្រះពស្ត្រប៉ាក់ ដូចកលស្រីទេពអមរា ។

២៥— នាងខ្វះព្រះពស្ត្រប៉ាក់ ខ្សែស្រយធ្លាក់កែមបុប្ផា
សុក័គខ្វាញ់ក្ដាមណ៌ា ប្រដាប់ដោយពណ៌ទីទៃ ។
នាងនាថនារីរតន៍ ផង់ផូរផាត់ស្រស់ល្អមល្អៃ
ទ្រង់ឆោមឆាយប្រពៃ សមទូវគ្រឿងប្រដាប់ក្ដាត់ ។
នាងខ្វះទ្រង់ខៀនជាំ ស្បៃជកគាំសមរូបរតន៍
សូត្រសើមកែមផ្ដល់ផ្ដិត ប៉ាក់ធ្លាក់ជាពណ៌ផ្កាគ្រប់ ។
ក្រអូបក្រអែបធុំ នាងក្រមុំតូចដណ្ដប់
ពិដោរដូចអ្នកអប់ ដោយសុក័គនាងនាថទ្រង់ ។

ស្រេចស្រស់ល្អលើសលន់ នាងស្រីគន់ប្រដាប់អង្គ
ប្រុសណាយល់ហើយរំ- ភ្លើនចិត្តដោយរូបនាងណា៎ ៗ
៣០— នាងខ្វះខ្លួនតូចក្តុំ ស្មើរក្រមុំឆោមសោភា
ទ្រង់ស្បៃជម្ពូផ្កា ប្រុះដាយជរខ្សែស្រយសើម ៗ
សំពត់បបូរថ្មី ទេសពិសីហើយកាល់កែម
ខ្សែស្រយស្បូត្រសើកសើម រំលេចឈាយកែមកាល់ទង ៗ
នាងទ្រង់គ្រឿងប្រដាប់ សព្វគ្រប់ស្រាប់ស្រេចហើយហោង
ផាត់ផាយដើរលំញៀង លំអអង្គនាងនារី ៗ
ចម្ងែកសោតល្អស្រេច អស់ក្បូរក្បាច់កជបុត្រី
សក់សោតបត់ចួនថ្មី ស្មៀតសក់សើមកែមជុំជិត ៗ
ព្រះហស្តនាងនាថទ្រង់ ព្រះទម្រង់រតន៍ពិចិត្រ
សឹងទ្រង់គ្រឿងល្អពិត លាបផង់ម្សៅផាត់កញ្ច្រា ៗ
៣៥— ផ្ទូរកត្រ្តស្រស់ល្អស្រេច ស្រីសម្តេចវរសោភា
លាយលាបចន្ទន៍ក្រស្នា ផ្តុំក្រអូបក្រអែបលន់ ៗ
តាំងសងនៃព្រះកាណ៌ ទ្រង់ត្រសាល់មាសទែងទន់
ហើយទ្រង់ព្រះសុគន្ធ បុប្ផាផងកែមកេសា ៗ

ហើយនាងយកព្រះធាយ ទតសព្វសាយអស់គន្ធា
ថ្ពាល់ឡើងដូចផលា មាក់ប្រាំងមាសមានរស្មី ។
ព្រះភក្ត្រវង់ចន្ទ ថែងសោភ័ណនាន់គី
កមោស្រស់ស្រួលស្រី ដូចចន្ទ្រយកៅទណ្ឌណ៌ ។
សុដន់ដូចខ្ទាប់- មាសមកផ្គាប់នៅទព
អស់អង្គពជធីតា សឹងពិសីពិសេសសម ។
៤០— បុត្រីស្ដេចយេងក ល្អពន់ពេកសឹងក្រមុំ
ប្រដាប់អង្គឧត្តម ដោយចំពូកលីលាទៅ ។
កីលៀនកៀនជុំជិត ក្នាក់ផ្ការព័ទ្ធពីស្នួតនៅ
តែងបក់នាងសោះក្ដៅ ពុំឲ្យហ្មងសម្បុរស្រី ។
សាវៃជំរុអស់នាង ហែសងខាងដើងហត្ថ
ដល់ក្រុងទេពបុរី ទើបអាមាត្យទៅក្រាបទូល ។
សម្ដេចព្រះបិតា- ធិកជារទ្រួតសួរ
ស្ដេចស្ដាប់អាមាត្យទូល ជ្រាបព្រះទ័យព្រះភូបាល ។
ស្ដេចទ្រង់ព្រះបណ្ដាំ ត្រាស់ឲ្យនាំអស់នាងនាថ
រៀបពេងព្រះភូបាល ឲ្យអញ្ជើញពាងបុត្រា ។

៤៩— វីរគន្ធកុមារ ស្តេចត្រអាលស្រូមម្មា
មកដល់ព្រះបិតា ព្រះអង្គក្រាបថ្វាយបង្គំ ។
ពីរព្រះអង្គត្រាស់ថ្វាត់ ហៃកូនរតន៍មាសឧត្តម
អ្នកចេញរកដកេងរម្យ ទតក្រមុំអស់បុត្រក្សត្រ ។
តាមតែអ្នកមាសថ្លៃ សព្វព្រះទ័យរើសយកថ្វាត់
អស់នាងនារីរតន៍ តាំងរយឯកអង្គនោះណា ។
សម្តេចព្រះកូបាល ស្តាប់ឧង្ការព្រះបិតា
ស្តេចថ្វាយបង្គំលា មកប្រជាប់ស្អាងព្រះអង្គ ។
ព្រះពស្ត្រប្រពៃពេក ល្អអនេកទិព្វទេសផ្ចង់
ប៉ាក់ជារូបរាជហង្ស ហើរចុះចាប់ចឹកទងភ្ញី ។
៥០— ស្បូត្រសើមខៀវសយកាល់ កែមគ្រប់ពណ៌ស្រស់សោភី
រំលេចដោយពណ៌ភ្លឺ ជេរជាសដោយពណ៌ទីទៃ ។
ស្តេចទ្រង់ព្រះភូសា ប៉ាក់ផុលផ្កាស្រស់ប្រពៃ
កញ្ចក់ក្នក់មាសម័យ រំលេចលាយតាមពណ៌ណា ។
ព្រះហស្តតាំងពីរទ្រង់ ព្រះទម្រង់រតន៍ធាយា
រស្មីឆ្នុះភ្លឺថ្លា ភ្លឺប្រភាត់ដូចតារា ។

ទើបស្តេចទ្រង់ព្រះមកុដ          វិសេសសុទ្ធសឹងសុវណ្ណា
ដាំជាសរដោយត្បូងជា-          កែវកាល់កែមក្ទឹប្រពាត់ ។
ស្រេចហើយព្រះរាជា          ស្តេចលីលាចេញពេងរតន៍
ព្រះអង្គគង់បិតស្ងាត់          លើគ្រែទេនទិព្វសុវណ្ណា ។

៤៨— នាងនាថក្រាបប្រណម្យ          ថ្វាយបង្គំព្រះរាជា
រៀបរៀងកលកាយគ្នា          អង្គុយគាល់ព្រះនរបតី ។
អស់នាងនាថនិម្មល          ហាក់ដូចកលទេពសួគ៌ស្រី
គង់គាល់ឥន្ទ្រកោសិយ          នៅនាសួគ៌ត្រៃត្រិង្សា ។
នាងនាថតាំងរយឯក          អតិរេករាជធីតា
ចង់ចិត្តគិតប្រាថ្នា          ប៉ង់ស្រឡាញ់ព្រះចមត្រៃ ។
ក្សិណនោះព្រះរាជា          ទតអង្គានាងនាថនៃ
ពុំសព្វព្រះហឫទ័យ          នឹងអស់នាងដល់តិចឡើយ ។

៤៩— ឯអស់នាងនាថយល់          ព្រះភូបាលក្សត្រត្រាណត្រើយ
ពុំសព្វព្រះទ័យឡើយ          នាងក្រាបលាព្រះអង្គទៅ ។

## បទកាកគតិ

៥០— រីកាលនោះណា          ព្រះវរមាតា          បិតាចមទៅ

ស្តេចបើកព្រះសូរ　បន្ទូលក្រេវ　ត្រាស់ដណ្ដឹងទៅ
បុត្រតេន៍ពុំងា ។
កូនអើយបទក្សី　អស់តាំងនារី　រយឯកអគ្គា
ក៏កូនពន្ទុក　មិនយកនាងណា　ដល់មួយជាតិជា-
អភិអគ្គមហេសី ។
ទើបតុទ្ធផ្កូល　ក្រាបបង្គំទូល　ព្រះជនកជននី
ថាខ្ញុំមើលជាក់　នរលក្ខណ៍អស់ស្រី　តាំងអស់នោះក្តី
ពុំបានឡើយណា ។
សឹងចេកសឹងចង់　សឹងបញ្ចើអគ្គ　សឹងស្អាងអាត្មា
សឹងឥតខ្មាសលន់　សរសេនមាយា　សឹងឥតចរិយា
ឥតនរលក្ខណ៍ផង ។
ព្រះវរបិតា　ស្តាប់បុត្រពុំងា　ក្រាបទូលហ្នោះហោង
ស្តេចបើកព្រះសូរ　បន្ទូលរឹងស្ងួន　ត្រាស់នុង្ការហោង
នឹងបុត្រពុំងា ។
៥៥– បើបាស្រាល់ស្រី　ឲ្យបានដូចក្តី　ចំណង់ចិត្តបា
ពោះអស់តាំងស្រី　លោកិយនេះណា　ពុំគាប់ចិត្តបា

ដល់មួយឡើយហោង ។

ក្រែងតែស្រីសួគ៌ ប្រពៃគាប់គួរ ថ្លៃថ្លាកន្ទង់
គ្រប់ខ្លួនលក្ខណ៍ ឥតអ្នកផ្ទឹមផង ដូចនោះឯងហោង
ទើបគាប់ចិត្តបា ។

រាជកុមារនោះ ស្ដាប់ជាក់ចំពោះ- ព្រះរាជឱង្ការ
បន្ទូលទ្រគោះ ដូចនោះហើយណា+ ព្រះអង្គក្រាបលា
តាំងពីរត្យត្រៃថ្ងៃ ។

មកឋានប្រាសាទ ប្រសើរស្អាងស្អាត ទែនទិព្វអាសម័យ
សេពសុខក្សេមក្សាន្ត ឥតមានគិតភ័យ ប្រក្រតីសព្វថ្ងៃ
នឹងបរិពារផង ។

កាលនោះមែនមាន អ្នកការពីប្រាណ សឹងនាយជាងទង
បែះចប់សព្វសា- រពើការកន្ទង់ លើសលែងអ្នកផង
ទូទាំងលោកា ។

៦០— មានកាលមួយថ្ងៃ ជាងទាំងពីរនៃ និយាយផងគ្នា
ដំណាលអួតអាង ថាជាងមហិមា ឥតអង្គអ្នកណា
នឹងផ្ទឹមស្មើបាន ។

ជាងមួយអួតថា　អង្គអញនេះណា　ប្រុសប្រាជ្ញមាន
ឆ្លាក់ឆ្លៅក្បូរក្បាច់　ម្តេចៗនៅប្រាណ　អង្គអញឥតមាន
អ្នកណាផ្ទឹមផង ។

ជាងមួយអួតថា　អង្គអញនេះណា　ប្រាជ្ញប្រាយកន្លង
ពោះបីទឹងធ្វើ　សារពើការផង　ឥតអ្នកណាហ៊ាន
ធ្វើផ្ទឹមអញបាន ។

ជាងទាំងពីរអួត　ប្រកែកប្រកួត　ក្រោធពន់ប្រមាណ
នាំគ្នាចូលទៅ　ក្រាបទូលក្សត្រក្សាន្ត　ស្តេចស្តាប់ហើយមាន
ព្រះបន្ទូលថា ។

ហៃជាងទាំងពីរ　ចង់ធ្វើការកើត　ប្រឡងប្រាជ្ញា
បើហ្នោះចូរទៅ　វិលទៅគ្រឹហា　ចូរជាងធ្វើជា-
ការផងទាំងឡាយ ។

៦៥— ទៅយកមាសប្រាក់　ដំផៃឆ្លៅឆ្លាក់　ក្បូរក្បាច់ក្លុបក្លាយ
ជាងធ្វើជាភាព　ដរាបសម្ពាយ　ធ្វើទាំងកាយនាយ
ដោយចំណោះណា ។

ជាងទាំងពីរស្តាប់　ព្រះបន្ទូលប្រាប់　ស្រេចហើយក្រាបលា

វិលវឹងទៅភ្ញាន ដល់បានគ្រឹហា ប្រដាប់ប្រដា
កាន់ការសារពើ ៗ

៦៧– សឹងប្រកួតគ្នា តែងតាមប្រាជ្ញា អស់សព្វអន្ទើ
កែមកាល់ក្បូរក្បាច់ ស្រាប់ស្រេចឥតស្មើ ជាងទាំងពីរធ្វើ
ដោយគួរទីទៃ ។

## បទពំនោល

កាលនោះជាងទាំងពីរនៃ តាក់តែងឆាប់ក្រៃ ក៏សឹងកាន់ការខ្មីឃ្មាត ៗ
ជាងមួយជហ្វាប្រាសាទ ប្រសើរស្អាងស្អាត គំនូរគំនាប់បីប្រពៃ ៗ
ទាំងពីរព្រោងព្រាយល្អក្រៃ មាសមានតម្លៃ ពិចិត្រនូវគន់រេខា ៗ
ត្រដែតតែមួយនោះណា+(១) មានទ្វារចេញជា- កំពែងប្រាំពីរជាន់ជុំ ៗ
ចតុទិសសសរស្តម្ភ មាលមាសទែងទុំ កំទ្រប្រាសាទប្រាំពីរ ៗ
សសរមាសមួយមានពណ៌ ឆ្លាក់ឆ្លៅក្បូរល្មើ ត្របកបទុមជ័បវរ ៗ
របនាជាងគួររូបមករ កទ្រសសរ កព្ទួរហើយពាំក្បូមាស ៗ
ក្នុងក្នុកកញ្ចក់ពេញពាស ដាំត្បូងដេរដាស រលេចរលោងផ្ទុះផ្លៅ ៗ
ប្រាសប្រាលបរន្ទាលល្ហៅ មាលមាសផ្អិនផ្អៅ ត្រចង់ត្រចះឆើតឆាយ ៗ
ត្របកបទុមកែករាយ រៀងរាល់សព្វសាយ ប្រពាក់ប្រព័ន្ធទងក្បី ៗ

---

១ ច្បាប់ខ្លះថា ប្រាសាទមែនមួយសោគណា ។

ក្ដារបែនត្រៃទេនមាសថ្មី ឆ្លាក់ផ្ដៅវល្លិ៍ភ្ញី ជាគ្រុឌករចាប់នាគា ។
ហោះទ្រត្រៃទេនសុវណ្ណា កាងកោងហត្ថា ក្រអើតក្រអួនស្ទួយស្អើត ។
ភាពនាគហើយហាក់បីចំអើត រូរស់កបកើត កព័ន្ធនូវជើងគ្រុឌគ្រប់ ។
បង្អួចរ័តន៍រៀងសាយសព្វ ជើងទៀនទល់គ្រប់ របបរបស់រាល់កាយ ។
១៩-ដោយទ្វារប្រាសាទសព្វសាយ ឆ្លាក់ជារាហ៊ុក្ដាយ ករចាប់នូវទងភ្ញីវល្លិ៍ ។
គ្រប់ជ្រុងសសរពេញពល់ ឆ្លាក់ផ្ដៅគ្រប់ព័ណ៌ ក៏រៀងក៏ពបភាពផង ។
រូបរាជសីហ៍ហោះផ្សង ចាប់អម្រឹតឃ្មុង សម្ដែងនូវតេជមហិមា ។
កេសររាជសីហ៍សោតណា ចេញពីគុហា ហើយចាប់អស់បុប្ផាផង ។
រូបគ្រុឌហោះឆក់នាគផ្គង សារពើភាពផង អានកអនន្តគណនា ។
២០–រូបហង្សបុះចាប់បុប្ផា ទំទឹមទៀបគ្នា ប្រចឹកប្រចាប់ទងភ្ញី ។
ត្របកបទុមរីកខ្ចី រូបសត្វបក្សី កំសួសសៀរទំទង ។
រូបសេកសារិកាសោតហោង ទំទឹមផ្អៀងផ្អង ក៏ចឹកនៃកេសរផ្កា ។
រូបបក្សីផងនានា ច្រើនពណ៌ភាសា ខ្លះហើរខ្លះលោតទំលេង ។
សាយសព្វប្រាសាទធំធេង ដោយផ្កាំងនូវល្វេង ប្រដាប់រចនាពិព័ណ៌ ។
២៩-មុខដាច់ជងក្ដាររៀងរាល់ ហាក់ហង្សកែមកាល់ មករក៏ពាំក្អក់ពេជ្រ ។
ស្រកីស្រកាស្រស់ស្រេច ភ្ញីវល្លិ៍លូតលេច ត្របកបទុមរីកពាយ ។

ត្រីសូលកំពូលគាន់ឃ្លាយ មាសម័យឆើតឆាយ ត្រដែតត្រដឹងដោមដួច។

កំពូលកំពស់ស្រោងស្រួច ក្នុងក្អកល់រួច តំណែងដំណួចទឹកទាល់។

រូបទេពប្រណម្យរៀងពល់ ករកាន់ក្បៀល្ង៏ ពិពណ៌បុប្ផាផងគ្រប់។

៣០- ប្រាសាទប្រសើរមណ្ឌប ឆ្លាក់ឆ្លៅសុសសព្វ សឹងរូបស្រីទេពអប្សរ។

កាន់ផ្កាឈូកមាសជំបវរ ទ្រង់ពស្ត្រអម្ពរ កំឈរគ្រប់រូបរៀងពល់។

ពនហាលគ្រប់ទ្វារមណ្ឌល រៀងរួចទៅទល់ កំពូលកំពែងក្រោមក្រៅ។

ភ្ជាក់ដៃដោយពនហាលទៅ រូបនាគនិត្យនៅ សន្ធឹងសងខាងឆ្វេងស្តាំ។

ឯក្បាលលើកពពារខាំ ផ្ទៀងផ្អងឃ្មៀងឃ្មាំ នៅទ្វារប្រាសាទសុវណ្ណ។

៣៤-ពងស័ហ៍សឹងយោរហោហា កំលៃនលៀងកា កំឈរជាជួររៀងរាយ។

ប្រែប្រឹងសម្ងឹងឈ្មោកឆ្ងាយ មៀងមើលសព្វសាយ រង្គាត់ប្រយ័ត្នគ្រប់ទ្វារ។

ប្រាសាទមាសម័យរន្ទាល រុងរឿងប្រាសប្រាល ចម្លាក់ចម្លៅស្រស់ស្រេច។

រុងរឿងក្បូរក្បាច់រំលេច ឆ្លាក់ឆ្លៅស្រស់ស្រេច រលេមរលោងផ្អិនផ្អៅ។

អម្រឹតមាសម័យចាំនៅ សាយសព្វស្ថានក្រៅ រហិតរហង់អាយនាយ។

៤០–ល្អល្អះបំត្រចះឆើតឆាយ ផ្អិនផ្អៅព្រោងព្រាយ ពិចិត្រទូរគន់រេខា។

ហាក់ដូចពិមានឥន្ទ្រា ចុះពាកសួគ៌ា កំស្រុតមកនៅផែនដី។

ជាងមួយប្រជាប់ឃ្នាតខ្វី ជារូបបក្សី នៅរូបអម្រឹតសម្លាយ។

សឹងជាជាងយន្តសព្វសាយ រូបសត្វតាំងឡាយ ដោយពណ៌ទទៃនានា ។
យន្តមករបវរថ្ងៃថ្លា ហែលលេងលីលា លលើកណ្ដាលជលធី ។
៤៩—ផ្តុកផ្តោះស្មោះស្មើតាំងទី ស្រកាទូវស្រែក រូហានវិញ្ញាណរូបរស់ ។
រាត់រាយទឹកខ្លាយខ្ពង់ខ្ពស់ អស់អង្គស្រេចស្រស់ប្រផាប់សឹងមាសប្រាសប្រាល។
យន្តនាគលោលើកពពារ អរឯងត្រអាល ក៏ហែលកណ្ដាលជលសា ។
ឃាតខ្លាញ់ហក់ដេញមច្ឆា ត្រីផងនានា រេរាទឹងយន្តនាគនោះ ។
យន្តរាជសីហ៍ហៀរហោះ ប្រឹងប្រាណស្វាញស្វុះ ក៏ចាប់អម្រឹតយង់យួង ។
៥០—យន្តកេសររាជសីហ៍ផង ចរចេញលេងលង ក៏ហោះកណ្ដាលនភី ។
ចុះចាប់ក្តិចក្តាប់ទងក្បី ពោចបានរួចរី រូហានរូបសត្វសើយ ។
ប្រែប្រឹងបិសន្ទឹងរិលវៃ នេត្រនោះបីរពៃ ក្រឡេកក្រឡៅដឹសម្ទឹង ។
យន្តមួយធ្វើជារូបសិង្ហ ឈរឈប់ប្រែប្រឹង ក្រឡេកក្រឡៅនេត្រា ។
យន្តស្នាទទូវយន្តលៀងកា ប្រយុទ្ធទូវគ្នា កណ្ដាលនៃអាកាសកង ។
៥១—យន្តព្យាក្ររូបឥតគ្ដង ចរចេញលេងលង ក៏ហោះកណ្ដាលវេហាស៍ ។
យន្តកីលែនសោតលីលា ពើចទឹងព្យាក ក៏ប្រយុទ្ធកណ្ដាលនភី ។
សហ័សកីលែនតាំក្បី ទាំងទង់រីកថ្មី គ្របកបទុមសុវណ្ណា ។
យន្តគ្រុឌធៀងឆាបនាគា នាគព័ន្ធហត្ថា សំដែងទូវតេជប៉ពទ្ធឹក ។

យន្តខ្លាចាំចាប់អម្រឹត ក្រោបក្រោមព្រៃព្រឹក្ស ក្រឡាស់ក្រឡាប់ស្ទុះស្ទាត់ ។
ហាក់រូបរស់វិស័យសត្វ សុទ្ធសាធពេកក្លាត់ ក៏ស្ទុះក៏លោតវិលវៃ ។
យន្តគជសារលោតស្ទឹមស្ទៃ តោតគៀងតោព្រៃ ក៏ស្រប់ដោយម្ទប់អញ្ជា ។
យន្តគោយន្តតោមហឹសា ភាពផងនានា អនេកអនន្តណាស់នៃ ។
យន្តបក្សីផងច្រើនក្រៃ ទំដោយព្រឹក្សព្រៃ ប្រចឹកប្រចាប់ទងភ្ញី ។
ខ្លះលោតលោតលេងដោយដី ប្រដាប់ទងភ្ញី ក៏ទំលេងលើព្រឹក្សា ។
យន្តសេកនូវយន្តសារិកា ទឹមទំខាងគ្នា ក៏ចឹកនូវបុប្ផាផង ។
យន្តកិន្នរីលោតហោង យាងយាសផ្សៀងផ្សង ទាំងគូក៏រេរាំ ។
កេងកាងយាសយាងទន្ទាំ បានបទលំនាំ ផ្ទួរផងដាយកេសរ ។
យន្តរូបស្រីទេពអប្សរ ទ្រង់ពស្ត្រអម្ពរ ករកាន់នូវភ្ញីទាំងទង ។
រាំទន់ភ្ជន់លំញង ស្រេចស្រស់ឥតគ្គង ស្រលូតស្រឡះឆោមឆាយ ។
អស់រូបសត្វផងសម្ងាយ ហាក់ពីស្ងួតិនាយ ច្យុតចុះពាកមកណា ។
ជាងទងទាំងពីរអង្គា បំណេះស្មើគ្នា អនេកអនន្តពេកក្លាត់ ។
សម្តេចព្រះបាទចមក្សត្រ ស្តេចឲ្យមណីរតន៍ ពិចិត្រនូវមាសសុវណ្ណា ។
ឲ្យជាងវៃតែងធ្វើផងគ្នា ទាំងពីរអង្គា ប្រដាប់ធ្វើជាហង្សយន្ត ។
ទើបជាងទាំងពីរគិតគន់ ធ្វើជាហង្សយន្ត ប្រដាប់នូវរតន៍រេខា ។

៧៩-តួហង្សប្រញាប់សោតណា  មាលមាសថ្ងៃថ្លា  ក៏ដាំទូវត្បូងរតន៍ពាយ ។
លួសលេចក្បូរក្បាច់ក្ងុបក្ងាយ  ភ្ញីវល្វៃលេចលាយ  ក៏ប្រាលរន្ទាលដើតឆាយ ។
ពផហង្សច្រើនពណ៌សព្វសាយ  ស្នោមស្នាបកែមកាយ  ពិចិត្រទូវរតន៍រេខា ។
សរសេរកើតកើ្ដជ្រះថ្លា  កែវកែមសុវណ្ណា  ក្រឡាបន្ទុំបញ្ចគ្គ ។
ស្រាប់ស្រេចក្បូរក្បាច់អស់អង្គ  ទីនាំងយន្តហង្ស  សួរេចបរិបូណ៌ហើយណា ។
៨០– ទើបផាន់ទាំងពីរនាំគ្នា  យកហង្សសុវណ្ណា  ទៅថ្វាយសម្ដេចជៀសួផ័យ ។
ស្ដេចទតហង្សយន្តមាសម័យ  សព្វព្រះហឫទ័យ  នឹងផាងទាំងពីរក្ដាត់ហោង ។
ស្ដេចឲ្យរង្វាន់ផាន់ទង់  មាសប្រាក់កែវកង់  អនេកអនន្តគណនា ។
ព្រះអង្គឲ្យយសសក្ដា  ទាំងពីរស្មើគ្នា  សឹងជាចៅហ្វាយស្រុកស្រេច ។
កាលនោះព្រះបាទសម្ដេច ព្រះអង្គស្ដេងស្ដេច គង់លើហង្សយន្តមាសម័យ ។
៨៥-ស្ដេចកើចខ្សែហង្សមាសថ្លៃ ហៀរហោះរំងែវ រួហានរួបរស់វិញ្ញាណ ។
កើចយន្តភាពផងហោះធ្យាន  ហិចហើរមែនមាន  ប្រភិតឯអាកាសកង ។
ខ្លះស្មៀងធៀងឆាបតំស្ដុផង  ខ្លះទំផ្អៀងផ្អង  ចាប់ទូវបុប្ផាផលា ។
ក្សណនោះព្រះបាទក្សត្រា  គង់យន្តលីលា  ស្ដេចត្រោះទៅព្រៃហិមពាន្ត ។
សប្បាយលោះលាយដោយហ៊ុន  ព្រះព្រៃហិមពាន្ត  ច្រើនពណ៌អនេកគណនា ។
៩០– ព្រះបាទប្រពាតព្រឹក្សា  សួរេចហើយណា  ទើបស្ដេចឡើងគង់យន្តយាន ។

ស្តេចកើចវៃយន្តវិលឋាន ទេពទិព្វពិមាន ប្រាសាទប្រសើរសោភា ។

## បទព្រហ្មគីតិ

៦០— ក្សិណនោះរាជកុមារ    រត់ត្រអាលផិកជា
អ្នកទ្រង់ព្រះចិន្តា    នឹងចង់រកព្រះមហេសី ។
ថាបើអញបានយន្ត    ហោះគយគន់សព្វទិសទី
រកស្រីសោភជទេពី    ឲ្យបានដូចចិត្តប្រាថ្នា ។
ទ្រង់ព្រះចិន្តាស្រេច    ព្រះអង្គស្តេចត្រាច់លីលា
ទៅឋានព្រះមាតា    នូវបិតាទាំងពីរពង្ស ។
អ្នកឱនព្រះសិរសិង្ឃ    ក្រាបផ្ទួញផិតលើកគំបង់
ដោមដាក់សិរសីផ្ទង់    ថ្វាយបង្គំហើយទូលថា ។
បពិត្រខ្ញុំក្រាបទូល    ព្រះឥស្សរជាបិតា
បទខ្ញុំនឹងក្រាបលា    ចង់ទៅរករៀនសិល្បសាស្ត្រ ។
៦៤— ខ្ញុំសូមហង្សយន្តណា    នឹងយាត្រាដោយអាកាស
ទៅរកអាចារ្យចាស់    ចេះវែងចប់សិល្បសាស្ត្រសាយ ។
ហើយខ្ញុំនឹងសំណាក់    ទីពឹងអ្នកជាបាធ្យាយ
រៀនសូត្រសិល្បទាំងឡាយ    ឲ្យបានដូចក្ដីប្រាថ្នា ។

| | |
|---|---|
| ឯព្រះបិតាស្តាប់ | បុត្រទូលប្រាប់ដោយធម៌ថា |
| ស្តេចយកយន្តនោះណា | ឲ្យបុត្ររតន៍ដូចបំណង ។ |
| ឯព្រះវរមាតា | តែងឱជារសោភោជន៍ផង |
| ដាក់ក្នុងហង្សយន្តហោង | ឲ្យដំណើររាជបុត្រា ។ |
| ពីរពង្សព្រះមហាក្សត្រ | ឱបបុត្ររតន៍ហើយសោកា |
| ទាំងពីរព្រះរាជា | សឹងសោកាពិលាបលន់ ។ |
| ៧០- ព្រះវររាជមាតា | បន្ទូលថាឱកូនតន់ |
| មាសអើយទុក្ខម្តាយធ្ងន់ | ពីថ្ងៃនេះឯងហោងណា ។ |
| ឥឡូវម្តាយទឹងឃាត់ | កូនស្ងួនរតន៍មាសពុំហ៊ា |
| ឱ្យខានពុំបានណា | ក៏ម្តាយថប់ថៃពេកពន់ ។ |
| កូនអើយម្តាយផ្តាំបា | បើយាត្រាដោយដំបន់ |
| ចូរអ្នកមាសស្ងួនតន់ | កុំប្រហែសអង្គអាត្មា ។ |
| កុំអ្នកគិតអាល័យ | លេងដោយព្រៃពេកឡើយណា |
| សង្វាតឃ្លាតយាត្រា | ឲ្យបានដល់ស្រុកទេសគេ ។ |
| មាសអើយម្តាយថប់ក្រែង | ខ្លាចវង្វេងពុំដឹងដែរ |
| តំបន់ស្រុកទេសគេ | ពុំបានដល់ដូចបំណង ។ |

៧៩– បើបាបានដល់ស្រុក- គេកុំទុកយន្តនោះហោង
ឲ្យអស់តាំងមនុស្សផង យល់ហង្សយន្តនោះឡើយណា ៗ
មួយសោតបើបាបាន ទៅដល់ឋានគ្រូអាចារ្យ
បានរៀនសិល្បសាស្ត្រ ចរិបូណ៌បានដូចបំណង ៗ
ចូរបាម្នីម្នាឆាប់ រួសក្រឡាប់វិលមកហោង
កុំកូនស្ងួនស្នេហ៍ស្នង នៅលង់ឡើយឯនាយណា ៗ
អ្នកមាសបរចេញទៅ ម្ដាយអ្នកនៅឯកកំព្រា
ឥតបើយល់អ្នកណា ក្រៃទឹនកូនពន្ទុកឡើយ ៗ
ម្ដាយគិតៗទៅគ្រប់ ហើយថែថប់ៗពុំស្បើយ
ឱកូនស្ងួនម្ដាយអើយ អ្នកក្រឡាប់មកឆាប់ណា ៗ
៨០– ទុក្ខម្ដាយធ្ងន់ដូចភ្នំ ជ្រុះរលំលើឱរា
សូមអ្នកឆាប់ម្នីម្នា វិលវិញមកដោះទុក្ខម្ដាយ ៗ
ម្ដាយផ្ដែម្ដាយផ្ដាំផ្ដិត កុំកូនរត់មាសពាយមាយ
ទៅហើយភ្លេចពាក្យម្ដាយ នៅយូរលង់ដោយស្រុកគេ ៗ
ទ្រូងម្ដាយពេញដោយទុក្ខ ដូចគេបុកពុំទំនេរ
ត្បិតកូនទៅស្រុកគេ ឥតអ្នកណាជាពីរផង ៗ

អ្នកមាសស្ងួនគន់ម្ដាយ　　រូបឆោមឆាយឥតឯផ្ទួន
មាសអើយទើបតែម្ដង　　នេះម្ដាយតឹងជាទុក្ខធ្ងន់ ។
នាងទូលទូបបុត្រា　　សោយសោកាពិលាបលន់
អាសូរកូនស្ងួនគន់　　បងទឹងចេញចាកឋានឆ្ងាយ ។
៨៩– ឯព្រះវរបិតា　　ទូបបុត្រភ្នារូបឆោមឆាយ
ទឹកព្រះនេត្រហូរខ្លាយ　　សស្រាក់ស្រោចព្រះភក្ត្រា ។
ស្ដេចទ្រង់ព្រះកន្សែង　　ហើយទំថ្លែងផ្ដាំបុត្រា
កូនអើយអាពុកបា　　ឥតទ្រព្យាជាត្រកាល ។
ទឹងឲ្យដំណើរបា　　បុត្រពុំងាកូនសង្ហារ
មានតែពាក្យនេះណា+　　អាពុកផ្ដាំបាបុត្រថ្ងៃ ។
បាទៅឥឡូវណា+　　ដោយវេហាស៍ផ្លូវក្រៃក្រៃ
កូនកើចយន្តនោះនៃ　　កូនរំពៃគន់ប្រយ័ត្ន ។
មាសអើយដោយអាកាស　　ផ្លូវវេហាសពុំដែលស្ទាត់
អសុរតែងវង្កាត់　　ស្កាត់ទៅមកជាប្រក្រតី ។
៩០– មួយសោតក្រែងត្រូវគ្រុឌរាជ　　មានអំណាចមកយាយី
រាំងសត្វនាទី　　ហោះវង្កាត់ស្កាត់ទៅមក ៗ

មួយសោតក្រែងឥន្ទ្រី ហើរយាយីរែងត្រាច់រក
ចុះចាប់ម្រឹគផងយក ជាអាហារបរិភោគ្គា ។
កូនអើយកុំបាធ្វេស កុំប្រហែសអង្គអាត្មា
ប្រយ័ត្នឲ្យណាស់ណា៎ កុំបាភ្លេចណា៎កូនអើយ ។
អាពុកបាចប់សល់ ឥតឯយល់អ្នកណាឡើយ
ពីថ្ងៃនេះទៅហើយ តែងនឹងស្វាត់ឯងហោងណា៎ ។
ក្រែងអ្នកនឹងហោះធ្យាន ទៅហិមពាន្តឋានព្រឹក្សា
បើបាយល់គុហា កុំកូនចុះចូលចតជិត ។

៩៤_ មាសអើយមានរាជសីហ៍ មានរិទ្ធីរែងតែងបិត
ជាឋានលំនៅនិត្យ ពឹងអាស្រ័យសព្វគុហា ។
ចូរមាសមើលប្រយ័ត្ន កុំកូនរត់ផ្ដោយឡើយណា៎
នោះយប់នឹងនិទ្រា បារកឈើណាគាប់កល់ ។
យកយន្តហង្សផ្គួផ្គាប់ ចងឲ្យខ្ជាប់នាមណ្ឌល
បាដេកជាសុខស្កល់ លើហង្សយន្តនោះឯងណា៎ ។
មួយសោតកុំមាសថ្ងៃ លេងដោយព្រៃព្រឹក្សអង្គា
ក្រែងសត្វផងពាធា កុំប្រហែសណា៎អ្នកអាយ ។

បាបនឹងឪពុកទៅ　　ឪពុកនៅឯនឹងកាយ
ស្មារតីធ្វេសរាយមាយ　　ឡើនឡង់ឡប់ថប់ថែសល់ ។
១០០– ចូរអ្នកមាសសង្វាត　　ហោះខ្មីឃ្មាតឲ្យបានដល់
ទីឋានទេពមណ្ឌល　　លំនៅគ្រូអាចារ្យផង ។
បានរៀនសព្វសិល្បសាស្ត្រ　　អភិកាសដូចបំណង
ស្រេចហើយបាវិលផ្គង　　ត្រឡប់មកពុំលង់ឡើយ ។
ឱកូនមាសពុំងា　　ឪពុកជាទុក្ខពុំស្បើយ
កុំបាយូរកូនអើយ　　រវៀសវិលវិញមកថ្វាត់ ។
ឪពុកអ្នកទឹងឲ្យ　　បាងង់សោយរាជសម្បត្តិ
ផ្សូរអស់មហាក្សត្រ　　ទាំងឡាយឡើងយើងនេះណា ។
ស្ដេចឱបបុត្រពិសាល　　ព្រះកូបាលស្ដេចសោកា
ផ្ដាំកូនស្ងួនពុំងា　　ពិលាបលន់សោយសោកសល់ ។
១០៥–ឯព្រះរាជបុត្រា　　សោយសោកា ៗ ណាល់
សម្ដេចព្រះទសពល　　ក្រញ្រាបក្រោមព្រះបាទា ។
ទាំងពីរព្រះអង្គក្សត្រ　　ថើបបុត្រតេន៍រាជស្នេហា
ហើយបុត្រខ្ញុំទូលថា　　ឱព្រះបិតាម្ចាស់ថ្លៃ ។

កុំបីអម្ចាស់ខ្ញុំ ស្តេចបារម្ភព្រួយព្រះទ័យ
ខ្ញុំទៅផ្លូវនៃ ពុំលង់ឡើយណាអ្នកឆាយ ។
កូនអ្នកនឹងក្រឡាប់ វិលមកឆាប់ណាអ្នកម្តាយ
អម្ចាស់នៅឯឆាយ រួមរក្សាអង្គអាត្មា ។
អ្នកអើយកូនថប់ណាស់ បងអម្ចាស់នៅកំព្រា
តែពីព្រះអង្គា ឥតឯយល់អ្នកណាឡើយ ។
១១០– ហាក់ដូចកូនទុជិន ណាស់ពេកពន់ណាអ្នកអើយ
ផ្លូវខ្ញុំឯងហើយ ទៅបោះបង់អម្ចាស់ថ្លៃ ។
ពាក្យអ្នកទាំងពីរផ្តាំ នោះកូនចាំ ៗ សព្វថ្ងៃ
ជាក់ជាអចិន្ត្រៃយ៍ កូនពុំភ្លេចពាក្យអ្នកណា ។
ក្សិណានោះក្សត្របីអង្គ បន្ទាបង់សោយសោកា
សម្តេចព្រះរាជា រៀបដំណើរឲ្យបុត្ររតន៍ ។
ឯព្រះរាជបុត្រា បង្គំលាពីរពង្សក្សត្រ
ស្តេចឲ្យពរបុត្ររតន៍ ចម្រើនសួស្តីមង្គល ។
១១៤–ឯអស់ទាំងអាមាត្យ មន្ត្រីព្រាតរត់មកដល់
សាយសព្វទាំងមណ្ឌល ជួយចម្រើនពរជយា ។

## បទមហាជ័យ

១– ជ័យ ៗ មហាព្រហ្ម សូមជួយរក្សា ចម្រើនព្រះពរក្សត្រថ្លៃ ៗ
ជ័យ ៗ សម្តេចបារមី សូមឲ្យពរថ្លៃ មកជួយរួបរួមរក្សា ៗ
ជ័យ ៗ ព្រះឥសូរ សូមអ្នកករុណា ចម្រើនវុឌ្ឍីព្រះពរ ៗ
ជ័យ ៗ ពណ្ណកយបវរ ជួយចម្រើនពរ ព្រះវរធិរាជបុត្រា ៗ
៥– ជ័យ ៗ សម្តេចឥន្រ្ទា សូមជួយរក្សា ព្រះរាជកុមារវិសាល ៗ
ជ័យ ៗ ទេពទាំងចក្រវាឡ សូមជួយព្យាបាល បុត្រតេន៍ឧត្តមពុំងា ៗ
ជ័យ ៗ នាគីនាគា ថ្វាយពរជយា ថ្កើងថ្កានសុខសំរឹទ្ធី ៗ
ជ័យ ៗ គ្រុឌរាជបក្សី ចម្រើនសួស្តី ឲ្យពរបវរមង្គល ៗ
ជ័យ ៗ យក្សយង់អសុរ ថ្វាយពរទសពល ថ្វាយជ័យស្តេចលីលាចរ ៗ
១០- ជ័យ ៗ ខុនពិទ្យាធរ ជួយចម្រើនពរ ជ្រោមជ្រែងគ្រប់គ្រងរក្សា ៗ
ជ័យ ៗ ទសពរនេះណា៎ ចម្រើនជយា រឹទ្ធានុភាពសព្វកាល ៗ

## បទភុជង្គលីលា

១– នឹងថ្លែងតំណែងដំណាល ព្រះសុវណ្ណកុមារ រតន៍រាជបុត្រា[1] ៗ
ក្រញ្ញក្រាបទន្ទាបសិរសា ថ្វាយបង្គំលា ជនកជននី ៗ

---

១ ច្បាប់ខ្លះថា នឹងថ្លែងតំណែងដំណាល ដំណើរពីកាល សុវណ្ណកុមារ ។

ព្រះអង្គអ្នកទ្រង់ស្នេហ៍ ទទួលពរស្រី សុមង្គលគាប់ ៗ
ស្ដេចទ្រង់គ្រឿងផ្ចង់ប្រដាប់ ព្រះអង្គស្រេចស្រាប់ ឡើងគង់យន្តយាន ៗ
៩-ស្ដេចកើចខ្សែយន្តហោះផ្កាន ឭអាកាសឋាន វេហាស៍នាយណ៎ា ៗ
ព្រះបាទប្រពាតវេហាស៍ ឯកឯងពកជា តែមួយព្រះអង្គ ៗ
ព្រានព្រាយដើតនាយគ្រចង់ គ្រដែតដោមជុន ដើរដោយវេហាស៍ ៗ
ស្ដេចហោះឆ្ពោះទៅព្រឹក្សា ហិមពាន្តនាយណ៎ា ស្រណុកសប្បាយ ៗ
ស្ដេចដល់មណ្ឌលព្រៃធ្លាយ ក្សត្រាពណ្ណរាយ ចរចុះសម្រាន្ត ៗ
១០-ព្រះបាទប្រពាតហិមពាន្ត ព្រះអង្គក្សត្រក្សាន្ត ស្រប់ស្រង់នទី ៗ
ព្រៃព្រឹក្សស្មោមស្មុកលាស់ខ្ចី ផុះដោយទួលទី រៀងរាបស្រះស្រង់ ៗ
មើលម្ចប់ឧត្តមឧត្តុង្គ ទីទួលកំពុង រះរាបសប្បាយ ៗ
គង្គាវាតាផាត់ផាយ រំលុះរំលាយ រំលេចរលក ៗ
សត្វសត្វរង្គាត់ទៅមក ឆ្វៀលឆ្វាត់រេក ឆៀងឆាបមច្ឆា ៗ
១៩-ទីនថ្ងៃសម្ដែងពណ៌នា ឯអស់ព្រឹក្សា កំឡុងស្រះស្រី ៗ
ឈូកប្រាលរន្ទាលស្នេហ៍ ក្រពុំប៉ុចពី- គង្គាលូតលេច ៗ
ស្រទាប់រីកស្រាប់ស្រស់ស្រេច រុះរោយរដាច់ អណ្ដែតដោយទឹក ៗ
ផាសជិតប្រកិតញាតញឹក លំពង់ស្មោមស្មុក លូតលាស់លាយផ្កា ៗ

ព្រលិតព័ន្ធព័ទ្ធលើគ្នា ផាសដោយគង្គា ទ្រង់បុប្ផាផង ។
២០- លំចង់ទ្រង់ផ្កាឥតគ្គង ត្រកួនបោះទង កំពីងពួយព័ន្ធ ។
សារាយស្នួងសាយណែនណាន់ កញ្ចុតវារណ្ឌ តែនព័ន្ធជ្រែកជ្រៀត ។
ត្រាវធំប្រឡំត្រកៀត ដុះដាសសែមសៀត លាស់លេចលើត្រឹប ។
ព្រឹក្សាខ្ទះផ្កាខ្ទះក្តឹប ស្រទបស្រទាប់ រុះរោយដាសដាល ។
ស្រះស្រីនាទីជ្រៅជ្រាល សម្តេចភូបាល ចុះលេងគង្គា ។
២៥-ស្តែងស្តេចត្រេកត្រាច់លីលា ប្រពាតព្រឹក្សា ក្រសាលហឫទ័យ ។
កែវកោដ្ឋលៀបលោតលាំងជ័យ ព្រីងព្រូសពោនពៃ ពួចពាលខែ ។
ស្នែស្នាច់ព្រាលព្រេចជ្រៃជ្រៃ ទន្សាទន្សៃ ក្រុចក្រាយក្រវ៉ាន់ ។
ញញាសណ្តាសណ្តាន់ វល្លិ៍វើកវារណ្ណ សោមសន្ទូធំ ។
ពពូលស្រល់ស្រូលសុក្រំ រោគរាក់ពាំងភ្នំ ចារចន្ទន៍ក្រស្នា ។
៣០-គ្រើលគ្រង់ខ្លឹងគង់ឆាំឆា ទន្លាប់ទន្លា ដង្កៀបក្តាមក្តុល ។
ត្រសេកទ្រមែងទ្រមល់ ស្តីស្តៅស្តុកស្តុរ ភ្ញាសស្មោងស្លូលស្នាយ ។
ពង្រីងដកពដកពាយ រលួសរលោយ រលួសផ្អុងផ្អាវ ។
ពពេលស្នាយដែល(១)ខ្នុងខ្នុរ ចង្គៅចង្គារ សម្បុរល្វែងល្វា ។
បេកទេសកាកែសកណិការ ដង្កោក្តាំងឆា ដុះដូចគេចារ ។

---

១ ស្នាយដែល ឈ្មោះឈើមួយប្រភេទ ដើមស្រលួត ស្លឹកទ្រវែងស្រួចៗ សាច់រឹង ។

៣៩-ស្អឹកស្អាមដើមផ្អាមសាខា ទ្រង់ដោយពណ៌ផ្កា ទីទៃនានា ។
ស្រលិតចំប៉ីចម្ប៉ា ត្រសាយសាខា ត្រសុំទៀងទាប ។
ផុះដោយជ្រុងជ្រោយទំនាប ធ្នេរស្រះរេះពប លំពង់លូតលាស់ ។
ស្អឹកស្អាមត្រសុំក្រែលក្រាស់ ដើមផុះធ្ងូកធ្លាស់ ក្រពុំប៉ិចផ្កា ។
រុះរោយផាសដោយដាក កេសរបុប្ផា ជាជុំត្រឡប់ ។
៤០-ព្រះពាយផាត់ផាយសាយសព្វ ហាក់ដូចអ្នកអប់ ទាំងព្រៃហិមពាន្ត ។
ចម្ប៉ាម្លិះលាភូតាន រំដេញមាសមាន រំដួលផុះដោយ ។
ខ្លះផ្កាបុប្ផារុះរោយ ខ្លះទើបផ្កាក្រោយ ក្រពុំប៉ិចខ្ចី ។
មហាហិង្គុប្រយង្គុមាលតី បុសនាគទួនស្រី ម្លិះរួតលទ្ដៃ ។
ផុះដេរដាស់ពេញហូរហៃ ខ្លះរីកដូចតែ- រំយោលរៀងរាយ ។
៤៥-ហិមពាន្តទីបានសប្បាយ រាលវែងលាយ រំលោងស្រោងស្រឹង ។
សព្វសត្វប្រវាត់អឺអឹង កមរាទ្រហឹង ត្រឹបកេសរផ្កា ។
ហោមហង្សចាប់ចុងក្រស្នា ប្របកៀងគូរ ចឹកចាប់ផលផង ។
ពាំផ្កាក្រស្នាទាំងទង ហិចហើរត្រសង រកឈើទៀតទំ ។
ក្អាំពាក់ត្រសាក់ត្រសុំ ហង្សហើរទើរទំ លេងលើរុក្ខា ។
៥០-ប៉ោលតោកក្ងោកមាសណ៌ា ចាប់ចុងព្រឹក្សា គឹកល្បព្រឹក្ស ។

ដើមដងស្រោងស្រោងស្ងោមស្ងុក បក្សីចាប់ចឹក ចរភោគផលផង ។
សារិការរកផ្អៀងផ្អង ហិចហើរត្រសង ចាប់ចុងកាកែស ។
ព្រឹក្សាទ្រង់ផ្កាពិសេស ទ្រទន់ទ្រទេស បក្សីចឹកចាប់ ។
ឯសេកផ្ទុកផ្ទោះធៀងធាប ទៅទំផ្ទឹមផ្ទាប់ នៃបទឹងសារិកា- ។
៥៩-កែវកល់យង់យល់សេកណា៎ លះលែងព្រឹក្សា ផ្ទុកផ្ទោះហើរចេញ ។
សេកយល់ហើយហើរឃ្លាតឃ្លាញ រកឈើទៀតវិញ ខ្ទាបទៀនទំ ។
ចម្ប៉ាសាខាត្រសុំ សារិកាទៅទំ ចាប់ចឹកបុប្ផា ។
លលកហើរមកម្ចីមា ទើរទំរេក លើដើមរុក្ខា ។
សត្វសត្វត្លៀលត្លាត់រេក ចាម់ចុងព្រឹក្សា ទំទាំងគូលេង ។
៦០-ខ្សៀវខ្សារត្ចេត្ចាតគតក្រែង គ្រអាលអរឯង ដោយដើមព្រឹក្សា ។
ព្រះអង្គទ្រង់ស្តេចលីលា ប្រពាតព្រឹក្សា ក្រសាលហឫទ័យ ។
ស្រាប់ស្រេចសម្តេចជៀស្ដជ័យ គង់យន្តមាសម័យ កើបហង្សហោះទៅ ។
ដល់ឋានពិមានលំនៅ ស្រុកមួយនាមហៅ នគរបញ្ចាល ។
បុរីនាទីនោះណា៎ មានព្រាហ្មណ៍ហោរា ចេះចប់ត្រៃវេទ ។
៦១-ចេះធម៌ចេះសិល្បសាស្ត្រសេដ្ឋ ជាស្នងព្រះនេត្រ ព្រះបាទចក្រី ។
ព្រាហ្មណ៍ព្រឹទ្ធតែងគិតសេចក្ដី លោកាលោកិយ តម្រង់ក្បត្រៃថ្ង ។

សម្ដេចសពិដ្ធជៀស្លជ័យ កើចយន្តមាសម័យ ចាប់ចុងព្រឹក្សា ។
ឈើធំត្រសុំសាខា ខ្ពស់លើសលែងនា អស់ទាំងឈើផង ។
ព្រះអង្គយកហង្សនោះហោង ផ្គូផ្គាប់ចាប់ចង ស្ងូរេចហើយណា ។
៧០. ក្សត្រក្សាន្តឈរឈានបាទា ចុះពីព្រឹក្សា រៀងរួចដល់ដី ។
ព្រះអង្គស្ដេចទ្រង់ស្មី កាន់ព្រះវីជនី មាលមាសសុវណ្ណា ។
ស្ដេចទ្រង់គ្រឿងផ្ទង់សោភា មេឡាផាត់កន្ត្រា ក្របេះប្លួងចន្ទន៍ ។
ព្រះកន្ត្រវរលក្ខណ៍សោភ័ន ពាក់ជួបព្រះចន្ទ ពាលពេញបូណ៌មី ។
ស្រាប់ស្រេចសម្ដេចចក្រី ព្រះអង្គចរលី- លាចូលនគរ ។
៧៥-ព្រះបាទសីហនាទចេញចរ សម្ដេចភូធរ ប្រពាតផ្កាផ្សេង ។
ក្នុងផ្កាប្រការផងគ្រប់ ឈ្ងុយឆ្ងាយសាយសព្វ រៀងពល់កនកាយ ។
ក្រមុំតូចធំទាំងឡាយ ដាក់ផ្កាសព្វសាយ ជុំជិតប្រក្រតី ។
យល់អង្គស្ដេចទ្រង់ស្មី ស្រស់ស្រេចប្រិមប្រិយ លើសលែងប្រុសផង ។
មិចមៀវខ្សឹបខ្សៀវផ្អៀងផ្អង ទឹងគ្នាសាសង់ ស្និទ្ធស្នាលចរចា ។
៨០-រុំយមើលដំណើរធាយា កម្ទោះទុះណា ចំណាប់ពេកពន់ ។
ស្រីផងផ្អៀងផ្អងគយគន់ មៀងមើលឥតធ្អន់ ដល់តិចឡើយណា ។
៨២-ព្រះអង្គពូជពង្សក្សត្រា ស្ដែងស្ដេចលីលា ទឹមផ្ទះព្រាហ្មណ៍ហោង ។

# បទកាកគតិ

៦៩– កាលនោះបុរោហិត អ្នកប្រាជ្ញព្រាហ្មណ៍ត្រឹទ្ធ ប្រដៅសិស្សផង
អង្គុយរៀនកល់ រៀនធម៌អឹងកង ច្រើនក្រៃកន្ទង
ជុំជាប្រក្រតី ។

ព្រាហ្មណ៍យល់ព្រះអង្គ ប្រសើរកិម- ង្គលគាប់ពិសី
រូបនោមវិលក្ខណ៍ វរកត្រៃសោភី ព្រាហ្មណ៍ប្រាជ្ញចេតី
កើតក្តួចស្រឡាញ់ ។

៧០– គេជះសម្ភារ សម្តេចភូបាល សាងពីមុនមិញ
ព្រាហ្មណ៍យល់ហើយគិត ក្នុងចិត្តឯងម្នេញ កន្ទក់កន្ទេញ
ស្ញើចសរសើរថា ។

រីអ្នកនេះនៃ រូបល្អប្រពៃ តើមកពីណា
មិនគឺកូនពស្ត្រ ទាំងផ្កាសខ្ចីខ្ចា សមកូនក្សត្រា
ត្រាច់មកពីឆ្ងាយ ។

សមមកនេះណា៎ រករៀនសាស្ត្រា ធម៌ផងទាំងឡាយ
អញហៅមកសួរ ដណ្តឹងនិយាយ ប្រការសម្នាយ
ឲ្យអស់សេចក្តី ។

ទើបព្រាហ្មណ៍ប្រាជ្ញហៅ   ថារ៉ឺយនៃចៅ   កម្លោះពិសី
អាពុកយល់ចៅ   ល្អញល្អៅប្រិមប្រិយ   អញ្ជើញតាប់ខ្ញី
មកណោះអ្នកអាយ ។

អាពុកទឹងដ-   ណ្តឹងអ្នកប្រុសគន់   បន្តិចពីកាយ
ក្បិណនោះព្រះអង្គ   ដំទ្រង់តោមតាយ   ឮព្រាហ្មណ៍ប្រាជ្ញប្រាយ
ហៅដូច្នោះណា៎ ។

៧៤–ទើបអ្នកខតចៅ   យល់សឹងសិស្សនៅ   រៀនធម៌សាស្ត្រា
ស្តែងស្តេចគិតក្នុង   កំឡុងខយា   ទ្រង់ព្រះចិន្តា
ត្រេកអរពេកក្រៃ ។

អញមកនេះម្តង   បានដូចបំណង   ពុំក្រឡើយនៃ
អញទៀនឹងសំណាក់   ពឹងពាក់អាស្រ័យ   យកព្រាហ្មណ៍នេះនៃ
ជាអាពុកធម៌ ។

ហើយអញនឹងរៀន   ឲ្យអស់របៀន   សិល្បសាស្ត្រធម៌អាថ៌
បំណោះអ្វីៗ   កុំបីទេសទាល់   ដូចអញសំគាល់
ប៉ុនប៉ង់ប្រាថ្នា ។

ទ្រង់ចិន្តាស្រេច   នោះទើបស្តែងស្តេច   យាងយាសយាត្រា

បរចូលទៅដ្ឋាន　　គ្រឹះស្ថានព្រាហ្មណា　　ព្រាហ្មណ៍សោតបរពា
សាកសួរព្រះអង្គ ។
ថាហៃអ្នកមាស　　តើអ្នកយាន់យាស　　មកពីកំឡង់
ដំបន់ឋានណា　　យាត្រាត្រាច់ត្រង់　　នេះអ្នកចោទចង់
ប្រាថ្នារកអ្វី ។

៨០— ចូរអ្នកប្រុសប្រាប់　　ឲ្យអាពុកស្តាប់　　ដឹងដើមសេចក្តី
មាសមកនេះណា　　ប្រាថ្នាព័ស្តុអ្វី　　ចូរអ្នកស្រដី
កុំលាក់លៀមឡើយ ។

មួយសោតនាមករ　　កូនស្ងួនបវរ　　ឈ្មោះអ្វីកូនអើយ
រីស្រុកទេសគន់　　ដំបន់ត្រាណាត្រើយ　　នៅណាអ្នកអើយ
នាមហៅស្រុកអ្វី ? ។

មួយនីសោតណា　　រីឯមាតា　　បិតាជាតិ
បង្កើតនៃបា　　ស្ងួនក្សាពិសី　　នាមហៅឈ្មោះអ្វី
ណាអ្នកកូនអើយ ។

ក្សិណនោះព្រះអង្គ　　អម្បូរពូជពង្ស　　ក្សត្រាត្រាណាត្រើយ
ស្តេចស្តាប់ព្រាហ្មណ៍សួរ　　ទទួលបោះហើយ　　ទើបព្រះអង្គឆ្លើយ

សាសន៍សូមៃ ។

ថាខ្ញុំនេះណា+ ជាកូនក្សត្រា- ធិកជជៀស្នជ័យ
ជាចៅបុរី ដែនដីគពាត្រៃ ឥសូរឯងញ
គ្រប់គ្រងភាព ។

៨៥–ខ្ញុំឈ្មោះសុវណ្ណ- កុមារសោភ័ន ត្រាច់ចរយាត្រា
មកតាំងម៉េះហោង ប៉ុនប៉ងប្រាថ្នា រៀនសិល្បសាស្ត្រា
អស់គាថិធមិផង ។

ក្សណោនោះព្រាហ្មណ៍ស្តាប់ ព្រះអង្គថ្លែងប្រាប់ បទដើមទំនង
ដំណើរក្សត្រា ប្រាថ្នាប៉ុនប៉ង រករៀនធមិផង
តាមសព្វហឫទ័យ ។

ព្រាហ្មណ៍ថាខ្ញុំសុំ អ្នកមាសឧត្តម ជាកូនធម៌ថ្លៃ
ទឹងប្រះដៅធមិ សិល្បវិសេសសៃយ តាមតែព្រះទ័យ
អ្នកទឹងប្រាថ្នា ។

កាលនោះព្រះចៅ ស្តែងស្តេចនិត្យនៅ ទឹងព្រាហ្មណ៍ហោរា
ព្រាហ្មណ៍ប្រះដៅធមិ សព្វសិល្បសាស្ត្រា សម្តេចរកជា
រៀនអស់ធមិផង ។

ហេតុព្រះប្រាជ្ញា ចិត្តវិសេសប្រា- កដកបកទូន
ស្តេចរៀនសេធមិ សិល្បសាស្ត្រផង បានដូចបំណង
ចប់បិដកត្រៃ ។

៩០— ព្រាហ្មណ៍សរសើរថា កូនស្ងួនពុំផា មានប្រាជ្ញាវៃ
អ្នករៀនអស់ធមិ សព្វសិល្បសាស្ត្រសៃយ តែរពេចខ្វិ
ចប់សាស្ត្រាគម[1] ។

អាពុកនឹងបែង បំណេះឡេងង អ្នកមាសឧត្តម
កាន់តួអាពុក សេពសុខកិរម្យ ជាអ្នកប្រាជ្ញធំ
លើសលែងលោកា ។

អាពុកនឹងយក បាបុត្រពន្ធក កូនស្ងួនពុំផា
ទៅថ្វាយព្រះបាទ នរនាថជេដ្ឋា រីឯចិត្តបា
គិតម្តេចកូនអើយ ? ។

ព្រះអង្គស្តេចស្តាប់ ពាក្យពីរោះគាប់ ព្រាហ្មណ៍ប្រាប់ម្នោះហើយ

---

១ សាស្ត្រ ន. (សំ.ម.) គម្ពីរ, ច្បាប់, ក្បួន គម្រោ ។ អាគម ន. (សំ.ម.) ការរៀនសូត្រ, ការចេះដឹង ។ ផ្សំសាស្ត្រនិងអាគម ជាសាស្ត្រាគម; ចប់សាស្ត្រាគម គឺចប់ការរៀនសូត្រតាមគម្ពីរក្បួនច្បាប់ ។

ក្សិណក្សត្រត្រកូល　　បន្ទូលផ្ទាស់ឆ្លើយ　　អ្នកអាពុកអើយ
ខ្ញុំនឹងថាអ្វី ។

ក្សិណនោះព្រាហ្មណ៍យក　　ព្រះអង្គពន្ទក　　សពេជ្រជិនស្រី
ទៅថ្វាយព្រះបាទ　　នរនាថនរបតី　　ជាចៅបុរី
នគរបញ្ចាល៍ ។

៩៥—ព្រាហ្មណ៍ឧនសិរសិដ្ឋ　　ក្រញ្ញក្រាបផ្ញញជិត　　បង្គំទូលថា
ខ្ញុំថ្វាយកូនប្រុស　　ស្រៀបស្រស់សោភា　　ជាខ្ញុំករុណា
តាងខ្ញុំឯងហោង ។

ក្សិណនោះក្សត្រា　　ស្ដេចបន្ទូលថា　　ព្រាហ្មណ៍អើយនេះម្ដង
ព្រាហ្មណ៍យកបុត្រា　　ពុំផាស្ងួនគ្រង　　មកថ្វាយជាស្នង
ត្ឋព្រាហ្មណ៍ប្រាជ្ញប្រាយ ។

កូនព្រាហ្មណ៍តើញាំង　　បេះចប់ទូទាំង　　សិល្បសាស្ត្រសព្វសាយ
ធមិអាថិក្បួនច្បាប់　　តម្រាប់សម្ដាយ　　ដូចព្រាហ្មណ៍ប្រាជ្ញប្រាយ
ឬទេព្រាហ្មណ៍ត្រឹម ? ។

ទើបព្រាហ្មណ៍ទូលថា　　បពិត្រព្រះមហា-　　ក្សត្រថ្លៃទ្រង់ឫទ្ធិ
កូនខ្ញុំនេះណា+　　មានប្រាជ្ញាពិត　　តោះខ្ញុំឯងគិត

ផ្ទឹមផងពុំបាន ។

ស្ដេចស្ដាប់ព្រាហ្មណ៍ទូល ទើបព្រះឥស្សូរ បន្ទូលទៅថ្កាន
ព្រាហ្មណ៍អើយអញអរ សាទរស្មោះស្មាន អរត្បិតព្រាហ្មណ៍មាន
កូនប្រុសប្រាជ្ញប្រាយ ។

១០០–ទ្រង់ព្រះចិន្ដា ក្នុងព្រះទយា ថាឱអញស្ដាយ
កូនព្រាហ្មណ៍នេះណា៎ សោភាពោមឆាយ លែងប្រុសទាំងឡាយ
លោកិយនេះណា៎ ។

ត្បិតតែយសតូច ពុំស្មើពុំដូច នាងនាថធីតា
បុត្រីសម្លាញ់ កូនអញនេះណា៎ ទឹងជ្រុំផងគ្នា
ពុំបានឡើយហោង ។

សម្ដេចរាជា ព្រះអង្គករុណា ស្រឡាញ់ស្នេហ៍ស្នង
ភស្សូរពោធី- សត្វិសេសហោង លើសលែងអ្នកផង
ទាំងឡាយនានា ។

ឯពុទ្ធង្កូល ពន្ធុកបណ្ដូល សពេជ្ញសាស្ដា
ព្រះអង្គតែងទៅ គាល់ហ្វោកជា តាងព្រាហ្មណ៍ហោក
ជាអ្នកប្រាជ្ញប្រាយ ។

រីបុរោហិត(១) ហោកព្រាហ្មណ៍ព្រឹទ្ធ នៅសុខសប្បាយ
រក្សាព្រះអង្គ ទ្រើសទ្រង់ដោមដាយ ក្សត្រថ្លៃពណ្ណរាយ
នៅទីនព្រាហ្មណា ។

១០៥– ព្រះបាទឥស្សូរ ក្សត្រាត្រកូល ព្រះចៅបញ្ចាល៍
ស្តេចមានបុត្រី ស្រស់ស្រីសោភា នាងទ្រង់នាមា
បទុមកេសរ ។

នាងនាថនារី គបបញ្ចិន្ទ្រិយ ដោមដាយបវរ
ដូចចន្ទថែនចាំង ខូទាំងអម្ពរ ជាឆ្នើមនគរ
បញ្ចាលបុរី ។

នាងល្អកន្លង ទ្រទេសទងវង ទ្រទន់ស្រស់ស្រី
វរអង្គវរលក្ខណ៍ វរភក្ត្រប្រិមប្រិយ ជាមកុដអស់ស្រី
ទាំងត្រៃភពផង ។

ទោះបីស្រីសួគ៌ ប្រពៃគាប់គួរ ថ្លៃថ្លាកន្លង
នៅត្រៃត្រឹង្សា សួគ៌ាឆាយហោង នោះទីផ្ទឹមផង
ពុំបានឡើយណា ។

---

១ ច្បាប់ខ្លះថា រីឯព្រាហ្មណ៍ព្រឹទ្ធ អ្នកប្រាជ្ញបណ្ឌិត នៅសុខសប្បាយ .... ។

សម្តេចជននី　　ជនកបេតី　　កូនស្ងួនពុំងា
ស្តេចឲ្យស្រីថ្លៃ　　នៅព្រប្រាង្គប្រា-　　សាទសួគ៌សោភា
មាសម័យព្រោងព្រាយ ៗ

១១០— ស្តេចឲ្យស្រោលស្រី ស្រស់ស្រៀបប្រិមប្រិយ គីលៀងទាំងឡាយ
ឲ្យចាំរក្សា　　បុត្រភ្ងាឆោមឆាយ　　នៅសុខសប្បាយ
លើប្រាសាទសម ៗ

រ័តន៍កជធីតា　　ឆោមឆាយសោភា　　ពាលពេញក្រមុំ
ស្រីស្រស់ថ្លាថ្លៃ　　ល្អមល្អៃក្មេងកុំ　　នាងនាថឧត្តម
សោឡសឆ្នាំណា ៗ

នាងនៅប្រាសាទ　　ប្រសើរស្អាងស្អាត　　មាសម័យសោភា
ទឹងអស់ស្រឹង្គារ　　បរិពារផងណា　　ក្សេមក្សាន្តសុខសា-
ប្បាយបរិបូណ៌ក្រៃ ៗ

ហេតុតែបុណ្យនាង　　បរិបូណ៌បានស្អាង　　ជាអស្ចេយ្យ
ទឹងព្រះពោធិ-　　សត្វវិសេសថ្លៃ　　ទឹងបានមូលមេ-
ត្រីត្រេកផងគ្នា ៗ

មានកាលមួយថ្ងៃ　　ស្រីរ័តន៍ថ្លាថ្លៃ　　បើកព្រះកៅវតារ

ទតយល់ព្រះអង្គ　ពូជពង្សក្សត្រា　ស្តែងស្តេចលីលា
ទៀបប្រាសាទថ្ងៃ ។

១១៨— ទើបនាងធីតា　គិតក្នុងទយា　ថាអ្នកនេះនៃ
មកពីឋានណា　ប្លែកនាសព្វថ្ងៃ　មានរូបប្រពៃ
សក្តិសមសោភា ។

ទើបនាងប្រាប់ទៅ　កីលៀងមួយនៅ　ខាងនាងធីតា
ចង់អោយបងមើល　គេដើរនោះណា+　រូបឆោមឆាយា
ចំណាប់ពេកក្រៃ ។

នាងនាថធីតា　នូវកីលៀងភ្លា　គយគន់រំពៃ
ហើយសឹងសរសើរ　ដំណើរក្សត្រថ្ងៃ　ទាំងពីរនាក់នៃ
ពុំលែងឡើយណា+ ។

នាងគយគន់មើល　ព្រះរាជដំណើរ　លុះផុតនេត្រា
នាងនាថរងឹរឹត　ចងចិត្តស្នេហា　គិតព្រះរាជា
ពិតពុំភ្លេចឡើយ ។

១១៩— នាងនាថឆោមឆាយ　ធ្វើជានិយាយ　ឯទៀតព្រងើយ
ធ្វើពុំនាំពា　ហាក់ជាគោះគើយ　គំមោះពុំស្បើយ

ក្នុងព្រះនគរ ។

# បទព្រហ្មគីតិ

១១៩– លង់លុះចូលកត្រី នាងនារីរ័តន៍និទ្រា
ទ្រង់ព្រះរាជចិន្តា រំពឹងគិតព្រះអង្គថ្លៃ ។
ថាឱអង្គកល នាអញយល់កាលពីថ្ងៃ
ប្រុសនោះល្អប្រពៃ តើគាត់មកពីឋានណា ។
បើតាមដែលអញយល់ រូបនិម្មលឆោមសោភា
សមគាត់កូនក្សត្រា គ្រាប់មកពីទីឋានឆ្ងាយ ។
ពុំគឺកូនសេនា កស្ត្រប្រជានៅស្រុកអាយ
បើកូនអ្នកខ្សត់ខ្សោយ មិនមានរូបដល់ម៉្លេះណា៎ ។
ល្អថ្លៃកនាលោកិយ ហាក់មកពីត្រៃត្រឹង្ស
ព្រះភក្រ្តដូចចន្ទ្រា ត្រចះចែងពេញបូណ៌មី ។
១២០– គន់ឯអស់ព្រះអង្គ សឹងវរវង្សសមសោភី
ល្អល្អះអស់ឥន្ទ្រិយ រូបល្អេញល្អៅពាលប្រពៃ ។
នាងទ្រង់ព្រះចិន្តា វរជាយាព្រួយព្រះទ័យ
គិតទៅវែងអាល័យ អាឡោះលទន់ពន់ប្រមាណ ។

ខ្ញុំអញឥឡូវអើយ    ធ្វើម្ដេចឡើយកទីងបាន
អ្នកនោះមករួមរ៉ាន    ជាស្វាមីអញសព្វថ្ងៃ ៗ
អញចង់ឲ្យទៅសួរ    យល់ពុំគួរពេកណាស់នៃ
គិតទៅវែងក្រៃក្រៃ    ឥតអ្នកណាទីងជួយចាត់ ៗ
បើអញទីងស្ងៀមនៅ    ក្រែងគាត់ទៅឯណាបាត់
គឺក្ដីនេះក្រក្ដាត់    ទឹងធ្វើម្ដេចឥឡូវណា៎ ៗ
១២៥– រូបអ្នកល្អពីសី    ដូចបុណ្ណមីព្រះចន្ទ្រា
គួរគូស្និទ្ធស្នេហា    ជាស្វាមីអញនេះសម ៗ
កំឡុងកត្រីស្វាត់    នារីរ័ត៌នវែងបារម្ភ
នាងនាថពុំបានផ្ដុំ-    ឡើយនាងគិតព្រះកជា ៗ
លុះព្រឹកព្រហាមស្រាង    ស្រេចហើយនាងនាថជាយា
នាងតើនចាកក្រឡា-    បន្ទុំទែនទិព្វរង្សី ៗ
ទើបនាងសោយព្រះស្ងួន    ស្រេចស្រីតន់សោយព្រះស្រី
ហើយនាងនាថទេវី    បើកព្រះកៅវ៉តារទតទៀត ៗ
នាងផ្អូកគិតអាល័យ    ក្នុងព្រះទ័យវែងចង្អៀត
នាងគយគន់មើលទៀត    នាងពុំយល់ព្រះកូមី ៗ

១៣០– នាងគង់ទុនសញ្ជាប់ ស្ងៀមស្ងួតស្ងប់ព្រះភក្ត្រស្រី
នាងនាថពុំស្រដី ចរចាបែងដល់គិចណា ។
ភីសៀងជំទិតនាង ចូលជិតខាងរាជធីតា
យល់នាងដាក់ភក្ត្រា ស្រពោនពុំដូចសព្វដង ។
ភីសៀងអធ្យាស្រ័យ ជាស្រីថ្លៃមានបើបង-
ចិត្តទឹងប្រុសនោះហោង ទើបជាទុក្ខអង្គីក្តី(១) ។
ភីសៀងតើទូលថា(២) នាងធីតាអផ្សុកអ្វី
ស្រពោនព្រះភក្ត្រស្រី ចូរមាសថ្លៃប្រាប់ខ្ញុំក៏ ។
ទើបនាងថាបងអើយ ឥឡូវអើយអញប្អូនមហា-
ព្រួយចិត្តពន់ពេកណា បងមិនជួយគិតប្អូនឡើយ ។
១៣៥– ភីសៀងទូលវាងវៃ ព្រួយព្រះទ័យអ្វីមាសអើយ
កុំអ្នកថ្លៃលាក់ឡើយ ប្រាប់ឲ្យបងបានដឹងក៏ ។
ទើបនាងត្រាស់ថាហៃ បងឯងនៃស្រាប់ហើយណា
ស្មើគេតឯកមាតា តើប្អូនទឹងលាក់ធ្វើអ្វី ។

---

១ ច្បាប់ខ្លះថា ភីសៀងអធ្យាស្រ័យ ជាស្រីថ្លៃមានបើបឹង ប្រុសណាថ្លៃវវង្ស ទុំហាក់យល់អង្គីក្តី ។ ២ ច្បាប់ខ្លះថា ភីសៀងចំអន់ថា ... ។

បងអើយប្អូនសែនឆ្ងល់ ត្បិតប្អូនយល់ប្រុសពិសី
ពីម្សិលអង្គីក្តី តើគាត់មកពីឋានណា ។
បងអើយអញប្អូនថប់ គិតទៅគ្រប់ហើយវែងជា-
ព្រួយចិត្តពេកមិនគ្រា- ស្បើយពីទ្រូងដល់តិចឡើយ(១)។
បើអ្នកណាទៅដល់ សួរឲ្យយល់ពាក្យគាត់ហើយ
អ្នកនោះណាបងអើយ អញនឹងឲ្យរង្វាន់ផង ។
នាងចរចាបញ្ជៀង ទើបគីលៀងទូលវិងស្នង
ត្រង់នោះទុកធារបង កុំព្រួយចិត្តណាមាសថ្លៃ ។
នាងស្តាប់គីលៀងថា ទូលឈានាជូបោះនៃ
ទើបនាងត្រាស់ថាហៃ បើបងទៅសួរឲ្យជាក់ ។
សួរឈ្មោះម្តាយអាពុក សួរទាំងស្រុកទាំងនាមអ្នក
សាកសួរឲ្យជាក់លាក់ ក្រែងគាត់មានប្រពន្ធហើយ ។
គីលៀងក្រញូក្រាបលា នាងធីតាពុំលង់ឡើយ
ទៅស្អាតព្រះត្រាណាត្រើយ ចាំមើលផ្លូវព្រះភជា ។

---

១ ច្បាប់ខ្លះថា អញប្អូនគិតទៅគ្រប់ ហើយវែងថប់ពេកមិនគ្រា
នឹងស្បើយពីទ្រូង ជាក្រសាលដល់តិចឡើយ ។

កាលនោះពោធិសត្វ　　បុរសរ័តន៍ស្តេចលីលា
ទឹងទៅគាល់ក្សត្រា　　ជួបទឹងនាងកីលៀងនោះ ៗ
១៤៥– ឯនាងកីលៀងណា　　ជណ្តឹងថាអ្នកកម្លោះ
ទឹងទៅឯណាហ្នះ　　ឈប់ខ្ញុំទឹងសួរសិនក៏ ៗ
រីឯព្រះជៀស្តជ័យ　　សងសូមត្រាស់ទៅថា
អញទឹងអាលយាត្រា　　អញមិនឈប់ណានាងអើយ ៗ
កីលៀងលោមចរចា　　អ្នកកុំថាដូហ្នោះឡើយ
ឥឡូវនេះអ្នកអើយ　　មានគេប្រើខ្ញុំមកណា ៗ
ស្តេចជ្រាបដូហ្នោះទៃ　　ក្បៀណក្សត្រថ្ងៃឈប់វេរា
កីលៀងនោះម្ទីម្ទា　　ចូលទៅទៀបព្រះជៀស្តជ័យ ៗ
នាងថាឱអ្នកអើយ　　ឥឡូវហើយក្សត្រថ្ងៃ
នៅប្រាសាទមាសម័យ　　បុត្រីព្រះចៅបញ្ចាល ៗ
១៥០– នាងទ្រង់ឆោមពិសី　　លើសលែងស្រីទេពសួគ៌ា
នាងទ្រង់ព្រះនាមា　　ឈ្មោះនាងបទុមកេសរ ៗ
នាងប្រើខ្ញុំមកណា　　នាងធីតារ័តន៍បវរ
ចង់ជ្រាបដល់នាមករ　　ឈ្មោះអ្នកឯងណាអ្នកអើយ ៗ

មួយសោតក្រៃអ្នកមាន គូបុកណាជាស្រេចហើយ
ប្តីមួយអ្នកគ្មានឡើយ នាងចង់ដឹងដោយទំនង ។
ហើយសួរពីមាតា នូវបិតាអ្នកឯងផង
ឯឈ្មោះស្រុកនោះហោង លំនៅគេនៅឋានណា? ។
ក្សិណនោះព្រះភូមី ព្ទាសីទៀងទូលថា
នាងនាថតោមសោភា ឲ្យដណ្តឹងដូច្នោះហើយ ។
១៥៥– ស្តេចគិតក្នុងព្រះទ័យ អរពេកក្រៃទើបស្តេចឆ្លើយ
ថ្លែងថាហៃបងអើយ អញបានបងនាំពតិមាន ។
ពីនាងឲ្យមកសួរ- សាកបរិបូណ៌ហើយអញបាន
ដឹងពាក្យពីកល្យាណ ចែងសាយសព្វប្រការផង ។
បងអើយឯមាតា នូវបិតាអញនេះហោង
ជាស្តេចស្តែងគ្រប់គ្រង ក្រុងភាពទេពបុរី ។
ឯអង្គអញនេះណា៎ ឥតជាយាពជមហេសី
ទើបអញចរចាកពី- នគរនាយដល់អាយណា៎ ។
បងអើយអញនេះមក ប្រយោជន៍រកពជជាយា
អញអាស្រ័យនៅនា- ផ្ទះព្រាហ្មណ៍ប្រាជ្ញមួយនុ៎ះហោង ។

១៦០— ឯឈ្មោះអញនេះណា  កូនព្រះបាលីជាម្តង
ថាទ្រព្យប្រសើរផង  វែងតែងស៊ើមសៀតកេសី ។
ឈ្មោះអញជូថ្នោះណា  ចងយាត្រាវិលវិញខ្ញី
ទៅទូលនាងទេវី  តាមប្រាជ្ញានាងគិតយល់ ។
ភីលៀងសោតស្តែងស្តាប់  ព្រះអង្គប្រាប់ប្រការគល
ជឿជាព្រះទសពល  ជាស្តេចស្តែងប្រាកដហោង ។
អរឯងឧទសីសោ  បង្គំមហាក្សត្រច្បាស់ច្បង
លុតលាវិលវិញផ្គង  ឋានប្រាសាទប្រសើរសល់ ។
រីឯព្រះរាជា  ស្តេចលីលាឡើងទៅដល់
ពេញរ័តន៍កដមណ្ឌល  គង់គាល់ព្រះចៅបញ្ចាល៍ ។
១៦៤— ស្រេចហើយព្រះពោធិ-  សត្វចុះពីគាល់រាជា
ទៅឋានព្រាហ្មណ៍ហោរា  ស្តេចនិត្យនៅជួបសព្វផង ។
ឯភីលៀងនោះណា  ទៅដល់ប្រាសាទហើយហោង
ម្នីម្នាឡើងទៅផ្គង  ក្រាបទូលនាងនាថជាយា ។
បពិត្រអ្នកម្ចាស់  ឥឡូវនេះខ្ញុំយាត្រា
ទៅជួបជួបប្រាថ្នា  បាននិយាយសព្វសេចក្តី ។

ម្ចាស់អើយអ្នកនោះណា　មិនគឺជាកូនមន្ត្រី
មិនគឺកូនសេដ្ឋី　មិនគឺកូនព្រាហ្មណ៍ហោរា ។
ព្រះអង្គជាត្រកូល　ជាអម្បូរបុត្រក្សត្រា
សោយរាជ្យគ្រងភារា　នគរឈ្មោះទេពបុរី ។

១៧០— ព្រះអង្គឥតជាយា　ប្រសើជាអគ្គមហេសី
នោះទើបព្រះភូមី　ស្ដេចត្រាច់មកដល់ស្រុកអាយ ។
ស្ដែងស្ដេចអាស្រ័យនា-　នៅគ្រឹហាព្រាហ្មណ៍ប្រាជ្ញប្រាយ
ប៉ុនប៉ងមកពីឆ្ងាយ　ប្រយោជន៍រកភជទេពី ។
រីឯព្រះនាមា　ស្ដេចប្រាប់ជាព្រះបាលី
ជាទ្រព្យប្រសើរវី-　សេសវែងសើមសៀតកេសា ។
ព្រះអង្គប្រស្នាមក　ឲ្យនាងរកតាមប្រាជ្ញា
ព្រះនាមព្រះរាជា　ក្នុងព្រះបាលីឯងនៃ(១) ។
នាងជ្រាបសព្វប្រការ　ហើយនាងនាថមានហឫទ័យ

---

១ ច្បាប់ខ្លះថា　ព្រះអង្គប្រស្នាមក　តាមនាងរកដោយប្រាជ្ញា
ព្រះនាមព្រះរាជា　ក្នុងបាលីចាំសុវណ្ណ ។

ត្រេកអរឯងពេកក្រៃ ទឹងថ្លឹងថ្លែងពុំបានណា៎(១) ។

១៧៩– នាងជឿថាព្រះអង្គ ប្រសើរពង្សពូជក្សត្រា

ឥតឯងមានសង្កា ក្នុងព្រះទ័យដល់តិចឡើយ ។

ទើបនាងទ្រង់ចិន្តា ដោះប្រស្នាព្រះត្រាណត្រើយ

ឃើញឈ្មោះពុំលង់ឡើយ ទើបនាងនាថបន្ទូលថា ។

បងអើយអញអរក្តាត់ បងឯងគិតឲ្យប្អូនភ្ញា

បងអើយឯប្រស្នា នោះប្អូនស្រាយឲ្យបងស្តាប់ ។

ថាទ្រព្យល្អប្រពៃ ប្រសើរក្រៃលោកវែងពប់

វែងស្អាងវែងប្រដាប់ សៀតកេសីគឺស្មៀតសក់ ។

នេះឯងទ្រព្យប្រពៃ មានតម្លៃពុំអាក្រក់

បងអើយឯស្មៀតសក់ សោតសឹងគឺមាសឯងណា៎ ។

១៨០– មនុស្សលោកសឹងហៅមាស ហៅទាំងផ្កាសសឹងដូចគ្នា

ថាបើនឹងហៅជា- ព្រះបាលីថាសុវណ្ណ ។

នាមអ្នកដូចោះហោង កុំបីបងគិតគ្នេរគ្នាន

---

១ ច្បាប់ខ្លះថា នាងជ្រាបអស់ប្រការ ហើយធីតាគិតគ្នេរគ្នាន់

ត្រេកអរគិតក្បួនកាន់ នឹងថ្លឹងថ្លែងពុំបានណា៎ ។

ស្ដេចឈ្មោះព្រះសុវណ្ណ- កុមារឯងមិនទេឡើយ ។
នាងនាថមានប្រាជ្ញា ដោះប្រស្នាព្រះត្រាណត្រើយ
ស្គាល់ព្រះនាមស្រេចហើយ នាងវែងពេញព្រះចិន្ដា ។
កីលៀងសងសូមៃ ថាមាសថ្លៃមានប្រាជ្ញា
ដោះសាអាថ៌ប្រស្នា រំពេចពុំកម្រឡើយ ។
ទន្ទឹងព្រះសុរិយា នាងធីតាឥតឯស្បើយ
នាងថាហៃបងអើយ បងជួយគិតប្អូនឆាប់ក៏ ។
១៨៥– កីលៀងខិតជិតខាង ទូលលោមនាងនាថជាយា
ម្ចាស់អើយកុំនាងបា- រម្ភគិតព្រះរៀមពេកឡើយ ។
កំសាន្តព្រះទយា គង់សុខសាបាយ(១)ម្ចាស់អើយ
ទុកធុរខ្ញុំឯងហើយ នឹងគិតគួរថ្វាយម្ចាស់ថ្លៃ ។
ខ្ញុំនឹងទៅឲ្យដល់ ឲ្យបានយល់ព្រះចមត្រៃ
អញ្ជើញស្ដេចមកវៃ រួមមណ្ឌលទឹងនាងណា+ ។
នាងស្ដាប់កីលៀងទូល នាងវែងចូលព្រះទយា
ទើបនាងបន្ទូលថា តាមតែបងឯងគិតលៃ ។

១ តាមដើមត្រឹមត្រូវ សរសេរ ‹‹សុខសប្បាយ›› តែនេះសម្រួលតាមសម្ព័ស្សកាព្យ ។

គីលៀងក្រញូងក្រាបលា នាងហើយយាត្រាឆាប់វៃ
ទៅដល់ព្រះចមរក្រៃ ថ្វាយបង្គំព្រះកជា ។
១៩០– ក្សិណនោះព្រះភូមី យល់ទាសីដល់ហើយបេណា
ស្តេចត្រេកសោមនស្សា បន្ទូលនូវពាក្យមេត្រី ។
បងមកឥឡូវណា នាងធីតាមានប្រើអ្វី ?
ចូរបងថ្លែងពាក្យពី- បណ្តាំនាងឲ្យស្រួក ។
គីលៀងសោតស្តែងស្តាប់ ទើបទូលប្រាប់ព្រះកជា
ថ្វាថ្លែងដោយប្រាជ្ញា ចំណោះនាងជាងសំដី ។
ខ្ញុំម្ចាស់មកក្រាបទូល ព្រះឥសូរខ្ពស់ជាតិ
ជាមកុដលើសិរសី ឲ្យបានជ្រាបព្រះទយា ។
ពីនាងខ្លួនទេវី មានស្វាមីកក្តិពជា
អនុជស្ងួនពុំងា នាងក្រញូងក្រាបថ្វាយបង្គំ ។
១៩៥– មកអង្គព្រះជៀសជ័យ ឲ្យក្សត្រថ្លៃស្តេចស្តែងផ្ជុំ
ឯកឯងកុំបារម្ភ សូមក្រសាលព្រះហឫទ័យ ។
ថាបើព្រះអង្គផ្ជុំ ឯកឯងពុំលក់ឡើយនៃ
ស្តេចយកព្រះពស្ត្រថ្លៃ ផណ្តាប់ផ្ជុំឲ្យលក់ណា ។

ស្តេចស្តាប់គីលៀងទូល ព្រះឥសូរសោមនស្សា
អរព្រួចព្រះទយា ហើយហាក់យល់រំពេចពិត ៗ
សម្តេចព្រះរាជា ទ្រង់ចិន្តាជាវរមិត្រ
នាងនាថព្រមចូលចិត្ត នាងឡើងហៅអញទៅហោង ៗ
ក្សិណនោះព្រះរាជា បន្ទូលថាហៃអ្នកបង
បងអើយវិលវិញផង ទៅទូលនាងនាថទេវី ៗ
ថាអញអរស្តាំទៅ នាងប្អូនទៅ ៗ ពិសី
អញចាំចូលរាត្រី ហើយអញទៅឋានទាំងហោង ៗ
គីលៀងក្រួញក្រាបលា ព្រះអង្គមហាក្សត្រច្បាស់ច្បង
លីលាវិលវិញផង ដល់ប្រាសាទនាងទេវី ៗ
រិតចូលទៅជិតខាង ក្រាបទូលនាងនាថនារី
ថាថ្ងៃអស់សេចក្តី ដូចបណ្តាំព្រះរាជា ៗ
នាងជ្រាបដូច្នោះនៃ ក្សត្រីថ្លៃសោមនស្សា
អរឥតឯគណនា ទឹងថ្លឹងថ្លៃពុំបានឡើយ ៗ
កាលនោះពោធិសត្វ បុរសរតនក្សត្រត្រាណត្រើយ
ស្តេចទៅឋានព្រាហ្មណ៍ហើយ ព្រះអង្គថ្លែងប្រាប់ព្រាហ្មណ៍ថា ៗ

២០៩– ហៃអ្នកតាពុកអើយ ឥឡូវអើយថ្ងៃនេះណ៎ា
ខ្ញុំទៅចាំលីលា កុំអ្នករកអញខ្ញុំឡើយ ។
ព្រាហ្មណ៍ហ៉ាឱមាសថ្លៃ តាមព្រះទ័យអ្នកមាសអើយ
រើលសត្យជាត្រើយ គ្រាណាពំនាក់យើងសព្វថ្ងៃ ។
ក្សិណានោះព្រះពជា ព្រះអង្គលាព្រាហ្មណ៍នោះនៃ
ស្តែងស្តេចត្រាច់ដល់ព្រៃ- ឈើដែលទុកយន្តនោះណ៎ា ។
កាលនោះឯព្រះអង្គ ឡើងដល់ចុងនៃព្រឹក្សា
គង់លើយន្តនោះណ៎ា ស្តេចស្រាយខ្សែស្រចហើយនៃ ។
រាត្រីពន់ពេលា- កាលហើយណ៎ាព្រះជៀស្ឋជ័យ
ស្តេចកើចយន្តមាសម័យ ហោះអណ្តែតដោយវេហាស៍ ។
២១០– កាលនោះឯក្សត្រី- រ័តន៍ទេវីពជធីតា
នាងនាថពុំនិទ្រា- ឡើយនាងចាំព្រះចមត្រៃ ។
នាងពំងទ្វារប្រាសាទ ប្រសើរស្អាតខ្ជាប់ពេកក្រៃ
នាងនាថនារីថ្លៃ នាងចង់ល្បងព្រះប្រាជ្ញា ។
ឯពង្សពោធិសត្វ បុរសរ័តន៍ស្តេចលីលា
ហិចហោះដោយវេហាស៍ ដល់ប្រាសាទមានីទេវី ។

ស្ដេចចុះបរបាកហង្ស　　ហើយព្រះអង្គព្រះភូមី
ស្ដែងស្ដេចត្រាច់ឡើងពី　　មានប្រាសាទប្រសើរសព្វ ។
ស្ដេចយកព្រះហស្ដថ្លៃ　　ទៅប្រាននៃទ្វារទាំងគ្រប់
យល់រឹងតឹងសាយសព្វ　　សោតសឹងរាំងខ្ទប់ក្ដាំងក្ដិត ។
២១៩– ស្ដេចទ្រង់ព្រះចិន្ដា　　ពិចារណាឯងគន់គិត
ថានេះនាងវរមិត្ត　　នាងចង់ល្បងលងប្រាជ្ញា ។
បើដោយអញគិតទៅ　　គួរអញហៅនាងជាយា
ស្ដេចទ្រង់ពិចារណា　　ក្នុងកំឡុងព្រះហឫទ័យ ។
ទ្រង់ព្រះចិន្ដាស្រេច　　ទើបស្ដែងស្ដេចត្រាស់ថាហៃ
ប្អូនមាសមិត្តថ្លើមថ្លៃ　　បងនាងមកដល់ហើយណា៎ ។
ឱប្អូនពៅពន្លក　　បើកទ្វារយកបងស្រូវរ៉ា
មាសអើយបងរងា　　តែម្នាក់ឯងណា៎ប្អូនស្រី ។
នាងស្ដាប់ព្រះបន្ទូល　　នាងអាសូរព្រះភូមី
ស្រយុតអស់ឥន្ទ្រិយ　　វរងចង់ចិត្តចាប់ស្នេហា ។
២២០– គឺមោះនាងខំអត់　　ខំសង្កត់ព្រះទយា
ចង់ដឹងព្រះប្រាជ្ញា　　ទើបនាងនាថដណ្ដឹងទៅ ។

ថាអ្នកណាស្រដី ថ្លែងថាអ្វីមកពីក្រៅ
ស្តេចឆ្លើយស្នងប្អូនពៅ ថាបងឯងណា៎ប្អូនស្រី ។
នាងសងសូមថា ខ្ញុំបុត្រភ្ញាចៅបុរី
កើតតែឯកឥទ្រិយ ឥតបងប្អូនជាពីរឡើយ ។
ទើបស្តេចបន្ទូលថា ហៃប្អូនភ្ញាមាសបងអើយ
កុំថាដូច្នោះឡើយ នាងស្តាប់បងនឹងប្រាប់ប្រាយ ។
អង្គប្អូនជាបុត្រី ក្សត្រពិសីគ្រងស្រុកអាយ
បងនេះណា៎តោមឆាយ សឹងកូនស្តេចដែរដូចពៅ ។
២២៥– ឥតបងប្អូនឡើយណា៎ អង្គឯកាដូចប្អូនពៅ
បងឮនាមប្អូនពៅ- ដល់ស្រុកបងឯនាយណា៎ ។
ថាប្អូនល្អពិសី លើសលែងស្រីទេពសួគ៌ា
តែខ្លួននាងប្អូនភ្ញា អង្គឯកាដូចខ្លួនបង ។
ទើបបងស្វះស្វែងមក សង្វាតរកប្អូនឯងហោង
ចិន្តាប្រាថ្នាប៉ង យកជាអគ្គមហេសី(១) ។
ប្អូនអើយបងឧបមា យើងនេះណា៎ដូចអគ្គី

---

១ ប្រាប់ឲ្យថា នឹងយកនាងជាមហេសី ។

បើអង្កត់មួយទី    ផ្ទុំកម្រទឹងទេះធាប់ ។
ប្អូនអើយបើយើងយក    ទុសពីរមកផ្គុំផ្គូផ្គាប់
ជាពីរផ្ទុំទេះធាប់    រំពេចពុំកម្រឡើយ ។
២៣០— ដូចកលអង្គប្អូនស្រី    ខ្លួនបងក្តីណាប្អូនអើយ
បើតែម្នាក់ឯងហើយ    វែងកម្រណាស់ពេកពៅ ។
ថាបើប្អូនស្រីស្រួល    នាងទទួលយកបងនៅ
ជាពីរនាក់ទឹងទៅ    ស្មើខ្លួនមួយមូលទឹងស្រី ។
មាសអើយពោះបើបើ    គិតសារពើការផងក្តី
បងក្រុចមានប្អូនស្រី    បើប្អូនក្រុចមាសមានបង ។
ទើបនាងសងស្បូមៃ    ថាតាប់បៃព្រះអង្គហោង
ជួយគិតឲ្យប្អូនផង    ខ្ញុំមិនភ្លាយជោយកជា ។
អញ្ជើញព្រះអង្គស្តេច    យាត្រាត្រាច់ទៅម្នីម្នា
វិលវឹងថ្កានសីមា    ស្រុកព្រះអង្គឯនាយនៃ ។
២៣៥— ស្តេចឆ្លើយស្នងវឹងពៅ    ថាប្អូនពៅមាសថ្លើមថ្លៃ
បងពុំវិលឡើយនៃ    បងចាំយកប្អូនឲ្យបាន ។
ថាបើនាងប្អូនគន់    ស្ងួនជិនផ្អូនមាសមិនក្សាន្ត

បណ្ដោញឲ្យបងថ្កាន ក្រឡាប់ទៅស្រុកនាយណា ។
ចូរប្អូនមាសត្រកាល មកបើកទ្វារឆាប់សួក៏
បងអ្នកទឹងយាត្រា ទៅឲ្យបានយល់មុខពៅ ។
សោះតែអភ័ព្វក្អក ដល់ថ្ងៃស្អែកបងទឹងទៅ
កុំឲ្យព្រួយចិត្តពៅ តែងបណ្ដោញបំបរបង ។
នាងសងសូមែថា កុំករុណាតែគេផ្ដោះផ្ដង
ជន្ទជន្ទេញលង ហាក់ដូចខ្ញុំសហាយស្មន់ ។
២៤០— ពុំកោតពុំគិតខ្លាច យកអំណាចណាស់ពេកពន់
ហាក់ហ៊ានគង្គានលន់ ពុំគិតខ្លួនក្រែងក្រក្រៃ ។
ទើបព្រះអង្គត្រាស់ឆ្លើយ ថាមាសអើយបងនេះនៃ
ពុំគិតពុំគាល័យ ពុំខ្លាចខ្លួនស្លាប់ឡើយណា ។
ឃ្លានតែប្អូនព្រលឹង ឲ្យបានដឹងចិត្តចិន្ដា
បើបានដូចប្រាថ្នា នោះប្រសើរនាលោកិយ ។
ខ្លួនបងដូចមមាច ពុំគិតខ្លាចទូរអគ្គី
ឃើញភ្លើងហើរចូលខ្ញី ដូចបងឃើញប្អូនស្នេហា ។
ម្ល៉េះបងមិនទើងទៅ បងទឹងនៅទឹងប្អូនក្វា

ឲ្យបានដូចប្រាថ្នា　　បងមិនឃ្លានស្ដាយជីវី ។
២៤៩– ស៊ូស្លាប់ ៗ បានខ្លាត　　លើប្រាសាទនាងប្អូនស្រី
ទឹងរស់ៗធ្វើអ្វី　　មកពុំបានដូចបំណង ។
ស៊ូរស្លាប់ពេញជាប្រុស　　ទុកជារស់កាលនេះម្ដង
ខ្មាសប្អូនបញ្ឆោតបង　　ឲ្យបងមកហើយប្រែវិញ ។
គេជះបងបានសាង　　សូមទឹងនាងពីមុនមិញ
ជាករិយាសម្លាញ់　　ពីបុពណាមែនពិតណា៎ ។
សូមឲ្យទ្វារប្រាសាទ　　របើកស្អាតតាកចេញក៏
ប្រាកដដូចសច្ចា-　　អធិដ្ឋានកាលនេះនៃ ។
ឯនាងនាថទង់វង់　　បន្ទូលផ្សង់ដូចក្សត្រថ្លៃ
ហេតុបុណ្យព្រះចមត្រៃ　　ទឹងនាងនាថពីមុនមិញ ។
២៥០– មកជ្រោមជួយព្រះបាទ　　ទ្វារប្រាសាទរបើកចេញ
នាងនាថរែងពោរពេញ　　ចិត្តជឿជាបារមីមាន ។
ក្សិណនោះព្រះរាជា　　ស្ដេចលីលាចរចូលថ្កាន
ទៀបនាងនាថកល្យាណ　　នាងទតយល់ព្រះរាជា ។
នាងខ្មាសនាងអៀនអាក់　　ប្រែព្រះភក្ត្រនាងចេញណា៎

នាងយកព្រះពស្ត្រា មកទទូរហើយនាងផ្ទំ ។
ទៀនយាមភ្លឺព្រោងព្រាត ក្នុងប្រាសាទប្រសើរសម
នារីរ័តន៍ឧត្តម នាងនិទ្រាលក់សេយ្យាសន៍ ។
ក្សិណនោះព្រះរាជា ស្ដេចលីលាដើរយាងយាស
ទៅដល់គ្រៃទនមាស ទិព្វបន្ទំនាងនិមល ។
២៥៩— ស្ដេចបើកវាំងននណា ព្រះរាជាទតទៅយល់
នាងផ្ទំលក់សុខស្កល់ ពុំកម្រើកព្រះអង្គា ។
ស្ដែងស្ដេចខិតចូលជិត ព្រះអង្គឋិតខាងនាងណា
ព្រះឱស្ឋថ្លៃបរតា ថ្លាថ្លៃនូវពាក្យមេត្រី ។
ថាហៃប្អូនព្រលឹង មានបើខឹងអាក់អន់អ្វី
ប្អូនមាសមិនស្រដី មកទឹងបងដល់តិចឡើយ ។
ឬមួយប្អូនអផ្សុក ឬផ្ទំលក់ណានាងអើយ
បងមកដល់នេះហើយ ម្ដេចប្អូនមាសមិននាំពា ។
ស្ដេចបើកនូវព្រះពស្ត្រ ពីស្រីស្រស់អង្គនាងណា
ឯនាងនាថធ្វើជា ពុំរពុកព្រះស្មារតី ។
២៦០— ស្ដេចទតសព្វសពាង្គ រូបនៃនាងនាថនារី

សម្តេចព្រះភូមី　　សព្វព្រះទ័យទឹងនាងណាស់ ។
ស្តេចទ្រង់ព្រះចិន្តា　　គិតឯងថាបើអញជាស់
នាងរឭកឡើងច្បាស់　　ពុំបានគន់សព្វត្រើយ ។
ទើបព្រះអគ្គពណ៌នា　　អស់អគ្គាព្រះប្អូនស្រី
ព្រះឱស្ឋថ្លៃប្រិមប្រិយ　　ថ្លែងសរសើរព្រះប្អូនភ្ងា ។
២៦៣– ឥឡូវបងមកដល់　　បងបានយល់ប្អូនពុំងា
បងមានចិត្តស្នេហា　　ប្អូនពិសីយ៉ាងក្រៃលែង ។

## បទកាកគតិ

១២០– នេះបទកាកា-　　គតិទើបថា　　និទានតាមបង
ដំណើរអំពី-　　ពោធិជាក់ស្តែង　　បើកព្រះឱស្ឋថ្លែង
　　សរសើរស្ងួនភ្ងា ។
រៀមរះគិតគន់　　អស់អង្គប្អូនគន់　　សួស្តីសមសោភា
បងគន់គិតពី-　　កេសប្អូនភ្ងា　　ដូចស្លាបកមក
　　ខ្មៅធ្នារដុកជក(១) ។
រៀមរកស្នេហា　　គន់ព្រះសិរសា　　មាសមេរមិត្ត

---

១ ច្បាប់ខ្លះថា ខ្មៅភ្ញាញ់ជួបជិត ។

ហាក់ដូចពពិល ស្រស់ស្រិលពិចិត្រ មាសឆ្អិនខឹមខាត់
ព្រោងព្រាយរស្មី ។
កមោប្អូនគន់ ទ្រទេសទ្រទន់ ទ្រទួយសល់ស្រី
ចង្កួយកៅទណ្ឌា សុវណ្ណមណី ស្រស់ស្រេចឥតបី-
បើត្គងឡើយណា ។
បងគន់ព្រះស្រូល ក្រពុំមាត់មូល សួស្ដិ៍សមនេត្រា
ព្រះឱស្ឋស្រស់ស្រី ប្រិមប្រិយផិតស្លា ថ្ពាល់ដូចផលា
មាក់ប្រាងមាសម័យ ។
១២៥— ព្រះកេត្រប្អូនស្រី ដូចចន្ទបូណ៌មី វៃងចាំងឯញ-
មណ្ឌលអាកាស វេហាសនាយនៃ ភ្លឺខ្ញូចាំងផ្ទៃ-
ក្រោមក្រមភាព ។
បងគន់សូរង មូលម៉ដ្ឋឥតត្គង សួស្ដិ៍សមសោភា
ផ្នត់បីជាន់ជុំ ក្លៀវក្លុំថ្លៃថ្លា សមព្រះកេត្រា
ស្រៀវស្រស់ប្រពៃ ។
ឯអង្គស្នាគាង គាងគូសមពាង ពងរៀវល្មមល្មៃ
ចង្កេះក្លៀវក្លុំ សួស្ដិ៍សមណាស់នៃ អស់អង្គប្អូនថ្លៃ

ស្រស់ស្រេចសោភា ។

តាំងសង់សុដន់ ដោះនាងប្អូនគន់ បងនឹងឲបមា
ដូចផ្លែឲទាប់ មាសផ្កាប់នៅនា- ទ្រូងទ្រង់ឲព
ទួននាងប្អូនស្រី ។

ប្អូនល្អឥតគ្គង ត្រូវនឹងភ្នែកបង គ្រប់បញ្ចេន្ទ្រិយ
មានតែប្អូនហោង កន្ទង់លែងស្រី ទូទាំងលោកិយ
ជម្ពូទ្វីបណា ។

១៣០— សម្តេចភូមី សរសើរប្អូនស្រី នូវពាក្យស្នេហា
សព្វសព្វាង្គស្រេច សម្តេចរាជា យកព្រះហត្ថា
ស្ទាបព្រះភក្ត្រ ។

រួចដល់សុដន់ ទើបព្រះប្អូនគន់ នាងធ្វើជាភ្ញាក់
ស្ទើរយល់សប្បាយ ពាយមាយពុំជាក់ ប្រែប្រាណហើយអ្នក
នាងផ្ងុំទៀតទៅ ។

ស្តេចយល់ប្អូនមាស ផ្តល់សេយ្យាសន៍ ទើបព្រះចមទៅ
ថើបថែព្រះភក្ត្រ ថ្ពាល់អ្នកប្អូនពៅ ថ្នមដាក់លើភ្លៅ
អង្រួលឲព ។

នាងធ្វើជាភ្ញាក់ ដឹងស្មារតីជាក់ ស្ទុះចេញម្នីម្នា
នាងធ្វើជាខឹង ខ្វល់នឹងកជា នាងនាថបរោហ
ហាក់មិនមេត្រី ។

ជាអង្គីកល អញមិនដែលយល់ ដូច្នេះទេវី
ប្រុសម្ដេចចិត្តធំ យល់ពុំដូក្តី មកទាំងរាត្រី
នឹងដេកពុំបាន ។

១៣៥— អញ្ជើញស្ដេចទៅ ស្រុកទេសលំនៅ នគរក្សត្រក្សាន្ត
កុំបីព្រះអង្គ ផ្សរផ្សងទៅស្ថាន នេះនាំរំខាន
ពុំបានទេណា៎(១) ។

## បទព្រហ្មគីតិ

២៦៤— ក្សិណានោះព្រះភូមី ស្ដាប់ប្អូនស្រីហើយស្ដេចទ្រង់-
ចិន្តាថានាងចង់ ដឹងចិត្តអញឥឡូវណា៎ ។
ស្ដេចត្រាស់ស្នងវិលវឹង ថាព្រលឹងមាសស្នេហា
កុំអាលពៅពុំផា ខឹងនឹងបងណា៎នាងអើយ ។

---

១ តាមច្បាប់ខ្លះថា អញ្ជើញស្ដេចទៅ ស្រុកទេសលំនៅ នគរក្សត្រក្សាន្ត
ព្រះអង្គចេញទៅ កុំនៅរំខាន នៅនេះពុំបាន
ទេណា៎ព្រះអង្គ ។

ចូរប្អូនមាសស្ដែងស្ដាប់ បងនឹងប្រាប់ពីដើមឡើយ
ឲ្យប្អូនមាសត្រាណត្រើយ ដឹងដោយដំណើរបងមក ៗ
កាលបងនៅនាយណា+ ព្រះបិតាអ្នកឲ្យយក
អស់បុត្រីពន្ទក ស្ដេចមួយរយនិងមួយណា+ ៗ
សឹងមានរូបពិសី ហាក់ដូចស្រីទេពសួគ៌ា
នឹងឲ្យជាពនិតា បងពុំយកដល់មួយឡើយ ៗ
បងឮនាមប្អូនពៅ ល្បីឮទៅដល់បងហើយ
ព្រលឹងមាសបងអើយ បងជាទុក្ខពីថ្ងៃនោះ ៗ
២៧០— បងអត់តាំងអាហារ ពីថ្ងៃកាលបងឮឈ្មោះ
ប្អូនទៅដល់បងនោះ បងជាទុក្ខពន់ពេកក្រៃ ៗ
ផ្អកផ្អើះទង្គឹះចិត្ត ពុំភ្លេចគិតដល់មួយថ្ងៃ
ជីវិតបងស្មើរក្ស័យ ត្បិតបងឮឈ្មោះប្អូនគន់ ៗ
ពីព្រះអង្គក្សត្រថ្ងៃ ព្រួយព្រះទ័យជាទុក្ខធ្ងន់
ទើបស្ដេចឲ្យផ្ញើយន្ត- ហង្សមាសម័យមួយឲ្យបង ៗ
បងបានហង្សយន្តនោះ បងកើចហោះមកអាយហោង
រកប្អូនសួនស្នេហ៍ស្នង ឲ្យបានដូចចិត្តចិន្តា ៗ

ឥឡូវបងមកដល់ ប្អូននិមិលមាសពុំផា
ម្តេចឡើយនាងមកថា ឲ្យបងវិលទៅវិញហោង ។
២៧៩— គួរតែប្អូនស្នេហ៍ស្និទ្ធ នាងអាណិអាសូរបង
អាសូរត្បិតបំណង ស្វះស្វែងមករកប្អូនពៅ ។
គួរតែប្អូនស្រីស្រួល ព្រមទទួលយកបងនៅ
ជាប្តីនាងប្អូនពៅ សឹងអម្បូរស្តេចដូចគ្នា ។
បើប្អូនអាសូរបង កាលនេះម្តងដូចប្រាថ្នា
គុណប្អូនមាសស្នេហា ធ្ងន់អនេកពេកក្តាត់ហោង ។
បងដូចកលពស់ខាំ ប្អូនជាថ្នាំលាយលាបបង
ស្រាកស្រាន្តជម្ងឺផង មានប្រការនោះម្តេចមិញ ។
បងនឹងសងគុណធ្ងន់ នាងស្រីតន់ប្អូនសម្លាញ់
ឲ្យថេរបើតធួនវិញ ដូចនាងមានគុណនឹងបង ។
២៨០— នាងស្តាប់ព្រះឱង្ការ ហើយនាងនាថទូលរឹងស្នង
ខ្ញុំអរព្រះអង្គហោង សង្វាតមកត្បិតតែខ្ញុំ ។
ខ្លួនប្អូនដូចព្រឹក្សា ទ្រង់ផលាបរិបូណ៌ពុំ
មានម្ចាស់រក្សាសម ស្តេចនឹងបេះឯងពុំបាន ។

បើទ្រង់សព្វព្រះទ័យ សូមម្ចាស់ថ្លៃទ្រង់ទៅថ្កាន
ក្រាបទូលមហាក្សត្រក្សាន្ត ជាព្រះបិតាមាតា ។
បើពីរអង្គក្សត្រថ្លៃ សព្វព្រះទ័យទ្រង់ករុណា
ខ្លួនប្អូនឥតបើថា ពុំប្រកែកប្រកួតឡើយ ។
ស្ដេចឆ្លើយស្នងវិញថា ហៃប្អូនភ្ញាមាសបងអើយ
កុំថាដូច្នោះឡើយ ហាក់ស្ដែងឆ្លើសឆ្កាគល ។
២៨៤– ខ្លួនប្អូនឯងដូចផ្កា ចន្ទន៍ក្រស្នាវិសេសសល់
ដើមដុះឥតគេយល់ ពិដោរតែក្លិនល្ហងល្ហើយ ។
បើបងបានក្លិនផ្កា ស្រេចហើយណាមាសបងអើយ
ឯដើមពុំក្រឡើយ បងគង់រកឃើញណាពៅ ។
បើឃើញទាំងពីរនាក់ បានរួមក្សេមូលលំនៅ
សមបងនឹងប្អូនពៅ ឃើញត្រិះរិះគិតផងគ្នា ។
គង់នេះទុកអោយបង បងនៅរង់ ៗ ណានា
លែងតែពៅពុំងា នាងចូលចិត្តព្រមនឹងបង ។
ទើបនាងសងស្ងៃ ថាគាប់ចៃព្រះអង្គហោង
យកខ្លួនណានារង អស់ប្រការទាំងនេះណា ។

២៩០– គឺមោះខ្ញុំមិនល្មោយ ខ្ញុំមិនដោយព្រះពជា
ពាក្យប្រុសវែងមាយា កុំសត្យាទៀងដល់ម្ដង ។
ខ្លួនប្អូនដូចព្រឹក្សា មានសាខាជាបង្គង់
ព្រះអង្គដូចឃ្មុំផង ទំផ្ញើសំហើយហើរទៅ ។
ឯឈើមិញឥតការ បង់អសារទំនេរនៅ
ប្រដូចខ្លួនប្អូនពៅ ជាមេម៉ាយឯងកំព្រា ។
កុំព្រះអង្គបំពោត កុំបញ្ឆោតខ្ញុំប្ចុះណា
កុំបីស្ដេចសង្កា ក្រែងប្អូនល្មោយដោយព្រះអង្គ ។
ខ្លួនប្អូនដូចសាលា ព្រះពជាចតសប្បាយ
ស្រេចហើយទៅបានឆ្ងាយ សាលាសោតរសោរសោះ ។

២៩៥– ស្ដេចឆ្លើយស្នងវិញថា ប្អូនឧបមាពាក្យពីរោះ
ឯបងមិនដូច្នោះ កុំប្អូនមាសមានសង្កា ។
ខ្លួនប្អូនដូចជលស័យ បងសោតនៃដូចមច្ឆា
អាស្រ័យព្រះគង្គា ដរាបលុះអស់ជីវី ។
ខ្លួនប្អូនដូចគុហា បងសោតណាដូចរាជសីហ៍
អាស្រ័យជាប្រក្រតី ពឹងពំនាក់នៅគុហា ។

ខ្លួនប្អូនដូចប្រឹថពី　　បងសោកនៃដូចព្រឹក្សា
ផ្ញើដើមផ្ញើឫសណ៉ា　　ពំនាក់នៅព្រះធរណី ។
ម្ល៉េះហើយទីងផ្ញើខ្លួន-　　បងលើទួនទាងប្អូនស្រី
លង់លុះអស់ជីវី　　តាមតែប្អូនអាសូរបង ។
៣០០– ម្ល៉េះបងមិនទើងទៅ　　បងទីងនៅនេះជាម្ដង
ពោះប្អូនបណ្ដេញបង　　បងមិនស្ដាប់ពាក្យប្អូនឡើយ ។
នាងស្ដាប់ព្រះរាជា　　នាងធីតាទូលថ្លាស់ថ្លើយ
បពិត្រព្រះត្រាណាត្រើយ　　កុំបន្ទូលដូច្នោះណ៉ា ។
សូមទានព្រះភូមី　　ស្ដេចប្រណីទ្រង់ខ្ញុំភ៉ា
អាសូរខ្ញោសប្អូនភ្ជា　　ស្រីក្រមុំពុំខ្សាកខ្សាយ ។
ជ្រាបដល់ព្រះបិតា　　ទ្រង់ក្រោធមែនមិនងាយ
ទោសខ្ញុំមរណកាយ　　សមស្លាប់ឯងពុំខានឡើយ ។
ឯអង្គព្រះចមពៅ　　យាត្រាទៅបាត់ព្រៃដើយ
ឯខ្លួនប្អូនអ្នកអើយ　　សមនេងទុក្ខឯក្រោយក្រៃ ។
៣០៥– ខ្លួនប្អូនដូចនាគ　　ព្រះរាជាដូចផលស័យ
ឯព្រះអង្គសោកនៃ　　ស្ដេចគន់លើនាគហើយ ។

បើទូកលង់លិចទៅ　　សមព្រះចៅហែលដល់ត្រើយ
ប៉ាំងដៃមើលព្រងើយ　　ទូកមិញលង់លិចអសារ ៗ
ស្ដេចឆ្លើយស្នងថាហៃ　　នាងប្អូនថ្លៃមាសត្រកាល
កុំប្អូនមាសសង្សារ　　មានសង្កាទឹងបងឡើយ ៗ
ក្រែងបងបង់ហោលហៅ　　ឲ្យនាងនៅឯងឥតត្រើយ
ព្រលឹងមាសបងអើយ　　បងទឹងនាងវេះម្ដេចបាន ៗ
ហេតុត្បិតបងស្នេហា　　ប្អូនណាស់ណា៏ពន់ប្រមាណ
ទើបបងបោះបង់ឋាន　　សង្វាតមកឲ្យបានដល់ ៗ
៣១០— ចិត្តបងស្រឡាញ់ហៅ　　ដូចសំពៅស្រឡាញ់ខ្យល់
ស្លាប់រស់ក៏តាមកល　　បងពុំគិតស្ដាយអាត្មា ៗ
ខ្លួនបងដូចស្ដេចគ្រុឌ　　ប្អូនប្រាកដដូចនាគា
បានដៃគ្រុឌហើយណា៏　　ពុំដែលលែងនាគនោះហោង ៗ
អង្គបងដូចខ្លួនខ្លែង　　នាងប្អូនឯងដូចមាន់ផង
ខ្លែងឆាបបានហើយហោង　　ពុំដែលបង់ហោលម្យៀតសល់ ៗ
ខ្លួនបងដូចកលឆ្នា　　ខ្លួនប្អូនភ្លាដូចកណ្ដុរ
កាលបើបានគាប់កល　　ក្នុងមាត់ឆ្នានោះមែនមិញ ៗ

ឯផ្កាពុំដែលខ្ពើម ពុំដែលផ្អើមទឹងលែងចេញ
ប្អូនអើយឯអង្គអញ បងឧបមាដូច្នោះហោង ។
៣១៩– សូមប្អូនមាសបណ្តូល នាងអាសូរប្រណីបង
ឲ្យដូចក្តីបំណង ណា៎ព្រលឹងមាសបងអើយ ។
ត្បិតបងកំព្រាសល់ ឥតឯយល់អ្នកណាឡើយ
មានតែប្អូនឯងហើយ សូមប្អូនមាសមេប្រណី ។
កាលបងនៅស្រុកឆ្ងាយ មានអ្នកម្តាយអ្លួនបេតី
មកអាយមានប្អូនស្រី បងទឹងផ្ញើខ្លួនលើហៅ ។
ពោះបើបងគាប់ខុស បងស្លាប់ស់លើប្អូនពៅ
ត្បិតបងស្រឡាញ់ពៅ ស្មើខ្លួនមួយរួមជីវ៉ា ។
ចុះបើបងលេបបាន ដោយចិត្តឃ្លានដូចចំណី
បងទឹងលេបប្អូនស្រី សោះប្អូនមាសមានសង្ស័យ ។
៣២០– នាងស្តាប់ព្រះភូមី នាងនារីពេញព្រះទ័យ
ទើបនាងសងសូមៃ ថាគាប់ចៃព្រះភជា ។
ចេះបទូលតីពេះ តែពុងពោះពុំដូចថា
ឯអង្គប្អូនទេះណា៎ មិនស្រើបស្រាលដោយព្រះអង្គ ។

ពាក្យប្រុសវែងស្រែស្រាយ　អភិប្រាយលួងលោមចង់
បានហើយហោលបោះបង់　ឲ្យតែស្រីអសារសល់ ។
ប្អូនគិតប្អូនជញ្ជឹង　ប្អូនរំពឹងគិតហើយយល់
ចំណោរទៅទឹងទល់-　ខ្ញុំម្នាក់ឯងឈឺផ្សាក្រៃ ។
កុំព្រះអង្គចាប់ខ្ញុំ　ខ្ញុំពុំដោយក្សត្រថ្លៃ
អញ្ជើញទៅគ្រងផ្ទៃ-　ក្រោមព្រះអង្គឯនាយណា៎ ។

៣២៥— ក្សិណនោះព្រះចមចក្រ　ធ្វើជាអាក់ក្អក់ចិន្តា
ភ្នាសនាងវរជាយា　បន្ទូលហាក់ពុំមេត្រី ។
ខអញអង្គឹកល　អស្ចារ្យសល់ពុំជួក្តី
ស្រឡាញ់តែរូបស្រី　ពុំគិតកេរ្តិ៍គេនិន្ទា ។
គេខឹងគេបណ្តេញ　មិនស្រឡាញ់ខ្លួនឡើយណា៎
គិតគាប់គួរយាត្រា　ក្រឡាប់ទៅក្ដូវគាប់ក្រៃ ។
ស្តេចខិតចូលជិតខាង　ជិតដល់នាងនាថថ្លៃ
ទើបស្តេចត្រាស់ថាហៃ　ប្អូនព្រលឹងមាសស្នេហា ។
បងទឹងសូមថើបទៅ　បងទឹងទៅឥឡូវណា៎
សោះតែស្រណោះគ្នា　ឥតបុកណាទឹងគ្នាហើយ ។

៣៣០- ស្ដេចកៀកព្រះស្ងួន    រំពេចផងពុំលង់ឡើយ
ឯនាងនាថខ្មាសហើយ    ផាត់ព្រះហស្ដចេញវិញណា៎ ។
ស្ដេចថាហៃប្អូនគន់    កុំទុជិនខឹងបងភ៏
ដៃជិតប៉ុណ្ណេះណា៎    តើខឹងក្ដៅក្រហាយអ្វី ។
នាងស្ដាប់ព្រះវៀមហើយ    នាងពុំឆ្លើយស្នងភទ៏
នាងខ្មាសព្រះភូមី    ខុនសញ្ឈប់ពុំចរចា ។
ព្រះអង្គថាហៃពៅ    បងខឹងទៅឥឡូវណា៎
សំណឹកប្អូនពុំងា    មិនអាសូរបងដល់តិច ។
បងលាប្អូនទៅហោង    ខឹងទៅគ្រងបុត្រីស្ដេច
សឹងមានរូបស្រស់ស្រេច    ចាំងរយឯកអង្គនារី ។
៣៣៥—អង្គបងអក័ត្វហើយ    មាសបងអើយខឹងទៅថ្វី
នៅនេះខ្មាសប្អូនស្រី    សូវបងទៅគួរគាប់ក្រៃ ។
ខ្លួនបងឥតទ្រព្យា    អ្វីនុជាជូនប្អូនថ្លៃ
មានតែពាក្យនេះនៃ    បងផ្ដែផ្ដាំព្រះប្អូនស្រី ។
ចាប់ពីថ្ងៃនេះទៅ    កុំប្អូនពៅមាសមានប្ដី
ស្ងួនបួសជានាងជី    នោះប្រសើរពេកក្ដាត់ណា៎ ។

អម្បាលបងជាក្សត្រ ក៏ប្អូនរ័ត្នមិនស្នេហា
ហើយប្អូនរកអ្នកណា ឲ្យគាប់គួរនឹងប្អូនស្រី ។
បងនឹងលាប្អូនទៅ សូមនាងនៅឯកឥន្ទ្រិយ
សោះព្រួយចិត្តប្អូនស្រី នាងកុំឆ្ងន់បទតៃបង ។
៣៨០— ប្អូននៅឯងឯកាយ ឲ្យសប្បាយចិត្តចៅហោង
កុំមាសមេគិតបង បងមិនបានមកវិញឡើយ ។
នៅណា៎នាងប្អូនណា៎ បងនឹងលាប្អូនទៅហើយ
ក្សិណនោះព្រះត្រាណត្រើយ ស្តេចដោះឡើងយានយាត្រា ។
ឯនាងនាថនិមិល នាងទតយល់ព្រះពជា
ស្តេចចរចាកនាងណា៎ នាងចាប់ជាយព្រះពស្ត្រថ្លៃ ។
រីឯព្រះពជា ផ្ទៀងនេត្រាគន់រំពៃ
ទតយល់ប្អូនមាសថ្លៃ ចាប់ព្រះពស្ត្រព្រះពជា ។
ក្សិណស្តេចធ្វើជាភ្ញាក់ ប្រែព្រះភក្ត្រមកមីមា
ទតយល់នាងធីតា ចាប់ព្រះពស្ត្រជូប្អោះហោង ។
៣៨៥— ទើបស្តេចបន្ទូលថា ហៃប្អូនភ្ញាមាសស្នេហ៍ស្នង
ប្អូនខឹងប្អូនស្អប់បង នាងបណ្តេញឲ្យបងទៅ ។

ឥឡូវនេះគេមាន　　　បើខុសខានពាក្យអ្វីទៅ
កាលបងលាប្អូនទៅ　　　កុំស្ងួនស្ងៀមពុំស្រដី ។
ឥឡូវស្រាប់តែមក　　　កើចអូសយកសំពត់ពី
បង្កែះបងវិញខ្ញី　　　នាងអាសូរបងសិទក៏ ។
សំពត់នេះថ្លៃខ្ពស់　　　ដែលព្រះហស្តព្រះមាតា
អ្នកត្បាញឲ្យបងណា៎　　　កុំឲ្យបាត់ណា៎នាងអើយ(១) ។
នាងស្តាប់ព្រះពជា　　　វរជាយាឥតចម្លើយ
នាងខ្មាសព្រះត្រាណត្រើយ　　　ក្សាយបង្គំព្រះពជា ។
៣៩០— ក្សិណានោះព្រះភូមី　　　យល់ប្អូនស្រីវរវន្ទា
ស្តេចគង់ចុះម្នីម្នា　　　ប្នីផ្នាក់ផ្នមព្រះប្អូនស្រី ។
ដាក់លើទពារ័ត្ន　　　ពីរអង្គក្សត្រស្រមេត្រី
ទើបនាងនាថទេវី　　　បង្គំទូលព្រះពជា ។
បពិត្រសូមព្រះអង្គ　　　បន្ទោបង់លែងក្រោធា
អាសូរខ្លួនប្អូនជា-　　　ខ្ញុំបាទាព្រះបាទបង ។
ក្សត្រីទូវក្សត្រា　　　ស្និទ្ធស្នេហាឥតឯហ្មង
ពីរពង្សព្រះអង្គហោង　　　រួមបន្ទំសុខសួស្តី ។

---

១ ប្រាប់ខ្លះថា នាងកុំអួសណាប្អូនអើយ ។

ស្ដេចលោមវរជាយា កដធីតាអគ្គមហេសី
ប្អូនអើយបងមកផ- ឡូវនេះលង់យូរហើយណា៎ ។
៣៥៩– បងចង់បបួលទៅ ក្រឡាប់ទៅឋានគាក
ស្រុកបងឯនាយណា៎ ចូរប្អូនទៅទៅទីបង ។
នាងស្ដាប់ព្រះឱង្ការ ទើបនាងនាថទូលវិញស្នង
បពិត្រខ្ញុំនេះហោង មានព្រះអង្គជាអម្ចាស់ ។
គឺមោះព្រះមាតា ទូវបិតាមានគុណណាស់
សោគសឹងផកចាស់ តាមតែទ្រង់ព្រះករុណា ។
ស្ដេចស្ដាប់នាងនាថទូល ទ្រង់អាសូរវរជាយា
ក្សត្រីទូវក្សត្រា ផ្ដុំក្រសាលព្រះហឫទ័យ ។
លុះមាន់រងាវណា៎ ស្ដេចលោមលាប្អូនស្រីថ្លៃ
មាសអើយឥឡូវនៃ រៀបទឹងព្រឹកហើយណា៎ទៅ ។
៣៦០– នុប្អូនមាសស្នេហា ឥឡូវណា៎ចូរនាងនៅ
បងនឹងលាប្អូនទៅ យប់បងនឹងវិលវិញណា៎ ។
សម្ដេចព្រះភូមី ថ្នមប្អូនស្រីរ័ត្នពុំផា
មហេសីស្ងួនសោភា ដាក់លើព្រះឧរារ័ត្ន ។

ស្ដេចថើបព្រះកន្ត្រា ព្រះរាជាផ្ដែផ្ដាំផ្ដិត
ស្រេចហើយស្ដេចឡើងបិត លើហង្សយន្តកើតហៀរហោះ ។
លុះដល់ដើមព្រឹក្សា ព្រះរាជាចងយន្តនោះ
ហើយព្រះចៅចរចុះ លីលាទៅផ្ទះព្រាហ្មណា ។
ព្រាហ្មណ៍យល់ព្រះភូមី ព្រាហ្មណ៍ព្រឹទ្ធសោមនស្សា
ស្រឡាញ់ព្រះរាជា ស្មើកលកូនបង្កើតនៃ ។
៣៦៥— ហើយស្ដេចតែងឡើងទៅ គាល់ព្រះចៅចមក្សត្រថ្ងៃ
ប្រក្រតីសព្វ ៗ ថ្ងៃ ពុំដែលដាច់ទិនមួយណា ។
លុះជួបចូលរាត្រី ព្រះភូមីទៅនិទ្រា
ទឹងនាងនាថជាយា ជាប្រក្រតីដូចសព្វដង ។
ស្ដេចនៅលង់ទៅណា៎ នាងធីតាទ្រង់គភ៌ផង
ទសមាសាហើយហោង ទឹងប្រសូតរាជបុត្រា ។
ពុំលង់ឡើយជ្រាបទៅ ដល់ព្រះចៅព្រះបិតា
ក្សិណនោះព្រះរាជា ឲ្យអញ្ជើញបុត្រីរ័តន៍ ។
ទើបនាងនាថនារី ចុះចាកទីប្រាសាទថ្វាត់

ទៅគាល់ពីរពង្សក្សត្រ    ព្រះបិតានូវមាតា ។

៣៧០— ឯព្រះបិតាគន់    យល់សុជន់នាងទៅណា

ស្ដេចជ្រាបជឿជាក់ជា    រាជបុត្រីនាងទ្រង់គភ៌ ។

ស្ដេចក្រោធក្រៃប្រាកដ    ហើយខំអត់ធ្វើក្រសាល

ហាក់ហ៊ាជាពុំខ្វល់    ស្ដេចពុំឲ្យនាងដឹងឡើយ ។

ក្សិណនោះនាងទេវី    លាជនទីជនកហើយ

ទើបនាងនាថត្រាណត្រើយ    វិលទៅស្ថានប្រាសាទណា ។

## បទពំនោល

៩២-កាលនោះព្រះចៅបញ្ចាល៍ ជ្រាបដូច្នោះណា ស្ដេចខ្វល់ពន្លឹកពេកក្រៃ ។

ហាក់ដូចអគ្គីវិស័យ    ឆេះក្នុងព្រះទ័យ    រន្ធត់បំប្រប់អង្គា ។

ទើបទ្រង់ព្រះចិន្ដាថា    កូនអញនេះណា    មិនគឹទឹងអ្នកដទៃ ។

៩៤-សមទឹងកូនព្រាហ្មណ៍នោះនៃ មានរូបប្រពៃ ប្រសើរលើសលែងអ្នកផង ។

បើច្នោះគួរអញទឹងលង យកចំណោះល្បង ល្បងចាប់ឲ្យបានហោងណា ។

ទើបស្ដេចយកគ្រឿងមាលា ចូងចន្ទន៍ក្រស្នា ហើយលាយទឹងជាតិហិង្គុះ ។

មានរសពិរោះសោតសល់ ផ្ដុំទាំងមណ្ឌល សឹងក្លិនត្រឡប់ល្វើងល្វើយ ។

ដាក់ក្នុងប្រអប់មាសហើយ ទើបក្សត្រត្រាណត្រើយ ត្រាស់ប្រើសាវផៃមួយណា ។

ឲ្យយកទៅថ្វាយធីតា សាវវៃឧម្មា ទទួលប្រអប់មាសម័យ ។
យកពីព្រះហស្តក្សត្រថ្ងៃ ចរចេញវៃ ៗ ទៅដល់ប្រាសាទនាងនាថ ។
យកប្រអប់មាសសោភា ថ្វាយរាជធីតា ទូលថាបពិតក្សត្រី ។
សម្តេចព្រះវរជននី ស្តែងស្តេចជាឥ- ស្សរប្រើខ្ញុំមកនេះណា ។
ឲ្យយកគ្រឿងព្រះមាលា ប្រសើរថ្ងៃថ្លា មកថ្វាយព្រះអង្គឯងនៃ ។
ព្រះរាជបុត្រីរ័តន៍ថ្ងៃ នាងស្តាប់សាវវៃ នាងក៏ទទួលយកហោង ។
សាវវៃក្រញួក្រាបពបរង វិលវឹងទៅផ្គង ក្រាបទូលព្រះវរបិតា ។
បពិត្រសម្តេចរាជា វររាជធីតា ក៏ថ្វាយបង្គំវន្ទិយ ។
មកព្រះនរនាថនរបតី ស្តែងស្តេចជាឥ- ស្សរអស់តាំងរាស្ត្រផងណា ។
ស្តេចបានជ្រាបស្រេចអស់អាថ៌ សម្តេចរាជា ស្តេចពេញព្រះរាជហឫទ័យ ។
លុះចូលរាត្រីនោះនៃ សម្តេចជៀស្លជ័យ ស្តេចចូលបន្ទំសុវណ្ណា ។
ឯពោធិសត្វសោភា ស្តេចទឹកជាយា ក៏ទ្រង់លីលាចរទៅ ។
ដល់ដើមឈើធំនិត្យនៅ ទើបព្រះចមហៅ ស្តេចឡើងធិលហង្សយន្តណា ។
ស្រេចហើយព្រះបាទក្សត្រា ស្រាយយទ្ធម្មា ស្តេចគង់ហង្សយន្តហោះធិល ។
ប្រាសាទប្រសើរសួស្តិ៍សល់ ហើយព្រះទសពល ស្តេចចុះពីហង្សយន្តណា ។
ទើបស្តេចយាងយាសយាត្រា ចូលទៅដល់នា- ក្រឡាបន្ទំក្សត្រី ។

ស្តេចគង់ខាងនាងប្អូនស្រី រួមរ័កមេត្រី សំណេះសំណាលចរចា ។
ទើបនាងយកគ្រឿងមាលា ដែលព្រះបិតា ស្តេចឲ្យមកនាងនោះនៃ ។
លាយលាបថ្វាយព្រះជៀស្នជ័យ ហេតុក្សត្រីថ្ងៃ ពុំដឹងជាគេឲ្យកល(១) ។
ស្រេចស្តេចផ្ទំលក់សុខសល់ លុះហៀបទឹងដល់ ពេលាព្រឹកព្រាងហើយណ៎(២)។
១២០-ស្រេចតើបព្រះបាទក្សត្រា ផ្ដែផ្ដាំជាយា ប្អូនអើយជិតព្រឹកហើយហោង។
បងនឹងលីលាទៅផ្គង ចាំយប់ឯងហោង បងមកកាន់ព្រះប្អូនស្រី ។
ស្តេចលោមនាងអគ្គមហេសី ស្រេចព្រះចក្រី ស្តេចថ្នមព្រះប្អូនស្នេហា ។
ថើបថៃអស់ព្រះអង្គា ស្រេចស្តេចលីលា ហើយស្តេចគង់យន្តមាសម័យ ។
ស្តេចកើចហង្សហោះវិលវៃ ផ្លេកផ្លោះប្រៀវប្រៃ កំដល់ចាប់ចុងព្រឹក្សា ។
១២៥-ស្តេចចង់ហង្សយន្តហើយណ៎ ស្តេចស្តែងលីលា ទៅដល់ផ្ទះព្រាហ្មណ៍ព្រឹទ្ធ ។
ព្រះអង្គយកព្រះពស្ត្រថ្មី មកទទូរតើ- ព្រះសិរដល់ព្រះបាទា ។

---

១-២ ច្បាប់ខ្ទះថា លាយលាបថ្វាយព្រះជៀស្នជ័យ ព្រះរៀមថ្វាថ្ងៃ ស្តេចទ្រង់ព្រះសុគន្ធា។
ស្តេចលាបលាយសព្វកាយា ប្ដូងចន្ទន៍ក្រស្នា កំប្រាលរន្ទាលផ្ទិតផ្ដៅ ។
លាបស្រេចគង់កៀកនែបនៅ លុះរាត្រីជ្រៅ ពុំដឹងជាគេឲ្យកល ។
ហើយស្តេចផ្ទំលក់សុខសល់ លុះហៀបនឹងដល់ ពេលាព្រឹកព្រាងហើយណ៎ ។
ខ្ទះទៀតថា នាងថ្វាយសម្តេចជៀស្នជ័យ ព្រះរៀមថ្វាថ្ងៃ ស្តេចទ្រង់ព្រះសុគន្ធា ។
ស្តេចលាបសាយសព្វកាយា ប្ដូងចន្ទន៍ក្រស្នា កំប្រាលរន្ទាលផ្ទិតផ្ដៅ ។
ស្តេចផ្ទំនឹងព្រះប្អូនពៅ ពីរាត្រីជ្រៅ លុះនឹងហៀបព្រឹកហើយណ៎ ។

ហើយផ្ទុំតែឯករង្គ លង់លក់ក្ដាត់ណា លុះព្រះអាទិត្យទ័យ ។
ពីទិសបូព៌ាប្រពៃ រៀងរះខ្ពស់ក្រៃ ព្រះអង្គពុំភ្ញាក់ឡើយណា ។
ក្សណនោះព្រះចៅបញ្ចាល ត្រឹនបាកទិទ្រា ស្ដេចចេញទៅគង់រោងរ័តន៍ ។
១៣០-មន្ត្រីគង់គាលច្រើនក្ដាត់ ទើបព្រះមហាក្សត្រ ត្រាស់ប្រើអាមាត្យមួយណា ។
ទៅហៅកូនព្រាហ្មណ៍ហោរ ក្សណនោះអមច្ចា ក្រាបលាសម្ដេចជៀសួដ៍យ ។
ខ្ញុំឃ្មាតសង្ខាតវៃៗ រូតរត់ឆាប់ក្រៃ ទៅដល់ផ្ទះព្រាហ្មណ៍ហោរ ។
ថ្លែងពីព្រះរាជអាជ្ញា ព្រាហ្មណ៍ប្រាជ្ញគិតថា កូនអញនេះមានហេតុអ្វី ។
ឲ្យហៅយល់អង្គគ្គី ទើបព្រាហ្មណ៍ត្រិទ្ធី ចរចូលទៅជាសបុត្រា ។
១៣៩-ព្រះអង្គតើនបាកនិទ្រា ព្រាហ្មណ៍យល់អង្គា សឹងប្រាលទោលផ្ទឹនផ្ទោ ។
ទើបព្រាហ្មណ៍ឲ្យព្រះចមទៅ ស្ដេចលីលាទៅ ស្រោចស្រង់ជម្រះអាត្មា ។
ព្រះអង្គស្រង់ព្រះគង្គា ជុសសព្វកាយា សូរចេចបរិបូណ៌ហើយនៃ ។
នៅកៀនខាងព្រះការណ៌ថ្ងៃ សម្ដេចជៀសួដ័យ ស្ដេចនុសពុំសព្វឡើយណា ។
ទើបស្ដេចទ្រង់ព្រះពស្ត្រា ស្រេចស្រាប់ម្ពុម្ពា រលះរលាំងទៅភ្ញាត់ ។
១៤០-លុះដល់មណ្ឌលរោងរ័តន៍ ថ្វាយបង្គំក្សត្រ ព្រះចៅបញ្ចាលនរបតី ។
ទើបស្ដេចត្រាស់ប្រើមន្ត្រី មើលសព្វឥន្ទ្រិយ ក្រែងមានជិតជាតិហិង្សិរ ។
អាមាត្យមើលព្រះទេសពល គន់សព្វសឹងយល់ បន្តិចខាងព្រះកាំហា ។

អាមាត្យក្រាបទូលរាជា  សម្តេចបេស្តា  ជ្រាបជាក់ក្នុងព្រះហឫទ័យ ។
ស្តេចទ្រង់ក្រោធពេកក្រៃ  បន្ទូលថាហៃ  រស់ទាំងពេជ្ឈឃាតកល់គ្នា ។
១៤៩-ស្រឡៀងធាប់ៗម្នីម្នា  ជុំហោមចាប់រា  កំណាចនេះចង់ឲ្យខ្ជាប់ ។
ហើយនាំចេញទៅឲ្យឆាប់  យកទៅសម្លាប់  ឥឡូវកុំយូរឡើយណា៎ ។
ពេជ្ឈឃាតក៏លោតម្នីម្នា  ហោមចាប់រាជា  បានហើយរុំចងខ្ជាប់ក្រៃ ។
ស្រេចហើយនាំចេញវៃ ៗ  ឆ្ពោះសំដៅព្រៃ  ប៉ុនប៉ងពិឃាតចំហុត ។
ឯសម្តេចពង្សត្រុ-  ទ្ធង្កុរបរិសុទ្ធ  បានលុះនាដៃពេជ្ឈឃាត ។
១៥០-ស្តេចសែនសោយសោកសល់ខ្លាត អាណិតអនាថតែព្រះអង្គឯងឯកោ។

## បទកាកគតិ

១៣៦— កាលនោះពោធិ-  សត្វសាងបារមី  វត្តមោ
ទៀងទល់ទុក្ខា  ឯកអនាថោ  ទូទ្ទូលោ
ថ្ងៃថ្មឹងពុំបាន ។
ព្រះឧស្សថ្លាថ្ងៃ  ទ្រង់ព្រះកន្សែង  ពិលាបប្រះប្រាណ
ថាឧអញអើយ  ម៉េះហើយពុំបាន  វិលវឹងទៅឋាន
មាតាបិតា ។
ឧអ្នកមានគុណ  គុណគាប់មហាធ្ងន់  ធ្ងន់ពេកក្តាត់ណា៎

ម្ល៉េះសមកូនក្សួយ ជីវិតជន្មា ឯកឯងអនា-
ថាសោះសូន្យសល់(១) ។
កូនមកស្រុកគេយ បង់អ្នកជាម្ដាយ កំព្រាទុពិល
មកស្លាប់អសោរ ឥតការឥតកល នៅនាមណ្ឌល
ដែនដីស្រុកអាយ ។
១៨០– ឱអញអភ័ព្វ ម្ដេចក៏មកស្លាប់ ស្លាប់បង់អ្នកម្ដាយ
បង់អ្នកអាពុក បង់ស្រុកឆ្ងាយ ត្បិតចិត្តពាយមាយ
ស្រើបដោយតណ្ហា(២) ។
មកស្វែងប្រពន្ធ បង់អ្នកមានគុណ ទាំងពីរអង្គា
មកដល់នគរ បវរបញ្ចាល៍ បានបុត្រក្សត្រា
ជាគូសម្ពន្ធ ។
ឱព្រេងអញអើយ ឥឡូវម្ដេចឡើយ មករង់ទុក្ខធ្ងន់
តែឯងគោកយ៉ាក លំបាកលើសលន់ គេធ្វើទឹងបុណ្យ
អំណាចណាស់នៃ ។
ឱអ្នកម្ដាយផ្ដាំ នោះមិញកូនចាំ ជាអចិន្ត្រៃយ៍

---
១ ច្បាប់ខ្លះថា ម្ល៉េះសមកូនក្សួយ នៅព្រៃព្រឹក្សា ឯកអង្គអាត្មា អសារសូន្យសល់។
២ ច្បាប់ខ្លះថា ឆ្កួតដោយតណ្ហា ។

ឥឡូវនេះណា+ វេរពៀរភ័យ មកផ្តល់នាថ្ងៃ
នេះឯងហោងណា+ ។

សមអ្នកទាំងពីរ តែងទតរមិល មើលផ្លូវបុត្រា
គិតស្មានកូនប្រុស រូបរស់សុខសា- បាយបានលីលា
ក្រឡប់វិលទៅ ។

១៨៩— មិនដឹងជាកូន ក្សីណក្ស័យសោះសូន្យ ប្រាសព្រះចមទៅ
ម៉្លេះព្រះបិតា មាតាអ្នកនៅ សង្រែងក្តាត់ក្តៅ
ទន្ទឹងបុត្របាត់ ។

នុះអនិច្ចា ខ្លួនអើយកំព្រា ត្រមោចព្រាកព្រាត់
មកស្លាប់អសារ កណ្តាលព្រៃស្ងាត់ ស្លាប់ម្តេចដូចសត្វ
ដោយដីច្នេះណា+ ។

បើម៉្លូទឹងស្លាប់ ឲ្យមានគំនាប់ នៅស្រុកតិចក៉ា
ព្រះជនកជននី ក្សត្រីក្សត្រា ប្រជាប់ប្រជា
លើកសពបុត្រថ្លៃ ។

ឥឡូវកូនស្លាប់ ឯកអង្គអភ័ព្វ កណ្តាលទ្រូងព្រៃ(១)

---

១ ច្បាប់ខ្លះថា ឥឡូវម្តេចស្លាប់ អសារឥតសព្វ កណ្តាលទ្រូងព្រៃ .... ។

កូនយកប្រឹថពី ផែនដីនេះនៃ ជាមឈូសមាសម័យ
និទ្រាទៅហោង ។

កូនយកអាកាស ជាពិតានមាស ផ្កាថ្ងៃកន្ទួង
លើកសពអាត្មា(១) កាលគ្រានេះម្តង តាមវេរាង
ចៀសពុំបានណា ។

១៩០— កូនទឹងយកព្រះ- សុរិយារឿងរះ ពីបូព៌ទិសា
អាស្រ័យរស្មី ជាភិរន្ទា លើកសពសំស្ការ
កូនកាលនេះនៃ ។

កូនយកព្រឹក្សា ជាពាំងននណា បិទបាំងប្រពៃ
កូនយកស័ត្វសត្វ ស្រដាក់ក្នុងព្រៃ កូនទឹងអាស្រ័យ
ទុកជាភ្លេងផង ។

ជាតូរ្យតន្ត្រី ប្រគំប្រក្រតី លើកសពកូនហោង
តាមកម្មវេរា កាលគ្រានោះម្តង គួរកូនទឹងរង
តាមវិបាកបាន ។

ឥតអ្នកណា ទឹងកាលយាត្រា វិលវឹងទៅថ្កាន
ទូលព្រះបិតា មាតាឲ្យបាន ជ្រាបថាកូនមាន-

១ ច្បាប់ខ្លះថា កូនយកអាកាស ជាពិតានមាស បិទបាំងកន្ទួង លើកសពសង្ការ .... ។

ទុក្ខទោសដល់ស្លាប់ ៗ

បានអ្នកទឹងមក ប្រយោជន៍ទឹងរក រៀបចំប្រដាប់

លើកសពកូនជា- បុត្រាធាប់ ៗ បរិបូណ៌ដោយច្បាប់

ដូចអស់ក្សត្រផង ៗ

១១៩- ឱអម្ចាស់ថ្លៃ ចាប់ដើមពីថ្ងៃ នេះឯងទៅហោង

ពុំបានយល់កូន សោះសូន្យជាមួង សមអ្នកទឹងវង

ទុក្ខទោមនស្ស ៗ

សម្តេចភូមី ថ្វាថ្ងៃងខ្ញុំពី- មាតាបិតា

អាណិតអនេក ពន់ពេកណាស់ណា៎ ហើយព្រះរាជា

ខ្ញុំទៅប្អូនស្រី ៗ

ទនាងបទុម- កេសរឧត្តម វររាជក្សត្រី

ម្ល៉េះសមបងបង់ ប្អូនសង្សារពី- ថ្ងៃនេះឯងឥ-

ឡូវណា៎ប្អូនអើយ ៗ

ឱមាសស្នេហ៍ស្និទ្ធ បងបានដូចចិត្ត ចិត្តចិន្តាហើយ

ល្គឹកអ្វីប្រែប្រាស ប្អូនមាសត្រាណាត្រើយ ព្រលឹងបងអើយ

បងប្រណីណា៎ ៗ

ខ្ញុំប្អូនបណ្ដាច់　　បណ្ដូលស្ងួតសាច់　　សាច់សង្វាក
ស្រីគន់តែមួយ　　ជាត្រួយទយា　　បងប៉ងយកជា
　　អយិអគ្គមហេសី ៗ

១៦០– ម្ដេចឡើយមកប្រាស　ព្រាត់ព្រលឹងមាស　នាគ្រានេះខ្ញុំ
ហេតុបាបបងឯង　　ពីព្រេងជាតិ　　តាមទាន់ឯងឥ-
　　ឡូវនេះហោងណា៎ ៗ

ខ្ញុំអញទឹងក្ស័យ　　ជីវិតប្រល័យ　　ប្រាសព្រះប្អូនភ្ងា
ខ្ញុំអាសូរហៅ　　នាងនៅកំព្រា　　សមនាងទឹងជា-
　　មេម៉ាយឯងហោង ៗ

បងមហាប្រណី　　អាសូរប្អូនស្រី　　ស្រគត់ឥតង្គ
សមហៅសោយសោក　អាមោក្យក្ដាត់ហោង　ចាំតែឈ្មោះបង
　　ខ្លួនមិញមិនយល់ ៗ

ខ្ញុំយើងទាំងពីរ　　ធ្លាប់រែងបិតថេរ　　មូលមួយមណ្ឌល
ស្រឡាញ់ស្នេហ៍ស្និទ្ធ　អស់ចិត្តឥតកល　　បាបអ្វីមកផ្ដល់
　　ឲ្យបងបង់មេ ៗ

ខ្ញុំអគ្គប្អូនមាស　　បើម៉្វីទឹងប្រាស　　លែងបានផ្ដាំផ្ដែ

ប្រាសម្តេចសោះសូន្យ បង់ប្អូនមាសស្នេហ៍ ពុំបានផ្តាំមេ
មកមរណ៍អសារ ។

១៦៥– បងគិតទៅគ្រប់ សព្វហើយវែងថប់ ថប់បីប្រការ
ថប់មួយត្បិតប្រាស ប្អូនមាសត្រកាល អាសូរអសារ
នៅឯងកំព្រា ។

បងថប់មួយក្តី គិតព្រះជននី ជនកជក
ចាស់ហើយវែងប្រាស និរាសបុត្រា សមអ្នកទឹងជា-
ទុក្ខឯងធ្ងន់ក្រៃ ។

ថប់មួយសោតហោង រីឯអង្គបង នេះហោងទឹងក្ស័យ
ជីវិតប្រែប្រាស ប្អូនមាសថ្ងើមថ្ងៃ ប្រាកដនាថ្ងៃ
នេះឯងហោងណា ។

ស្តេចទ្រង់ព្រះក- ន្សែងសោកស្រីគន់ វរវង្សសោកា
អាណិតអនាថ សល់ខ្នាតសោកា ជោរជលនេត្រា
ពុំស្បើយឡើយហោង ។

ក្សិណនោះក្សត្រី វររាជទេវី អនុជស្នេហ៍ស្នង
នាងព្ទុបិតា ក្រោធាកន្ទង ព្រះអង្គខ្ញាល់ផង

ទឹងរៀមកជា ៗ

១៧០— ព្រះអង្គឲ្យចាប់ យកទៅសម្លាប់ បំបាត់ជន្មា
នាងព្រួស្វាមី ត្រូវក្តីហើយណា៎ នាងសោយសោកា
ពន់ពិលាបលន់ ៗ

នាងយកព្រះករ ទាំងពីរគក់គ ខុភស្រីគន់
ហាក់ហៀបទឹងក្ស័យ ប្រល័យជីពជន្ម នាងទ្រង់ព្រះក-
ន្សែងសោកខ្សួញថា ៗ

ឱអម្ចាស់ថ្លៃ បើព្រះអង្គក្ស័យ ខ្ញុំសូមមរណា
ស្លាប់ផងដៀវស្ពដ័យ នាថ្ងៃនេះណា៎ ព្រមព្រះភជា
ស្មើឯកជីវី ៗ

នាងខ្សួញបណ្តើរ ស្រីរ័តន៍ប្រសើរ លីលាចុះពី-
ប្រាសាទមកដល់ មណ្ឌលជនទី ទើបនាងទេវី
ទូលព្រះមាតា ៗ

បពិត្រព្រះមេ ជាមកុដសិរ គុណគម្ពីភ
សូមមានព្រះអង្គ ស្តេចទ្រង់ករុណា អាសូរខ្ញុំជា-
កូនកាលនេះម្តង ៗ

១៧៤— ឥឡូវកូនស្ងួន  កើតទុក្ខកង្វួន  ធ្ងន់ក្រៃកន្លង
ត្បិតព្រះបិតា  ក្រោធាខ្ញាល់ផង  ទឹងប្តីខ្ញុំហោង
ពន្ទឹកមហិមា ៗ

សូមអ្នកមេទៅ  ទូលទាស់ព្រះចៅ  ព្រះវរបិតា
ទូលសូមជីវិត  ស្វាមីខ្ញុំណា៎  កុំឲ្យពជា
ពិឃាតបង់បាត់ ៗ

ត្បិតបុត្រព្រលឹង  បានជាខុសទឹង-  ប្រុសមានរូបរ័តន៍
បើព្រះបិតា  ក្រោធាពេកក្តាត់  មិនអាសូរសត្វ
ដល់តិចឡើយណា៎ ៗ

សូម្បីខ្ញុំក្ស័យ(១)  ជីវិតប្រល័យ  មូលហ៊ានផងគ្នា
សឹមទៅយកប្តី  ស្វាមីស្នេហា  រួមហ៊ាននៅនា-
ស្រុកខ្មោចនោះនៃ ៗ

ព្រះមាតាស្តាប់  បុត្រទួញទូលប្រាប់  ជ្រាបក្នុងហឫទ័យ
អាសូរបុត្រី  ប្រិមប្រិយពេកក្រៃ  បន្ទូលថាហៃ

---

១ គួរថា សមខ្ញុំនឹងក្ស័យ ...... ។

កូនស្ងួនពុំងា(១) ។

១៨០– កុំទល់ទុក្ខឡើយ ព្រលឹងម្ដាយអើយ ម្ដាយនឹងជានា
ទៅទូលអង្វរ ព្រះវរបិតា ឲ្យនាងកាលត្រា
ឥឡូវកូនអើយ ។
ទើបនាងនាថទៅ ទូលទាស់ព្រះចៅ ពិតពុំលង់ឡើយ
បពិត្រព្រះមហា- ក្សត្រាត្រាណត្រើយ សូមស្ដេចលំហើយ
លំហៃក្រោធា ។
អាសូរកូនស្ងួន ពន្ធកខ្ញីមខ្ញួន ឥឡូវនេះវា
បានជាអាល័យ នឹងក្ស័យផងគ្នា សូមស្ដេចករុណា
អត់ទោសទៅហោង ។
មិនតែកូនយើង នេះទេបើង ក្រៅច្បាប់គន្លង
និយាយបុរាណ សឹងមានច្បះហោង សូមទានកុំចង
ព្រះទ័យក្រោធា ។

---

១ ច្បាប់ខ្លះថា ព្រះមាតាស្ដាប់ បុត្រីទូញប្រាប់ អម្បាលនោះនៃ
ស្រយុតទយា បន្ទូលថាហៃ ឱភ្ញាប្រិយថ្លៃ
កូនស្ងួនពុំងា ។

ក្សិណានោះកូមី ស្តាប់ពជទៅ ទូលដូច្នោះណា៎

ស្តេចទ្រង់ព្រះក្រោធ ពិរោធមហិមា បន្ទូលត្រាស់ថា

មិនកុំធ្វើច្នេះ ។

១៨៤ — កូនកាចឥតខ្មាស ឲ្យអាស្រូវកាស មុខអញទាំងម្ល៉េះ

ត្បិតគំនិតហាន សមផងវានេះ ខ្សឹបខ្សៀវចញ្ចោះ

លាក់លៀមទៅមក ។

បើវាចង់ស្លាប់ អញសោកពុំរប់ ទុកស្មើឈាមកក

បង់ម្សៀតដោយដី កុំបើមិនមក ស្រដីរះរក

អន្ទូរអញឡើយ ។

ឯព្រះមាតា ស្តាប់ព្រះរាជា បន្ទូលច្នោះហើយ

នាងខ្លាចស្វាមី ឥតបើហានឆ្លើយ សងព្រះឱស្ឋឡើយ

នាងនាថក្រាបលា ។

មកដល់បុត្រី ទើបព្រះជននី ឱនឱបបុត្រភ្លា

ទ្រង់ព្រះកន្សែង ថ្វាថ្លែងប្រាប់ថា នាងអើយបិតា

ក្រោធពន់ពេកក្រៃ ។

ជេរជាលដល់ម្តាយ ខ្វល់ណាស់នាងអាយ ក្រោធក្រៅវិស័យ

ម្តាយកំកិតខ្លាច  ព្រះរាជហឫទ័យ  ដូចកូនមាសថ្លៃ

នាងដឹងហើយក៏ ៗ

១៩០— នាងនាថទេវី  ស្តាប់ព្រះជននី  ប្រាប់ផ្លូវហ្នះណា

នាងយកព្រះករ  គក់គទ្រា  សែនសោយសោកា

ពន់ពិលាបលន់ ៗ

នាងទូលមាតា  ខ្ញុំសូមក្រាបលា  អ្នកមានគុណធ្ងន់

ក្បិតខ្ញុំនឹងក្ស័យ  ប្រល័យជីពជន្ម  ថ្ងៃនេះឯងអ-

ន្តរធានតាមប្តី ៗ

ព្រះវរមាតា  ស្តាប់បុត្រទូលលា  ទឹងថយទៅខ្ញី

នាងឱបកូនរ័ត្ន  លោមឃាត់បុត្រី  នាងអើយកុំបី

កូនគិតហ្នះណា ៗ

ម្តាយសោកពាស់ហើយ ព្រលឹងម្តាយអើយ  ម្តាយមាននាងជា-

កូនស្រីតែមួយ  ជាត្រយ្យទយា  ប្រាណម្តាយនេះណា

ផ្ញើលើនាងហោង ៗ

ពីរពង្សក្សត្រ  សែនសោយសោកពី- លាបលន់កន្ទួន

សឹងសន្ទប់លង់  ពីរពង្សជាម្តង  ហេតុតែនាងវង្ស

ទុក្ខទៀតសោកសោះ ។

១៩៤— នេះនឹងស្រដី ដំណើរអំពី- អស់ពេជ្ឈឃាតនោះ
នាំព្រះអង្គដល់ មណ្ឌលព្រៃស្មោះ ដោយចិត្តចំពោះ
ប៉ងនឹងពិឃាត ។

កាលនោះពោធិ- សត្វសាងបារមី ប្រសើរសល់ខ្នាត
ការនាព្រះធម៌ សម្មាជាអាទិ៍ សម្ដេចនរនាថ
ពុំភ្លេចធម៌ថ្លៃ ។

ទើបស្ដេចត្រាស់ថា ហៃអស់ទាំងគ្នា បងប្អូននេះនៃ
សំណឹក(១)អង្គអញ នេះមិញនឹងក្ស័យ ប្រាកដនាថ្លៃ
នេះឯងហោងណា ។

អញមានទ្រព្យថ្លៃ មួយមានតម្លៃ ប្រពៃមហិមា
រូបកដហង្សមាស ធ្ងះធ្ងាសថ្លៃថ្លា អញទុកនៅនា-
ចុងឈើមួយហោង ។

អញនឹងឲ្យជា រង្វាន់អស់គ្នា កាលគ្រានេះម្ដង

---

១ សំណឹក បើជាកិ. បានន័យថា នឹក, នឹកឃើញ រលឹកឃើញ ។ ក្នុងទីនេះ ជាន. បានន័យថា បំណាច់, បើបានជា.... ។

បើគ្នាស្រឡាញ់ នាំអញទៅផុន ដល់ឈើនោះហោង
អ្នកឡើងយកណា៎ ៗ

២០០– អស់ពេជ្ឈឃាតស្តាប់ ព្រះអង្គថ្លែងប្រាប់ ត្រេកអរគ្រប់គ្នា
ឲ្យស្តេចនាំទៅ សំដៅព្រឹក្សា ទើបព្រះកញ្ញា
នានាំទៅដល់ ៗ

ក្រោមដើមព្រឹក្សា ហើយព្រះកញ្ញា បង្ហាញឲ្យយល់
រូបហង្សមាសម័យ ថ្វាថ្ងៃសួស្តីសល់ នៅនាមណ្ឌល
ចមចុងព្រឹក្សា ៗ

ឯអស់ពេជ្ឈឃាត យល់ហង្សមាសស្អាត ត្រេកអរមហិមា
ដណ្តើមគ្នាពាន ចង់បានសុវណ្ណា គ្នាខ្លះស្រែកថា
ឲ្យអញឯងពាន ៗ

ខ្លះស្រែកថាទៅ ចំណោះអ្វីហៅ ហៅទឹងឡើងបាន
ឈើសោតធំលន់ ខ្ពស់ពន់ប្រមាណ អត់ឲ្យអញពាន
ម្នាក់ ៗ សិនកា៎ ៗ

គ្នាខ្លះពានឡើង គ្នាខ្លះចាប់ជើង កើចចុះវិញណា៎
ដណ្តើមឡើងឯង កោងកែងអាត្មា របូតហត្ថា

ធ្លាក់ចុះដល់ដី ។

២០៩– ខ្ទះយល់គ្នាធ្លាក់ ស្ទុះទៅកន្ត្រាក់ ដៃដោះឡើងវិញ
មិនឈប់មើលអញ ឡើងវិញខាចអ្វី យកឲ្យបានក-
ឡ្បែនេះហោងណា ។

ក្សិណស្ទុះទៅពាន ប៉ុនប៉ងឲ្យបាន ដូចចិត្តចិន្តា
ធ្វើហក់ឯងស្ទាត់ ក្សិណភ្លាត់បាតា របូតហត្ថា
ធ្លាក់ចុះវិញហោង ។

ឯពេជ្ឈឃាតណា ខំឡើងព្រឹក្សា ច្រើនគ្រាច្រើនដង
ពុំបានដូចចិត្ត គំនិតប៉ុនប៉ង រសាយដៃហោង
ឈរមើលមុខគ្នា ។

តេជះបារមី សម្តេចជិនស្រី សពេជ្ញសាស្តា
ពុំឲ្យពេជ្ឈឃាត នេសាទ(១)នោះវា ឡើងដើមព្រឹក្សា
រួចដល់មួយនៃ ។

ក្សិណនោះព្រះបាទ សម្តេចនរនាថ ធិរាជជៀស្តជ័យ
ទ្រង់ព្រះចិន្តា ប្រាជ្ញាទិព្វថ្លៃ ចន្ទូលថាហៃ

១ គួរថា „ ធ្នូជាតិ ” វិញសមជាង ។

បងប្អូនទាំងឡាយ ។

២១០— ចូរបបួលគ្នា ចាំដើមព្រឹក្សា ស្រេចហើយសឹមស្រាយ
អញទឹងឡើងយក ចុះមកទាំងរាយ ឲ្យអ្នកទាំងឡាយ
ជារង្វាន់ណា ។

ពេជ្ឈឃាតស្ដែងស្ដាប់ ស្ដេចបន្ទូលប្រាប់ ត្រេកអរគ្រប់គ្នា
មកស្រាយពោធិ- សត្វវិសេសប្រា- កដហើយនាំគ្នា
ចោមជុំវិញហោង ។

កាលនោះពោធិ- សត្វរូបពីក្តី បរិបូណ៌ឥតហ្មង
ស្រេចហើយក្សត្រថ្លៃ ប្រពៃច្បាស់ច្បង ឡើងឈើដូចប៉ង
ពុំលង់ឡើយណា ។

សម្តេចទសពល ស្តេចឡើងទៅដល់ លុះលើរុក្ខា
ខ្ពស់ពន់ពេកក្រៃ ក្សត្រថ្លៃធ្វើជា- ភិតភ័យមហិមា
ស្ទើរឡើងពុំបាន ។

ឯអស់ពេជ្ឈឃាត យង់យល់ព្រះបាទ គក់ទ្រូងគក់ប្រាណ
ខ្លះស្រែកដេរថា អាចោរសាមាន្យ បើឡើងពុំបាន

ចុះមកវិញណា៎(១) ។

២១៥— ទើបព្រះអង្គឆ្លើយ ថាអស់អាអើយ កុំគិតរញ៉ា
សំណឹកអញក្ស័យ នាថ្ងៃនេះណា៎ កុំបីអស់គ្នា
គិតអញឡើយហោង ។

លែងតែអញបាន រូបហង្សមាសមាន តម្លៃកន្លង
ឲ្យជារង្វាន់ គ្រប់គ្រាន់អស់បង- ប្អូនទាំងនេះហោង
បំណាច់ប្រាជ្ញា ។

ស្តេចឡើងទៅដល់ ហង្សយន្តនិមិល ហើយទ្រង់ចិន្តា
អញចង់ទម្លាក់ មាសប្រាក់ឲ្យវា គិតម្តងកុំគ្រា
ដល់តិចឡើយនៃ ។

វាសឹងចូលចិត្ត ព្រមទឹងមហាក្សត្រ ឥតធម៌ពេកក្រៃ(២)
ទើបពុទ្ធង្កុរ បន្ទូលថាហៃ អស់អាទៃ

---

១ ច្បាប់ខ្លះថា ឯអស់ពេជ្ឈឃាត យង់យល់ព្រះបាទ គក់ទ្រូងគ្រប់ប្រាណ
ស្រែកទៅនោះថា អាចោរកុំពាន បើឡើងពុំបាន
ចុះមកវិញណា៎ ។

២ ច្បាប់ខ្លះថា ចិត្តចោរចង្រៃ...។

វិលទៅម្នីម្នា ៗ

ទៅប្រាប់មហាក្សត្រ ឥតធម៌ក្រៅក្រឹត្យ ជាអម្ចាស់អា
ថាអញទឹងញាន ទៅឋានភាព ស្រុកអញនាយណា៎
ថ្ងៃនេះជាម្ដង ៗ

២២០— ពេជ្ឈឃាតស្ដែងស្ដាប់ ស្ដេចបន្ទូលប្រាប់ ហើយឆ្លើយវឹងស្នង
ថាអាកុំអួត ប្រកួតប្រឡង ចូរទៅវិលផ្គង
ចុះមកវិញណា៎ ៗ

បើមិនខែងខំ យើងទឹងរលំ នូវដើមព្រឹក្សា
ផ្ដួលបុះដល់ដី សូម្បីអាត្មា មិនក្ស័យឯងណា៎
ពុំលែងឡើយហោង ៗ

ទើបស្ដេចត្រាស់ថា នៃម្នាលអស់អា- ពេជ្ឈឃាតទ្រើសឃ្នង
ចូរមិនក្រឡាប់ វិលឆាប់ទៅផ្គង កុំមិនព្រួយហោង
ចាំអញឡើយណា៎ ៗ

ក្សណនោះព្រះបាទ សម្ដេចនរនាថ- ធិរាជបេក្ខ
តែស្ដែងស្ដេចឡើងគង់ លើហង្សយន្តណា៎ ហោះដោយវេហាស៍
ព្រោងព្រាយរស្មី ៗ

ឯអស់ពេជ្ឈឃាត　យន់យល់ព្រះបាទ　ហោះអោយមនភី
ភិតភ័យខ្ចបខ្ចាច　អំណាចបារមី　ក្រួញក្រាបអភិ-
វាទវន្ទា ៗ

២២៩– ស្រែកថ្វាយសព្ទសា-　ធុការព្រះបាទ　សពេជ្ញសាស្តា
ជាទព្រះអង្គ　ទ្រង់បារមិតា　សូមទានករុណា
ប្រោសយើងខ្ញុំផង ៗ

អស់ទាំងពេជ្ឈឃាត　សឹងថ្វាយសព្ទសា-　ធុការអឹងកង
ស្រេចហើយក្រឡាប់　វិលធាប់មកផ្គង　ដល់ក្បែរហើយហោង
ក្រួញក្រាបទូលថា ៗ

បពិត្រព្រះបាទ　ត្រើយត្រៃភូវនាថ　ឥស្សូរសិរសា
សូមទានព្រះអង្គ　ដែលទ្រង់ក្រោធា　ប្រើខ្ញុំករុណា
នូវអស់គ្នាផង ៗ

នាំអ្នកទោសទៅ　បណ្តើរសំដៅ　ដល់ព្រៃហើយហោង
ទើបអស់យើងខ្ញុំ　ពោមជុំជាមួង　ដោយចិត្តប៉ុនប៉ង
មិនមានប្រណី ៗ

យើងពោមស្រេចស្រាប់　លើកដាវនឹងកាប់　ឲ្យក្ស័យជីវី

គាប់មានបក្សា　មហិមារិទ្ធី　ឆៀងឆាបឆក់ពី-
យើងខ្ញុំទៅហោង ៗ

២៣០— ក្សណៈនោះព្រះបាទ　លុះឮពេទ្យឃាត　ទូលដោយគន្ទង
ព្រឺព្រះហឫទ័យ　ភិតភ័យកន្ទង　នុអញនេះម្ដង
ឥតការទេណា ៗ

ឲ្យទៅសម្លាប់　ឥឡូវមិនស្លាប់　មកមានបក្សា
ឆៀងឆាបពារពាំ　នានាំយាត្រា　ហោះដោយវេហាស៍
ប្រាកដគួរស្ញែង ៗ

ម្ល៉េះហើយសមនឹង-　ក្រឡាប់វិលវឹង　មកវិញមិនលែង
ត្បិតបានបក្សា　មហិមាខះខែង　ម្ល៉េះហើយគេតែង
ទឹនធ្វើពាសា ៗ

នុខ្លួនអញអើយ　បើគេមកហើយ　ដោយចិត្តក្រោធា
ឯខ្លួនអញនេះ　ចាស់ម្ល៉េះហើយណា　សមក្ស័យជន្មា
ពិតពុំលែងឡើយ ៗ

ព្រះចៅបញ្ចាល់　ទ្រង់ព្រះចិន្ដា　អម្បាលនោះហើយ
ភិតវែងសល់ភិត　ឯងឥតឯស្បើយ　ទើបក្សត្រត្រាណាត្រើយ

ខំបន្ទូលថា ។

២៣៥– ប្រាប់ប្រើបុត្រី ប្រសើរសស់ស្រី រ័ត្នកជធីតា
ឲ្យវិលវាំងថ្កាន បិតបាំងប្រាង្គប្រា- សាទសួគ៌សោភា
ពិតពុំលង់ឡើយ ។

ឯនាងបទុម- កេសរឧត្តម ក្សត្រត្រាណត្រើយ
នាងព្រួស្វាមី រួចពីក្តីហើយ នាងនាថបានស្បើយ
ទុក្ខទោមនស្សា ។

២៣៧– ទើបនាងកល្យាណ វិលវាំងទៅថ្កាន ប្រាសាទនាងណា៎
ហើយនាងគង់នៅ នាព្រះកៅវគារ មើលផ្លូវព្រះមហា-
ពន្ធកថ្ងើមថ្ងៃ ។

## បទព្រហ្មគីតិ

៣៧៣– នេះទីវាំងស្រដី ដំណើរពីព្រះចមក្រៃ
ស្តេចគង់យន្តមាសម័យ ហោះត្រៃសេតអណ្តែតដល់ ។
ប្រាសាទប្រសើរបាន កដពិមានរ័តន៍មណ្ឌល
ឯនាងនាថនិមិល ទតយង់យល់ព្រះកជា ។

៣៧៥– នាងមានព្រះហឫទ័យ ស្រីរ័តន៍ថ្ងៃសោមនស្សា

អវេឥតឯគណនា ទឹងថ្ងៃថ្ងឹងពុំបានឡើយ ។
ក្សិណនោះឯព្រះបាទ ដល់ប្រាសាទប្រសើរហើយ
ព្រះអង្គពុំលង់ឡើយ ស្តេចចុះចាកហង្សមាសម័យ ។
ស្តេចថ្នមព្រះប្អូនស្រី អគ្គមហេសីដាក់ដល់ពូ-
ទភារ័តន៍ប្រពៃ ពីរពង្សក្សត្រពិលាបលន់ ។
ព្រះអង្គថ្នមបបក់ ព្រលឹងអ្នកមាសស្ងួនគន់
បីដាក់លើហង្សយន្ត ស្រេចហៀរហោះចេញចាកឋាន ។
ប្រទក្សិណប្រាសាទ ប្រសើរស្អាតបីជុំបាន
បរិបូណ៌ហើយក្សត្រក្សាន្ត ហោះទៅត្រង់នាមណ្ឌល ។
៣៨០— នៃព្រះបៅបញ្ចូល ជាបិតានាងទិមិល
ទើបព្រះបាទទសពល បន្ទូលពីអាកាសថា ។
ហៃហាស្តេចកម្លោលន់ ជាទុជិនជួមោហា(១)
ខ្ញៅឥតពិចារណា ពុំបេះគិតឲ្យអស់ក្តី ។
ឥឡូវបូរស្តេចស្តាប់ អញទឹងប្រាប់ដំណើរតើ-
អង្គអញឯងជាតី មិនគឹកូខព្រាហ្មណ៍ហោរា ។

១ ច្បាប់ខ្លះថា ជាទុជិនជួមហិមា ... ។

អញឯងបុត្រព្រះអគ្គ　　អាទិត្យវង្សធិរាជា
គ្រប់គ្រងក្រុងអាក　　អស់ក្សត្រាទាំងរយឯក ៗ
អញឯងចរយាត្រា　　បង់សីមាមកឆ្ងាយពេក
តែអង្គអញសង្វេគ　　សំណាក់នៅព្រាហ្មណ៍ហោក ៗ
៣៨៩— ព្រះចៅបញ្ចាល់ស្តាប់　　ព្រះអង្គប្រាប់ដូច្នោះណា៎
គិតញ័រអស់អង្គា　　ទំមើលទៅឯអាកាស ៗ
យល់ជាក់ជាព្រះអង្គ　　ស្តេចសែនគង់លើហង្សមាស
ស្ញើគ្ញុះធ្ញាស់　　ត្រចះចែងទាំងវេហាស៍ ៗ
ស្តេចយល់ហើយរៃគិត　　ភ័យឯងឥតពិចារណា
ទំទូលអង្វរថា　　អ្នកម្ចាស់អាតុកអើយ ៗ
សូមទានអ្នកសន្តោស　　កុំយកទោសអាតុកឡើយ
ឯអាតុកខុសហើយ　　សូមអ្នកប្រោសជីវិតវិញ ៗ
ទោសអាតុកនេះជ្រៅ　　ធ្ងន់ក្រាស់ក្រៅប្រមាណមិញ
សូមអ្នកប្រោសពោលចេញ　　អត់ទោសទៅយកតែបុណ្យ ៗ
៣៩០— អាតុកមានបុត្រី　　ដោមពិសីពិសេសលន់
ថ្វាយស្នងជាប្រពន្ធ　　ជាបរោហសិអ្នកឯងណា៎ ៗ

វីព្រាហ្មណ៍ប្រាជ្ញបុរោហិត　　កុំអ្នកគិតទុកឲ្យអា-
ពុកនេះទឹងវក្យា　　ពុំឲ្យព្រួយព្រះទ័យឡើយ ។
បើអ្នកមានមេត្តា　　ទ្រង់ករុណាអត់ទោសហើយ
ព្រះគុណអ្នកជាត្រើយ　　អាពុកពុំភ្លេចឡើយណា៎ ។
ក្សិណនោះឯព្រះបាទ　　បរមនាថផិតផា
យល់ព្រះទៅបញ្ឆាល់　　ចាញ់ខ្ចបខ្ចាចព្រះបារមី ។
ពុំអាចហ៊ានប្រឡង　　ប្រកួតផងព្រះបារមី
សម្ដេចព្រះជិនស្រី　　ស្ដេចពុំយកទោសឡើយណា៎ ។

៣៩៤— ឯនាងនាថទេវី　　អគ្គមហេសីសួគិសោភា
នាងផ្ដាំព្រះមាតា　　ថាបពិត្រព្រះមេអើយ ។
ខ្ញុំសូមទានក្រាបលា　　ព្រះមាតាឥឡូវហើយ
អ្នកម្ចាស់កូនអើយ　　កូនទឹងនៅពុំបានណា៎ ។
ក្សិណនោះព្រះជននី　　ព្រះបុត្រីនាងទូលលា
នាងចេញស្រួសម្មា　　ទតទៅយល់រាជបុត្រី ។
នាងចូលទ្រង់ព្រះកន្សែង　　សោកស្រប់ស្រែងស្លុតស្មារតី

ពិលាបឡោមឃាត់ខ្ចី    ជាទកូនស្ងួនមាតា(១) ។
មាសអើយកុំទាន់ទៅ    ចូរនាន់នៅទីន៍ម្តាយក៏
ម្តាយមានមេមាសជា-    ថ្លើមដ៏ថ្លើមម្តាយសព្វថ្ងៃ ។

៤០០— អ្នកនៅនេះតាំងពីរ    ម្តាយបន្ទូរផ្ទេរតាំងផ្ទៃ-
ក្រោមក្រមឲ្យមាសថ្ងៃ    តាំងពីរសោយកផសម្បត្តិ ។
ទុកកូនតាំងពីរអើយ    កុំទៅឡើយម្តាយសូមឃាត់
អញ្ជើញចុះមកថ្កាត់    នៅទីន៍ម្តាយក៏មាសថ្ងៃ ។
ខ្ញុំនម្តាយសោកចាស់ហើយ    មាសម្តាយអើយបើម្តាយក្ស័យ
ម្តាយផ្ញើខ្មោចនេះនៃ    ឲ្យកូនស្ងួនលើកខ្មោចម្តាយ(២) ។
មាសអើយកុំទាន់ទៅ    ចូរនាន់នៅនេះនាន់អាបេ
អាសូរតែទ្រូង៍ម្តាយ    កុំយកទោសព្រះបិតា ។

---

១ ច្បាប់ខ្លះថា    នាងទ្រង់ព្រះកន្សែង    សោកខ្លួញថ្លែងបន្ទូលថា
ហៃមាសបុត្រពុំងា    ម្តេចនាងប្រាសពីម្តាយណា ។

២ ច្បាប់ខ្លះថា    ខ្ញុំនម្តាយសោកចាស់ហើយ    មាសម្តាយអើយសមម្តាយក្ស័យ
ជីវិតម្តាយនេះនៃ    ក្បិតកូនឃ្លាតបង់ម្តាយទៅ ។

ថាបើនាងកូនពៅ　　　មាសមិននៅទឹងយាត្រា
ទៅផងប្ដីនាងណា៎　　　សមម្ដាយក្ស័យណា៎កូនអើយ ៗ

៤០៩– ត្បិតម្ដាយកំព្រាសល់　　　ឥតឯយល់អ្នកណាឡើយ
ប្រលឹងមាសម្ដាយអើយ　　　សូមនាងនៅទឹងម្ដាយក៏ ៗ
ក្សិណនោះពជបុត្រី　　　ស្ដាប់ជនទីនាងសោកា
បន្ទូលដូច្នោះណា៎　　　នាងសែនសោយៗសោកសល់ ៗ
អាណិតព្រះមាតា　　　នាងសោកាៗណាស់
ព្រះនេត្រជោរជោកជល　　　សស្រាក់ស្រោចព្រះភក្ត្រា ៗ
នាងសោកពុំអាចថ្លែង　　　ចរចាថែងចេញឡើយណា៎
គានតឹងអួលទក　　　បង្អៀតអស់ព្រះហឫទ័យ ៗ
ក្សិណនោះព្រះភូបាល　　　យល់នាងនាថសោកពេកក្រៃ
ស្ដេចកើបយន្ដមាសម័យ　　　ហោះអណ្ដែតដោយវេហាស៍ ៗ

៤១០– ព្រះអង្គស្ដេចគង់យន្ដ　　　ហោះដោយបុណ្យព្រះចេស្ដា
ខ្ពស់ផុតព្រះនេត្រា　　　នៃអ្នកផងពុំយល់ឡើយ ៗ
ឯព្រះវរបិតា　　　សែនសោកាឥតឯស្បើយ

ត្បិតកូនស្ងួនគ្រាណាត្រើយ ប្រែប្រាសព្រាត់ចម្ងាយផង់(១) ។
សម្តេចវរមាតា សោយសោកាសទ្ធប់លង់
នាងឈឺត្បិតបុត្របង់ ប្រែប្រាសពីព្រះឧរា(២) ។
រីឯព្រះភូមី យល់ទៅសទ្ធប់ណា
ស្តេចយកព្រះគង្គា ត្បិតព្រះក្រ្តនាងនាថហើយ ។
ក្បិណានោះវរក្សត្រី ភ្ញាក់ស្មារតីពុំលង់ឡើយ
នាងសោយសោកឥតស្បើយ ពិលាបលន់ពន់ពេកណា ។

៤១៥— នាងនាថយកព្រះករ ទាំងពីរគគក់ឧរា
ព្រះឱស្ឋថ្លែងទួញថា ឱកូនស្ងួនមាសម្តាយអើយ ។
ពីតូចមាសឧត្តម កើតមកធំដល់ម៉្លេះហើយ
ពុំដែលបង់ម្តាយឡើយ ដល់រាត្រីថ្ងៃមួយណា ។

---

១-២ តាមច្បាប់ខ្លះថា ឯព្រះវរបិតា យល់បុត្រភ្ជាហោះទៅហើយ
ទៀងទេតពុំលែងឡើយ លុះធល់ដុតព្រះនេត្រា ។
ពុំយល់រាជបុត្រី ទ្រង់វែងពីលាបសោកា
ឯអង្គព្រះមាតា សឹងសោកាទាំងពីរពង្ស ។
សម្តេចព្រះមាតា សោយសោកាពិលាបលង់
នាងឈឺត្បិតបុត្របង់ ប្រែប្រាសពីព្រះឧរា ។

នេះម្ដងម្ដេចកូនពៅ ប្រែប្រាសទៅពីមាតា
ទាំងនេះហេតុវេរា ឯងមកផ្ដល់កូននិងម្ដាយ ។
ឱកូនស្ងួនប្រាសទៅ ពីលំនៅទៅឋានឆ្ងាយ
ឱកូនមាសមិត្តម្ដាយ ម្ដាយថប់ច្រើនប្រការក្ដាត់ ។
ឱម្ដាយប្រណីនាង ធ្លាប់នៅប្រាង្គប្រាសាទរ័តន៍
ឥឡូវនេះមកព្រាត់ ទៅឯកាណ៌ាកូនអើយ ។
៤២០— ម្ដាយថប់មួយពេកក្រៃ គភ៌ពេញផ្ទៃបរិបូណ៌ហើយ
ក្រែងពុំដល់ស្រុកឡើយ ជួនប្រសូតដោយមាគ៌ា[១] ។
ថប់មួយក្រែងដល់ឋាន រាជពិមានព្រះអង្គជា-
បាក្ដុកមេក្ដុកណា ក្រែងលោកពុំអាសូរមេ ។
មិនអស់ចិត្តដូចខ្លួន ម្ដាយរែងស្ងួនកូនមាសស្នេហ៍
ម្ដាយគិត ៗ ទៅថៃ ថៃហើយថប់ ៗ ពេកពន់ ។
សម្ដេចព្រះជននី សោកបុត្រីពិលាបលន់
ទល់ទុក្ខជាទុរន់ ដរាបរីងរៀងទៅហោង ។

---

១ ច្បាប់ខ្លះថា ម្ដាយថប់ ៗ ពេកក្រៃ ដើមពេញផ្ទៃបរិបូណ៌ហើយ
ក្រែងពុំដល់ស្រុកឡើយ ជួនប្រសូតដោយវេហាស៍ ។

នេះនឹងចរចាចែង    និទានថ្លែងដោយគន្ថ
ដំណាលនូវទំនង    ដំណើរព្រះពោធិសត្វ ។

៤២៩– ស្តេចហោះនឹងប្អូនភ្ងា    ដោយវេហាស៍ប្រសើរក្តាត់
ពីរពង្សព្រះអង្គក្សត្រ    បន្ទាបង់លែងសោកា ។
ស្តេចស្តែងដើរដោយបុណ្យ    កណ្តាលមណ្ឌលវេហាស៍
ឥតក្សត្រដទៃណា    ទៅផ្ទឹមនឹងព្រះអង្គបាន(១) ។
ក្សត្រានូវក្សត្រី    ប្រសើរវិសេសថ្កើងថ្កាន
ស្តេចហោះពីកឋាន    គម្រប់ជួនសត្តទិវា ។
នាងឈឺព្រះឧទរ    គ្រប់បរិបូណ៌ខែហើយណា+
នឹងប្រសូតបុត្រា    នាងក្រាបទូលព្រះភូមី ។
ស្តេចស្តាប់ព្រះប្អូនតន់    ស្តេចកើចយន្តមាសមណី
ធៀងធាបបន្ទាបខ្ចី    ចុះដល់ដីដែនព្រឹក្សា ។

៤៣០– ស្តេចចូលចតអាស្រ័យ    ក្រោមម្លប់ជ្រៃព្រៃក្រស្នា
ខាងឆ្នេរព្រះគង្គា    គឺស្រះស្រង់បោក្ខរណី ។

---

១ ច្បាប់ខ្វះថា    ស្តែងស្តេចហោះដោយបុណ្យ    ហោះដោយមណ្ឌលវេហាស៍
ឥតក្សត្រដទៃណា    នឹងមកផ្ទឹមព្រះអង្គបាន ។

ទេត្តខ័ណ្ឌាហាមពាន្ត　　ស្តេចសម្រាន្តអាស្រ័យទី
ស្តេចចុះឲ្យប្អូនស្រី　　នាងីប្រសូតព្រះរាជបុត្រ ។

៤៣៦— នាងនាថនារីថ្លៃ　　នាងឈឺផ្ទៃញ័ររន្ធត់
អស់ឥន្ទ្រិយស្រយុត　　ពុំស្រយោលដល់តិចក៏ ។

## បទកាកគតិ

២៣៨— កាលនោះព្រះបាទ　សម្តេចនរនាថ　យល់ព្រះប្អូនក្លា
ឈឺទទេណាស់　ញ័រអស់កាយា　សម្តេចរាជា
ថ្នមព្រះប្អូនរ័តន៍ ។

ព្រះអង្គបបក់　ព្រលឹងនៃអ្នក　ប្អូនមាសខ្ចឹមចិត្ត
ក្បៀណក្បត្រខ្សឹកខ្សួល　អន់អួលអាណិត　ព្រះប្អូនពេកក្តាត់
សែនសោយសោកា ។

២៤០— ទ្រង់ព្រះកន្សែង　ខំបន្ទូលថ្លែង　ទូវទំនួញថា
ឱប្អូនមាសបង　ម្តេចម្តងនេះណា　យើងមកកំព្រា
លំបាកពេកក្រៃ ។

តែបងនិងប្អូន　មកសម្រាលកូន　កណ្តាលទ្រូវព្រៃ

ឥតអ្នកណាមួយ ទីងជួយឡើយនៃ ជាធ្មបកាន់ថ្ងៃ
ប្អូនមាសឡើយហោង ។

នៅស្រុកនាយក៏ ព្រះអយ្យិកា ព្រះអយ្យកោផង
ព្រះជនកជននី បេតីស្ងួនគ្រង់ អស់ញាតិផៅផង
តាមចាំរក្សា ។

នេះម្តងឥតញាតិ លំបាកសល់ខ្នាត កណ្តាលអត្ថា
ឲ្យប្អូនកំសត់ ទំអត់ទៅក៏ យើងរងវេក
តាមវិបាកផ្ទាន ។

បើនៅស្រុកនាយ បងមានអ្នកម្តាយ អ្នកជាប្រធាន
អស់ញាតិកា វង្សាសន្តាន មើលមាសកល្យាណ
ថ្នាក់ថ្នមបីទ្រ ។

២៤៥– ខ្លះតែងរកថ្នាំ រកធ្មបមកបាំ កុំឲ្យមានក្រ(១)
ខ្លះរកមេមត់ ខ្លះរត់ទៅរក អស់តាំងពេទ្យហ្ម
មានមន្តដាប់ធុត ។

ការខ្មោចបិសាច ការអស់តាំងក- ដក្កុតប្រាកដ

---

១ ច្បាប់ខ្លះថា មិនមានខ្វត់ក្រ . . . ។

ពេញស្មោះឆ្វេងស្តាំ ពេញថ្នាំបរិសុទ្ធ ទូរអស់មេមត់
សែនព្រេនលៀងលា ។

ខ្លះសោតសឹងស្រទ់ អង្វរហើយបន់ ខ្មោចក្នុងគ្រឹហា
ខ្លះសោតរត់រក ហោរមកម្ម្មា ទៀងទាយជតា
គន់គូរឫក្សពារ ។

ខ្លះសោតសឹងទៅ រកដាំទឹកក្តៅ ស្រង់ប្អូនសង្ក្រារ
ខ្លះរកមេទំ ស័ក្តិសមព្យាបាល់ រក្សាកុមារ
មិនឲ្យមានហ្មង ។

ឥឡូវតោកយ៉ាក សមយើងលំបាក កាលគ្រានេះម្តង
គ្រមោចសោះសូន្យ តែប្អូនទិងបង នៅកណ្តាលទ្រូង
ព្រៃព្រឹក្សហិមពាន្ត ។

២៥០— ឥតញាតិផៅផង តែប្អូនទិងបង ម្តេចឡើយមកមាន
ជម្ងឺមហាធ្ងន់ ពេកពន់ប្រមាណ ធ្វើម្តេចនឹងបាន
រួចឥឡូវអើយ ។

សម្តេចពជា សែនសោយសោកា- ណាល់ណាស់ពុំស្បើយ
នាងនាថទេវី សឹងពីលាបហើយ ក្សត្រាត្រាណត្រើយ

លោមយាត់ប្អូនរ័តន៍ ។

ព្រលឹងបងអើយ កុំសោយសោកឡើយ ព្រៃនេះបានស្ងាត់
ក្រែងខ្លាចបិសាច រាជក្អូតព្រមាត់ ប្អូនមាសប្រយ័ត្ន
រាបៀតបិណ្ឌា ។

ប្អូនអើយឥឡូវ ឥតពេទ្យណាគួរ បេះមន្តគាថា
ការខ្មោចបិសាច រាជក្អូតមាយា នាងអើយបងមហា-
ថប់ពន់ប្រមាណ ។

ហាក់ដូចអ្នកយក ភ្នំសុមេរុមក សង្កត់លើប្រាណ
បងធុញថប់ថៃ ឥតឯស្រាកស្រាន្ត ត្បិតប្អូនមាសមាន
ជម្ងឺនេះម្តង ។

២៨៨— ប្អូនអើយហេតុរី- បាកយើងអំពី- បុណជាតិផង
តាមមកពាន់ៗ នៅព្រៃនេះហោង អាចឲ្យយើងរង
ទល់ទុក្ខពុំក្សាន្ត ។

បេះអ្វីបងបេះ ជម្ងឺប្អូននេះ មកទុកឯប្រាណ
បងទីងឈឺគាង ឲ្យនាងស្រាកស្រាន្ត ឥតទុក្ខរំខាន
ឯងឥឡូវអើយ ។

ចូរប្អូនមាសអត់ តាមក្តីកំសត់ យើងណា៎នាងអើយ
វេរាពីព្រេង យើងឯងផល់ហើយ ព្រលឹងបងអើយ
ចៀសចាកពុំបាន ។
នាងនារីរ័តន៍ ស្តាប់ព្រះរៀមឃាត់ នាងនាថកល្យាណ
កាចអត់ជម្ងឺ នាងឈឺក្នុងប្រាណ ហាក់ស្បើយស្រាកស្រាន្ត
នាងពុំសោកា ។
សម្តេចភូធរ ថ្វាថ្លែងអង្វរ អស់ទាំងទេវតា
ទូរខ្មោចបិសាច ពដភូតផងណា៎ ស្តេចសូត្រគាថា
ប្រសើរឧត្តមោ ។
២៦០— អ្នកជាកន្តេ ទេវសព្វេ វិសន្តិសោ-
ម្យសសគ្គំ ឋានវនោ ផលបញ្ញាកេ
បិសាចសព្វំ ។
យាវសម្មា នាសិទេវ មហាទុក្ខំ
ឯវមេវ មយ្ហមយ្ហំ និរខិប្បំ
ឥតានិយេ ។
បពិត្រទេពតា អ្នកបិតនៅនា សួគិសោឡសេ

តោះអ្នកបិតបាំង ព្រៃហិមវន្ត សត្វបក្សារ(១)
ស្រះស្រង់គង្គា ។
សូមទេពតាំងនោះ ជ្រោមជ្រែងជួយដោះ ទុក្ខយើងកាលគ្រា
នេះម្ដងឲ្យបាន ស្រាកស្រាន្តទុក្ខា ឆុតឆាប់ប្រាសប្រា-
កដកាលនេះម្ដង ។
តោះអស់បិសាច ភជភូតផងអាច ថេរបិតដោយដង
ព្រៃព្រះហិមពាន្ត ទីឋាននេះហោង កុំបីអ្នកប៉ង
ចងចិត្តបិណ្ឌា ។

២៦៩— សូមអ្នកមែនមាន ចិត្តចិន្តាក្សាន្ត ជ្រោមជ្រែងរក្សា
ក្បិតយើងគោកយ៉ាក លំបាកណាស់ណា៎ តែពីរអង្គា
កណ្ដាលព្រឹក្សព្រៃ ។
ស្ដេចសូត្រគាថា អង្វរទេពតា មានឫទ្ធិប្រពៃ
ទើបព្រះភូមិន្ទ នរិន្ទជៀសជ័យ មានព្រះហឫទ័យ
ទ្រង់ព្រះចិន្តា ។
ផ្ចង់ព្រះស្មារតី សម្ដេចភូមី បំម្រើនភាវនា

១ ញកភ្នំ, ជ្រលងភ្នំ ។

ការខ្មោចបិសាច  រាជភូតមាយា  ស្តេចយកធម៌ជា

ពំនាក់សព្វថ្ងៃ ។

គេជះសម្ភារ  សម្តេចភូបាល  និងនាងនាថនៃ

បានស្អាងអំពី-  ជាតិក្រាស់ក្រៃ  ព្រះបារមីថ្លៃ

ថ្លែងថ្លឹងពុំបាន ។

ក្សិណនោះណាអ្នក  នាងនាថអង្គអគ្គ-  មហេសីកល្យាណ

ប្រសូតរាជបុត្រ  បរិសុទ្ធប្រុសប្រាណ  រួចបរិបូណ៌បាន

ចាកព្រះឧទរ ។

២៧០— បុត្ររ័តន៍ត្រកូល  ដូចកែវពិទូរ្យ  ថ្លាថ្លៃបវរ

ព្រះភ័ក្ត្រសោភ័ណ  ដូចចន្ទចែងចរ  ញាកអម្ពរ

ពាលពេញបូណ៌មី ។

ប្រកបកើតមក  ជាបុត្រពន្លក  ព្រះជនកជននី

ត្រកាលត្រកូល  អម្បូរជាតិ  កើតមកជាឥ-

ស្សរសក្តិលោកា ។

ក្សិណនោះព្រះអង្គ  ដងទឹកមកស្រង់  ព្រះរាជបុត្រា

ស្រន់ទាំងទេពី ក្សត្រីកញ្ញា សាយសព្វអង្គា
ជាស្រេចហ្មត់ហ្មង ។

នាងនាថរងា ដោយស្រន់គង្គា ត្រជាក់នោះហោង
នាងថ្វាយបង្គំ ប្រណម្យកបរង អង្វរព្រះបង
ព្រះបាទភូមី ។

បពិត្រអម្ចាស់ ខ្ញុំរងាណាស់ ញ័រអស់ឥន្ទ្រិយ
ទល់ទប់ពុំបាន សូមទានភូមី ស្ដេចរកអគ្គី
ឲ្យខ្ញុំអាំងក៏ ។

២៧៥— ពង្សពុទ្ធង្កុរ ស្ដាប់ព្រះប្អូនទូល ស្ដេចសោយសោកា-
ណាល់ណាស់គន់គិត អាណិតអានាថ៍ អាសូរប្អូនភ្ងា
ពេកពន់ប្រមាណ ។

ស្ដេចខំបន្ទូល ឱប្អូនបណ្ដូល ធ្វើម្ដេចនឹងបាន
ភ្លើងឲ្យប្អូនស្ងួន ខ្លឹមខ្លួនអាំងប្រាណ ដែកភ្លើងសោតគ្មាន
សូន្យសោះទេណា ។

មាសអើយខីបាន ព្រៃព្រះហិមពាន្ដ ខេត្តខ័ណ្ឌអង្វា

ផុះដោយរបោះ(១) ចន្លោះព្រឹក្សា(១) សឹងចន្ទន៍ក្រស្នា
ឥតមានក្រសោះ(២) ។

ទើបស្ដេចទតទៅ យល់ភ្លើងភ្លឺនៅ នាកេត្រានោះ
កណ្ដាលសមុទ្រ ប្រាកដស្នានស្មោះ ស្ដេចចិន្តាត្ដោះ
យកភ្លើងនោះណា៎ ។

សម្ដេចភូមី ថ្នមព្រះប្អូនស្រី បន្ទូលផ្ដាំថា
ហៃប្អូនព្រលឹង បងនឹងលីលា ទៅថ្កានកេត្រា
យកភ្លើងមកហោង(៣) ។

២៨០— ឱប្អូនពុំងា សាច់ស្ងួតសង្សារ ខ្ញុំមខ្លួនស្នេហ៍ស្ងួន
នាងនៅនឹងកូន ណា៎ស្ងួនមាសបង បងអ្នកនឹងផ្គង
វិលវិញឆាប់ណា៎(៤) ។

---

១–១.២ ច្បាប់ខ្វះថា សឹងផុះដោយផ្លូវ ដោយពណ៌ព្រឹក្សា សឹងចន្ទន៍ក្រស្នា
ឥតឫស្សីសោះ ។

៣ ច្បាប់ខ្វះថា ..... យកភ្លើងនុ៎ះកូវ ។

៤ ច្បាប់ខ្វះថា ឱប្អូនមាសថ្លៃ នាងនៅនេះនៃ បិតបើរទិត្យនៅ
នឹងកូនមាសថ្លៃ ស្ងួនភ្ងាណា៎ពៅ បងនឹងលាពៅ
រកភ្លើងឆាប់ណា ។

រីឯនាងនាថ ទូនទូលព្រះបាទ ទៀងទួញទូលថា
សូមព្រះអង្គឆាប់ ក្រឡាប់មកក៏ អ្នកអើយប្អូនមហា-
ខ្លាចពន់ពេកក្រៃ ។
៤៨២– ខ្ញុំនៅម្នាក់ឯង គ្រមោចកណ្ដាង កណ្ដាលទ្រូងព្រៃ
កុំបីព្រះអង្គ ផ្សូរផ្សងឡើយនៃ ស្ដេចឆាប់វិលវៃ
កុំយូរឡើយហោង ។

## បទព្រហ្មគីតិ

៤៣៣– កាលនោះព្រះភូមី ផ្ដាំប្អូនស្រីស្រេចឥតគ្គង
ស្ដេចគង់យន្តហោះផ្សង លុះកណ្ដាលសាគរ ។
ធៀងឆាបបន្ទាបទៅ ស្ដេចសំដៅដល់កេត្រា
ព្រះហស្តថ្វៃប្រក ចាប់អង្កត់នៃអគ្គី ។
៤៣៥– បានហើយហោះម្មម្មា ពីកេត្រាចរចេញខ្ញី
ព្រះហស្តកាន់អគ្គី ដាក់លើយន្តហើយហោះផ្សង ។
ឯអស់អ្នកកេត្រា គិតតក្កមាផ្អើលអឺងកង
ស្ទើរក្ហុកកេត្រាផង ស្រែកបង្អើលកងគ្រប់គ្នា ។
ឯអង្គព្រះភូមី បានអគ្គីពីកេត្រា

ដាក់លើយន្តនោះណា៎ ព្រះករកាន់កើបយន្តហោះ ។

រីភ្លើងមិញត្រូវខ្យល់ ឆេះដួចដល់ខ្សែយន្តនោះ

ឆេះទាំងខ្សែហង្សហោះ ឆេះខ្សែស្ពាយសងខាងណា៎ ។

យន្តមាសមិញរង្គោះ រុះធ្លាក់ចុះក្នុងគង្គា

សម្តេចព្រះរាជា ធ្លាក់ចុះផងកាលនោះនៃ ។

៤៤០– ហង្សយន្តមិញសោតសាត់ អណ្តែតបាត់ខ្ចាត់ទីទៃ

ពីព្រះបាទជៀស្នជ័យ ដោយទឹកហូរខ្យល់ផាត់ទៅ(១) ។

កាលនោះពោធិសត្វ លំបាកក្តាត់កាលធ្លាក់ទៅ

កណ្តាលសាគរជ្រៅ សាត់ព្រាត់ពីយន្តមាសម័យ ។

ស្តេចហែលហើយសោយសោក សែនអាមោក្យពន់ពេកក្រៃ

បង្អៀតក្នុងហឫទ័យ វែងគានតឹងចុករ័តន៍ ។

ផ្អុកផ្អើះក្សត្រខ្សឹកខ្សួល ឯងអន់អួលៗអាណិត

ទ្រង់ព្រះកន្សែងក្តាត់ ទូវទំនួញដោយពាក្យថា ។

ឱអញបានតែយន្ត ហោះដោយមណ្ឌលវេហាស៍

---

១ ច្បាប់ខ្លះថា ហង្សមាសមិញសោតសាត់ អណ្តែតបាត់ទៅទីទៃ
រីឯព្រះជៀស្នជ័យ ព្រាត់ពីយន្តហង្សសាត់ទៅ ។

ឥឡូវយក្ខនោះណា ធ្លាក់ក្នុងទឹកសាត់បាត់បង់ ៗ

៤៤៩– ម្ល៉េះហើយសមអញក្ស័យ កាលនេះនៃពិតពុំលង់

អសារកណ្ដាលក្នុង- មហាសមុទ្រនេះឯងណា ៗ

ទោះបីអង្គអញមរណ៍ ក្នុងសាគរគម្ភីរ

ពុំស្ដាយខ្លួនឡើយណា គិតអាសូរតែប្អូនស្រី ៗ

ខ្ញុំប្អូនគន់ពន្លក សង្វាតមកបង់បុរី

បង់តាំងព្រះជននី ព្រះជនកនៅនាយផង ៗ

ហេតុតែប្អូនមាសថ្លៃ នាងអាល័យអាឡោះបង

ខ្ញុំឥឡូវនេះម្ដង ទេះបងបង់មេមាសមិត្ត ៗ

អសារសោះមកមរណ៍ ក្នុងសាគរតែឯងឥត

ដំណួចដំណឹងពិត ពុំបានដឹងដល់ប្អូនភ្ងា ៗ

៤៥០- ខ្ញុំពាក្យពៅផ្ដែផ្ដាំ នោះបងចាំ ៗ ក្ដាត់ណា

តាំងនេះហេតុវេរា បងមកផ្ដល់ណានាងអើយ ៗ

ម្ល៉េះសមមាសព្រលឹង តែងទន្ទឹង ៗ ហើយ

មើលផ្លូវពុំលែងឡើយ គិតស្មានបងបានវិលទៅ ៗ

មិនគិតជាបងមរណ៍ ក្នុងសាគរគម្ភីរជ្រៅ

ហោលប្អូនស្ងួននោះទៅ ជាមេម៉ាយឯងកំព្រា ។
តែពីរនាក់នឹងកូន ស្ងាត់សោះសូន្យក្នុងអត្មា
ឱបងប្រណីក៏ ក្រែងសត្វម្រឹគពាលយង់ឃ្នង ។
ការដើរមកពើបពះ ជួនប្រទះស្ងួនមាសបង
និងបុត្រកូនស្ងួនគ្រង ក្រែងការចាប់ចរិតភោក្តា ។
៤៩៩-មួយសោតក្រែងត្រជាក់ រងាអ្នកមាសពុំងា
ដោយអត់អគ្គីណា+ ក៏ប្អូនក្ស័យតែឯកអង្គ ។
នៅព្រៃព្រះហិមពាន្ត ខ្ងួលទីឋានឆ្ងាស្រះស្រង់
សោះសូន្យជីវិតបង់ បុត្រពន្លកសល់កំព្រា ។
ឱមាសៗថ្លើមថ្លៃ ក្រែងប្អូនក្ស័យៗ ជន្មា
បានបងនៅនោះពី បងនឹងលើកសពប្អូនស្រី ។
ស្រេចហើយបងនឹងក្ស័យ ផងមាសថ្លៃពេចខ្ទី
ទាំងបុត្រស្ងួនភ្ញាប្រិយ បរិបូណ៌មួយនឹងគ្នាហោង ។
ឥឡូវម្តេចប្អូនមាស មេព្រាត់ប្រាសចម្ងាយបង
ស្ងួនអើយនេះម្តេចម្តង បងថែថប់អន់អួលផ្សា ។
៥០០- ឈឺទុកទៀបស្ទើរឆេះ ហាក់នឹងប្រេះព្រះឱរា

ផ្លូវយន្តនោះណា ធ្លាក់ក្នុងទឹកសាត់បាត់បង់ ៗ
៤៤៩– ម៉្លេះហើយសមអញក្ស័យ កាលនេះនៃពិតពុំលង់
អសារកណ្តាលក្នុង- មហាសមុទ្រនេះឯងណា ៗ
ទោះបីអង្គអញមរណ៍ ក្នុងសាគរគម្ភីរ
ពុំស្តាយខ្លួនឡើយណា គិតអាសូរតែប្អូនស្រី ៗ
ឱប្អូនគន់ពន្លក សង្វាតមកបង់បុរី
បង់ចាំងព្រះជននី ព្រះជនកនៅនាយផង ៗ
ហេតុតែប្អូនមាសថ្លៃ នាងអាល័យអាឡោះបង
ឱផ្លូវនេះម្តង នេះបងបង់មេមាសមិត្ត ៗ
អសារសោះមកមរណ៍ ក្នុងសាគរតែឯងឯក
ដំណួចដំណឹងពិត ពុំបានដឹងដល់ប្អូនភ្ងា ៗ
៤៥០- ឱពាក្យពៅផ្តែផ្តាំ នោះបងចាំ ៗ ក្តាត់ណា
ចាំងនេះហេតុវេរា បងមកផ្តល់ណានាងអើយ ៗ
ម្នេះសមមាសព្រលឹង តែងទន្ទឹង ៗ ហើយ
មើលផ្លូវពុំលែងឡើយ គិតស្មានបងបានវិលទៅ ៗ
មិនគិតជាបងមរណ៍ ក្នុងសាគរគម្ភីរជ្រៅ

ពោលប្អូនស្ងួននោះនៅ ជាមេម៉ាយឯងកំព្រា ។
តែពីរនាក់នឹងកូន ស្ងាត់សោះសូន្យក្នុងអញ្ញា
ទុកបងប្រណីក៏ ក្រែងសត្វម្រឹគពាលយង់ឃ្នង ។
កាដើរមកពើបពះ ជួនប្រទះស្ងួនមាសបង
និងបុត្រកូនស្ងួនគ្រង ក្រែងកាចាប់បរភោគ្គា ។
៤៩៩-មួយសោតក្រែងត្រជាក់ រងាអ្នកមាសពុំងា
ដោយអត់អត្តណាំ កុំប្អូនក្សយតែឯកអង្គ ។
នៅព្រៃព្រះហិមពាន្ត ទួលទីឋានផ្ទៃស្រះស្រង់
សោះសូន្យជីវិតបង់ បុត្រពន្ទកសល់កំព្រា ។
ទុកមាសៗថ្ងើមថ្ងៃ ក្រែងប្អូនក្សយៗ ជន្មា
បានបងនៅនោះក៏ បងនឹងលើកសពប្អូនស្រី ។
ស្រេចហើយបងនឹងក្សយ័ ផងមាសថ្លៃពេចខ្ចី
តាំងបុត្រស្ងួនភ្ជាប្រិយ បរិបូណ៌មួយនឹងគ្នាហោង ។
ឥឡូវម្ដេចប្អូនមាស មេព្រាត់ប្រាសចម្បែងបង
ស្ងួនអើយនេះម្ដេចម្ដង បងថៃថប់អន់អួលផ្សា ។
៥០០-ឈឺទុកធៀបស្មើរផេះ ហាក់នឹងប្រេះព្រះទុក

ដូចអ្នកយកខ័នថ្លា　　មកកាប់ក្នុងពុងពោះបង ។
ពោះឈឺដោយពិសខ័ន　　ឈឺពុំទាន់ដូចខ្នះហោង
ផ្សែតប្រាសប្អូនស្នេហ៍ស្នង　　ក៏បងឈឺពន់ពេកណាំ ។
ប្អូនអើយបងគិតឈ្មង　　មួយសោកក្រែងអស់ទេវតា
លោកជួយជ្រោមរក្សា　　ឲ្យប្អូនមានជន្មជីវ៍ ។
និងបុត្រស្ងួនសង្សារ　　នៅកណ្ដាលព្រៃទួលទី
ខបងគិតប្រណី　　សមនាងស្ងាត់ឯងហោងណាំ ។
សមប្អូនទទួលក្ដាត់　　ចាំបងបាត់ពន់វេលា-
កាលហើយសោយសោកា　　ពិលាបលន់ពន់ពេកក្រៃ ។
៤៦៥-សមបីបុត្រពន្លក　　ដើរតែរកដោយដងព្រៃ
នេត្រានាងរំពៃ　　ឯអាកាសវេហាសហោង ។
សមប្អូនរកសព្វឋាន　　ព្រៃហិមពាន្តជ្រោះជ្រលង
អស់ចិត្តពុំឃើញបង　　នាងរំពឹងក៏យំសោកា ។
ពិលាបអស់ចិត្តប្អូន　　ហើយពកូនចរយាត្រា
ដើរដោយដងអដ្វា　　ពុំដឹងតំបន់ទិសទី ។
ខប្អូនមាសប្រសើរ　　ពុំដែលដើរឯងដោយដី

ឥឡូវនេះប្អូនស្រី | មកលំបាកត្បិតខ្លួនបង ។
ទោះសួរប្អូនក្រៃ | កម្មពៀរទុក្ខភ័យផង
ទើបតែគ្រាទេះម្ដង | មាសមេមកលំបាកក្រៃ ។
៤៧០-បងគិតមួយខ្លាចក្រែង | នាងវង្វេងកណ្ដាលព្រៃ
សមដើរហត់ហាលថ្ងៃ | ដាំពុះពងបាទាតន់ ។
ប្អូនអើយបងថប់ថៃ | ឈើឥតឯស្រោកស្រាន្តស្រន់
ផ្អកផ្អើះអួលអង្គអន់ | ឥតឯស្បើយដល់តិចណា+ ។
មួយឈើប្អូនបណ្ដូល | មួយអាសូរឈើបុត្រា
ទោះកូនស្ងួនពុំផា | បាកើតមកលំបាកក្រៃ ។
ទោះបាបុត្រសម្លាញ់ | ប្រសូតចេញៗពីផ្ទៃ
មាតានាព្រឹក្សព្រៃ | ព្រះហិមពាន្តឋានព្រឹក្សា ។
កាលនោះឯអាពុក | បានយល់មុខៗប៉ា
រំពេចពុំលង់ណា+ | ហើយអាពុកប្រែប្រាសបង់ ។
៤៧៥-បាបុត្រស្ងួនថ្លើមថ្លៃ | មកក្បីណាក្ស័យមរណ៍លិចលង់
កណ្ដាលប្រវាលក្នុង- | មហាសមុទ្រគម្ភីរ ។
អាពុកពុំគិតខ្លួន | គិតតែស្ងួនៗកំព្រា

ពីរនាក់ទីងមាតា នៅកណ្តាលព្រៃហិមពាន្ត ។
ថ្ងៃនេះអាពុកប្រាស ប្រាសនិពសបុត្រកល្យាណ
ម្ទះហើយសមពុំបាន យល់មុខកូនពន្ទុកឡើយ ។
អាពុកគិតទៅគ្រប់ គ្រប់ហើយថប់ៗពុំស្បើយ
ឱស្ងួនអាពុកអើយ ឈឺពេកពន់ប្រើនអស់ក្តី(១) ។
បំណាច់មាសពន្ទុក(២) បាបានមកតាប់ប្រតី-
សន្និបុត្រភ្ញាប្រិយ លែងអាពុករក្សាបា(៣) ។
៤៨០- ថ្នាក់ថ្នមៗផ្តេកផ្តិត ឲ្យអស់ចិត្តអាពុកក៏
សន្សឹមប្រាសឃ្លាតឃ្លា តាមដោយកម្មវិបាកបាន ។
មួយសោតទោះបើបី បាបអំពីព្រេងបុរាណ
ក្រែងយើងទាំងបីបាន ធ្វើអំពើអំពល់ពិត ។
វេកនូវពៀរកម្ម នោះចងចាំដោយកំហិត

---

១ ច្បាប់ខ្លះថា អាពុកថប់ពន់ប្រើនក្តី ។ ២ ទាបុត្រពន្ទុក . . ។ ៣ អាពុកពុំបានរក្សា ។

| | |
|---|---|
| និងផ្តល់ផ្តាច់ជីវិត | ឲ្យក្សិណក្ស័យនៃជន្មា(១) ។ |
| សូមឲ្យមូលទាំងបី | រំពេចខ្ចីព្រមផងគ្នា |
| កុំឲ្យប្រាសឃ្លាតឃ្លា | ចាកចម្បែងដូច្នេះណា ។ |
| សម្តេចព្រះចក្រី | សោកមហោសីទូវបុត្រា |
| ពិលាបសោយសោកា | នឹងថ្លែងថ្លឹងពុំបានឡើយ ។ |
| ៤៨៩— នេះទើបស្តេចខ្លួញតី- | ព្រះជននីជនកហើយ |
| ថាឱអម្ចាស់អើយ | មានគុណធ្ងន់ទាំងពីរពង្ស ។ |
| កាលកូននឹងយាត្រា | ព្រះមាតាបិតាទ្រង់ |

---

១ កាលបោះពុម្ពលើក ទី ១-២-៣-៤ មានច្រឡំសាន់វ័ណ្ណសេចក្តីមុនជាក្រោយៗ ជាមុនតាំងពាក្យពេចន៍ក៏ឃ្លៀងឃ្លាតចាកច្បាប់ដើមច្រើនអន្លើ មើលស្តាប់លែងកើត យកសេចក្តីមិនបានល្អ ចាប់តាំងពីពាក្យថា:

| | |
|---|---|
| ម្ទេះសមមាសព្រលឹង | តែងទន្ទឹងរហើយ |
| មើលផ្លូវពុំលែងឡើយ | គិតស្មានបងបានវិលទៅ ។ |

។ ល ។

| | |
|---|---|
| វេរនូវពៀរកម្ម | នោះចងចាំដោយកំហិត |
| និងផ្តល់ផ្តាច់ជីវិត | ឲ្យក្សិណក្ស័យនៃជន្មា ។ |

កាលដែលបោះពុម្ពលើកទី-៥ យើងបានកែសម្រួលចង្អុលឲ្យត្រូវតាមលំដាប់ហូរហែស្រប តាមច្បាប់ដើមវិញហើយ ។

កន្សែងតាំងពីពេញ　　ទុនទុបផ្កាៗផ្ដាំផ្ដិត ។
ពាក្យអ្នកតាំងពីរផ្ដាំ　　នោះកូនចាំៗទៀងទាត់
ឲ្យកូនធាប់វិលថ្វាត់　　កុំឲ្យយូរលង់ឡើយណា៎ ។
អ្នកអើយឥឡូវកូន　　អសារសូន្យក្នុងគង្គា
ហង្សយន្តសោតឃ្លាតឃ្លា(១)　　ដាច់សោត់បាត់បង់ហើយ(២) ។
ម្ល៉េះកូនពុំបានទៅ　　ឋានព្រះទៅតាំងពីរឡើយ
សមកូនលុះនៅហើយ　　ក្នុងអំណាចម្រឹត្យូវហោង ។
៤៩០— ឱអ្នកមេមានគុណ　　គុណមហាធ្ងន់ៗកន្លង
ម្ល៉េះកូនពុំបានស្នង　　សងគុណអ្នកតាំងពីរឡើយ ។
ហេតុបាបពៀរពីព្រេង　　កម្មកូនឯងមកផ្ដល់ហើយ
ឱម្ចាស់ថ្លៃកូនអើយ　　ក៏កូនគិតពុំបានណា៎ ។
សម្ដេចព្រះភូមី　　ហែលផលធីតម្រប់ជា
បីទិនទៀងទាត់ប្រា-　　កដនូវបីកត្រើផង ។
ព្រះអង្គលើកទសករ　　ថ្វាត់ថ្វាយវរវន្ទាផ្គង
ដាក់លើព្រះសិរហោង　　បង្គំគុណព្រះរ័តន៍ត្រៃ ។

---

១-២ ច្បាប់ខ្លះថា　ភ្លើងឆេះហង្សយន្តណា៎　　ដាច់ខ្សែធ្លាក់បង់ទៅហើយ ។

មួយគឺគុណព្រះពុទ្ធ ជាមកុដប្រសើរក្រៃ
ទូវគុណព្រះធម៌ថ្លៃ ទូវគុណព្រះសង្ឃកន្ទង់ ។
៤៩៩– ទូវគុណអស់ទេវតា រែងរក្សាសមុទ្រផង
ទូវគុណមាតាគ្រង ទូវគុណព្រះវរបិតា ។
ហើយព្រះអង្គក៏រើន តែងចម្រើនធម៌ភាវនា
ស្ដេចយកព្រះធម៌ជា ត្រើយពំនាក់ព្រះអង្គហោង ។
គេជះព្រះធម៌ថ្លៃ ក្បត្រជៀសផ្លជ័យរក្សាគ្រង
អស់ទាំងទេពតាផង រួមរក្សាព្រះភូវនាថ ។
មួយសោតហេតុបារមី ស្ដេចសាងពីបុរាណជាតិ
ជ្រោមជ្រែងជួយព្រះបាទ ប្រាកដកាលនោះឯងហោង ។
ក្បិណានោះនាយកេត្រា ទូវអស់ពាណិជនោះផង
នាំនាយកេត្រាច្បង ឈ្មោះចៅសមុទ្រគោចរ ។
៥០០– បើកការកេត្រាត្រង់ យល់ព្រះអង្គក្នុងសាគរ
ឯនាយកេត្រាអរ ឲ្យកូនក្មួយចុះសំប៉ាន ។
ទៅស្រង់ពោធិសត្វ ចុះសែកន់រូបឡើងបាន
ដល់ដាក់លើសំប៉ាន ហើយនាំទៅដល់កេត្រា ។

ឯនាយសំពៅសឹង　　　សួរដណ្ដឹងព្រះកដា
អ្នកអើយហេតុអ្វីណា៎　　　កុំអ្នកមកហៃលផលធី ៗ
ត្រមោចលំបាកប្រាណ　　　ម៉្លេះតើមានប្រការអ្វី
ចូរអ្នកថ្លែងពិតពី-　　　ដំណើរនោះប្រាប់យើងក៏ ៗ
ក្បៀណនោះព្រះជៀស្គជ័យ　　　ស្ដាប់សូមែនាយកេត្រា
នោះទើបព្រះកដា　　　បន្ទូលប្រាប់ដំណើរពី- ៗ
៩០៩– កំណើតព្រះអង្គជា.　　　បុត្រក្សត្រាត្រង់បុរី
ប្រាប់កាលព្រះភូមី　　　ចេញចាកទីព្រះនគរ ៗ
ប្រាប់កាលព្រះអង្គបាន　　　នាងកល្យាណនាំចេញចរ
គាប់ជួនឈើ១ទេរ　　　ឈប់ប្រសូតរាជបុត្រា ៗ
នៅនាកណ្ដាលព្រៃ　　　ហើយក្សត្រថ្ងៃប្រាប់កាលគ្រា
ស្ដេចគង់យន្តយាត្រា　　　មកយកភ្លើងពីសំពៅ ៗ
ប្រាប់កាលព្រះភូមិ　　　បានអគ្គីហើយហោះទៅ
ប្រាប់កាលព្រះចមទៅ　　　ជាប់យន្តធ្លាក់ក្នុងសាគរ ៗ
ស្ដេចប្រាប់អស់សេចក្ដី-　　　ដើមឥតបិទ្ធះឡើយណា៎
រីឯនាយកេត្រា　　　ទូលអស់ទាំងកូនក្មួយផង ៗ

៤១០— ស្ដែងស្ដាប់ព្រះគូបាល ប្រាប់ប្រការដូច្នោះហោង
ហើយបរិហាឥតគ្គង សឹងកាសូរព្រះកជា ។
ឯអន្តពង្សពោធិ- សត្វវិសេសសោកា
នៅទីងនាយកេត្រា ស្ដេចពុំគិតតួព្រះអង្គ ។
គិតតែវេជាយា និងបុត្រភ្ញាត្យិតប្រាសបង់
ស្ដេចគិតហើយស្ដេចទ្រង់ ព្រះកន្សែងពន់ពេកណា៎ ។
ពុំដែលហើយហៅមាន ស្រាលស្រាកស្រាន្តពីទុក
ព្រះអង្គសោយសោកា ជានិរន្តន៍រៀងទៅហោង ។
កាលនោះមានកេត្រា មួយទៀតណា៎បើកផ្លាស់ផ្លង
ដោយជានដែលគន្លង កេត្រាមុនលីលាចរ ។
៤១៥— ឯនាយកេត្រានោះ សោតនាមឈ្មោះហៅសាគរ-
ពាណិជបានចេញចរ ទីងអស់កូនក្មួយផងណា៎ ។
បើកសំពៅផ្លងផ្លាស់ យល់ហង្សមាសក្នុងជលសា
រើសយកឡើងម្ទម្ទា ដាក់លើសំពៅនោះនៃ ។
យល់ហង្សមាសពិចិត្រ ត្រេកអរក្ដាត់ពន់ពេកក្រៃ
យកទុកទៅវិស័យ(១) ពុំដឹងហោះដោយវេហាស៍ ។

---

១ ឃ្លានេះមានន័យថា គ្រាន់តែយកទុក ព្រោះហួសវិស័យខ្លួន ។

ដំណើរពោធិសត្វ　　បុរសរ័តន៍ធិរាជា
នៅទីឯនាយគេត្រា　　យើងឈប់ស្នេះនៅនេះនៃ ។
៥១៩– ហើយយើងមកស្រង់　　ហ្វាថ្ងៃពីក្សត្រថ្ងៃ
នាងនៅឯក្នុងព្រៃ　　កំព្រាព្រាត់ព្រះស្វាមី ។

## បទកាកគតិ

២៨៣– កាលនោះនាងនាថ　ចាំព្រះភូបាល　ជួបជាទិនបី
យល់ព្រះបងបាត់　វររ័តន៍ក្សត្រី　សែនសោយសោកពី-
លាបលន់ក្ដាត់ណា ។
នាងយកព្រះករ　ទាំងពីរគក់គ　គគក់ទុក
ហាក់ហៀបនឹងក្ស័យ ប្រល័យជន្មា　ហេតុត្បិតសោកា
ឈឺសង្សារសល់ ។
២៨៤– ដាំអស់ទុក　នាងនាថឈឺផ្កា　ព្រះរៀមទសពល
ផ្កាខ្លោចក្ដៅក្ដាត់　ស្រីរ័តន៍វិមល　ប្រះប្រាណដួលដល់
ដេកដោយណាក(១) ។
នាងឈឺស្វាមី　ហាក់ដូចអគ្គី　ឆេះក្នុងទុក
សព្វសាច់ស្ងួតថ្មើម　ដង្ហើមខយា　ក្ដៅក្ដាត់ឈឺផ្កា-

១ សព្ទនេះក្លាយមកពី «ធរា=ផែនដី» ។

លន់ឡឺនឡង់ឡប់ ។

វង្វេងស្មារតី សម្តេចទេវី សោកសល់ថៃថប់
ពុំអាចបីបាន ប្រឹងប្រាណទល់ទប់ ដួលដល់សន្ធប់
លន់ពន់ពេកក្រៃ ។

លុះភ្ញាក់ស្មារតី ដាលដោះឡើងពី- ភូមិកពោះនោះនៃ
នាងបីបុត្ររតន៍ ត្រាច់កាត់ដោយព្រៃ រកព្រះចមក្រៃ
ពុំឃើញឡើយណា៎ ។

នាងនាថប្រសើរ ទៀយណាស់ដែលដើរ ក្នុងព្រៃព្រឹក្សា
ហើយហាលថ្ងៃផង ពុះពង់បាទា នាងបីបុត្រា
ចូលឈប់អាស្រ័យ ។

២៩០— ក្រោមម្លប់ក្រស្នា ហើយយកពស្ត្រា ល្អមានតម្លៃ
នាងក្រាលផ្តេកបុត្រ បរិសុទ្ធប្រពៃ បំពៅហើយនៃ
នាងនាថទួញថា ។

ឱបុត្រថ្លៃម្តាយ បាបអ្វីអម្បាយ ឲ្យកូនស្ងួនភ្ងា
កើតក្នុងសានគ្រោះ សូន្យសោះកំព្រា ប្រាសព្រះបិតា-
ធិរាជជៀសស្លួជ័យ ។

កូនអើយម្ដាយស្រោក់ រកអាពុកអ្នក ដោយផងព្រះព្រៃ

ពុំយល់សោះសូន្យ ណា៎កូនមាសថ្លៃ ទ្រូងម្ដាយសង្រៃ

សង្រេងសោកា ៗ

អម្ចាស់ម្ដាយអើយ ឥឡូវនេះហើយ ម្ដាយនឹងយាត្រា

រកព្រះគូជរ ព្រះវរបិតា ម្ដាយនឹងយកបា

ទៅពុំបានឡើយ ៗ

ក្រែងកូនមាសថ្លៃ ត្រូវកំដៅថ្ងៃ កើតជម្ងឺហើយ

ម្ដាយរែងផ្សាក្ដៅ ឥតបីហៅស្បើយ អម្ចាស់ម្ដាយអើយ

អ្នកនៅនេះនៃ ៗ

២៩៤— នាងយកព្រះខ- ម្រង់រ័ត៌នឧត្ដម ប្រសើរពេកក្រៃ

ត្បូងសូរ្យកាន្តរ័ត៌ន ល្អមានតម្លៃ នាងចងនៅដៃ

ព្រះហស្ដបុត្រា ៗ

ហើយនាងបីបុត្រ នាងទ្រង់កំសត់ ពិលាបខ្សួញថា

ឱមាសឆ្អិនឆ្អៅ អ្នកបៅមាតា ឲ្យឆ្អែតហោងណា៎

អម្ចាស់ម្ដាយអើយ ៗ

ម្ដាយនឹងយាត្រា ទៅតាមបិតា អ្នកឥឡូវហើយ

ម្តាយឈើពីរក្តី(១) ឥតបីហៅស្បើយ អម្ចាស់ម្តាយអើយ
ម្តាយមកវិញណា៎ ។
នាងផ្តេកកាដបុត្រ សោយសោកស្រយុត ញ័រអស់អង្គា
ទន្ទឹះទ្រឹកទ្រូល អន់អួលទុក នាងថើបបុត្រា
ស្រេចហើយនាងចរ ។
ចេញបង់បុត្រា វរកជាយា ត្រាច់រកគូគរ
ស្រីតែនពន្លក នាងយកព្រះករ ទាំងពីរនាងគ-
គក់ទ្រូងសោកា ។
៣០០— នាងស្រែកអន្ទះ អន្ទូងស្ទែងស្ទះ រត់រកកាជា
សព្វជ្រោះជ្រលង ដោយដងអញ្ញា ពុំយល់ព្រះមហា-
ពន្លកថ្លើមថ្លៃ ។
នាងវែងសសុល រុកពនដួបដល់ សាគរនាយនៃ
ត្រាច់ដើរដោយឆ្នេរ គម្ភីរជលស័យ ពុំឃើញជៀស្តជ័យ
នាងនាថខ្លួញថា ។
ឱព្រះបពិត្រ ប្រសើរវែងបិត ឱនខ្ញុំមិញណា៎
ឥឡូវព្រះមាស ប្រែប្រាសឃ្លាតឃ្លា ចោលប្អូនឯកា(២).

---

១ មានន័យថា ឈើពីររឿង។ ២ សម្រួលតាមសម្ផស្សកាព្យ ដែលត្រឹមត្រូវជា «អសារ»។

សារសោះសូន្យសល់ ។

ឱព្រះពន្លក ប្អូនត្រាច់ដើររក ដោយដែនក្រវល់
ព្រៃព្រឹក្សហាន់អាយ សត្វសាយពុំយល់ អ្នកអើយប្អូនទល់
ទុក្ខតែម្នាក់ឯង ។

ឱព្រះប្រសើរ អ្នកអើយប្អូនមើល សមុទ្រធំធេង
ខូលាយបាត់ត្រើយ ព្រះអើយប្អូនក្រែង ខ្លាចព្រះអង្គឯង
ក្ស័យក្នុងគង្គា ។

៣០៩– ប្អូនត្រាច់ដើររក ក្រែងខ្លាចរលក បោកសពនោះណា
សាត់មកប្របន្ទោរ តម្កើរផលសា សពព្រះកាជា
ពុំយល់ឡើយនៃ ។

ប្អូនមើលអាកាស ពពកដេរដាស សាត់ទៅច្រើនក្រៃ
ឱព្រះប្រសើរ ប្អូនមើលស្រមៃ ហាក់ដូចក្សត្រថ្ងៃ
ស្តេចហៀរហោះផ្សង ។

ឱប្អូនស្រមៃ ពពកនេះនៃ ស្មានជាព្រះបង
ឯព្រះបពិត្រ បាត់មិនទេហោង អ្នកអើយប្អូនរង
ទុក្ខទោមនស្ស ។

ឱប្អូនយល់ហឫទ្យ ហិចហើរវិលវង់ តាមដោយវេហាស៍
ប្អូនស្មានព្រះបង ហោះផ្សងមកណា មិនដឹងបក្សា
ហឫទ្យហើរហួសទៅ ។
ប្អូនរែងស្រណោះ យល់បក្សានោះ គិតជាព្រះថៅ
ព្រះអង្គធ្លាប់គង់ យន្តហឫទ្យឆ្អិនឆ្អៅ រសើសរស្មៅ
សន្ធោព្រានព្រាយ ។

៣១០— ម្ដេចឡើយព្រះមាស មិត្តមកប្រែប្រាស បង់ប្អូនទៅអាយ
ប្អូនឈឺផ្សែងផ្សា ខ្ញុំពាស្ដួរស្ដាយ ស្មារតីកយមាយ
ធ្វេសធ្វេរធ្វេង ។
ឱព្រះពជា ប្អូនគិតមួយណា មួយនឹងខ្លាចក្រែង
ព្រះមាសពន្លក ហោះរកប្អូនឯង ហើយស្ដេចវង្វេង
ទីឋានដែលឈប់ ។
ក្រែងព្រះទសពល រកប្អូនពុំយល់ ហើយហោះត្រឡប់
ទៅរកដោយផង ព្រៃផងសាយសព្វ ពុំយល់ស្ដេចឈប់
ហឫទ្យហើយយាត្រា ។
ត្រាច់ដើររុករក សព្វព្រៃឈូងឆក ពុំយល់ប្អូនភ្ញា

ក្រែងសត្វម្រឹគផង យង់យូងពាធា ក្សីណក្សយ័ជន្មា
សោះសូន្យបាត់បង់ ។

ទោះព្រះចក្រី មរណ៍មែនពិតក្តី លែងតែ(១)ឃើញហង្ស
ប្អូនរែងធ្លល់ក្តាត់ ត្បិតបាត់ព្រះអង្គ បាត់ម្តេចតាំងហង្ស
តាំងអង្គកជា ។

៣១៥– ឱព្រះទេសពល អ្នកអើយប្អូនធ្លល់ ពន់ពេកណាស់ណា
ប្អូនពុំដឹងថែន ទិសទីមាតា នឹងរកព្រះមហា-
ពន្ធកថ្លើមថ្លៃ ។

ឱព្រះត្រាណត្រើយ អម្ចាស់ប្អូនអើយ ប្អូនកំព្រាក្រែ
ត្រមោចកណ្តែង ឯកឯងក្នុងព្រៃ ប្រាសព្រះជៀស្លដ៏យ
ឥស្សូរសិរសា ។

ឱព្រះបាទបង ពីថ្ងៃនេះហោង តែងនឹងឃ្លាតឃ្លា
និរាសរសោះសូន្យ បង់ប្អូនកាលគ្រា នេះនៅអញ្ញា
ព្រៃព្រះហិមពាន្ត ។

---

១ ឲ្យតែ..., គង់តែ... ។

ឱព្រះពន្លក ស្តេចនាំប្អូនមក ប៉ងទឹងទៅឋាន
ក្រុងទេពបុរី ជាទីកជហាន ម្តេចឡើយមកមាន
ទុក្ខព្រាត់ប្រាសគ្នា ។

ឱអម្ចាស់ថ្ងៃ ប្អូនជាទុក្ខក្រៃ ឯកអង្គអនិច្ចា
ត្រមោចព្រាត់ប្រាស ព្រះមាសស្នេហា ក្នុងព្រៃព្រឹក្សា
ទូរទីឋានស្ងាត់ ។

៣២០ —ឱព្រះចមចៅ ប្រែប្រាសប្អូនទៅ អសារសល់ក្តាត់
ប្អូនឈឺផ្សាខ្លោច ល្អោះល្អោចប្រមាត់ ត្បិតព្រះប្រាសព្រាត់
ចាកចម្បែងចង់ ។

ប្អូនឈឺសព្វសល់ ឈឺធៀបដូចកល អគ្គីឆេះក្នុង-
ឱពក្តៅក្តាត់ ត្បិតបាត់ព្រះអង្គ ព្រះអើយប្អូនផ្សង
ផ្សងវែងសោកសល់ ។

នាងនាថទេវី វររ័ត្នក្សត្រី សោយសោកាណល់
ទៀងទួញព្រះបាទ នរនាថទសពល នេត្រាជោរជល
ស្រក់ស្រោចកត្រ្តា ។

នាងទួញបណ្តើរ ស្រីរ័ត្នប្រសើរ គ្រាច់ក្នុងអង្គា

ពុំយល់ស្វាមី ក្សត្រីថ្លៃថ្លា នាងនាថរែងជា-
ទុក្ខខួញទៅហោង ។
ដំណើរនេះនៃ កាលក្សត្រីថ្លៃ ត្រាច់រកព្រះបង
និទានទាំងនេះ យើងស្ទុះសិនហោង ដោយបទទំនង
ដំណើរនាងនាថ ។

៣២៥— ទើបយើងនឹងថ្លែង ដំណើរតំណែង និទានគិរកាល
ក្សត្រមួយព្រះអង្គ រើសរាជកុមារ កាលក្រោយនាងនាថ
ត្រាច់រកស្វាមី ។
ឥឡូវនេះនៃ សុរិយាល្ងាចថ្ងៃ ថ្ងៃទាបហើយខ្ញុំ
យើងនឹងបញ្ឈប់ ទុកស្ទុះសិននៃ ខែពីរប្រពៃ
គ្រាន់គ្រប់ម៉ោះហោង ។

## បទភុជង្គលីលា

៨៣- នេះបទប្រាកដចងជា ភុជង្គលីលា ថ្លែងនិទាននៃ ។
នឹងថ្លែងសម្ដែងស្រង់ដី ដំណើរអំពី- ក្សត្រមួយនោះណា ។
នគរបវរសីមា សន្តតនាមា ពារាណសី ។
ព្រះអង្គស្ដេចទ្រង់រឹទ្ធី ជាចៅបុរី នាមព្រះព្រហ្មទត្ត ។

សម័យថ្ងៃមួយមហាក្សត្រ ស្ដេចចិន្ដាថ្វាត់ ប្រពាតព្រឹក្សា ។
រេហ៍ពលសកលយោធា មន្ត្រីសេនា ហែព្រះជៀស្ឋជ័យ ។
ស្ដេចដល់មណ្ឌលព្រឹក្សព្រៃ ព្រះបាទក្សត្រថ្ងៃ ប្រពាតសប្បាយ ។
៩០-ទីឋានហិមពាន្ដព្រៃឆ្ងាយ ភលវែងលោះលាយ ឈើផ្ការច្រើនពណ៌ ។
ស្រះស្រង់កំពង់កបកល ស្ទឹងបឹងរុងផ្ការ(១) ខ្ពង់ខ្ពស់ខ្វង់ខ្វាត់ ។
ព្រះពាយរំភើយផាយផាត់ ព្រះអង្គមហាក្សត្រ ក្រសាលក្សេមក្សាន្ដ ។
ព្រះបាទនរនាថថ្កើងថ្កាន ស្ដែងស្ដេចលុះបាទ ដល់ដើមក្រស្នា ។
ក្សណានោះស្ដេចផ្ទោះនេត្រា យល់កដកុមារ ពិសេសពិសាល ។
៩៥-អស់អង្គផូរផង់ត្រកាល បុត្រានាងនាថ បទុមកេសរ ។
ក្សត្រថ្ងៃព្រះទ័យសាទរ ស្ដេចយកព្រះករ បីបុត្ររ័ត្នផូង ។
ពជាទតនាអស់អង្គ យល់ព្រះទម្រង់ រ័ត្នមានតម្លៃ ។
បងនាហត្ថាបុត្រថ្ងៃ ក្សណក្សត្រជៀស្ឋជ័យ ត្រេកសោមនស្សា ។
បន្ទូលមធុរត្រាស់ថា រីកូននេះណា+ មិនកូនកស្ដ្រផង ។
១០០-បុត្រមហាក្សត្រាច្បាស់ច្បង(២) ស្ដេចសោយរាជ្យត្រង់ នគរធំក្លាត់ ។
ទើបមានត្បូងសូរ្យកាន្ដរ័ត្ន ត្បូងពេជ្ររ៉ែកិត បង់ជាសំគាល់ ។

---

១ ស្ទឹងបឹងធំតូច ។ ២ ច្បាប់ខ្លះថា បុត្រព្រះមហាក្សត្រជាម្ដង សោយរាជ្យគ្រប់គ្រង... ។

កត្រ្តាសោភាពិពណ៌ សោតជាបន្ទាល់ ទៀងប្រាកដក្តាត់ ។
សេចក្តីហេតុអ្វីវិចិត្ត បានជាប្រាសព្រាត់ មាតាបិតា ។
ជាភ័ព្វអញគាប់ហើយណា៎ អញរើសយកជា- កូនធម៌អញហោង ។
១០៩-អញឲ្យសេពសោយរាជ្យត្រង់ ជាស្តេចស្តែងស្នង អង្គអញឯងណា៎ ។
ក្សត្រក្សាន្តស្តេចបានបុត្រា ហើយព្រះរាជា ផ្តុំបរិពារពល ។
ស្រាបស្រេចស្តែងស្តេចបានដល់ ទីឋានមណ្ឌល មណីពេជរ័ត្ន ។
ពុំលង់ព្រះអង្គមហាក្សត្រ ស្តេចឲ្យដញ្ចាក់ ព្រលឹងបុត្រា ។
បរិបូណ៌ពុំយូរឡើយណា៎ សម្តេចរាជា រើសរកមេទំ ។
១១០-រក្សាបុត្រាឧត្តម ពីលៀងជិតជុំ នូវបរិពារផង ។
ពិភក្តិរួមរក្សាត្រង់ មិនឲ្យមានហ្មង ដល់តិចឡើយណា៎ ។
ក្សិណក្សត្រព្រហ្មទត្តរាជា ទ្រង់ព្រះចិន្តា ក្នុងព្រះហឫទ័យ ។
បុត្រាពុំផាថ្មើមថ្ងៃ អញរើសនៅនៃ ក្រោមដើមក្រស្នា ។
អស់អង្គពុំហ្លួងដូចផ្កា រូបសគន្ធា ពិដោល្ងេងល្ងើយ(១) ។
១១៩-ស្តេចគិតក្នុងចិត្តស្រេចហើយ ក្សត្រាត្រាណត្រើយ បើកបន្ទូលថា ។
សន្មត់ប្រាកដនាមា ស្តេចឲ្យហៅថា ចៅក្រឹស្នកុមារ ។

---

១ ក្បាប់ខ្វះថា អស់អង្គពុំហ្លួងដូចផ្កា សឹងចន្ទន៍ក្រស្នា ពិដោរល្ងេងល្ងើយ ។

យើងថ្លែងសម្ដែងពីកាល សម្ដេចភូបាល ព្រហ្មទត្តរាជា ។
រើសបុត្រពិសុទ្ធសោភា ដំណើរនេះណា យើងស្ទេះសិនហោង ។
យើងនឹងនិយាយទំនង ដំណើរដើមទង នាងនាថឧត្ដម ។
១២០-ក្សត្រីមហេសីសួស្ដីសម **នាមនាងបទុម-** កេសរមិញណា ។
នាងនាថសង្វាតយាត្រា ក្នុងព្រៃព្រឹក្សា រកព្រះបាទបង ។
អស់កលពុំយល់ជាម្ដង នាងវិលវឹងផ្គង ដល់ដើមក្រស្នា ។
នាងរកពុំយល់បុត្រា នាងគក់ឧរា សោយសោកាក្រៃ ។
ឈឺចៀបហាក់ហៀបនឹងក្ស័យ ហេតុនាងអាល័យ ឈឺត្បិតបុត្របាត់ ។
១២៥-នាងរែងផ្សាផ្សែងក្ដៅក្ដាត់ ញ័រថ្លើមប្រមាត់ ស្លុតសរសៃសាច់ ។
ហាក់អ្នកប្រឡាក់ប្របាច់ យកខ្ញីទូរម្រេច ញាំញីប្រចល់ ។
នាងឈឺជម្ងឺខ្ទាំងសល់ សោកសោះផាលផល់ ដួលសន្ធប់លង់ ។
នៅនាណាឯកអង្គ- ឯងឥតចិត្តលង់- លុះនាងភ្ញាភ្ញាក់- ។
ស្មារតីក្សត្រីអួលអាក់ ដលនេត្រសស្រាក់ ធ្លាក់ដល់ស្រប់ស្រោច- ។
១៣០-កក្ដាឧកផ្កាខ្ទោច ដូចកលគេបោច ពុងពោះបោះបង់ ។
ក្សត្រីទេវីវរវង្ស គគក់ទ្រូងទ្រង់- កន្សែងសោកា ។
នាងទួញទំនួញថ្លែងថា ឱកូនស្ងួនភ្ងា ព្រលឹងមាសម្ដាយ ។

ម្តេចបាបុត្រាពណ្ណរាយ ប្រែប្រាសព្រាត់ឆ្ងាយ ពីទ្រូងម្តាយទៅ ។
ម្តាយប្រាសទិកសព្រះចៅ លែងបានបានៅ ជាតីនោក់ណា៎ ។
១៣៩-ឥឡូវម្តាយនៅកំព្រា ប្រាសម្តេចទាំងបា បណ្តូលថ្លើមថ្លៃ ។
កូនអើយម្ល៉ះហើយពីថ្ងៃ- នេះសមម្តាយក្ស័យ ជីវិតហោងណា៎ ។
ត្បិតប្រាសទិកសបិតា ហើយប្រាសទាំងបា ពន្លកហឫទ័យ ។
ស្ងូវស្ងាប់ក្ងូវគាប់ជាក្រៃ រស់នៅម្លេះនៃ តែងរងទុក្ខា ។
រីរស់ជាមនុស្សម្លេះណា៎ រស់រងវេទនា ទល់ទុក្ខក្រាស់ក្រៃ ។
១៤០-ឱស្ងួនខ្លឹមខ្លួនថ្លើមថ្លៃ ម្តាយក្រែងមួយនៃ សត្វផងពាធា ។
មាសថ្លៃប្រពៃពុំងា នាំយកទៅជា- អាហារចំណី ។
ឱបាបុត្រភ្ងាពិសី ម្តាយគិតក្រែងបី- សាចផងទាំងឡាយ ។
យកបាពុំងាឆោមឆាយ ទៅទុកហាននាយ តំបន់នានា ។
ឱស្ងួនខ្លឹមខ្លួនពុំងា ម្តាយក្រែងទេពតា ទេព្រក្សនោះផង ។
១៤៩-លាក់បាស្ងួនភ្ងាស្នេហ៍ស្នង ឱម្តាយតែងរង ទុកទៀងធ្ងន់ក្រៃ ។
ម្តាយឈ្មោងគិតឯងមួយនៃ ខ្លាចក្រែងថ្មើរព្រៃ ត្រាច់ព្រង់ហើយណា៎ ។
មកជល់យង់យល់ស្ងួនភ្ងា ហើយរើសបុះនបា នាំទៅហានឆ្ងាយ ។
ក្រស្នាសាខាត្រសាយ ឈើនេះដែលម្តាយ ផ្តេកបំបៅបា ។

ម្ដាយអ្នកចាំជាក់ណាស់ណា៎ ឃើញតែព្រឹក្សា ដែលម្ដាយឈប់នៅ ។
១៥០- ម្ដេចប្រាសកូនមាសផ្អិនផ្អៅ ពីទ្រូងម្ដាយទៅ បាត់បង់ឃ្លាតឃ្លា ។
ម្ដាយស្រាក់រកអ្នកត្រង់ណា ឲ្យម្ដាយយល់បា ដូចចិត្តបំណង ។
ឱស្ងួនខ្ញឹមខ្លួនឥតគ្គង កូនអើយនេះម្ដង ម្ដាយគិតពុំយល់ ។
ទ្រូងម្ដាយឈឺសាយសព្វសល់ បងបាត់ពុំយល់ មុខមាសថ្ងើមថ្ងៃ ។
នាងសោកអមោក្សពេកក្រៃ សង្រេងសង្រៃ ត្បិតបុត្របាត់បង់ ។
១៥៥-ក្សត្រីទេវីវរវង្ស លើកទសករផ្គង់ ដាក់លើសិរ ។
វន្ទាទេវាសព្វ ទេព្រ័ក្សបរិគង- ព្រះព្រៃព្រឹក្សា ។
ក្សត្រីប្រណិធានថា បពិត្រទេពតា ទេព្រ័ក្សនៅនៃ ។
ទីឋានឋិមពាន្ធព្រះព្រៃ ផងអ្នកដទៃ សោឡសសួគ៌ា ។
សូមអ្នកកុំលាក់បុត្រា អ្នកប្រាប់ខ្ញុំក៉ា ឲ្យខ្ញុំបានយល់ ។
១៦០-កូនស្ងួនខ្ញឹមខ្លួនទិមិល សោះខ្ញុំតែងទល់- ទុក្ខដូច្នេះណា៎ ។
ក្សត្រីទេវីសោភា អង្វរទេពតា ទេព្រ័ក្សនោះផង ។
រំពេចស្រាប់ស្រេចហើយហោង ទាងចិត្តាផ្គង ទឹងតាមបុត្រា ។
ស្រីតន់នាងគន់សព្វទា- ក្រោមដើមក្រស្នា យល់ស្នាមដើងជាន់ ។
នៅនាធាពជាក់ស្បាន់ នាងគិតគ្នេរគ្នាន់ ថាមនុស្សនេះនៃ ។

រាមករិះរកលេងព្រៃ  រាយល់បុត្រថ្លៃ  រើសយកទៅណា ។
នាងនាថខ្ចីឃ្លាតយាត្រា  តាមបុត្រស្ងួនភ្ងា  ដោយដាននោះនៃ ។
ក្សត្រីទេវីតែនថ្លៃ  ដើរដោយដងព្រៃ  ហិមពាន្តនោះហោង ។
ឈូងឆកជ្រោះច្រកជ្រលង  អស់ទាំងម្រឹគផង  ដើរដោយហ្វូងរា ។
ស្រីថ្លៃប្រពៃសោភា  នាងនាថយាងយា–  ត្រាត្រាច់យង់យល់ ។
ពជសីហ៍ចេញពីមណ្ឌល  គុហាថ្កើងថ្កល់  សីហនាទចេញចរ ។
មើលស្ទឹងប្រែប្រឹងឈប់ឈរ  ដោយព្រឹក្សាករ  សម្រាន្តអាត្មា ។
គជសីហ៍តាមរលៀងកា  ដើរដោយគូរា  រិះរកអាហារ ។
ដំរីរកស៊ីជាសដារ  គោតកៀងកណ្ដាល  ខ្លាងខ្លះស៊ីឆ្ងាយ ។
រមាំងខ្ទីងទាំងប្រើសព្រាយ  ញីញងក្សែរខ្សាយ  ដោយពណ៌ទីទៃ ។
ទាំងមហឹសាសឹងក្រាស់ក្រៃ  ទន្សោងគោព្រៃ  ឈ្លូសរមាសខ្លា ។
សំពោចទាំងពោចស្វានស្វា  ចចកប្រមា  ទន្សាយសោតនៃ ។
សត្វម្រឹគគគឹកច្រើនក្រៃ  ដើរដោយផងព្រៃ  ទួលគោកថ្នាក់ថ្នល់(១) ។
ខ្លះស្រប់ខ្លះឈប់ខ្លះផល់-  គ្នាលេងអស់កល  ខ្លះកៀងគូរា ។
ខ្លះព្រាត់កូនបាត់ឃ្លាតឃ្លា  រត់រកកូនរា  ពុំឃ្លានស៊ីស្មៅ ។

---

១ ច្បាប់ខ្លះថា ពាឧទួលថ្នាក់ថ្នល់ ។

១៨០-ខ្វះយល់កូនដល់ឈប់នៅ អត់ឲ្យកូនទៅ ផ្អែតផ្អន់ស្កប់ស្កល់ ។
ក្សត្រីទេវីទិមិល នាងខតទៅយល់ អស់តាំងម្រឹគផង ។
នាងវែងកន្ទេងកន្ទង សោយសោកក្ដាត់ហោង ពិលាបខ្សួញថា ។
ឱសត្វនេះព្រាត់កូនរ៉ា ដូចអញឯណា៎ ព្រាត់កូនបាត់បង់ ។
កូនស្ងួនខ្ញុំមខ្លួនសាច់ស- ន្សារស្ងួនឲ្យជន្មក្ន- ព្រះព្រៃព្រឹក្សា ។
១៨៥- សត្វខ្វះប្រទះកូនរ៉ា កូនសោតម្នីម្នា រត់រកទៅមេ ។
ឱអញវែងម្នេញឥតល្ហែ ប្រាសកូនមាសស្នេហ៍ សោះសូន្យពុំយល់ ។
កូនអើយម្ទេះហើយម្ដាយទល់– ទុក្ខទៀងលុះដល់ ក្សិណក្ស័យជន្មា ។
ឱស្ងួនខ្ញុំមខ្លួនមាតា ម្ទេះហើយសមបា ទឹងអត់ទឹកដោះ ។
ម្ដាយទឹករពុកដើមនោះ កូនអើយពុំនោះ ម្ដាយវែងខ្វាចផ្សា ។
១៩០-ក្សត្រីឃ្មាតខ្មីយាន់យា- គ្រាគ្រាំពុះពារ កណ្ដាលហ្វូងសត្វ ។
នាងសោកអមោក្សពេកក្ដាត់ នាងនាថពុំគិត ខ្លាចខ្លួនឡើយណា៎ ។
គេដ៏ព្រះបារមិតា នាងសាងច្រើនគ្រា ថ្ងឹងថ្ងៃពុំបាន ។
ទេវតានៅនាហិមពាន្ត សិងសព្វពិមាន សោឡសសួគ៌ា ។
សិងតែងព្រោមជ្រែងរក្សា វររ័តន៍ជាយា ប្រក្រតីទៅហោង ។
១៩៥-ហ្វូងសត្វច្រើនក្ដាត់កន្ទង់ ពុំអាចឃើសឃ្មង បៀតបៀននាងនាថ ។

# បទព្រហ្មគីតិ

៥១៩- ក្រណានោះនាងទេវី អគ្គមហេសីវរជាយា
នាងតាមរកជបុត្រា ត្រាច់ក្នុងព្រៃព្រះហិមពាន្ត ។
ឈើផងសោកច្រើនពណ៌ សត្វរុងផ្ការទំសម្រាន្ត
កៀងគូយំស័ព្ទសាវិន លោតលេងលើៗព្រឹក្សព្រៃ ។
នាងយល់អស់បក្សា នាងសោកាៗក្រៃ[១]
ទួញទៅព្រះជៀស្ដជ័យ ទូរទំទួញនោះឯងថា ។
ឱព្រះបាទបពិត្រ ធ្លាប់រែងស្និទ្ធៗស្នេហា
រួមឯកៗអង្គា មូលមណ្ឌលទីនប្អូនស្រី ។
នេះម្តងម្តេចព្រះមាស- មិត្តប្រែប្រាសប្រែប្រាសទី-
រាសចាកចេញៗពី- ទ្រង់ប្អូនទៅអសារសល់ ។
ខ្ញុំប្រាសពីព្រះបង ក៏ខ្ញុំរងៗទុក្ខទល់
ហើយប្រាសៗពុំយល់ ទាំងកូនស្ងួនៗស្នេហ៍ស្នង ។
៥២៥- ប្អូនរែងឈឺផ្សាសល់ ម្តេចមកយល់ៗសត្វផង
ទាំងពីរកើតត្រសង ទៅទំលើៗព្រឹក្សព្រៃ ។

---

១ នោះនាងអាឡោះពេកក្រៃ ... ។

នុចន្ទន៍ាងក្រស្នា  មែកសាខា លាស់លូតលៃ
ទ្រង់ផ្កាប្រពៃ  រីករុះរោយដោយធាក ។
ពិដោរដូចអ្នកអប់  ផ្តុំត្រឡប់តាំងអព្ភា
ត្រសៀកផាត់កេតា  បក់លំទោនៗទន់ ។
ហង្សហើរៗតាំងគូ  ទៅទំនៅរុក្ខាហោង
ចឹកចាប់ៗផលផង  ហើរទៅទំៗតាំងគូ ។
នុព្រះៗបពិត្រ  ធ្លាប់តែងបិតាៗនៃបនៅ
ទឹងប្អូនម្តេចឥឡូវ  ព្រះប្រែប្រាសៗពុំយល់ ។
៩៣០– នុដើមៗក្តាំពាក់  ធំត្រសាក់ត្រសាយសល់
ទ្រង់ផ្កានិមិល  ពិដោរក្រៃៗពេកណា ។
ទៀវហើរៗទៅទំ  ទំយោសយំរកគូហា
ដូចអន្តអញឯណា  ទៀនខ្ញញរកព្រះរៀមថ្លៃ ។
នុដើមៗកល្បព្រឹក្ស  លូតលាស់ស្លឹកៗល្អក្រៃ
ទ្រង់ផ្កាប្រពៃ  ប្រពៃពេកៗកន្ទន់ ។
រុះរោយដាសដោយដី  ផ្តុំក្លិនពិដោរល្អប់ល្អួន
ព្រះពាយបក់ទន្ទួន  ផ្តុំត្រឡប់តាំងទិសា ។

| | |
|---|---|
| មយូរ ៗ ទំ | ទំហើយយំថ្ងូយថ្ងន់គ្នា |
| ប្រកៀងកៀងគ្នា | វាចឹកតាប់បុប្ផាផល ៗ |
| ៤៣៩– ចម្ប៉ា ៗ ធំ | ធំត្រសុំត្រសាយសល់ |
| មានផ្កា ៗ និម៉ល | ផុំក្រអូបក្រអៃបឈ្ងប់ ៗ |
| មយូរ ៗ ចឹក | ចឹកកល្បព្រឹក្សបរគោគស្កប់ |
| ហើយហើរ ៗ ទៅឈប់ | ឈប់នាដើម ៗ ចម្ប៉ា ៗ |
| ឱប្អូនយល់បក្សី | តាំងឈ្មោលញីកៀងគ្នា |
| ប្អូនផ្អក ៗ ឈើផ្កា | ផ្កាអម្ពលក្តៅ ៗ ពេកក្តាត់ ៗ |
| ឱព្រះ ៗ ចមទៅ | ធ្លាប់វែងនៅ ៗ នៃបទិត្យ |
| ធ្លាប់ស្អាល ៗ ស្នេហ៍ស្និទ្ធ | ស្និទ្ធនៃបទិត្យ ៗ សព្វថ្ងៃ ៗ |
| ឥឡូវម្តេចព្រះមាស | មកប្រែប្រាស ៗ ទីទៃ |
| ប្អូនផ្អក ៗ អាល័យ | អាឡោះលន់តន់ពេកណាស់ ៗ |
| ៤៤០– ឱដើមៗកាកែស | ល្អពិសេសទ្រង់បុប្ផា |
| ឱសត្វ ៗ សារិកា | ហើរទៅទំ ៗ លោតលេង ៗ |
| មាក់ប៉ែនៗធំ | ផ្លែសោតទុំ ៗ រុះឯង |
| ពិដោរ ៗ ល្វែង | ទូរក្លិនផល ៗ ឧត្តម ៗ |

សារិកាៗមើល　　　　មើលហើយហើរៗទៅទំ
ទំហើយៗយាសយំ　　　　យំហើយបរិភោគផល ។
កូតានៗគន់　　　　ផ្កាល្អលន់ពិសេសសល់
ហើយទ្រន់ៗនូវផល　　　　ផលប្រសើរៗក្រៃ ។
សេកហើរៗតាមទៅ　　　　ហើរសំដៅៗ៧
កូតានៗនៃ　　　　ទំទាំងគូទាំងគូក ។
៥៤៥— នុះដើមៗស្រគំ　　　　លាស់ត្រសុំទ្រន់ផ្លែផ្កា
មានផលៗផងផា　　　　ផាបផ្កើមៗទង ។
ស្រគំស្រគាលផល　　　　សេកសោតយល់ៗហើយហោង
ហិចហើរៗត្រសង　　　　ចេញពីដើមៗកូតាន ។
រន្ទួបៗទំ　　　　នៅស្រគំយំសព្ទសាន
បរិភោគផលផងមាន　　　　រសពិសាៗសល់ ។
ប្អូនឃើញៗបក្សា　　　　ប្អូនសោកាសោកាណាស់
ប្អូនផ្អកៗគិតដល់　　　　ដល់ព្រះបាទៗបង ។
ធ្លាប់នៅ ៗនៃបទិត្យ　　　　និត្យស្នាលស្និទ្ធៗស្នេហ៍ស្នង
ដល់ឥឡូវនេះម្តង　　　　ព្រាត់ប្រែប្រាសពីប្អូនថ្លៃ ។

៤៤០– លលក ៗ ហើរ ហើរហើយមើលៗរំពៃ
ចុះទំៗនៅព្រៃ ព្រៃដំដើមៗរំដួល ៗ
រំដួល ៗ ផ្កា មានផលាដូចគេព្យួរ
លលកលោតសៀរសួ ទៅទំលើៗរុក្ខា ៗ
ឱប្អូនយល់លលក យាសយំរកៗគូរ
ប្អូនផ្អកស្រណោះណា+ +ណាព្រះមាសៗប្អូនអើយ ៗ
ប្អូនឈឺស្អួលអន់អាក់ ប្អូនរកអ្នកពុំយល់ឡើយ
ឱអម្ចាស់ប្អូនអើយ អ្នកនិត្យនៅៗឋានណា ៗ
ឱសត្វៗហ៊ឹពូ ទំតាំងគូ តាំងគូរ
លើព្រៃៗសាខា ជាដំណេកៗនៅ ៗ

៤៤៤– បរិភោគបរិភោគផល ផ្អែតស្កប់ស្កល់ហើយហើរទៅ
ខ្ទុះទំៗនិត្យនៅ នៅតាំងគូតាំងគូណា+ ៗ
ឱសត្វៗបក្សី វែងរកស៊ីតាំងគូរ
ឱអញម្តេចឃ្លាតឃ្លា ទីងព្រះបាទព្រះភូមី ៗ
ប៉ោលគោកហិចហើរទៅ ទៅទំនៅៗសុរគី
តាំងគូ ៗ ឈ្មោលញី ស៊ីហើយយំៗល្វេងល្វើយ ៗ

៖ប្អូនឮស័ព្ទសត្វ　　ប្អូនអាណិតណាស់អ្នកអើយ
ត្បិតប្រាសព្រះគ្រាណត្រើយ　　ពីទ្រង់ប្អូនអសារសោះ ៗ
ម្ដេចឮតែស័ព្ទសត្វ　　យំស្រងាត់ឲ្យគាឡោះ
ឲ្យប្អូនវែងស្រណោះ　　វែងលន្វង់លន្វោចលង់ ៗ
៤៦០– វែងថប់ៗអួលអាក់　　ពេកអ្នកៗប្រុសគង់
វែងឈឺៗធៀបលង់　　ឥតឯស្បើយដល់តិចណា ៗ
គាបៅៗ ទំ　　នៅកំពង់ភ្នំៗផ្កា
ស្មោមស៊ីកៗសាខា　　គាបៅយំៗរកគូ ៗ
៖អញគួរអនិច្ចា　　សត្វនេះណាប្រដូចនូវ
អង្គអញឯកឯងត្រូវ　　តែងទួញរកព្រះរាជា ៗ
រន្ធុបៗទំ　　ចាំងគូយំនៅសាខា
ហើយហើរពីទុំណា　　ទៅទំលើរដេញមាស ៗ
ទ្រង់ផ្កាៗក្រពុំ　　ផលផង់ទុំរុះដេរដាស
រំដេញៗមាស　　សត្វរន្ធុបៗទំ ៗ
៤៦៤– ៖ប្អូនយល់បក្សា　　ចាំងគូវាៗយាសយំ
៖ឥឡូវម្ដេចខ្ញុំ　　កំព្រាព្រាត់ព្រះភូមី ៗ

ឱព្រាបៗព្រៃធំ ធំហើយយំទាំងឈ្មោលញី
ខ្លះសោតរកចំណី មកឲ្យកូនបរិភោគ្គា ។
ឱម្ដាយយល់បក្សី រកចំណីឲ្យកូនវា
កូនអើយទ្រូងម្ដាយផ្សា ផ្សព្វទូវទុក្ខពេកណាស់នៃ ។
ត្រិតម្ដាយក៏ព្រាព្រាត់ ប្រាសកូនរ័តន៍ស្ងួនថើមថ្លៃ
ទ្រូងម្ដាយឈឺក្រំក្រៃ ទីងថ្ងៃងថ្ងៃពុំបានឡើយ ។
ករវិកៗយំ យំសូរសមស័ត្វល្វេងល្វើយ
ទាំងគូវាហើយ ទំនៅដើមៗបុសនាគ ។
៤៧០— ឱប្អូនព្រស័ព្ទសត្វ ក្នុងព្រៃស្ងាត់ស្រមៃហាក់
ប្រហែលដូចពាក្យអ្នក(១) ព្រះរៀមរ័ក្សដង្ហោយហៅ ។
ប្អូនវែងៗខ្ញីឃ្លាត ឃ្លាតសង្វាតផ្ដោះសំដៅ
ដើរត្រាច់ៗដើរទៅ យល់ករវិកៗយំ ។
ប្អូនវែងៗឈឺផ្សា គក់ឧរាៗក្រំ
ឱអ្នកៗថ្លៃខ្ញុំ ខ្ញុំទល់ទុក្ខៗកន្ទួង ។
ឱបាបផ្ដល់នាជាតិ នេះខ្ញុំឃ្លាតពីព្រះបង

១ ច្បាប់ខ្លះថា ប្រហែលៗអ្នក . . ។

ខ្ញុំសូមសព្វជាតិផង　　កុំបីមានហៅឃ្លាតឃ្លា ។
ជាតិអើយជាតិនេះហោង　　បើព្រះបង់ស្ដេចកើតជា
សួគ៌ទេពសោយសុខសា-　　ប្បាយនូវបុណ្យបរិបូណ៌ក្រៃ ។
៤៧៥— ខ្ញុំប្អូនសូមប្រាថ្នា　　សូមកើតជាស្រីសួគ៌ថ្ងៃ
ប្រកបនឹងជៀស្ឋជ័យ　　បានជាខ្ញុំស្វាមីភក្ដិ ។
ជាតិអើយជាតិឯណា　　ព្រះកើតជាៗស្ដេចយក្ស
ព្រះអើយខ្ញុំប្អូនអ្នក　　សូមកើតជាស្ដេចយក្សស្រី ។
អញខ្ញុំសូមប្រាថ្នា　　ឲ្យបានជាអគ្គមហេសី
ជាតិអើយជាតិណាក្ដី　　បើព្រះបង់ស្ដេចកើតជា- ។
រាជហង្សមាសមណី　　កំប្អូនស្រីសូមប្រាថ្នា
ឲ្យបានទៅកើតជា　　គូនឹងព្រះបាទកូមី ។
ជាតិអើយជាតិណាហោង　　បើព្រះបង់ចាប់ប្រតិ-
សន្ធិជារាជសីហ៍　　ប្អូនសូមកើតជាគុហា- ។
៤៨០— មាសមានស្នេផ្អើ　　ជាលំនៅព្រះរាជា
ស្ដេចគង់ក្សេមសុខសា-　　ប្បាយក្រសាលព្រះហឫទ័យ ។
ឬមួយស្ដេចកើតជា　　ជាមច្ឆាៗថ្ងៃ

ខ្ញុំប្អូនព្រះជៀសជ័យ　　សូមកើតជាព្រះគង្គា ។
ថ្វាយថ្ងៃ ១ ជ្រះជ្រៅ　　ជាលំនៅព្រះរាជា
ស្ដេចហែល ។ លេងណា　　ក្រសាលឥត ១ ឯហ្ន ។
ព្រះអើយខ្ញុំប្អូនស្រី　　ប្រាថ្នាពីជាតិនេះម្ដង
សូមសព្វ ១ ជាតិផង　　កុំបីមានហៅឃ្លាតឃ្លា ។
៥៨៤— ជាបរួចលុះបាន　　ជល់និព្វាននិរទុក្ខា
ព្រះអើយខ្ញុំប្រាថ្នា　　ឲ្យបានជួបទីននាថ ។

## បទកាកគតិ

៣២៦- បទកាកគតិតែង　　ដំណើរតំណែង　　អំពីនាងនាថ
ទៀងទួញព្រះបង　　នោះហោងសល់ខ្នាត នាងនាថសង្វាត
　　ត្រាច់ក្នុងព្រៃហោង ។
កាលនោះទេវី　　វរពជក្សត្រី　　អនុជស្នេហ៍ស្នង
សោយសោកទួញពី-　　ស្វាមីនាងហោង　　នាងនាថរៃរង
　　ទុក្ខទោមនស្ស ។
នាងឈឺពីរក្តី　　មួយឈឺស្វាមី　　មួយឈឺបុត្រា
នាងសោយសោកសល់ ទួញទល់ទុក្ខា　　នាងត្រាច់រកជា

អំឡុងយូរក្រៃ ។

នាងតាមដោយដាន ដល់ស្រុកពារា- ណសីនោះនៃ

គាប់ជួនរាត្រី ឥតបីអាស្រ័យ ក្សត្រីគន់ថ្លៃ

នាងខំយាត្រា ។

៣៣០– ដល់ផ្ទះជូនចាស់ មានសប្បុរសណាស់(១) ជាអ្នកក្រងផ្កា

ក្សណនោះក្សត្រី ទេវីគិតថា អញសុំបតនា-

ផ្ទះជូននេះនៃ ។

ទើបនាងថ្លែងថា អ្នកជូនអ្នកតា ខ្ញុំសូមអាស្រ័យ

សូមផ្ទះជូនឈប់ តែយប់នេះនៃ រួចបានដល់ថ្ងៃ

ខ្ញុំលាជូនទៅ ។

យាយមាលាស្ដាប់ ពាក្យពីរោះគាប់ ត្រេកអរហើយហៅ

នាងអើយយាយអរ នាងចរមកនៅ នេះទីងយាយទៅ

អម្ចាស់យាយអើយ ។

នាងនាថកល្យាណ នាងឡើងទៅឋាន ផ្ទះជូនចាស់ហើយ

វរពេជក្សត្រី ទេវីត្រាណត្រើយ នាងគង់ស្រេចហើយ

---

១ ច្បាប់ខ្លះថា មានធម៌សប្បុរស ... ។

នាងនាថប្រណិប័តន៍ ។

នូវជូនទិនតា　សួរបេហើយណា　នាងគង់ស្ងៀមស្ងាត់
ទើបយាយមាលា　ចរចាផ្ដេកផ្ដិត　សួរក្សត្រីរ័តន៍
នូវពាក្យនេះថា ។

៣៣៩—អ្នកអម្ចាស់យាយ　មានរូបឆោមឆាយ　អ្នកមកពីណា?
ចូរនាងរៀបរាប់　ប្រាយប្រាប់យាយក៏ នាងអើយយាយអា-
សូរនាងពេកក្រៃ ។

នាងនាថឆ្លាស់ឆ្លើយ　ថាអ្នកយាយអើយ　ខ្លួនខ្ញុំនេះនៃ
ព្រាត់ប្រាសពីប្ដី　ស្វាមីថ្លើមថ្លៃ　នាមអ្នកនោះនៃ
សុវណ្ណកុមារ ។

ប្រាសចាំងបុត្ររ័តន៍　ទើបប្រសូតថ្វាត់　គម្រប់បុក្សពារ
បីទិនទៀងទាត់　ហើយព្រាត់អសារ　សូន្យសោះកណ្ដាល
ព្រឹក្សានាយនៃ ។

ដោយខ្ញុំមើលជាន　ស្នាមជើងសមមាន　មនុស្សផងដើរព្រៃ
ករើសបុត្របាន　នាំថ្កានមកៗ　ក្នុងស្រុកនេះនៃ
មែនមិនទេឡើយ ។

ឯយាយមាលា ស្តាប់នាងប្រាប់ប្រ- ការដូច្នោះហើយ
ទើបគាត់ចរចា ប្រាប់ថានាងអើយ មហាក្សត្រត្រាណត្រើយ
នាមព្រះហ្មទត្ត ។

៣៤០— ស្តេចទៅប្រពាត សម្តេចនរនាថ រើសកផបុត្ររ័តន៍
ព្រះបាទក្សត្រា លីលាវឹងថ្វាត់ មកថ្កានហានប៉ិត
ស្តេចឲ្យរើសរក ។

មេទ្ធក្រមការ រក្សាកុមារ បុត្រាពន្លក
សព្វព្រះហឫទ័យ ក្សត្រថ្លៃឲ្យយក បុត្រានោះមក
ជាតិជាកូនជមិ ។

នាងអើយពាក្យយាយ ដំណើរប្រាប់ប្រាយ ឲ្យនាងបានស្គាល់
កុំបីនាងថ្លែង ហារថែងទូទ័រ ជ្រាបដល់ព្រះកាណិ
ទ្រង់ព្រះក្រោធក្រៃ ។

យាយសូមឃាត់នាង នៅនេះអំភ្លាង ទឹងយាយឯងនៃ
ក្រែងបានជួបជួន កូនស្ងួនថើមថ្លៃ បានដូចហឫទ័យ
ចិត្តនាងប្រាថ្នា ។

នាងនាថស្តែងស្តាប់ ពាក្យពីរោះគាប់ ទើបនាងឆ្លើយថា

បើអ្នកយាយមាន ចិត្តក្សាន្តមេត្តា ខ្ញុំនៅនេះណា
ទឹងយាយឯងហោង ។

៣៤៥- ឯយាយមាលា ពិភក្តិរក្សា ស្រឡាញ់ស្នេហ៍ស្ងួន
យកនាងទុកនៅ ជាចៅចៅហោង មិនមានឲ្យហ្មង
ដល់តិចឡើយណា ។

ឯក្សត្រីថ្ងៃ នាងនៅនេះនៃ ទឹងយាយមាលា
វរាជក្សត្រី ទេវីក្រងផ្កា តាងយាយមាលា
ប្រក្រតីសព្វដង ។

៣៤៧- ឯយាយទិងតា បានទៅក្រងផ្កា ជួសតាងហើយហោង
រីយាយមាលា តែងយាត្រាផ្គង នាំផ្កាកម្រង
ទៅថ្វាយកជា ។

## បទភុជង្គលីលា

១៩៥— នេះបទប្រាកដបងជា ភុជង្គលីលា ដោយដានទំនង ។
ថ្ងៃងកាលទេវីនាងក្រង ល្អល្អះហ្មត់ហ្មង រំលេចបុប្ផា ។
ទឹងថ្ងៃសម្តែងពណ៌នា កាលនាងក្រងផ្កា ក្បូរក្បាច់ថ្ងៃក ៗ ។
បុប្ផានានាអតិរេក ច្រើនពណ៌អនេក អនន្តណាស់ណា ។

ទេវីក្សត្រីកញ្ញា    នាងយកចម្ប៉ា    នៃបទឹនរំដួល ។
២០០-នាងក្រងទាំងទងគងគួរ    ជារូបស្រីសួគ៌    សោតសឹងរេរាំ ។
កែក្រោយដរជាយទន្ទ្រាំ(១)    បានបទលំនាំ    ទន់ភ្លន់ផ្សាស្រ័ ។
នាងក្រងកម្រងមួយទី    នាងយកមាលតី    នៃបទងស្រលិត ។
នាងក្រងកម្រងផ្តេកផ្តិក    ជាបក្សីពិត    គីហង្សមាសម័យ ។
ទំនាវុក្ខាព្រឹក្សព្រៃ    ហាក់រស់វិស័យ    ចឹកចាប់បុប្ផា ។
២០៥-នាងក្រងកម្រងមួយណា    នាងយកក្តាំងងា    នៃបទឹងមហាហគ្គុ ។
នាងក្រងទាំងទងសោតផ្គង់    ជារូបរាជហង្ស    ហើរពាំក្រមាស ។
នាងក្រងផ្កាផងឆ្លូកឆ្លាស់    យករំដេញមាស    នៃបទឹងប្រយគ្គុ ។
នាងក្រងទាំងទងជាកង់    ក្ងោកមាសពេនពង់    យាងយាសរេរា ។
នាងក្រងកម្រងមួយណា    នាងយកយុថ្កា    អញ្ជួនបញ្ជាប្រាល ។
២១០-នាងក្រងផ្កាផងត្រកាល    ជារូបសេកសា-    រិកាពាំក្រី ។
នាងក្រងកម្រងមួយទី    នាងយកទួនស្រី    រីកស្រស់កេសរ ។
នាងក្រងកម្រងបវរ    ជារូបកិន្នរ    ទ្រើសទ្រង់របាំ ។
កែក្រោយដរជាយរេរាំ    យាងយាសទន្ទ្រាំ    ទន្ទេងបានបទ ។

---

១ ច្បាប់ខ្លះថា កែងកោងយាសយាងទន្ទ្រាំ ទន្ទេងរេរាំ ផ្សាស្ងួតពាំស្រី ។

នាងក្រងកម្រងប្រាកដ ជារូបស្តេចគ្រុឌ ឆាបឆក់នាគា ៗ
នាងក្រងកម្រងមួយណា៎ សុពណ៌កេត្រា ផ្លាស់ផ្លង់ផ្លេកផ្លោះ ៗ
នាងក្រងកម្រងមួយនោះ សន្មតនាមឈ្មោះ មាលាសិរសី ៗ
ក្បូរក្បាច់លេចសឹងក្ដី ច្រើនពណ៌ពិសី ពិសេសសោភា ៗ
នាងក្រងផ្កាផងនានា ប្រសើរជាតិជា គ្រកាលពេកពន់ ៗ
ដូនតាសោតណា៎សឹងគន់ យល់នាងស្រីគន់ ក្រងផ្កាល្អក្រៃ ៗ
ដូនតាថ្លែងថាមាសថ្លៃ មានប្រាជ្ញាវៃ លើសលែងអ្នកផង ៗ
ក្សត្រីក្រងក្ដីឥតឆ្គង សូរេចហើយហោង ទើបយាយមាលា ៗ
នាំក្ដីឃ្មាតខ្មីយាត្រា ទៅដល់រាជា ក្រាបទូលថ្វាយហោង ៗ
ក្សត្រថ្លៃប្រពៃឥតឆ្គង ទតយល់កម្រង ផ្កានោះល្អក្រៃ ៗ
ព្រះបាទនរនាថជៀស្ឋជ័យ សព្វព្រះហឫទ័យ ទឹងផ្កានោះណាស់ ៗ
ពុំលង់ព្រះអង្គស្ដេចត្រាស់ ដណ្ដឹងដូនចាស់ គឺយាយមាលា ៗ
ព្រះស្បូរបន្ទូលត្រាស់ថា ដូនអើយនរណា ក្រងផ្កាថ្លៃនេះ? ៗ
ល្អប្លែកចម្លែកដល់ម្ល៉េះ កម្រងផ្កានេះ មិនគឺយាយក្រង ៗ
ទើបយាយអភិប្រាយឥតឆ្គង បង្គំទូលស្នង ព្រះបន្ទូលថា ៗ
បពិត្រសម្ដេចរាជា ចៅខ្ញុំមួយណា៎ ប្ដូរលែងបង់ ៗ

២៣០-គេថាត្បិតវាពុំចង់ ធ្វើការផ្គត់ផ្គង់ រកស៊ីឡើយណា ។
ហើយចង់តែស្អាងអាត្មា គឺមោះរូបអា- ក្រក់ក្រៃពេកពន់ ។
រូបស្បាតស្រែងគ្រាតគគ្រន់ អាក្រក់លើសលន់ ក្រៃលែងអស់ស្រី ។
សិរលេខ្លាញខ្លិលអប្រិយ ហេតុនោះទើបប្ដី វាលែងបង់បោះ ។
គិតពីកាលប្ដីលែងនោះ ជាឆ្នាំមួយស្មោះ ឆ្ងាយខែផងណា ។
២៣៩-វាមកត្រាច់រកខ្ញុំជា ដីដូនហើយវា នៅទីងខ្ញុំហោង ។
ខ្ញុំឯងតាក់តែងឲ្យក្រង ផ្កានេះនាំផ្គង មកថ្វាយក្សត្រថ្ងៃ ។
បើវាក្រងផ្កានេះនៃ សព្វព្រះហឫទ័យ ខ្ញុំអរក្ដាត់ណា ។
ហើយខ្ញុំទូលសូមក្រាបលា ឲ្យទៅខ្ញុំវា ក្រងតាងខ្ញុំហោង ។
ទើបមហាក្សត្រាច្បាស់ច្បង ស្ដេចបន្ទូលស្នង ទៅយាយមាលា ។
២៤០-អញស្ដាយទៅយាយនេះណា ចេះជាងក្រងផ្កា គ្រកាលក្រមាន ។
ខុសត្បិតគំនិតពុំបាន ឥរិយាបថគ្មាន រូបអាក្រក់ក្រៃ ។
ទឹងយកវាមកនៅនៃ ក្នុងផ្ទះសព្វថ្ងៃ ពុំបានឡើយហោង ។
ពីថ្ងៃនេះទៅជាម្ដង យាយឲ្យវាក្រង តាងយាយហោងណា ។
ក្សិណក្សត្រមែនមានមេត្តា ស្ដេចឲ្យទ្រព្យា ថ្ងៃផ្កាគ្រប់គ្រាន់ ។
២៤៩-ក្សត្រថ្ងៃប្រសើរសោភ័ណ ស្ដេចឲ្យរង្វាន់ ដល់យាយមាលា ។

យាយបានប្រពានក្សត្រា  បង្គំក្រាបលា  ទៅឋានឋានបិត ។
ប្រដាប់ស្រេចស្រាប់ដញ្ញាត់  ព្រលឹងទៅថ្វាត់  ពុំលង់ឡើយហោង ។
ស្រីថ្លៃប្រពៃកន្ទង  នាងនាថនៅផង  ទឹងយាយមាលា ។
ដូចចប់គម្រប់ជាក់ជា  សោឡសវស្សា  បរិបូណ៌ហើយនៃ ។
២៩០-ក្សត្រីក្រងភ្សីសព្វថ្ងៃ  ថ្វាយមហាក្សត្រថ្លៃ  នូវរាជបុត្រា ។
នាងបានប្រពានក្សត្រា  ចិញ្ចឹមអាត្មា  ជាប្រក្រតីហោង ។
យើងស្នេះសម្តែងដោយផង  ដំណើរដើមទង  វររាជក្សត្រី ។
ន័យនេះយើងស្នេះសិទ្ធិ  ហើយយើងថ្លែងពី-  ព្រះបាទព្រហ្មទត្ត ។
២៩៤-ព្រះអង្គទ្រង់ធម៌ពេកក្តាត់  រើសរាជបុត្ររ័តន៍  នាងនាថមិញណា ។

## បទកាកគតិ

៣៤៨—  នេះទឹងថ្វាថ្លែង  បទកាកគតិតែង  និទានដំណាល
ដំណើរអំពី-  ព្រហ្មទត្តភូបាល  រើសបុត្រត្រកាល
ក្រោមដើមក្រស្នា ។
កាលនោះព្រះបាទ  សម្តេចនរនាថ  ព្រហ្មទត្តរាជា
បានរាជកុមារ(១)  ព្យាបាលរក្សា(២)  បានបរិបូណ៌ជា

---
១-២ ច្បាប់ខ្លះថា បានបុត្រពន្លក យកមករក្សា .... ។

សោឡសឆ្នាំនៃ ។

៣៩០— ទៅក្រឹស្នាកុមារ  បរិបូណ៌ពេញពាល  ទ្រង់ដោមប្រពៃ
ព្រះវរបិតា  ករុណាពេកក្រៃ  នឹងឲ្យគ្រងផ្ទៃ-
ក្រោមតាងរាជា ។

កាលនោះព្រះបាទ  ត្រាស់ប្រើអាមាត្យ  ចរចេញមឺ្មម្មា
ប្រាប់អស់ក្សត្រផង  គ្រប់គ្រងសីមា  ចំណុះរាជា
ទាំងរយឯកអគ្គ ។

ឲ្យរើសបុត្រី  កបកល្យាណី  សោភសឹងតែទ្រង់
គ្រឿងគ្រប់ប្រដាប់  ស្រេចស្រាប់គ្រប់អង្គ  នាំមកពុំលង់
ថ្វាយព្រះភូបាល ។

ស្ដេចនឹងឲ្យជា  ព្រះរាជជាយា  ទៅក្រឹស្នកុមារ
តាមសព្វព្រះទ័យ  បុត្រថ្លៃសង្ហារ  រើសរាជកញ្ញា
មួយៗឯងណា ។

នោះទើបអាមាត្យ  ទូលអភិវាទ  បង្គំក្រាបលា
នាំព្រះទូង្ការ  រាជសារទៅថា  នឹងអស់ក្សត្រា
សព្វគ្រប់ហើយនៃ ។

៣៥៩– អស់ស្តេចស្តែងស្តាប់ ព្រះរាជប្រញាប់ ម្មីម្មាវៃ ៗ
តែងតួក្សត្រី ឃាតខ្មីឆាប់ក្រៃ ដោយតួទីទៃ
នាំចូលទៅថ្វាត់ ៗ
ដល់ដុំពុលង់ ទាំងរយឯកអង្គ សឹងនារីរ័តន៍
ទ្រង់គ្រឿងប្រដាប់ ស្រេចស្រាប់ពេកក្កាត់ នាំថ្វាយមហាក្សត្រ
ព្រហ្មទត្តរាជា ៗ
ក្សិណក្សត្រជៀស្លជ័យ ឲ្យហៅបុត្រថ្លៃ ទតអស់ធីតា
ហៅក្រឹស្នកុមារ ត្រអាលម្មីម្មា ទតអស់កញ្ញា
បុត្រីក្សត្រផង ៗ
ទតគ្រប់ហើយនៃ ពុំសព្វព្រះទ័យ ដល់មួយជាម្តង
អស់រាជធីតា ក្រាបលាទៅហោង វិលវឹងទៅផ្គង
ស្រុកទេសទីទៃ ៗ
ក្សិណនោះព្រះបាទ ព្រហ្មទត្តនរនាថ - ធិរាជជៀស្លជ័យ
ស្តេចបើកព្រះសូរ បន្ទូលថាហៃ កូនស្ងួនថ្មើមថ្លៃ
ពន្លកបិតា ៗ
៣៦០– កូនអើយហេតុអ្វី អស់ទាំងនារី រយឯកអង្គា

កំកូនពន្ទក　　ពុំយកនាងណា　　ដល់មួយជាតិជា
អភិអគ្គមហេសី ។

ចៅក្រឹស្នកុមារ　　បុត្រស្ងួនសង្សារ　　ថ្វាយវរវន្ទីយ
ទូលថាបពិត្រ　　សម្តេចភូមី　　ខ្ញុំមើលអស់ស្រី
អស់បុត្រក្សត្រផង ។

ខ្ញុំមើលមិនពេញ　　ចិត្តមិនស្រឡាញ់　　ដល់មួយឡើយហោង
សព្វថ្ងៃខ្ញុំគិត　　ក្នុងចិត្តខ្ញុំប៉ង　　អធិដ្ឋានផ្សង
តាមបុណ្យបុរាណ ។

ក្សិណនោះមហាក្សត្រ ព្រះបាទព្រហ្មទត្ត- ធិរាជថ្កើងថ្កាន
ស្តាប់បុត្របណ្តូល　　ក្រាបទូលក្សត្រក្សាន្ត ទើបព្រះអង្គមាន
ព្រះបន្ទូលថា ។

ហៃអស់អាមាត្យ　　ចូរទៅខ្នីខ្នាត　　ឆាប់ ៗ ម្នីម្នា
ស្រាល់ស្រីឲ្យបាន　　មួយមានរូបា　　មកឲ្យបុត្រា
អញកាលនេះម្តង ។

៣៦៥— អាមាត្យទូលថា　　ចៅយាយមាលា　　ល្អក្រៃកន្លង
អស់អគ្គឥន្ទ្រិយ　　ឥតបីមានត្គង　　លើសលែងស្រីផង

លោកិយនេះនៃ ។

បើព្រះរាជបុត្រ  បានយល់ប្រាកដ  សមព្រះជៀស្ឋជ័យ
មានព្រះទយា  ស្នេហាពេកក្រៃ  សព្វព្រះហឫទ័យ
មិនទេឡើយណា៎ ។

ព្រះបាទឥសូរ  ស្ដាប់អាមាត្យទូល  ទើបព្រះរាជា
ស្ដេចបើកព្រះសូរ  បន្ទូលត្រាស់ថា  ទៅយាយមាលា
អាក្រក់ក្ដាត់ហោង ។

គាត់ប្រាប់អញថា  កើតព្យាធិ៍ពេកា  ពេញទាំងខ្លួនផង
យកមកផតការ  អសារទេហោង  នឿយអស់អ្នកផង
ព្រួយដើរទេណា៎ ។

អាមាត្យស្ដេងស្ដាប់  ស្ដេចបន្ទូលប្រាប់  ទើបក្រាបទូលថា
បពិត្រព្រះបាទ  នរនាថករុណា  យើងខ្ញុំអស់គ្នា
ចង់ទៅឲ្យដល់ ។

៣៧០_ មើលឲ្យជាក់ជុំ  បើរូបឧត្ដម  ពិសីនិមិល
យើងនាំមកថ្វាត់  ថ្វាយក្សត្រទសពល  ទតឲ្យបានយល់
រូបនាងនោះណា៎ ។

ស្តេចស្តាប់អាមាត្យ ទូលទើបព្រះបាទ បន្ទូលត្រាស់ថា
បើហ្នះចូរទៅ ចរទៅមើលក់ ឲ្យសោះសង្កា
សន្ទិះចិត្តឡើយ ។
ក្សិណានោះអាមាត្យ ក្រាបលាព្រះបាទ ក្សត្រាត្រាណត្រើយ
ទៅដល់គ្រឹហា យាយមាលាហើយ ថ្លែងថាយាយអើយ
ព្រះបាទក្សត្រា ។
ត្រាស់ប្រើយើងមក ប្រយោជន៍ទឹងយក ទៅយាយឯណា
ទៅឥឡូវថ្វាត់ មហាក្សត្រចេស្តា ស្តេចទឹងឲ្យជា-
មហេសីបុត្ររ័តន៍ ។
យាយមាលាអរ សោមនស្សសាទរ ព្រើសចិត្តពេកក្តាត់
ស្រវស្រក់ ចាប់បានកំណាត់- ស្បៃបង់កថ្វាត់
ហើយហៅទៅថា ។
៣៧៤— ហៃអ្នកមាសថ្លៃ មកណេះចាប់វៃ ផ្សិតមហាក្សត្រា
ទ្រង់មានតម្រាស់ ត្រាស់ប្រើអាជ្ញា យកនាងឯណា
ថ្វាយព្រះចក្រី ។
ទ្រង់ទឹងរៀបចំ ផ្គូងផ្សែផ្សំ ឲ្យជាមហេសី

នៃបុត្រព្រះអគ្គ ទ្រើសទ្រង់ប្រិមប្រិយ ប្លេះចុះឃ្លាតខ្ចី
កុំទៅផ្សូរផ្សង ។
នាងនាថស្ដែងស្ដាប់ ជីដូនប្រាយប្រាប់ នាងអរកន្ទុង
គិតថាអញបាន រួមហានស្នេហ៍ស្ងួន ទឹងកូនស្ងួនគ្រង
កាលម្ដងនេះនៃ ។
នាងនាថជាយា ទឹងយាយមាលា ម្នីម្នាវ ។
ទៅតាមតាជ្វា ក្សត្រាជៀស្ជ័យ កាលនោះឯងនៃ
ពុំលង់ឡើយណា៎ ។
នរអ្នកផងយល់ នាងនាថនិមិល ទ្រង់ឆោមសោភា
សឹងរត់មកមើល សរសើរថ្លែងថា នាងនេះល្អជា
អស្ចារ្យពេកក្រៃ ។
៣៨០— នាងនាថជាយា ទៅតាមតាជ្វា ក្សត្រាជៀស្ជ័យ
ដល់រាជរោងរតន៍ ក្សត្រាថ្វាថ្ងៃ ទតពេញព្រះទ័យ
ត្រេកសោមនស្សា ។
ក្សិណានោះមហាក្សត្រ ទ្រង់ព្រះក្រោធក្ដាត់ ជេរយាយមាលា
មឹងហៅរកញ្ចាស់ កូតណាស់មហិមា មឹងប្រាប់អញថា

ទៅអាក្រក់ក្រៃ ៗ

លុះអញឲ្យយក　បានទៅមិនមក　ឥឡូវនេះនៃ

នាងល្អកន្លង　ហ្មត់ហ្មង់ល្មមល្មៃ　ឥតស្រីដទៃ

ផ្ទឹមផងបានណា ៗ

ក្សិណនោះព្រះចៅ　ស្ដេចត្រាស់ប្រើទៅ　អញ្ជើញបុត្រា

រីឯកុមារ　ត្រអាលម្ពីមា　មកឋានបិតា-

ធិបជជៀស្ដជ័យ

យល់ព្រះមាតា　ស្ដេចពុំស្គាល់ជា-　ជនទីក្សត្រថ្លៃ

គិតស្មានអ្នកព្រស្ត　តាំងផ្ដាសវិស័យ　សព្វព្រះហឫទ័យ

កើតក្តួបស្នេហា ៗ

៣៨៥— ចៅក្រឹស្នាកុមារ　ទូលព្រះភូបាល　ព្រះវរបិតា

ដោយព្រះហឫទ័យ　ក្សត្រថ្លៃករុណា　ស្ដេចទឹងយកជា-

អយិអគ្គមហេសី ៗ

កាលនោះមហាក្សត្រ　ព្រះបាទព្រហ្មទត្ត　ស្ដាប់បុត្រភ្ញាប្រិយ

ក្រាបទូលព្រះមហា-　ក្សត្រាធិបតី　សម្ដេចភូមី

ត្រេកសោមនស្សា ៗ

ស្ដេចឲ្យស្រីង្គារ ព្រះស្នំក្រមការ អក់យាយផងណា
នាំនាងទៅស្រង់ ស្រេចទ្រង់គន្ធា ជូនចន្ទន៍ក្រស្នា
គ្រប់គ្រឿងប្រដាប់ ៗ

ស្ដេចឲ្យភ្នាក់ងារ រៀបបណ្ណាការ បរិបូណ៌ស្រេចស្រាប់
ធ្វើការជាធំ ដោយក្រមក្រឹត្យច្បាប់ គិមង្គលគាប់
អាពាហ៍ពិពាហ៍ ៗ

អស់មុខមន្ត្រី សេនាបតី បុរោហិតា
រៀបរោងក្សត្រថ្ងៃ ច្រើនក្រៃណាស់ណា គាល់ព្រះរាជា-
ធិរាជឧត្តម ៗ

៣៩០— អស់តូរ្យតន្ត្រី ពិណពាទ្យភេរី សោតសឹងប្រគំ
បម្រើក្សត្រា ដោយនាក្រឹត្យក្រម ច្បាប់ការជាធំ
ឥតខ្វះឡើយណា ៗ

ហើយគោះគងជ័យ បុរោហិតសោតនៃ សឹងសូត្រគាថា
បម្រើនសួស្ដី វ្ឡើជយា ថ្វាយពរព្រះមហា-
ក្សត្រទាំងពីរអង្គ ៗ

សម្ដេចភូបាល រៀបបណ្ណាការ បុត្រទាំងពីរពង្ស

ចម្លាប់ការជាធំ ឧត្តមឧត្តុង្គ ហើយទើបព្រះអង្គ
ព្រះបាទជេដ្ឋា ៗ
ស្ដេចយកបុរី ចម្រើនព្រះស្រី បុត្រពីរអង្គា
ព្រះអង្គអភិសេក ជាឯកកជា គ្រប់គ្រងសីមា
ពាកណាសី ៗ
ស្រេចការហើយណា ព្រះរាជបុត្រា ទូវព្រះជននី
គង់ប្រាសាទមាស ខ្ពុះខ្ពាស់ស្មើ លុះចូលរាត្រី
យប់យូរសន្ធិយា ៗ
៣៩៤— ពន់វេលាកាល ហៅក្រឹស្នកុមារ ចេញចរយាត្រា
ទៅឋាននាងនាថ នាកាលនោះណា នោះទើបទេពតា
បែដខ្យមកខ្ញី ៗ
កាលនោះមានឆ្មា មេទិងកូនរ៉ យល់ព្រះភូមី
ស្ដេចយាត្រាទៅ សំដៅសិរសី កូនឆ្មាស្រដី
ដណ្ដឹងមេរ៉ ៗ
ថាហៃប៉ៃអើយ នរណាឯងហើយ ហៅហ៊ានមហិមា
ដើរលើក្បាលយើង ធ្ងន់ជើងម៉្លេះណា ពុំកោតសរសោ

យើងដល់តិចឡើយ ៗ

រីឯមេធា ថ្លែងឃាត់កូនរា ថាម្ចាស់ម្តាយអើយ
កុំកូនចរចា ថ្លែងថាហ្លោះឡើយ លោកកោតអ្វីអើយ
យើងជាតិរោទន ៗ

អម្បាលមាតា បង្កើតសិរសា ម្ល៉ោះគួរលោកហ៊ាន
យកម្តាយឯងជា- ភរិយានៃប្រាណ កុំកូនមាសមាន
ចិត្តគិតហ្លោះឡើយ ៗ

៤០០— ក្សិណានោះរាជា ស្តាប់ម្រឹតមេរា ស្រដីហ្លោះហើយ
ព្រះអង្គស្តេចខាន ពុំហ៊ានទៅឡើយ ក្សិណាក្សត្រត្រាណត្រើយ
ទៅផ្ទុំវិញណា៎ ៗ

យាមមួយទៀតនោះ ស្តេចចរទៅផ្តោះ គម្រប់ពីរគ្រា
កាលនោះមានមេ ពពែមួយណា៎ បំបៅកូនរា
កម្ពុជត្រើ ៗ

មេពពែថា កូនអើយញុំាងបា ដែលយល់ពោធិ
យកព្រះមាតា ឯងជាមហេសី ពុំដែលមានពី-

បុរាណប្ដេះណា៎(១) ។

ក្សិណនោះស្ដេចស្ដាប់ លុះឮសាស័ព្ទ ពាក្យពពៃថា
ស្រដីប្ដោះនៃ ក្សត្រថ្ងៃយាត្រា ទៅឋានក្រឡា-
បន្ទំវិញហោង ។

យាមមួយទៀតណា៎ ស្ដេចចូលទៅជា គម្រប់បីដង
កាលនោះសោតនៃ សេះញីមួយហោង ទឹងកូនវាផង
កូនសោតស្រដី ។

៤០៥— ដណ្ដឹងមេវា ដូចកលពាក្យផ្ដា យើងបានថ្ងៃពី-
កាលមុនជាអាទិ៍ ព្រះបាទភូមី ឮសត្វស្រដី
ជាអស្ចារ្យក្រៃ ។

ស្ដេចទ្រង់ចិន្ដា ក្នុងព្រះទយា ជាអញនេះនៃ
ព្រះវរបិតា ក្សត្រាជៀស្ដជ័យ រើសអញពីព្រៃ
មកជាកូនធម៌ ។

---

១ ច្បាប់ខ្លះថា

មេពពៃថា កូនអើយមាតា បង្កើតសិរសី
យកព្រះមាតា ឯងជាមហេសី ពុំដែលមានពី-
បុរាណប្ដេះណា៎ ។

សមនាងនេះណា⁺ ជាព្រះមាតា តែអញពុំស្គាល់
នេះសមទេពតា ធ្វើជាកិច្ចកល ឲ្យអញបានយល់
ជាព្រះមាតា ។

សមអ្នកត្រាច់មក ប្រយោជន៍ទីងរក អញជាបុត្រា
ដល់ស្រុកនេះអ្នក ពីងពាក់នៅនា- ផ្ទះយាយមាលា
មែនមិនទេឡើយ ។

ស្តេចទ្រង់ចិន្តា អម្បាលនូវប្រ- ការដូច្នោះហើយ
ក្សិណនោះព្រះមហា- ក្សត្រាត្រាណត្រើយ ស្តេចពុំទៅឡើយ
វិលវិញមកស្ថាន- ។

៦១០— ក្រឡាបន្ទំ ក្សិណក្សត្រឧត្តម ស្តេចអធិដ្ឋាន
ទីងអស់ទេពតា បិតនាពិមាន សោឡសសួគិឋាន
សឹងសព្វប្រឹថពី ។

បពិត្រទេពតា បើនាងនេះណា⁺ ជាក់ជាជននី
អញចរចូលទៅ ឥឡូវនេះខ្នី សត្វផងកុំបី
ចរចាទៀតឡើយ ។

ស្តេចអធិដ្ឋាន សច្ចាប្រណិធាន ជាសូរេចហើយ

ក្សិណានោះព្រះអង្គ ពូជពង្សត្រាណត្រើយ ពុំផ្សូរផ្សង់ឡើយ
ស្ដេចទៅទៀតហោង ។

អស់សត្វនោះណា៎ ពិតពុំចរោ ស្ងៀមស្ងាត់ជាម្ដង
នោះទើបព្រះមហា- ក្សត្រាច្បាស់ច្បង ស្ដែងស្ដេចទៅផ្គង
ដល់ព្រះមាតា ។

(១)ឯព្រះជននី ប្រសើរសល់ស្រី យល់កាជបុត្រា
ទៅដល់ក្សត្រី ចុះពីក្រឡា បន្ទំមីមា
ទៅថ្កានបុត្ររ័តន៍ ។

៤១៥– នាងបន្ទូលថា អ្នកឯងនេះណា៎ ព្រះបាទព្រហ្មទត្ត
រើសអ្នកពីព្រៃ ហើយនៃមហាក្សត្រ យកអ្នកមកថ្វាត់
ជាកូនធម៌ថ្ងៃ ។

---

១ បីវគ្គតាប់ពីវគ្គនេះទៅ ច្បាប់ខ្លះមានតែពីរវគ្គ មានសេចក្ដីដូច្នេះថា

នាងយល់ភជបុត្រ អរឯងពេកក្ដាត់ ពេញព្រះទយា
ទើបនាងស្រដី ប្រាប់ពីដើមណា៎ កាលប្រាសបុត្រា
ពន្ទុកច្រើនថ្ងៃ ។

អង្គអ្នកឯងណា៎ សុភាពមែនជា កូនម្ដាយឯងនៃ
កាលនោះម្ដាយព្រាត់ ឆ្ងាយឆ្ងាត់ទីទៃ នឹងអ្នកនៅព្រៃ
ហិមពាន្តនាយណា៎ ។

អង្គអ្នកឯងណា ប្រាកដជាក់ជា កូនម្ដាយឯងនៃ
កាលនោះម្ដាយព្រាត់ ខ្វាយខ្វាត់ទទៃ ទឹងអ្នកនៅព្រៃ
ហិមពាន្តនាយណា ។

សម្ដេចភូមី ស្ដេចស្ដាប់ជនទី ប្រាប់ព្រះរាជា
ទើបក្សត្រត្រកូល ស្ដេចទូលមាតា ថាខ្ញុំនេះណា
ព្រះជនកជៀស្ឋជ័យ ។

កាលនោះព្រះបាទ ស្ដេចទៅប្រពាត រើសខ្ញុំពីព្រៃ
យកមករក្សា ជាកូនធម៌ថ្លៃ អង្គខ្ញុំសព្វថ្ងៃ
ពុំស្គាល់ម្ដាយឡើយ ។

ឯព្រះមាតា ស្ដាប់កូនទូលប្រ- ការដូច្នោះហើយ
ទើបនាងថ្លែងថា ស្ងួនភ្ងាម្ដាយអើយ កុំកូនត្រាណត្រើយ
សន្ទិះសង្កា ។

៤២០— កូនអើយសំពត់ មួយដែលម្ដាយបត់ ម្ដាយក្រាលផ្ដេកពា
កាលម្ដាយចូលឈប់ ក្រោមម្លប់ក្រស្នា ចិញ្ចៀនមួយជា
ត្បូងស្បូវកាន្តរ័តន៍ ។

សឹងមានតម្លៃ ម្ដាយបង់នៅដៃ កូនមាសប្រមាត់

ចិញ្ចៀននោះណា៎ ភក្ត្រាទិត្យរ័តន៍ គង់នៅឬបាត់
ណា៎កូនមាសថ្លៃ? ។

សម្ដេចភូមី ស្ដាប់ព្រះជននី ប្រាប់ដូច្នោះនៃ
ស្ដេចជឿជាក់ជា មាតាក្សត្រថ្លៃ ឥតមានព្រះទ័យ
សន្ទិះសង្កា ។

ក្សិណានោះព្រះអង្គ យកព្រះទម្រង់ នូវព្រះពស្ត្រា
ថ្វាយជាសាក្សី ជននីកាលត្រា នោះឯងជាក់ប្រា-
កដពិតពុំលង់ ។

សម្ដេចពជា សែនសោយសោកា- ណាល់ណាស់ទ្ងួញទ្រង់
កន្សែងសោកសោះ កាលនោះព្រះអង្គ ក្រាបក្រោមបាទប-
ង្គំព្រះមាតា ។

៤២៥- ឯព្រះជននី វរពជក្សត្រី ទទួលពស្ត្រា
នូវព្រះទម្រង់. រ័តន៍ផ្ទង់ហើយណា៎ នាងឱបបុត្រា
ទ្រង់ព្រះកន្សែង ។

សែនសោយសោកា អាណិតអានាថ បន្ទូលទ្ងួញថ្លែង
ឱកូនមាសម្ដាយ សព្វថ្ងៃម្ដាយតែង- ទល់ទុក្ខចម្បែង

ក្នុងទ្រូងពីរក្តី ។

ជាទុក្ខមួយណា ត្បិតម្តាយព្រាត់បា បុត្រស្ងួនភ្ងាប្រិយ
ទុក្ខមួយត្បិតប្រាស និរាសស្វាមី សម្តេចភូមី

ជនកកូនអើយ ។

នេះម្តងម្តាយបាន ហេតុបុណ្យបុរាណ ជួបនឹងបាហើយ
ក្នុងទ្រូងម្តាយបាន ស្រាកស្រាន្តកូនអើយ ស្រយាលល្ហែល្ហើយ

ទុក្ខមួយនោះហោង ។

ចៅក្រឹស្នកុមារ កូនស្ងួនសង្វារ បង្គំទូលស្នង
បពិត្រអ្នកម្តាយ និយាយដើមទង ដំណាលចំនង

ដំណើរនោះម្តេច ? ។

៤៣០– នាងស្តាប់បុត្រា ទូលសូមចិន្តា ចង់ជ្រាបសេចគ្រេច
នាងបរចាថែង ថ្វាថ្វែងសព្វសេច- ក្តីប្រាប់សម្តេច

ព្រះរាជបុត្រា ។

ឱ! ម្ចាស់ម្តាយអើយ ដំណើរដើមឡើយ ឯឪពុកបា
គ្រប់គ្រងរេហ៍ពល សកលយោធា បិតនៅសីមា

ក្រុងទេពបុរី ។

ឯអញម្ដាយបា ជាបុត្រក្សត្រា- ធិរាជធិបតី
សោយរាជ្យនៅនា- បញ្ចាលធានី ឯកឯងជាឥ-
សូរអស់រាស្ត្រផង ។
ឯឪពុកបា គង់ហង្សយន្តណា យាត្រាហោះផ្សង
ជួបដល់ស្រុកម្ដាយ ឯអាយជាម្ដង សំណាក់នៅផង
ព្រាហ្មណ៍ប្រាជ្ញហោរា ។
ហើយព្រះអង្គទៅ បម្រើព្រះចៅ ជាជីតាបា
ស្ដេចនៅឯកអង្គ យូរលង់ទៅណា កាលនោះជីតា-
បាទ្រង់ក្រោធក្រៃ ។
៤៣៥— ព្រះអង្គឲ្យចាប់ នាំទៅសម្លាប់ នៅនាព្រះព្រៃ
ឯអាពុកបា ប្រាជ្ញាឈ្លងវៃ សម្ដេចជៀសក្ស័យ
លួងអស់ពេជ្ឈឃាត ។
ស្ដេចរួចពីភ័យ គង់យន្តមាសម័យ ហោះដល់ប្រាសាទ
យកម្ដាយដាក់ក្នុង- ហង្សយន្តមាសស្អាត ស្រេចហើយព្រះបាទ
ហោះចេញមកខ្មី ។
ប៉ុនប៉ងសំដៅ ទីឯហោះផ្ដោះទៅ ក្រុងទេពបុរី

ហោះពីសីមា បញ្ចាលជាទី ចរចេញចាកពី-
ស្រុកប្រាំពីរថ្ងៃ ។

ពុំទាន់ដល់ឡើយ អម្ចាស់ម្ដាយអើយ គាប់ម្ដាយឈឺផ្ទៃ
ទឹងប្រសូតបា ឯងណា+មាសថ្លៃ ក្បៀណក្បែត្រជៀសស្លដ័យ
ព្រះជនកបា ។

កើបយន្តចុះឈប់ អាស្រ័យក្រោមម្លប់ ព្រះជ្រៃសាខា
ហើយម្ដាយសម្រាល- បាកាលនោះណា+ កណ្ដាលព្រឹក្សា
ហិមពាន្តនាយនោះ ។

៤៤០— ព្រះជនកបា យល់ម្ដាយរង៉ា ស្ដេចគង់យន្តហោះ
ទៅរកអគ្គី ប្រាសពីកាលនោះ និពសសូន្យសោះ
ទឹងម្ដាយហោងណា+ ។

កូនអើយម្ដាយនៅ នោះចាំព្រះចៅ ពីនោក់ទឹងបា
ចាំបីចិនចាត់ យល់បាត់ល្ពោះណា+ ម្ដាយសោយសោកា
ណាល់ណាស់កូនអើយ ។

ម្ដាយយកព្រះករ ចាំងពីរតក់គ ទុកម្ដាយហើយ
ផលនេត្រស្រោក់ ឥតអាក់កូនអើយ មិនមានហៅស្បើយ

ពីទ្រូងម្ដាយណា៎ ។

ម្ដាយសោកសន្ទប់ ឯកឯងសូន្យសព្វ ដេកដោយធារា(១)
ម្ដាយភ្ញាក់ស្មារតី ពីសន្ទប់ណា៎ ហើយម្ដាយបីបា

រុករកដោយព្រៃ ។

ម្ដាយស្រាក់ស្រែកហៅ រកព្រះចមចៅ ពុំយល់ឡើយនៃ
កូនអើយម្ដាយអា- សូរបាហាលថ្ងៃ ម្ដាយឈប់អាស្រ័យ

ក្រោមដើមក្រស្នា ។

៤៤៩— ម្ដាយយកសំពត់ នេះឯងម្ដាយបត់ ម្ដាយក្រាលផ្ដេកបា
យកព្រះទម្រង់- រ័តន៍ផ្ទំនេះណា៎ ម្ដាយចងដៃបា

ហើយម្ដាយផ្ដេកនៅ ។

ក្រោមដើមក្រស្នា ម្ដាយបំបៅបា ស្រេចហើយម្ដាយទៅ
រកព្រះជៀស្ដជ័យ ដោយព្រៃជ្រោះជ្រៅ ពុំយល់ព្រះចៅ

ម្ដាយវិលមកថ្វាត់ ។

ដល់ដើមក្រស្នា ម្ដាយពុំយល់បា ស្មារតីម្ដាយបាត់
ដួលសន្ទប់នា- ធរាហានបិត ហេតុត្បិតម្ដាយគិត

---

១ ក្លាយមកអំពីពាក្យ «ធរា= ដី»។

ស្រឡាញ់កូនក្រៃ ។

ម្ដាយសន្ធប់លង់ តែឯងឯកអង្គ កណ្ដាលទ្រូងព្រៃ
លុះភ្ញាក់ស្មារតី ម្ដាយពិលាបក្រៃ តាមកូនមាសថ្លៃ
ដោយដានទោះណា ។

ម្ដាយដើរព្រៃស្ងាត់ ឃើញតែហ្វូងសត្វ យង់យ្ហងពាធា
ម្ដាយសោយសោកសល់ ខ្លួញទល់ទុក្ខា ម្ដាយមករកបា
ដល់ស្រុកនេះនៃ ។

៤៩០– ម្ដាយមកជួនយប់ កូនអើយម្ដាយឈប់ សំចតអាស្រ័យ
ផ្ទះយាយមាលា គាត់ជាពេកក្រៃ ឃាត់ម្ដាយនៅនៃ
ទឹងគាត់ហោងណា ។

ហើយគាត់និយាយ ដំណើរប្រាប់ម្ដាយ ថាព្រះរាជា
នាមព្រះព្រហ្មទត្ត មហាក្សត្រសើបា យកចិញ្ចឹមជា-
កូនធមិក្សត្រថ្លៃ ។

ម្ដាយគិតបង់មក កាន់កូនពន្ធក ខ្លាចក្សត្រជៀសជ័យ
ព្រះអង្គយល់ម្ដាយ មេម៉ាយបុះនៃ ក្រែងមហាក្សត្រថ្លៃ
យកជាមហេសី ។

ម្ដាយនៅលង់ណា៎ សោឡសវស្សា ម្ដាយតែងក្រងភ្ញី
ឲ្យយាយមាលា នាំផ្កាមកខ្ញី ថ្វាយព្រះនរបតី
និងបាងឯងហោង ។

ក្រែងកូនមាសថ្លៃ បានយល់លាយដៃ ផ្កាដែលម្ដាយក្រង
ហើយបាឲ្យយក ម្ដាយមកដូចប៉ង បានជួបជួនផង
កូនស្ងួនពុំងា ។

៤៩៥— សម្ដេចកូមី ស្ដាប់ព្រះជននី បន្ទូលប្រាប់ប្រ-
ការដូរឈ្មោះនៃ ក្សត្រថ្លៃសោកា បន្ទូលខ្ញូញថា
ឱអម្ចាស់ថ្លៃ ។

ម្ដេចឡើយអ្នកម្ដាយ លំបាកអម្បាយ ពេកពន់ណាស់ក្រៃ
ប្រាសម្ដេចទាំងកូន សោះសូន្យទីទៃ ប្រាសទាំងជៀសស្ន័យ
ព្រះវរបិតា ។

ឱព្រះជននី កាលកូនចាកពី- ឱទអ្នកណា៎
បានបីទិនទាត់ ហើយប្រាសព្រាត់គ្នា លង់លុះជួបជា-
សោឡសឆ្នាំនៃ ។

ក៏កូនពុំបាន ស្គាល់អ្នកមេមាន គុណគាប់ប្រពៃ

ហេតុបាបកូនឯង ពៀរព្រេងក្រាស់ក្រៃ ឲ្យឃ្លាតទីទៃ
នឹងព្រះមាតា ។

កូនជួបតិរច្ឆាន សត្វជួសមាឲ្យ មែនមិនស្គាល់ជា-
អ្នកមេមានគុណ មហាធ្ងន់ឡើយណា៎ នេះហេតុវេរ
កម្មកូនឯងនែ ។

៤៦០— មកផ្តល់កូនហើយ អម្ចាស់កូនអើយ ទើបតែនាថ្ងៃ-
នេះកូនស្គាល់អ្នក- មេជៀងជាក់ក្រៃ ជននីនេះនៃ
កូនសោយសោកសល់ ។

កូនឃើញអ្នកហើយ អម្ចាស់កូនអើយ កូនជាទុក្ខទល់
តាន់តឹងទុក មួយប្រការកល ត្បិតកូនពុំយល់
ព្រះវរបិតា ។

អ្នកអើយកូនស្តាប់ ពាក្យអ្នកម្តាយប្រាប់ កូនវែងឈឺផ្សា
ផ្សាយផ្សព្វអស់អង្គ ប្រត្យង្គទយា ត្បិតកូនកំព្រា
ប្រាសព្រះបមចៅ ។

ឱព្រះបិតា- ធិពជឃ្លាតឃ្លា ប្រាសពីកូនទៅ
ជាព្រះអង្គមាន វិញ្ញាណរស់នៅ ឬមួយព្រះចៅ

ក្សីណក្ស័យជន្មា ។

ឱព្រះទេសពល កូនពុំបានយល់ ព្រះកក្ត្រអ្នកណា
ហេតុបាបកូនឯង ពីព្រេងវេក ផ្តល់កូនកាលគ្រា
នេះឯងអ្នកអើយ ។

៤៦៨– អង្គព្រះមាតា នាងស្តាប់បុត្រា សោយសោកខ្លោះហើយ
នាងនាថវរជា- សោកាពុំស្បើយ ថ្លែងថាកូនអើយ
ម្តាយបាសត្វថ្ងៃ ។

នៅតែទីងទុក្ខ ត្បិតព្រះអាពុក- បាឃ្លាតទៃ
ម្តាយឈឺផ្សាផ្សេង សស្រេងសស្រៃ សន្ធឹកសន្ធៃ
ឥតស្បើយឡើយហោង ។

កូនអើយចូរបា ឲ្យសង់សាលា ឲ្យមានភោជន៍ផង
ហើយគួរនិយាយ អតិប្រាយដើមទង ដំណើរទំនង
កាលព្រាត់ប្រាសគ្នា ។

ក្រែងព្រះទេសពល ស្តេចដើរមកដល់ ស្រុកនេះស្តេចជា-
អ្នកកំសត់បាន យកមានយើងណា ហើយព្រះពជា
ទតគំនូរផង ។

បើស្ដេចទតយល់ សមសោយសោកសល់ មិនទេឡើយហោង
កូនអើយយើងបាន រួមឋានដូចប៉ង ទាំងបីជាម្ដង
ដូចចិត្តចិន្ដា ។

៤៧០– កូនអើយមួយទី កុំបាស្រដី ប្រាប់ព្រះរាជា
ថាជាម្ដាយឡើយ កូនអើយចូរបា អកប្រាយប្រាប់ថា
ជាករិយាហោង ។

៤៧១– ព្រះរាជបុត្រា ស្ដាប់ព្រះមាតា ករុណាក្រត្រចង្វាស់ចង្វង
គាត់តែងប្រដាប់ ឆាប់ ៗ ដូចប៉ង ស្ដេចត្រាស់ថាផង
នឹងអ្នកភ្នាក់ងារ ។

## បទពំនោល

១៥១-កាលនោះចៅក្រឹស្នកុមារ ត្រាស់បើអ្នកការ ប្រដាប់ឲ្យសង់សាលា ។
គ្រិតស្ដេចមានព្រះទយា ទ្រង់ព្រះសទ្ធា នឹងស្អាងព្រះរាជកុសល ។
អាមាត្យបង្គំទសពល ទៅតែងខ្វាយខ្វល់ ប្រដាប់សង់ជាសាលា ។
ជាងជៅធ្លាក់ធ្មៅរចនា ហាងហង្សដហ្វា កំសឹងបិទមាសព្រាលផ្កា ។
១៥៥-ស្រេចហើយអាមាត្យចូលទៅ ក្រាបទូលព្រះចៅ ពំរាបព្រះទ័យភូបាល។
ករុណានោះចៅក្រឹស្នកុមារ ឲ្យតែងភ្នាក់ងារ មកគួរគំនូរបើប្រពៃ ។

មានជាន់ស្រាប់ស្រេចហើយនៃ ក្សណក្សត្រជៀស្លជ័យ នូវព្រះវរាជមាតា ។
ស្ដែនស្ដេចទៅដល់សាលា ទើបព្រះមាតា បង្គាប់ឲ្យអស់ជាន់ផង ។
តូរដោយដំណើរទំនង និយាយដើមទង ព្រះបាទសម្ដេចជេដ្ឋា ។
ល្វែងមួយគូរកាលពជា គង់យន្តយាត្រា មកជាអាមាត្យក្សត្រថ្ងៃ ។
ព្រះចៅបញ្ចាលជៀស្លជ័យ ល្វែងមួយនោះនៃ គូរកាលសម្ដេចពជា ។
ស្ដេចទ្រង់ព្រះសុគន្ធា ជិតអស់អង្គា ក៏ប្រាលរន្ទាលផ្អិនផ្អៅ ។
ល្វែងមួយគូរកាលព្រះចៅ បញ្ចាលឲ្យហៅ ស្ដេចទៅហើយទ្រង់គ្រោធា ។
ឲ្យអស់ពេជ្ឈឃាតផងពក នាំព្រះពជា ទៅដល់នាក្នុងព្រះព្រៃ ។
ល្វែងមួយគូរកាលក្សត្រថ្ងៃ គង់យន្តមាសម័យ ហោះទៅដល់ប្រាសាទរ័ត្ន ។
ល្វែងមួយគូរកាលមហាក្សត្រ នាំនាងនាថថ្កាត់ ហោះចេញពីឋាននោះណ៎ា ។
ល្វែងមួយគូរកាលពជា កើតយន្តរេក កាលផ្ដាំនៃព្រះជននី ។
ល្វែងមួយគូរកាលភូមី ស្ដេចហៀរហោះពី- នោះទៅឈប់ក្រោមព្រះជ្រៃ ។
ខានផ្ទេរស្រះស្រង់នោះនៃ ហើយក្សត្រីថ្ងៃ ប្រសូតព្រះពជបុត្រា ។
ហើយស្ដេចដងព្រះគង្គា ស្រង់ពជបុត្រា ស្រង់តាំងអគ្គមហេសី ។
ល្វែងមួយគូរកាលភូមី គង់យន្តហោះពី- កម្ពុងព្រះជ្រៃនោះណ៎ា ។

ទៅយកភ្លើងពីកេត្រា ល្ងៃមួយគូរជា នាងនាថទូវបុត្រាថ្លៃ ។
នៅរង់ក្រោមដើមព្រះជ្រៃ ខាងធ្នូរផលស័យ តែពីព្រះអង្គឯងហោង ។
នាងឲ្យគូរស្រេចហ្មត់ហ្មង ដោយបទទំនង ដំណើរដំណាលរាជា ។
១៧៩-នាងទតហើយសោយសោកា ទួញទៅរាជា ព្រះរៀមព្រះរាជស្វាមី ។
ព្រះរាជបុត្រាសីនតី- លោបផងជនទី ទាំងពីរព្រះអង្គសោកា ។
លុះបន្ទោសោកហើយណា នាងតែងភោជន៍អា- ហារផងអនេកពេកក្រៃ ។
ឲ្យជាទានទិព្វបីប្រពៃ ស្មូមយាចកនៃ ជាសព្វប្រក្រតីទៅណា ។
ហើយនាងនាថឲ្យទ្រព្យា ដល់យាយមាលា ឥតខ្វះកន្លះឡើយហោង ។
១៨០-ហើយឲ្យជាសេដ្ឋីផង ជាធំកន្លង លៃងអ្នកទាំងឡាយនានា ។
ហើយនាងឲ្យចាំសាលា បើអ្នកឯណា ចូលមកយកទានយើងហោង ។
ឲ្យមើលអស់គំនូរផង ដោយបទទំនង ដំណើរនិយាយនេះណា ។
ថាបើមើលហើយសោកា ចូលយាយម្ចា ទៅប្រាប់អញកុំលង់ឡើយ ។
នាងផ្តាំយាយមាលាហើយ ក្សិណក្សត្រព្រាណត្រើយ នូវរាជបុត្រាថ្មើមថ្ងៃ ។
១៨៩-វិលច្ហានប្រាសាទមាសម័យ ព្រួយព្រះហឫទ័យ អំពល់នូវទោមនស្ស ។
ឯព្រះព្រហ្មទត្តរាជា ស្តេចពុំដឹងថា ជនទីនិងបុត្រាឡើយ ។
ស្តេចថាជាករិយាហើយ ក្សត្រាត្រាណត្រើយ ស្តេចសោមនស្សាភិរម្យ ។

យើងថ្លែងឯនាងបទុម- កេសរឧត្តម បានជួបនឹងកដបុត្រា ។
យើងស្ងេះទុកសិនវិញណា៎ ហើយយើងចរចា ឯនាយសំពៅមួយនៃ ។
១៩០-ដែលរើសហង្សយន្តមាសម័យ ចូលមកជួញញ- នគរពារាណសី ។

## បទកាកគតិ

៤៧២— នេះបទកាកគ- តិទើបចរចា ពីនាយសំពៅ
រើសរូបហង្សមាស ឆ្កុះឆ្លាស់នាំទៅ ថ្វាយព្រះបមទៅ
ព្រហ្មទត្តក្ខរ ។
វិកាលនោះណា៎ ឯនាយគេត្រា នាមឈ្មោះសាគរ-
ពាណិជលីលា ចេញចរទៅមក ចូលជួញនគរ
ពារាណសី ។
ឯនាយសំពៅ ពិភាក្សាទៅ ផងកូនក្មួយខ្ញី
ថារូបហង្សមាស ឆ្កុះឆ្លាស់ស្មើ យើងទុកធ្វើអ្វី
ឥតការទេណា៎ ។

៤៧៤— យើងយកទៅថ្វាយ មហាក្សត្រពណ្ណរាយ ផាគុណអាត្មា
យើងបានរង្វាន់ គ្រប់គ្រាន់មហិមា ឯចិត្តអស់គ្នា
តើគិតម្ដេចទៅ? ។

ឯអស់កូនក្មួយ　　សោកសឹងព្រមដោយ ដូចនាយសំពៅ
ទើបនាំរូបហង្ស　　បញ្ចូនផ្អិនផ្អៅ　　ឡើងថ្វាយព្រះចៅ
　　សម្តេចរាជា ។

ក្សិណនោះព្រះអង្គ　　ទតយល់យន្តហង្ស　　ហើយទើបក្សត្រា
ត្រាស់សួររួសរាយ　　ទៅនាយកេត្រា　　ចៅបានពីណា
　　ហង្សមាសផ្អិនផ្អៅ ? ។

ចៅអើយឯអង្គ　　នៃម្ចាស់យន្តហង្ស　　នេះកើតជាទៅ
ឯណាបាត់បង់　　បានហង្សមកចៅ　　នាំមកសំដៅ
　　ថ្វាយអញនេះនៃ ? ។

ទើបនាយកេត្រា　　បង្គំទូលថា　　បពិត្រក្សត្រថ្វៃ
រីរូបហង្សមាស　　ត្លុះធ្លាស់ប្រពៃ　　ខ្ញុំរើសនៅនៃ
　　កណ្តាលជលសា ។

សូមទានឯអង្គ　　នៃម្ចាស់យន្តហង្ស　　នោះកើតទៅណា
បាត់ពុំអាចបាន　　ដឹងដានសោះសា　　យើងខ្ញុំអស់គ្នា
　　រើសបានតែហង្ស ។

នាងនាថបទុម-　　កេសរទុត្តម　　ក្សត្រីរម-

ផ្គលគាប់សួស្ដីសល់ យង់យល់យន្ដហង្ស ដែលព្រះរៀមគង់
ហៀវហោះយាត្រា ។

នាងយកព្រះករ ទាំងពីរនាងគ- គគក់ទុក
នាងទុបហង្សយន្ដ ស្រីគន់សោកា បន្ទូលទួញថា
ឱ! អម្ចាស់ថ្លៃ ។

នាកាលព្រះចៅ ប្រាសពីប្អូនទៅ កណ្ដាលទ្រូងព្រៃ
ស្ដេចគង់យន្ដហោះ ផ្លុកផ្លោះឯឰ- អាកាសនាយនៃ
ទៅរកអគ្គី ។

ឥឡូវហង្សយន្ដ មាសម៉យធ្លាក់អ- ណ្ដែតដោយនទី
ឯអគ្គក្សត្រថ្លៃ ស្ដេចក្ស័យជីវី ឬមួយភូមិ
មែនមានជន្មា ។

៤៨៥– ប្អូនយល់តែហង្ស ម្ដេចបាត់ព្រះអង្គ ពុំឃើញឡើយណា
ទ្រូងប្អូនស្ទើរខ្លោច ល្អោះល្អោចទុក ខ្លោចហើយឈឺផ្សា
ក្ដៅហើយក្ដៅក្ដាត់ ។

ហាក់ដូចអ្នកយក នូវអគ្គីមក ដុតគរបង្កាត់
ឆួលឆេះក្ដៅថ្លើម ដង្ហើមប្រមាត់ ផ្សាផ្សែងក្ដៅក្ដាត់

អស់ឥន្ទ្រិយកាយ ។

ខ្ញុំទូលទុក្ខពី- ប្រាសព្រះភូមិ ក្សត្រថ្លៃពណ្ណរាយ
ប្អូននៅទីងទុក្ខ ពុំសុខសប្បាយ ឥតឯរសាយ
ផល់ប៉ុនកេសី ។

ឯកជបុត្រា សឹងសោយសោកា ព្រមព្រះជននី
ក្សិណនោះព្រះអង្គ ស្តេចផ្ចង់ស្មារតី បន្ទោរសោកពី-
ព្រះទុករតន៍ ។

ទើបព្រះភូមី ទូលព្រះជននី អង្វរលោមឃាត់
កុំឲ្យសោយសោក អមោក្សពេកក្តាត់ ព្រះមាតាក្សត្រ
ស្តេចស្តាប់បុត្រថ្លៃ ។

៤៩០— លោមឃាត់ហ្នោះណា ទើបព្រះមាតា កំសាន្តហឫទ័យ
បន្ទោរសោកចង់ ពុំលង់ឡើយនៃ ទើបព្រះជៀសឆ្ងៃ
សម្តេចរាជា ។

ស្តេចឲ្យកិត្តិយស ឲ្យទ្រព្យរបស់ ទៅហៅគេត្រា
ហើយឲ្យរង្វាន់ គ្រប់គ្រាន់អស់ពា- ណិជផងនោះណា
ឥតខ្វះឡើយហោង ។

ឯនាយកេត្រា　　នូវអស់ទាំងពា-　　ណិជគួនគ្ឃួយផង
ទទួលព្រះទាន　　ក្សត្រក្សាន្តឥតគ្គង់　　ក្រាបលាវឹងផ្គង
ទៅឋានកេត្រា ។

កាលនោះប្រាកដ ឯនាយសមុទ្រ-　　គោចរវិញណ៉ា
ដែលស្រង់ព្រះបាទ　　នរនាទជេដ្ឋា　　ស្តេចទ្រង់នាមា
ព្រះសុវណ្ណកុមារ ។

បើកកេត្រាចរ　　ចូលជួញនគរ　　សម្តេចភូបាល
បតជិតកេត្រា　　នាយសាគរកាល-　　នោះទើបនាយនាថ
សមុទ្រគោចរ ។

៤៩៥– គាត់តែងឆាប់ៗ　　រៀបចំប្រដាប់　　អស់ទ្រព្យាករ
នាំឡើងទៅថ្វាត់　　ថ្វាយក្សត្រភូធរ　　ជាចៅនគរ
ពារាណសី ។

ក្រញូក្រាបទូនអង្គ　　លុតលើកកំបង់　　ថ្វាយវរវត្ថុយ
ក្សិណនោះព្រះមហា-　　ក្សត្រាធិបតី　　ឲ្យរង្វាន់ខ្ញី
ដល់នាយកេត្រា ។

ឯនាយសំពៅ　　ក្រាបលាព្រះចៅ　　សម្តេចរាជា

នាំកូនក្មួយស្មោះ បរបុះម្មីមា មកឋានកេត្រា
សូរបេហើយហោង ។

ក្សិណានោះកូបាល ព្រះសុវណ្ណកុមារ ក្សត្រថ្ងៃច្បាស់ច្បង
ស្ដេចនៅទីងទូក ពុំសុខប៉ុនល្អង ព្រះហឫទ័យប៉ង
រកព្រះប្អូនពៅ ។

ស្ដេចស្ដែងបរបុះ ពីកេត្រាក្ដោះ បេញបរសំដៅ
ដើរដោយផ្សារផង គន់គ្រប់រៀងទៅ ពុំឃើញប្អូនពៅ
ពន្ទុកឡើយហោង ។

៩០០– ស្ដេចដើរដោយផ្សារ ឃើញគ្រប់សព្វសារ- ពើទំនិញផង
ឈ្មួញឆ្ងាយតូចធំ ចុះជុំអឺងកង ច្រើនក្រៃកន្ទង
ដាក់ផ្សារនោះណា៎ ។

ក្សិណានោះព្រះពៅ ស្ដេចលីលាទៅ បានដល់សាលា
ស្ដេចឈប់សម្រាន្ត នាហ៎ននោះណា៎ សម្ដេចរាជា
ស្ដេចទតគយគន់ ។

ស្ដេចយល់គំនូរ កំណាព្យក្បាច់ក្បូរ និយាយហង្សយន្ត
ក្សិណក្សត្រខ្សឹកខ្សួល ឯងអួលអាក់អន់ ស្ដេចទ្រង់ព្រះក-

នៃស្រីសោកខ្ញួញថា ។

ឱគំនូរនេះ អ្នកណាគេចេះ ដឹងដំណើរណា៎
កាលអញព្រាត់ប្រាស ប្អូនមាសស្នេហា ហើយអ្នកជាងជា-
គំនូរនេះនៃ ។

ឱល្វែងមួយនោះ ដូចកាលអញហោះ មកនៅអាស្រ័យ
ជាកដអាមាត្យ ព្រះបាទក្សត្រថ្លៃ ល្វែងមួយនោះនៃ
កាលអញឯងណា៎ ។

៥០៩— លាយលាបអស់ម្សៅ ក្អាលប្រាលខ្ពៅ ខែងទាំងអគ្គា
ល្វែងមួយសុទ្ធក្អាត់ ដូចក្សត្រក្រោធា ឲ្យពេជ្ឈឃាតក
នាំអញដល់ព្រៃ ។

ឱ! ល្វែងមួយនោះ ដូចកាលអញដោះ បានរួចពីភ័យ
ជិះយន្តហង្សហោះ ផ្លូកផ្លោះទៅឮ- ប្រាសាទប្អូនថ្លៃ
មិត្តមាសតុំងា ។

ឱល្វែងមួយនោះ ដូចកាលយើងស្មោះ ទាំងពីរអង្គា
ទៅផ្តាំជននី ប្អូនស្រីហើយណា៎ ហើយហោះយាត្រា
ឆ្ពោះទៅឯងនៃ ។

ឱ! ល្វែងមួយនោះ ដូចកាលយើងចុះ ឈប់ក្រោមម្លប់ជ្រៃ
ខាងឆ្នេរស្រះស្រង់ កម្ពុជលស័យ ហើយព្រះប្អូនថ្លៃ
ប្រសូតបុត្រា ។

ល្វែងមួយដូចអង្គ អញដងទឹកស្រង់ កូនស្ងួនពុំផា
ស្រង់តាំងនាងនាថ សង្សារស្នេហា ល្វែងមួយនោះណា
សុទ្ធសាធអស់ក្តី ។

៥១០— ហាក់ដូចកាលអង្គ អញជិះយន្តហង្ស ហោះរកអគ្គី
ល្វែងមួយដូចស្ងួន ខ្ញុំមខ្លួនពិសី និងបុត្រភ្ញាប្រិយ
នៅក្រោមព្រះជ្រៃ ។

ឱ! អង្គប្អូនមាស ពីកាលបងប្រាស សោឡសឆ្នាំនៃ
ហោះរកអគ្គី ពុំយល់មុខម័យ មាសស្នេហ៍ថ្មើមថ្លៃ
ថ្ងៃនេះបងយល់ ។

និយាយគំនូរ កំណាព្យក្បាច់ក្បូរ អស់ប្រការគល
សុទ្ធសាធដូចហៅ ប្អូនពៅនិមិល មាសអើយបងទល់
ទុក្ខទៀងវិញខ្ញី ។

ឱ! អ្នកឯណា មែនមានប្រាជ្ញា អង់អាចដឹងពី-

ដំណើរអញប្រាស  ប្អូនមាសពិសី  ហើយគួរជាទី-
យាយនៅនេះនៃ ។

រីកាលនោះណា +  អ្នកតាំសាលា  យល់ក្សត្រជៀសជ័យ
ស្ដែងស្ដេចសោយសោក អមោក្យពេកក្រៃ  រត់ទៅវៃ ៗ
ប្រាប់យាយមាលា ។

៤១៤— ឯយាយស្ដែងស្ដាប់  គេដំណាលប្រាប់  អររត់ម្នីម្នា
ទៅទូលក្សត្រី  ទេវីសោភា  ដោយដំណើរការណ៍
បានជ្រាបហឫទ័យ ។

នាងជឿជាក់ជា-  ព្រះរៀមស្នេហា  ហើយត្រាស់ថាហៃ
យាយអើយចូរឆាប់  ប្រញាប់វៃ ៗ  ឥឡូវនេះនៃ
រត់ទៅម្នីម្នា ។

អញ្ជើញព្រះអង្គ  មកផ្ទាត់កុំលង់  ឥឡូវស្រក៏
ក្សិណនោះឯយាយ  ក្រាបថ្វាយវន្ទា  បង្គំលុតលា
នាងនាថទេវី ៗ

ទៅដល់សាលា  ទើបយាយមាលា  ទូលព្រះភូមី
បពិត្រព្រះបាទ  នរនាថនរបតី  ពីព្រះប្អូនស្រី

អនុផពុំង៉ា ។

ប្រើខ្ញុំមកថ្កាន អញ្ជើញក្សត្រក្សាន្ត ទៅផ្លូវណា

ក្សិណានោះព្រះបាទ នរនាថជេដ្ឋា ស្ដាប់យាយមាលា

ទូលព្រះភូមី ។

៤២០- ទើបស្ដេចត្រាស់ថា ប្អូនអញនោះណា តើនាមឈ្មោះអ្វី?

ឯយាយមាលា ទូលថាក្សត្រី នាមនាងទេវី

បទុមកេសរ[1] ។

នាងព្រាត់បុត្រា គេមោចកំព្រា ក្នុងព្រៃក្សាករ

នោះទើបនាងនាថ ខ្ញុំឃ្លាតចេញចរ មកដល់នគរ

---

១ ច្បាប់ខ្វះថា

ស្ដេចត្រាស់សួរថា ប្អូនសួនពុំងា ប្រសើរសល់ស្រី

អង្គអញនោះណា តើនាមឈ្មោះអ្វី ទូលយាយស្រដី

ប្រាប់មកឆាប់ហោង ។

ឯយាយមាលា លុះលុតបាទា ករប្រណម្យផង

ទូលថាក្សត្រី ទេវីទងវង ព្រះនាមពិតផ្គង

បទុមកេសរ ។

នេះឯងហោនណា៎(១) ។

ឥឡូវនាងបាន ជួបចូលរួមហាន ទីងពជបុត្រា
ទាំងពីរព្រះអង្គ បានទ្រង់ពជា ស្ដេចគ្រងសីមា
ពាពណសី ។

សម្ដេចពជា ស្ដាប់យាយមាលា ទូលព្រះចក្រី
ស្ដេចជឿជាក់ជា- ព្រះអគ្គមហេសី សម្ដេចភូមី
ត្រេកសោមនស្សា ។

ក្សណនោះព្រះពៅ ស្ដេចលីលាទៅ ផងយាយមាលា
ឯព្រះមហេសី ក្សត្រីសោភា មើលផ្លូវពជា-
ធិពជបមក្សត្រ ។

៤២៥— នាងនាថយង់យល់ ព្រះវៀមស្ដេចផល់ នាងរត់មកថ្វាត់
ឱបព្រះបាទា សោភាពេកក្ដាត់ សន្ទប់បង់បាត់
ស្មារតីពុំលង់ ។

---

១ ច្បាប់ខ្លះថា

នាងព្រាត់ភស្ដា ធ្ងវិភជបុត្រា ក្នុងព្រៃក្សាករ
នោះទើបនាងនាថ សង្វាតបីរបរ មកដល់នគរ
ស្រុកនេះឯងណា៎ ។

សម្តេចរាជា សោកសន្ធប់ណាំ ទាំងពីរព្រះអង្គ
បុត្រាសោកសព្វ សន្ធប់បាត់បង់- ស្មារតីពុំលង់
ទាំងបីក្សត្រថ្លៃ ។

ឯយាយមាលា សោកសឹងសោកា អាណិតពេកក្រៃ
អក់យាយស្រីការ ស្រឹង្គារផងនៃ សឹងភ្ញាកិតភ័យ
ថ្ងៃងថ្ងឹងពុំបាន ។

គេជះសម្ការ សម្តេចភូបាល ស្អាងពីបុរាណ
កក្រើកទៅដល់ មណ្ឌលទិព្វឋាន អាសនាពិមាន
សម្តេចឥន្ទ្រា ។

ព្រះឥន្ទ្រប្រែក្រ្ត ស្តេចបើកទិព្វចក្សុ ទតយល់ព្រះមហា-
ក្សត្របីព្រះអង្គ បាត់បង់ជន្មា ស្តេចហោះម្មីម្មា
ចុះមកពុំលង់ ។

៤៣០— ក្សិណនោះកោសិយ យកទឹកមកពី- ស្ពូគិសោតស្រោចស្រង់
ទាំងបីមហាក្សត្រ ភ្ញាក់ថ្វាត់ពុំលង់ បរិបូណ៌បានគង់
ជន្មាវិញហោង ។

មហាក្សត្រទាំងបី រុងរឿងរស្មី ឥតអ្នកផ្ទឹមផង

ទើបព្រះឥន្ទ្រា លីលាហោះផ្សង វិលវឹងទៅផ្គង
ពិភពសួគ៌ា ។
កាលនោះមហាក្សត្រ ចមទៅចក្រវត្តិ នូវរាជបុត្រា
នូវអគ្គមហេសី ទេវីសោភា មែនមានជន្មា
ផុតផុងស្មារតី ។
នាងនាថជាយា សែនសោយសោកា ខ្សួញខ្សូលស្វាមី
ដោយដំណើរកាល នាងនាថទេវី ព្រាត់ប្រាសពិតពី-
ព្រះរៀមកជា ។
ឱ! អម្ចាស់ថ្លៃ នាកាលជៀសភ័យ ប្រាសខ្ញុំមិញណា
ខ្ញុំសោយសោកសល់ ខ្សួញខ្វល់ទុក្ខា ដល់សន្ធប់ទា-
កណ្តាលទ្រូងព្រៃ ។
៤៣៤— ខ្ញុំភ្ញាក់ស្មាតី បីបុត្របរលី- លាកក្សត្រថ្លៃ
ហើយខ្ញុំចូលឈប់ ដោយម្ចប់អាស្រ័យ ផ្តេកកូនទៅនៃ
ក្រោមដើមក្រស្នា ។
ហើយខ្ញុំតែកែ ព្រះអង្គពន្ធក ដោយដងអញ្ញា
ក្រោយនោះមហាក្សត្រ ព្រហ្មទត្តជា រើសរាជបុត្រា

ស្ដេចយកមកហោង ។

ខ្ញុំសោយសោកសល់ រកព្រះទសពល ដោយជ្រោះជ្រលង

ពុំយល់ភូមិ ដូចក្ដីបំណង ហើយខ្ញុំវិលផ្គង

ដល់ដើមក្រស្នា ។

រកបុត្របាត់បង់ ខ្ញុំគក់ទ្រូងទ្រង់ កន្សែងសោកា

ដល់ជួលសន្ទប់ សូន្យសត្វនៅណា- កណ្ដាលអដ្វា

តែឯកឥន្ទ្រិយ ។

ក្នុងព្រះព្រៃស្ងាត់ សន្ទប់លង់ក្ដាត់ ខ្ញុំភ្ញាក់ស្មារតី

ខ្ញុំតាមដោយដាន មកឋានបុរី ពារាណសី

នេះឯងហោងណ៉ា ។

៤៤០— ហើយខ្ញុំអាស្រ័យ ពុំទាក់នៅព- ផ្ទះយាយមាលា

ទើបគាត់រៀបរាប់ ប្រាយប្រាប់ខ្ញុំថា ព្រះបាទក្សត្រា

នាមព្រះព្រហ្មទត្ត ។

ស្ដេចទៅប្រពាត ព្រៃទើបព្រះបាទ រើសពជបុត្ររ័តន៍

សម្ដេចរាជា ករុណាពេកក្ដាត់ ហើយស្ដេចវិលថ្វាត់

មកឋានបុរី ។

ព្រះអង្គយកជា បុត្រធម៌ស្នេហា ថ្នាក់ថ្នមបេតី

គាត់ថ្លែងប្រាប់ខ្ញុំ　សុខុមភទី　ពុំឲ្យស្រដី
សុសសាយឡើយណ៊ា ។
ខ្ញុំនៅនឹងគាត់　ជាអំឡុងក្តាត់　សោឡសស្យា
លុះកូនសំឡាញ់　ពាលពេញរូបា　ទើបព្រះរាជា
ព្រហ្មទត្តឧត្តម ។
ព្រះអង្គឲ្យរក　រើសខ្ញុំឯងមក　ហើយស្តេចឲ្យផ្សំ
នឹងកូនឯងណ៊ា　បុត្រាសោតពុំ　បានស្គាល់អញខ្ញុំ
ជាជននីឡើយ ។

៤៨៥— លុះស្បូរេចការ　ទើបខ្ញុំដំណាល　ប្រាប់បុត្រត្រាណត្រើយ
កូនស្គាល់ខ្ញុំជា-　មាតាជាក់ហើយ　សោយសោកពុំស្បើយ
ខ្ញួរកក្សត្រថ្លៃ ។
ហើយខ្ញុំក៏មត់　នឹងព្រះរាជបុត្រ　ព្រហ្មទត្តជៀសជ័យ
ថាខ្ញុំនិងកូន　បុត្រស្នួនវិស័យ　ជាអ្នកជទៃ
គូគួរផងគ្នា[1] ។

---

១ តាមសាស្ត្រាស្លឹករឹតនៅពុទ្ធសាសនបណ្ឌិត្យ ល. ៤៦៦ – ៤៦៨ ថា:

ហើយខ្ញុំមោសា　ប្រាប់ព្រះរាជា　ព្រហ្មទត្តជៀសជ័យ
ថាខ្ញុំនឹងកូន　សោះស្នួនវិស័យ　ជាអ្នកជទៃ
គូមួយនឹងគ្នា ។

ទើបខ្ញុំបង្គាប់ ឲ្យកូនប្រដាប់ តែងសង់សាលា
ហើយគូរផាទិ- យាយពីកាលគ្រា ខ្ញុំប្រាសព្រះមហា-
ពន្ធកថ្មើមថ្ងៃ ។

លុះស្រេចសាលា ទើបនាយកេត្រា មួយនោះមានក្រៃ
យកយន្តឧត្តម ដែលអម្ចាស់ថ្លៃ តែងគង់នោះនៃ
នាំមកឲ្យខ្ញុំ ។

ប្អូនយល់យន្តហង្ស ពុំឃើញព្រះអង្គ ខ្ញុំគក់ទ្រូងយំ
ថ្ងួញទល់ទុក្ខា ឧរាប្អូនក្រំ សព្វថ្ងៃពិតពុំ-
ស្រាកស្រាន្តល្ហែល្ហើយ ។

៤៤០— ឱ! អម្ចាស់ថ្លៃ ព្រះអើយទើបថ្ងៃ- នេះខ្ញុំបានស្បើយ
ទុក្ខសោកទាំងឡាយ រសាយបង់ហើយ ទ្រូងប្អូនអ្នកអើយ
អរឥតគណនា ។

## បទព្រហ្មគីតិ

៤៨៤- កាលនោះព្រះភូមី ស្តាប់ប្អូនស្រីស្តេចសោកា
ហើយទើបព្រះពជា បន្ទូលប្រាប់ព្រះប្អូនគន់ ។
ឱ! ប្អូនមាសស្នេហ៍ស្ងួន នាកាលបងជិះហង្សយន្ត

ហោះតាកចម្បៃងគន់ ទៅយកភ្លើងពីកេត្រា ។
បងតាប់យកភ្លើងបាន ដាក់លើយានយន្តហើយណា៎
ហោះចេញពីកេត្រា ភ្លើងមិញឆេះខ្សែយន្តនោះ ។
ធ្លាក់ក្នុងព្រះគង្គា បងសោកណា៎សឹងធ្លាក់ចុះ
កណ្ដាលជលសាសោះ សាត់ព្រាត់ព្រាយយន្តមាសម័យ
បងមិនគិតឃ្លានខ្លួន គិតតែស្ងួននិងបុត្រថ្លៃ
ត្រមោចកណ្ដាលព្រៃ ក្រែងពុំរស់រូបជីវី ។
៤៩០- បងហែលហើយសោយសោក សែនអមោក្យក្នុងជលធី
គម្រប់ជាទិនបី ទើបបងបានយល់កេត្រា- ។
មួយបើកសំដៅថ្នង គេយល់បងក្នុងគង្គា
ហើយស្រង់បងម្ចា ដាក់លើសំពៅនោះនៃ ។
ប្អូនអើយបងទល់ទុក្ខ ពុំស្រណុកបានមួយថ្ងៃ
គិតតែប្អូនមាសថ្លៃ និងកូនស្ងួនកំព្រាសល់ ។
ទើបតែឆ្នាំនេះណា៎ នាយកេត្រាមកជួញដល់
ស្រុកនេះបងខ្វាយខ្វល់ ដើរត្រាច់រកស្ងួនឯងណា៎ ។
ពុំយល់មាសកល្យាណ បងរុករានដល់សាលា

បងយល់គំនូរជា- និយាយកាលយើងឯងនៃ ។
៥៩៥– លំបាកព្រាត់ប្រាសគ្នា បងសោកាពន់ពេកក្រៃ
គិតជាអ្នកដទៃ គេគូរទុកនៅសាលា ។
បងពុំដឹងជាស្ងួន មាសខ្ញុំមខ្លួនទិងបុត្រា
គាត់តែងឲ្យគូរជា- និយាយដូច្នោះប្អូនអើយ ។
ក្សត្រីនូវក្សត្រា ប្រាប់ទុក្ខគ្នាសូរេចហើយ
ទាំងបីក្សត្រត្រាណត្រើយ សឹងសោយសោកាណាល់ក្តាត់ ។
ពុំលង់ជ្រាបដល់នា នៃព្រះកាណិមហាក្សត្រ
សម្តេចព្រះព្រហ្មទត្ត ជាព្រះវរពជបិតា ។
ទើបព្រះបាទឥសូរ ស្តេចបន្ទូលប្រើអមច្ចា
ទ្រង់ព្រះបង្គាប់ថា អាមាត្យអើយចូលទៅទ្ធ ។
៦០០– ទូលសួរកូនកល្យាណ ថាតើមានសុខទុក្ខអ្វី
ថ្ងៃនេះក៏ស្តេចពី- លាបសោយសោកពន់ពេកក្រៃ ។
អាមាត្យលាក្សត្រក្សាន្ត ចូលទៅក្កានព្រះជៀស្លជ័យ
ក្រញ្ញក្រាបទូលដោយន័យ បង្គាប់ព្រះវរបិតា ។
ក្សិណានោះឯព្រះបាទ ស្តាប់អាមាត្យទូលច្នោះណា +

នោះទើបព្រះពជា ស្ដេចបន្ទូលត្រាស់ថាហៃ ។
អាមាត្យអើយចូរទៅ វិលវិញទៅទូលក្សត្រថ្លៃ
ឲ្យជ្រាបព្រះហឫទ័យ ត្បិតបងនាងនាថនិមិល ។
ព្រាត់គ្នាយូរលង់ក្រៃ ទើបនាថ្ងៃនេះបានយល់
គ្នាហើយសោយសោកសល់ ត្បិតដំណើរដូច្នោះណា+ ។

៦០៩— ក្សិណនោះឯអាមាត្យ លាព្រះបាទហើយយាត្រា
ទៅទូលព្រះបិតា ដូចបណ្ដាំពជបុត្រថ្លៃ ។
ឯអង្គព្រះបិតា ស្ដាប់អមច្ចាទូលច្នោះនៃ
ស្ដេចជ្រាបព្រះហឫទ័យ ជឿជាក់ជាបុត្រសង្សារ ។
ឯក្រោយអាមាត្យទៅ ក្សិណនោះហៅក្រស្នកុមារ
យកហង្សយន្តនោះណា+ មកថ្វាយដល់បិតាហោង ។
ទើបព្រះបិតាទ្រង់ ប្រដាប់ហង្សយន្តឥតគ្គង
ធ្វើខ្សែថ្មីហ្មត់ហ្មង ខ្ជាប់ដូចដើមបរិបូណ៌ថ្វាត់ ។
ក្សិណនោះពដកញ្ញា តែងអាហារជូនច្រើនក្ដាត់
ហេតុត្បិតព្រះមហាក្សត្រ ទីងទៅក្រុងទេពបុរី ។

៦១០— ទើបព្រះអង្គឲ្យហៅ នាយសំពៅមកតាំងទ្វី

ស្តេចឲ្យផ្អាក់ខ្ញី　　នាយកេត្រាតាំងពីរផង ។
ហើយស្តេចឲ្យទ្រព្យ　　យាយមាលាច្រើនកន្ទង
ស្រេចហើយក្សត្របួសបួង　　ស្តេចប្រដាប់ឲ្យជាទាន ។
សូរេចបរិបូណ៌ហើយ　　ពុំលង់ឡើយទើបក្សត្រក្សាន្ត
ស្តេចទឹងហោះទៅថ្កាន　　នគរក្រុងទេពបុរី ។
ស្តេចយកអាហារផង　　ដាក់ក្នុងហង្សយន្តមាសខ្ញី
ហើយទើបព្រះភូមី　　ទូរសម្តេចពជបុត្រា ។
ស្តេចធ្វើជាសំបុត្រ　　បិទប្រាកដនៅទ្វារប្រា-
សាទសោតឲ្យបានជា-　　ដំណឹងព្រះបិតាថ្វាត់ ។

៦១៥— ក្នុងពជសារនោះថា　　អក្ខរប្រសើរក្តាត់
គឺបុត្រក្រាបប្រណិប័តន៍　　ក្រញួក្រាបថ្វាយបង្គំលា ។
ព្រះជនកដ៏មានគុណ　　ប្រសើរលទ់ឥតគណនា
ឥឡូវត្បិតបុត្រា　　បានជួបជួនព្រះជននី ។
និងព្រះវរបិតា　　បង្កើតនាកាលនេះខ្ញី
ខ្ញុំលាព្រះចក្រី　　ទៅផងក្សត្រតាំងពីរពង្ស ។
កុំស្តេចបារម្ភណា +　　ខ្ញុំយាត្រាទៅទឹងហង្ស

យន្តហោះសំដៅត្រង់ ទេពបុរីរាជសីមា ។
ស្ដេចធ្វើរាជសារហើយ ពុំលង់ឡើយព្រះរាជា
យករាជសារនោះណា៎ បិទនៅទ្វារប្រាសាទថ្ម ។
៦២០— ក្សិណក្សត្របីព្រះអង្គ ស្ដេចឡើងគង់យន្តមាសម័យ
នារាត្រីនោះនៃ ស្ដេចកើចយន្តហើយហោះទៅ ។
មណ្ឌលមេឃស្រឡះ ចន្ទចែងជ្រះភ្លឺស្នៅ
ទាំងបីព្រះចមទៅ ស្ដេចក្រសាលព្រះហឫទ័យ ។
ក្សិណនោះព្រះបិតា- ធិរាជក្សត្រជៀស្ដដ័យ
ស្ដេចណែបុត្រាថ្ងៃ ឲ្យកើចខ្សែយន្តហង្សហោះ ។
ហើយស្ដេចបន្ទូលថា កូនអើយបាកើចយន្តផ្ដោះ
ត្រង់ទិសទក្តនោះ នគរយើងឯងហោងណា៎ ។
ចៅក្រឹស្នកុមារទ្រង់ កើចខ្សែហង្សយន្តសោភា
ហៀរហោះដោយវេហាស៍ ខ្ពស់ពេកផុតភ្នែកអ្នកផង ។
៦២៥— ព្រះចន្ទចែងត្រចះ ភ្លឺស្រឡះឥតឯហ្មង
ព្រះមហាក្សត្រច្បាស់ច្បង ហោះក្រសាលព្រះទយា ។
វេលាកាលរាត្រី ព្រះកូមីឈប់និទ្រា

ព្រឹកឡើងស្ដេចលីលា    កើតខ្សែយន្តហៀរហោះផ្សង ។
ព្រះមហាក្សត្រតាំងបី    ប្រសើរវិសេសកន្លង
ស្ដែងស្ដេចគង់យន្តផ្គង    គម្រប់ជួបសត្តទិវា ។
ដំណើរពោធិសត្វ    បុរសតេន៍ស្ដេចយាត្រា
ហៀរហោះដោយវេហាស៍    បញ្ឈប់ស្ទុះនៅនេះថ្កាត់ ។
ហើយយើងមកស្រដី    ថ្វាថ្លែងពីព្រះព្រហ្មទត្ត
កាលបើព្រះមហាក្សត្រ    ស្ដេចតើនចាកព្រះក្រឡា- ។
បន្ទំទិព្វរង្សី    ព្រះភូមីបានជ្រាបថា
បុត្របាត់ជូហោះណា    ស្ដេចសោយសោកឯងឥតស្បើយ ។
ក្សិណនោះព្រះទសពល    ស្ដេចមកដល់ប្រាសាទហើយ
រកពុំបានយល់ឡើយ    ស្ដេចទួញទ្រង់ព្រះកន្សែង ។
ឱកូនស្ងួនពុំងា    មាសអើយអាពុកធ្លាប់វែង
យល់មាសថ្ងៃគន់តែង    គង់ប្រាសាទប្រសើរសល់ ។
ម្ដេចឡើយថ្ងៃនេះណា    បង់បាត់បារកពុំយល់
កូនអើយអាពុកធ្ងល់    ត្បិតបាបាត់ឥតដំណឹង ។
បាបើកូនមាសមិត្ត    មានចិត្តគិតទីទៃផ្សេង

ប្រាប់ឲ្យអាពុកដឹង　　　ដោយដំណឹងនោះផងក៏ ។
៦៣៩— ម្ដេចឡើយក៏កូនរត់　　　ស្រាប់តែបាត់ដូច្នេះណា៎
កូនអើយក្នុងទ្រូងអា-　　　ពុកអួលផ្សាខ្លោចសាយសព្វ ។
អាពុកពុំដឹងរក　　　កូនពន្លកហើយថែថប់
ស្មារតីឡើនឡង់ឡប់　　　ត្បិតបុត្របាត់ចរចាកចេញ ។
ឱកូនស្ងួនកំព្រា　　　មាសអើយអាពុកស្រឡាញ់
រក្សាកូនលុះពេញ　　　កម្លោះបរិបូណ៌ហើយណា៎ ។
ឪពុករកប្រពន្ធ　　　ឲ្យកូនគន់ស្ងួនពុំងា
ហើយឲ្យគ្រងសីមា　　　ជាស្ដេចស្ដែងប្រសើរក្រៃ ។
ឱកូនធម៌តែមួយ　　　មាសជាត្រួយថ្លើមហឫទ័យ
ឪពុកបាសព្វថ្ងៃ　　　ទឹងផ្ញើខ្លួនលើស្ងួនភ្ងា ។
៦៤០— ត្បិតអាពុកត្រមោច　　　ទឹងផ្ញើខ្មោចនៅលើបា
ឥតបើមានអ្នកណា　　　ក្រៃទឹងកូនស្ងួនឧត្ដម ។
ឱបាបុត្រពន្លក　　　ពីតូចមកលុះដល់ធំ
ក៏ស្ងួនភ្ងាពិតពុំ　　　មានចិត្តវៀរពីឪពុក ។
លុះមាសស្ងួនទៃនគន់　　　យកប្រពន្ធនេះមិញទុក

ឲ្យបាបង់អាពុក　　នៅត្រមោចឯងកំព្រា ៗ
កូនអើយម្ល៉េះឪពុក　　តែងទល់ទុក្ខទោមនស្ស
ដរាបដល់ឃើញបា　　នោះទុក្ខអាពុកបានបាត់ ៗ
រីឯយាយមាលា　　សឹងសោកាតន់តេកក្តាត់
ទូញទៅព្រះមហាក្សត្រ　　ក្បិតវែងទ្រង់ព្រះករុណា ៗ
៦៤៩– អស់ពួកស្នំក្រមការ　　ស្រីស្រឹង្គារព្រះរាជា
ទូវអក់យាយផងណា　　ទូវអស់តាំងបរិពារផង ៗ
ទូវអស់មុខមន្ត្រី　　សឹងសោកពីលាបក្តាត់ហោង
ទូវប្រជារាស្ត្រផង　　សឹងសាយសោកតន់តេកក្តាត់ៗ
ក្សិណនោះព្រះទសពល　　ទតយង់យល់សំបុត្របិទ
នៅទ្វារប្រាសាទរ័តន៍　　ហើយស្តេចយកមកម្នីម្នា ៗ
ស្តេចទតសំបុត្រហើយ　　ពុំលង់ឡើយស្តេចក្រោធា
ត្រាស់ជេរយាយមាលា　　ថាមឹងចោរចាស់ឥតត្រើយ ៗ
មឹងជឹងនាងនេះណា　　ជាមាតាកូនអញហើយ
ម្តេចមឹងស្ងៀមព្រងើយ　　ពុំប្រាប់អញឲ្យដឹងផង ៗ
៦៥០– រីឯយាយមាលា　　ក្រាបវន្ទាហើយទូលស្នង

ថាខ្ញុំម្ចាស់សោកហោង　　ពុំបានដឹងដល់តិចឡើយ ។
ស្ដេចស្ដាប់យាយមាលា　　ក្រាបទូលថាដូច្នោះហើយ
ក្សិណនោះក្សត្រត្រាណត្រើយ　　សែនសោយសោកពន់ពេកក្ដាត់ៗ
សម្ដេចព្រះរាជា　　សោយសោកាឥតបុត្របាត់
ខ្ញួញទល់ទុក្ខទៀងទាត់　　ជានិរន្តរ៍ពៅហោងណា៎ ។
ដំណើរព្រះមហាក្សត្រ　　សោករ័តន៍បុត្រស្ងួនពុំផា
យើងនិទានពណ៌នា　　នូវប្រការតែម្ល៉េះហោង ។
៦៥៤— នេះទើបយើងថ្លាថ្លែង　　បរាបែងដោយទំនង
ដំណើរក្សត្រច្បាស់ច្បង　　តាំងពីអង្គស្ដេចយាត្រា ។

## បទកាកគតិ

៥៥១— កាលនោះភូបាល　　ព្រះសុវណ្ណកុមារ　　នូវនាងជាយា
និងបុត្រស្នេហ៍ស្នង　　ហោះផ្សងលីលា　　ដើរដោយវេហាស៍
ព្រោងព្រាយរស្មី ។
ស្ដេចចរយាត្រា　　ជួបសត្តទិវា　　ទើបព្រះភូមី
ស្ដែងស្ដេចបានដល់　　សកលធានី　　ក្រុងទេពបុរី
នគររាជា ។

ស្ដេចឲ្យបុត្រថ្លៃ　កើចយន្តមាសម័យ　ចុះចាប់នៅនា-
ព្រះលានព្រះបាទ　នរនាថជេដ្ឋា　ព្រះវរបិតា-
ធិរាជជៀស្លជ័យ ។

ស្ដេចនាំជាយា　នូវរាជកុមារ　ឡើងទៅថ្កានព-
ប្រាសាទនានា　បិតាហើយនៃ　កាលនោះក្សត្រថ្លៃ
ពុំលង់ឡើយណា ។

ឯអង្គព្រះបាទ　សម្ដេចភូវនាថ　ព្រះវរបិតា
នូវព្រះជនទី　ក្សត្រីថ្លៃថ្លា　យល់បុត្រស្ងួនភ្ងា
ស្ដេចផល់រាជស្ថាន ។

៥៥៥– ទាំងពីរមហាក្សត្រ　ត្រេកអរពេកក្ដាត់　ថ្ងៃថ្មីពុំបាន
ពីព្រះរាជា　យាត្រាមកឋាន　ឱបបុត្រកល្យាណ
សែនសោយសោកា ។

ក្សណានោះមហាក្សត្រ　សឹងពិលាបក្ដាត់　ទាំងប្រាំអង្គា
សឹងសន្ទប់លង់　ប្រាំអង្គរាជា　ហេតុត្បិតសោកា-
ណាល់ណាស់ពេកក្ដាត់ ។

លុះព្រះភូមី　បានភ្ញាក់ស្មារតី　ទាំងប្រាំអង្គថ្វាត់

ព្រះអគ្គតាំងបី　　វន្ទីយប្រណិប័តន៍　　ពីព្រះចមក្សត្រ-
ផិកដដៀស្ពជ័យ ។

ព្រះវរមាតា　　បន្ទូលខ្ញួញថា　　ឳកូនមាសថ្លៃ
កាលក្រោយបាពៅ　　ម្ដាយនៅឯងនៃ　　ម្ដាយសោកសង្រៃ
សង្រេងឥតស្បើយ ។

ម្ដាយនៅទីងទុក្ខ　　ពុំដែលស្រណុក　　ដល់ថ្ងៃមួយឡើយ
ត្បិតបាបាត់បង់　　យូរលង់ណាស់ហើយ　ព្រលឹងម្ដាយអើយ
ម្ដាយជាទុក្ខក្រៃ ។

៩២០— ម្ដាយតែងឲ្យគេ　　កូនស្ងួនពន្លក　　ដោយដងព្រះព្រៃ
ពុំយល់សោះសូន្យ　　បាត់កូនមាសថ្លៃ　　ម្ដាយស្មានជាក្ស័យ
បាត់បង់ជន្មា ។

ម្ដាយគិតទៅគ្រប់　　គ្រប់ហើយម្ដាយថប់　ថប់ហើយឈឺផ្សា
ពុំដែលហៅមាន　　ស្រាកស្រាន្តសោកា　ដល់ទិនទិវា
រាត្រីមួយឡើយ ។

ព្រះវរបិតា　　សោយសោកខ្ញួញថា　ស្ងួនឳពុកអើយ
នាកាលក្រោយបា　　ឃ្លាតឃ្លាទៅហើយ　ឳពុកពុំស្បើយ

ទ្រុងផលមួយថ្ងៃ ។

កូនអើយអាពុក ថែងទួញទល់ទុក្ខ សាស្រែងសាស្រៃ
ឥតឯទៅមាន ស្រាកស្រាន្តឡើយនៃ ជាអចិន្ត្រៃយ
នៅទីងទុក្ខា ។

ឪពុកឡេវក អស់ពួកហោរមក ទៀងទាយជតា
គួរគ្រោះកូនស្ងួន ខ្ញុំខ្លួនពុំផា ហោរទាយថាជា
តែលំបាកក្រៃ ។

៤៦៤– អស់អ្នកហោរទាយ ដោយនូវទំនាយ ជួបប្រទះហើយនៃ
កូនអើយឪពុក ទល់ទុក្ខក្រាស់ក្រៃ ប្រក្រតីសព្វថ្ងៃ
ពុំស្បើយឡើយណា ។

ក្សណានោះកូមី ស្ដាប់ព្រះជននី នូវព្រះបិតា
ជួបប្រទះហើយនៃ ក្សត្រថ្ងៃសោកា ហើយព្រះរាជា
ទួញទូលជននី ។

នូវព្រះបិតា សម្ដេចរាជា ទួញកាលអតី-
តស្ដេចជ័យន្ដហង្ស ហោះត្រង់បុរី ទៅដល់ធានី
នគរបញ្ចាល ។

ទូលកាលព្រះចៅ រៀនសិល្បសាស្ត្រនៅ ព្រាហ្មណ៍ប្រាជ្ញហោរា
ស្ដេចរៀនលុះចប់ សិល្បសព្វហើយណា៎ ទូលកាលពជា
ចូលទៅភក្តី ។

ព្រះចៅបញ្ចាល់ ជាព្រះបិតា នាងនាថទេវី
បានបុត្រកញ្ញា នោះជាមហេសី ទូលកាលអំពី-
ស្ដេចនោះក្រោធា ។

៤៧០-ឲ្យពេជ្ឈឃាតផង ចាប់ព្រះអង្គផង នាទៅមីមា
បណ្ដើរដួបដល់ មណ្ឌលព្រឹក្សា ប៉ង់ទីន៍ពាធា
ឲ្យអស់ជីវ៉ ។

ទូលកាលព្រះចៅ លួងពេជ្ឈឃាតទៅ ស្ដេចបានរួចពី
ភ័យហើយស្ដេចគង់ យន្តហង្សហោះខ្ពី ទៅឋានប្អូនស្រី
នៅប្រាសាទនោះ ។

ទើបព្រះកូមី យកព្រះប្អូនស្រី ដាក់លើយន្តហោះ
ចេញចាកពិតពី- បុរីរឹងស្ដោះ ពីរព្រះអង្គហោះ
ជួបសត្តទិក ។

ទូលកាលប្អូនស្រី នាងនាថឈឺផ្ទៃ កណ្ដាលវេហាស៍

ស្ដេចកើចយន្ដនោះ ចូលចុះឈប់នា- ក្រោមម្ជៃសាខា
ខាងឡេវផលផ ។

ទូលកាលជាយា ប្រសូតបុត្រា ប្រាណប្រុសពិសី
ទូលកាលស្ដេចគង់ យន្ដហោះរំហោះឡើ ទៅយកភ្លើងពី-
ការកេត្រានោះ ។

៦៧៥— ទូលកាលភូមី ស្ដេចបានអគ្គី ដាក់លើយន្ដហោះ
ចេញពីកេត្រា ភ្លើងឆេះឆ្ពោះ ដាច់ខ្សែយន្ដនោះ
ធ្លាក់កុងគង្គា ។

ទូលកាលព្រះអង្គ ស្ដេចព្រាត់ពីហង្ស- យន្ដយានឃ្លាតឃ្លា
ស្ដេចទូលពីចៅ សំពៅមួយណា ស្រង់ព្រះកាជា
ឡើងពីផលស័យ ។

ដាក់លើកេត្រា ឯអស់តាំងពា- ណិជផងសោតនៃ
រក្សាព្រះអង្គ ពួដពង្សក្សត្រថ្លៃ ស្ដេចនៅអាស្រ័យ
ទីងនាយកេត្រា ។

ទូលកាលព្រះបាទ ព្រហ្មទត្តនរនាថ- ធិកដចេស្ដា
ស្ដេចទៅប្រពាត ព្រះបាទក្សត្រា រើសរកជបុត្រា

នាំទៅបុរី ។

ព្រះអង្គយកជា　　បុត្រធម៌ស្នេហា　　ថ្នាក់ថ្នមបេតី
ទូលពីនាងនាថ　　សង្វាតឃ្មាតខ្មី　　តាមបុត្រភ្ញាប្រិយ
ដល់ស្រុកនោះណា ។

៤៨០— ទូលពីនាងទៅ　　សំណាក់និត្យនៅ　　ផ្ទះយាយមាលា
ទូលពីមហាក្សត្រ　　ព្រហ្មទត្តរាជា　　នឹងឲ្យបុត្រា
គ្រងរាជបុរី ។

ទូលពីកូបាល　　ឲ្យយកនាងនាថ　　ជាព្រះជននី
ផ្សំនឹងបុត្រា　　កាលគ្រានោះខ្មី　　ឯបុត្រពិសី
សោកពុំស្គាល់ជា- ។

ជននីនោះឡើយ　　លុះរួចការហើយ　　ទើបព្រះមាតា
ប្រាប់បុត្រថ្ងើមថ្ងៃ　　ហើយនៃបុត្រា　　ស្គាល់ជាមាតា
កាលនោះឯងហោង ។

ស្ដេចទូលអំពី-　　ព្រះអគ្គមហេសី　　និងបុត្រស្នេហ៍ស្នង
ឲ្យសង់សាលា　　កាលគ្រានោះផង　　គួរដោយដើមទង
និយាយរាជា ។

សម្តេចភូបាល ស្តេចទូលពីកាល- នោះនាយគេត្រា
ដែលស្រង់ព្រះចៅ ចេញទៅផ្ចញនា- នគរបុត្រា
និងនាងមហេសី ។

៥៨៥– ទូលកាលព្រះចៅ ឡើងពីសំពៅ ត្រាច់រកប្អូនស្រី
ស្តេចទៅឈប់នា- សាលាឃើញទី- យាយកាលអំពី-
ស្តេចព្រាត់ប្រាសគ្នា ។

ទូលកាលអំពី- សែនសោយសោកពី- លាបកាលនោះណា+
ឯអស់ពួកឆ្មាំ ដែលចាំសាលា នាំព្រះរាជា
ទៅឋានប្អូនស្រី ។

ទូលកាលស្តេចបាន បរិបូណ៌ម្លប់ហាន នឹងព្រះមហេសី
នូវរាជបុត្រា កាលគ្រានោះខ្ញី នៅនាបុរី
នោះឯងហោងណា+ ។

ទូលកាលក្សត្រថ្ងៃ បានហង្សយន្តនៃ ទើបព្រះរាជា
ប្រដាប់ស្រាប់ស្រេច សម្តេចផ្លា ទាំងបីអង្គា
ជិះហោះមកហោង ។

សម្តេចរាជា ទូលព្រះបិតា មាតាស្នេហ៍ស្នង

ដោយនាស្តេចទល់- ទុក្ខសោកកន្លង សព្វសុខទុក្ខផង
អស់អាថ៌សេចក្តី ។

៥៩០— សព្វគ្រប់ស្រេចគ្រេច ដោយនូវគន្ទេច គន្ធងរាទី
ពាក្យពេចន៍ក្តិកក្តក់ សុខទុក្ខអ៊ីៗ ស្តេចទូលឥតបី
មានខ្វះឡើយហោង ។
ឯព្រះមាតា នូវព្រះបិតា ស្តាប់បុត្រស្នេហ៍ស្នង
ទូលព្រះពជា សព្វប្រការផង ដោយបទទំនង
ដំណើរនោះណា ។
តាំងពីព្រះអង្គ ក្សត្រថ្លៃវង្សទ្រង់ កន្សែងសោកា-
ណល់ណាស់ពេកក្តាត់ អាណិតបុត្រា នូវបុត្រប្រុសា
នូវព្រះចៅផង ។
កាលនោះមហាក្សត្រ សឹងសោយសោកក្តាត់ តាំងប្រុំជាម្តង
អាណិតអនាថ ពន់ពេកកន្លង ព្រះទុព្វរង
ទុក្ខទោមនស្ស ។
ស្រេចហើយព្រះអង្គ បន្ទោរសោកបង់ តាំងប្រុំអង្គា
បរិបូណ៌សែនសុខ និរទុក្ខភយា ក្សេមក្សាន្តសុខសា

ឃាយបរិបូណ៌ហោង ។

៤៩៥– ក្សិណនោះមាតា ទូលព្រះបិតា ក្សត្រថ្លៃច្បាស់ច្បង
ព្រះអង្គទឹងឲ្យ បុត្រសោយរាជ្យស្នង ជាស្ដេចស្ដែងគ្រង
ក្រុងទេពបុរី ។

៤៩៦– ព្រះបាទឥសូរ មានព្រះបន្ទូល ត្រាស់ប្រើមន្ត្រី
គាត់តែងប្រដាប់ ដាប់ៗឃ្មាតខ្មី រៀបការអភិ-
សេករាជបុត្រា ។

## បទពំនោល

១៩១- ក្សិណនោះព្រះរាជមាតា ទូលព្រះបិតា ស្ដែងស្ដេចប្រដាប់ដាប់ក្រៃៗ
សូរបេចស្រាប់ស្រេចហើយនៃ ទើបព្រះដៀស្ឋជ័យ ព្រះអង្គឲ្យអស់ហោរាៗ
គួរកេឫក្សពារពេលា លុះបានឫក្សជា នោះទើបព្រះអង្គមហាក្សត្រ ។
ស្ដេចរៀបប្រុងប្រៀបជញ្ជាត់ ព្រលឹងបុត្ររ័ត្ន ទូរព្រះហោកាលនោះណា ។
១៩៥- លុះគម្រប់សត្តទិវា ទើបព្រះរាជា ទាំងពីរព្រះអង្គអភិសេក ។
បុត្រទាំងពីរប្រសើរពេក ជាស្ដេចឯងឯក ឥសូរកំពូលក្សត្រផង ។
ទៅក្រឹស្នកុមារសោតហោង ជាឧបរាជស្នង- នគរព្រះវរបិតា ។
ស្រេចទើបគោះគង់ជយា អស់បុរោហិតា សឹងសូត្របម្រើនព្រះពរ ។

អស់មុខមន្ត្រីលើកករ អញ្ជលីថ្វាយពរ បង្គំសម្តេចរាជា ។
៣០០-អស់ក្មេងប្រគំព្រមគ្នា បំរើក្សត្រា គ្រប់ដោយជំពូកទទៃ ។
ដោយច្បាប់ជាការធំក្រៃ សព្វគ្រប់ប្រពៃ ឥតខ្វះកន្ទះឡើយហោង ។
លុះរួចការស្រេចហ្មត់ហ្មង ក្សិណក្សត្របួសបួង ទាំងពីរព្រះអង្គសទ្ធា ។
ស្តេចត្រាស់ឲ្យសង់សាលា សម្តេចរាជា ព្រះអង្គឲ្យទានសព្វថ្ងៃ ។
គម្រប់ជាប្រាំពីរថ្ងៃ បរិបូណ៌ពេកក្រៃ ក្សេមក្សាន្តអស់បរិពារផង ។
២០៥-ប្តីនកេរ្តិ៍ថ្កើងយសកន្ទួង ព្រះអង្គជាបួង អស់ទាំងឯកសតរាជា ។
ស្តេចសោយរាជ្យលង់ទៅណា លុះព្រះរាជា ស្តែងស្តេចចម្រើនពិធី ។
រំលាងបញ្ចក្ខន្ធពី- មនុស្សលោកនេះខ្ពី ស្តេចបានទៅឋិតនៅនា- ។
សួគ៌សុខសេពសម្បត្តិជា- ទេវបុត្រនៅនា- ពិមានពិភពសួស្តី ។
លុះបានទុំព្រះបារមី ស្តេចច្យុតចាកពី- សួគ៌សុខពិមានឋានបិត ។
២១០-មកបដិសន្ធិថ្វាត់ ជាបុត្រមហាក្សត្រ ព្រះបាទសុទ្ធោទន៍ធិបតី ។
ចម្រើនព្រះពរជិនស្រី ទ្រង់ព្រះនាមថ្លៃ សិទ្ធត្ថព្រះរាជកុមារ ។
ស្តេចសាងនូវបារមិតា ទ្រង់បានត្រាស់ជា ព្រះពុទ្ធប្រពៃពេកក្កាត់ ។
បន្ទូលទេសនាប្រោសសត្វ នគរច្រើនក្កាត់ អនេកអនន្តសំខ្យា ។

# បទកាកគតិ

៥៩៧— ព្រះបានត្រាស់ហើយ ពិតពុំលង់ឡើយ ព្រះអង្គទេសនា
និទានជុំជាតក ដោយអតីតា និយាយនេះជា-
សណ្តាប់អ្នកផង ។

ព្រះបន្ទូលថា ព្រះចៅបញ្ចាល ចិត្តទ្រុស្តឃ្នើសឃ្នង
ធ្វើទោសពោធិ- សត្វវិសេសហោង ហេតុវេរង
មិញមកកើតជា- ។

ទេវទត្តត្រិយ នៅនាអវិចី ទល់ទុក្ខភយា
ហេតុត្បិតចិត្តនោះ ទ្រើសទ្រុស្តមោហា ទល់ទុក្ខនៅនា-
ឋាននរកនោះ ។

៦០០— ឯនាយកេត្រា នាមឈ្មោះហៅសា- គរពាណិជនោះ
ចេរិលវិលមក យោនយកជាតិស្មោះ ទ្រង់ព្រះនាមឈ្មោះ
ព្រះមោគ្គល្លាន ។

វិនាយសមុទ្ទ- សាគរប្រាកដ ចេរិលវិលបាន
ជាព្រះសារីបុត្ត បរិសុទ្ធទ្រង់ញាណ ទេសនាទូន្មាន
នាំសត្វផងណា ។

រីឯជូនចាស់ មានសប្បុរសណាស់ ឈ្មោះយាយមាលា
បេរវិលវិញមក យោនយកជាតិជា នាងឧប្បលវណ្ណា
ប្រាកដរឹទ្ធិ ។

ឯព្រះព្រហ្មទត្ត បេរវិលវិញផ្កាត់ មកយកជាតិ
ជាព្រះអានន្ទ អនុជជិនស្រី ទ្រង់ព្រតព្រឹទ្ធ
បរិសុទ្ធពេកពន់ ។

រីឯព្រះឥន្ទ ចមហៅទេវិន្ទ ប្រសើរគុណធ្ងន់
បេរវិលវិញមក យកបដិស- ន្ធិជាព្រះអ-
នុរុទ្ធាចារ្យ ។

៦០៤– ឯនាយអ្នកការ សម្រាប់គូបាល វិលមកបានជា-
ព្រះកោរនាគម(១) ឧត្តមថ្លៃថ្លា វៃមនមានកិរិយា
ទ្រង់ព្រតព្រឹទ្ធ ។

ឯនាងបទុម- កេសរឧត្តម ប្រសើរសល់ស្រី
បេរវិលវិញមក យោនយកជាតិ ទ្រង់នាមនាងស្រី
យសោធរា ។

ហៅក្រឹស្នកុមារ ត្រកូលត្រកាល ជាតិជាបុត្រា

---

១ តាមការស្រាវជ្រាវ , ពុំឃើញមានព្រះនាមនេះក្នុងពួកសាវក៏របស់ព្រះពុទ្ធសមណគោតមទេ ។

បេរវិលវិញមក    យោនយកជាតិជា-    សម្តេចព្រះរា-
ហុលគ្រូមុនី ៗ
ព្រះបាទអាទិត្យ-    វង្សាទ្រង់ឫទ្ធិ    បិតាពោធិ-
សត្វសោតសឹងមក    ស្តេចយកជាតិ    ទ្រង់ព្រះនាមស្រី-
សុទ្ធោទន៍រាជា ៗ
ឯព្រះជននី    វរកញ្ញត្រី    នាមនាងពិម្ពា
បេរវិលវិញមក    យោនយកជាតិជា    ព្រះវរមាតា
សម្តេចជិនស្រី ៗ

៦១០— រីកាលនោះនាង    សុគតរំលាង    បញ្ចកន្ធពី-
មនុស្សលោកទៅឋិត    សម្បត្តិសួគ៌ា    ទ្រង់នាមនាងស្រី
មហាមាយា ៗ
រីព្រះសុវណ្ណ-    កុមារសោភ័ណ    គឺអង្គតថា-
គតង់បានត្រាស់    ប្បន់ប្បាស់ប្រាជ្ញា    សពេជ្ញតា-
ញាណញេយ្យគន្ធ ៗ
ត្រាស់ធម៌វិសេស    ព្រះអង្គតែងទេ-    សនានាំសត្វផង
ដាក់ដល់និព្វាន    ក្សេមក្សាន្តឥតហ្មង    និរទុក្ខផង

លុះលែងវេក ។

នេះគឺជំណាល ព្រះអង្គត្រកាល ត្រាច់ស្អាងចរិយា
បំពេញបារមី ពោធិសម្ភារ លុះលែងសង្សារ
ប្រសើរពេកហោង ។

អ្នកណាបានស្តាប់ បានរៀនត្រង់ត្រាប់ បានចាំបានចង
បានចារសេរសេរ ជាកេរ្តិ៍ជនផង ប្រសើរកន្ទង
ពំនាក់អាត្មា ។

៦១៩– អ្នកនោះហៅបាន ចូលសំណាញ់ញាណ សម្តេចគតព
ស្រង់ស្រោចដាក់ដល់ មណ្ឌលសួគ៌ា ពោលគឺមហា-
និព្វានប្រាកដ ។

អញខ្ញុំស្រង់ស្រាល់ ប្រែប្រៀបអស់អាថ៌ ពីពាក្យសៀមសុទ្ធ
ជាពាក្យខ្មែរវិញ ចែងចេញប្រាកដ ពីគ្រោះតាមបទ
និទាននេះណា ។

ដាក់ស្រេចដោយនូវ គន្ទេបគន្ទៅ គន្ទងកាព្យា
ជៀងដាក់ប្រាកដ ដោយបទគាថា សូរេចអក្ខា
បរិបូណ៌ចប់ហោង ។

– ចប់ –

Imprimé en France
par **AIK** (Atelier d'Impression Khmère) du Cedoreck-Montrouge
Dépôt légal : 2e trimestre 1986
ISBN 2-86731-022-9

មជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ

CENTRE DE DOCUMENTATION ET DE RECHERCHE
SUR LA CIVILISATION KHMÈRE

**CEDORECK**

218,rue Saint-Jacques - 75005 PARIS

Tél. 43 29 93 94 - C.C.P. Paris 777 32 X

70 FF

**AIK**

**ISBN 2-86731-22-9**